ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
NGO EDUCATION PARTNERSHIP

# ម៉ោងបង្រៀននៅបឋមសិក្សាក្នុងប្រទេសកម្ពុជា



**អាង សុផា   ខូលីន អាន់ឌ័រសុន  ឈុំ ស៊ីរ៉ុម**

**ខែ កក្កដា ឆ្នាំ ២០១៥**

ផ្ដល់មូលនិធិដោយ

MISEREOR
IHR HILFSWERK

## សេចក្តីថ្លែងអំណរគុណ

ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល(NEP) សូមថ្លែងអំណរគុណដោយស្មោះចំពោះក្រសួងអប់រំ យុវជន និង កីឡាដែលបានអនុញ្ញាត ឱ្យអង្គការNEPធ្វើការសិក្សាស្រាវជ្រាវនេះ។ សូមថ្លែងអំណរគុណចំពោះ នាយក នាយិកាសាលា គ្រូបង្រៀន និងសិស្សានុសិស្សទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃរបស់ខ្លួន ក្នុងការផ្តល់នូវព័ត៌មានដែលទាក់ទងនឹងការស្រាវជ្រាវនេះ។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការជាសមាជិកធ្វើការនៅតាម រាជធានី ខេត្តដែលតំបន់គោលដៅស្រាវជ្រាវ រួមមាន អង្គការ ពុទ្ធិកុមារ អង្គការកុមារកំព្រាតាមជនបទ អង្គការប្រតិបត្តិការកុមារកម្ពុជា អង្គការសាមគ្គី អង្គការគ្រួសារយើង អង្គការអភិវឌ្ឍស្ត្រីក្រីក្រក្នុងទីក្រុង អង្គការយៃអេនន្តរជាតិ អង្គការវីអេសអូ អង្គការទស្សនៈពិភពលោកកម្ពុជា អង្គការមជ្ឈមណ្ឌលសហប្រត្តិបត្តិការ និងការអភិវឌ្ឍន៍ អង្គការព្រះពុទ្ធសាសនាសម្រាប់សកម្មភាពអភិវឌ្ឍសង្គម និងអង្គការម្លប់តាប៉ាង ដែលបានអនុញ្ញាតឱ្យបុគ្គលិករបស់ខ្លួនមួយចំនួនចូលរួមប្រមូលព័ត៌មានសម្រាប់កាសិក្សានេះនៅតាមខេត្តគោលដៅរបស់ខ្លួន។ អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល សូមវាយតម្លៃខ្ពស់ចំពោះលោក អោ សៀម និងលោកអាំ សុបុល មកពីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ព្រមទាំងលោក សឿង សុខ និងលោក លី សុរដ្ឋ មកពីនាយដ្ឋានបឋមសិក្សា ចំពោះការចូលរួមរបស់ពួកគាត់នៅក្នុងការរៀបចំវិធីសាស្ត្រស្រាវជ្រាវ និងការប្រមូលទិន្នន័យនៅតាមមូលដ្ឋាន។

យើងសូមថ្លែងអំណរគុណជាពិសេសចំពោះលោកបណ្ឌិត ឈិញ ស៊ីថា និងលោកបណ្ឌិត ហេង គ្រេង មកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញដែលបានជួយក្នុងការធ្វើតេស្តស្ថិតិ ដើម្បីពិនិត្យមើលពីទំនាក់ទំនងរវាងអថេរមួយនិងអថេរមួយទៀត ព្រមទាំងវិភាគទិន្នន័យទៅលើការចុះសាលារៀនដោយពុំមានផ្តល់ ដំណឹងជាមុន និងអវត្តមានរបស់គ្រូបង្រៀន។ អង្គការNEP ក៏សូមថ្លែងអំណរគុណផងដែរចំពោះការគាំទ្ររបស់តំណាងមកពីអង្គការជាសមាជិក ដៃគូអភិវឌ្ឍ និង ក្រសួងអប់រំ យុវជន និងកីឡា ដែលបានចូលរួម និងផ្តល់ជាតុចូលស្តីពីមូលហេតុសំខាន់ៗដែលនាំឱ្យបាត់ម៉ោងបង្រៀន និងលើកឡើងនូវអនុសាសន៍នានាសម្រាប់កែលម្អម៉ោងបង្រៀននៅក្នុងប្រទេសកម្ពុជា។

អង្គការNEP សូមសម្តែងការដឹងគុណចំពោះសមាជិក សមាជិការបស់គណៈកម្មការប្រឹក្សាយោបល់ស្រាវជ្រាវទាំងអស់ដែលចំណាយពេលវេលាដ៏មមាញឹករបស់ខ្លួនមកចូលរួមនៅក្នុងការប្រជុំផ្តល់មតិយោបល់ ប្រកបដោយស្ថាបនា និងជាតុចូលនៅក្នុងការរៀបចំវិធីសាស្ត្រស្រាវជ្រាវនេះ។

ជាចុងក្រោយ សូមអរគុណចំពោះលោក ហ្គូដិន កូណូឈី អតីតទីប្រឹក្សាផ្នែកតស៊ូមតិនិងស្វែងរកមូលនិធិរបស់NEP មកពីអង្គការវីអេសអូ ដែលបានផ្តល់ការគាំទ្រនៅក្នុងការរៀបចំទិន្នន័យមូលដ្ឋាន និងការវិភាគទិន្នន័យ និងសូមអរគុណចំពោះលោក យីវ៉ាន់ វ៉េ អតីតទីប្រឹក្សាផ្នែកស្រាវជ្រាវរបស់NEP មកពីអង្គការវីអេសអូ ដែលបានពិនិត្យមើលឡើងវិញនូវការសិក្សាពាក់ព័ន្ធនានា ដើម្បីផ្តល់នូវបរិបទមួយនៃម៉ោងបង្រៀនទាំងនៅថ្នាក់ជាតិនិងអន្តរជាតិ។

សូមថ្លែងអំណរគុណជាពិសេសចំពោះអង្គការ MISEREOR សម្រាប់ការផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ ដែលធ្វើឱ្យការសិក្សានេះដំណើរការទៅបាន។


សមាជិកក្រុមប្រឹក្សាស្រាវជ្រាវ ៖

| | |
|---|---|
| លោកបណ្ឌិត ឈិញ ស៊ីថា | មកពីសាកលវិទ្យាល័យភ្នំពេញ |
| លោក ភីតធ័រ ដេវ្រីស | អតីតប្រធានផ្នែកអប់រំរបស់អង្គការយូនីសេសប្រចាំប្រទេសកម្ពុជា |
| លោក រស់ សេរីសត្យា | អ្នកឯកទេសផ្នែកអប់រំរបស់អង្គការទស្សនៈពិភពលោកកម្ពុជា |
| លោកស្រី អាលី ទ្វៃន | អតីតទីប្រឹក្សារបស់អង្គការ KAPE |
| លោក ចាន់ សុភា | ប្រធាននាយកដ្ឋានបឋមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា |

## តារាងមាតិការ

**សេចក្តីថ្លែងអំណរគុណ** ........ 2
**តារាងមាតិការ** ........ 4
**បញ្ជីតារាង** ........ 5
**ពាកក្យកាត់** ........ 9
**និយមន័យនៃពាក្យគន្លឹះ** ........ 10

សេចក្តីសង្ខេបរួម ........ 11

I. សេចក្តីផ្តើម និងវត្ថុបំណងនៃការស្រាវជ្រាវ ........ 15

II. ម៉ោងសិក្សានៅថ្នាក់បឋមសិក្សាក្នុងប្រទេសកម្ពុជា ៖ បរិបទ ........ 16
**២.១ម៉ោងសិក្សាដែលគេកំណត់ជាផ្លូវការ** ........ 17
២.១.១ ការប្រៀបធៀបជាលក្ខណៈអន្តរជាតិ ........ 19
២.១.២ ឆ្នាំសិក្សា ........ 20
**2.2 ការប៉ាន់ប្រមាណពីម៉ោងបង្រៀនជាក់ស្តែង** ........ 22
**២.៣ អវត្តមានរបស់គ្រូបង្រៀន** ........ 23
**២.៤ ការស្រាវជ្រាវ ស្តីពីវិធីសាស្ត្រក្នុងការកាត់បន្ថយអវត្តមានរបស់គ្រូបង្រៀន** ........ 24
**២.៥ ប្រព័ន្ធត្រួតពិនិត្យស្នាដៃបំពេញការងាររបស់គ្រូបង្រៀន** ........ 26
**២.៦ ការចូលរួមរបស់គ្រូបង្រៀនក្នុងការងារគ្រប់គ្រងការបំពេញការងារ** ........ 28

III. វិធីសាស្ត្រស្រាវជ្រាវ ........ 29
**៣.១ ទំហំនៃសំណាក និងវិធីសាស្ត្រជ្រើសរើសសំណាក** ........ 30
៣.១.១ ការរៀបចំ ........ 30
**៣.១.២** ការអនុវត្តជាក់ស្តែង ........ 31
***៣.២ វិធីសាស្ត្រប្រមូលទិន្នន័យ*** ........ 33
៣.២.១ ការពិនិត្យតាមដានសៀវភៅសរសេររបស់សិស្ស និងរបាយការណ៍សាលារៀន ........ 35
៣.២.២ ការធ្វើទស្សនកិច្ចសាលារៀនដោយមិនផ្តល់ដំណឹងជាមុន ........ 36
៣.២.៤ ការសម្ភាសគ្រូ ........ 36
៣.២.៥ ការសម្ភាសនាយកសាលា ........ 37
៣.២.៦ ការធ្វើតេស្តសមត្ថភាពសិស្ស ........ 37
***៣.៣ ការវិភាគទិន្នន័យ*** ........ 38
**៣.៤ ឥទ្ធិពលនៃការសង្កេត** ........ 38

IV. លទ្ធផលរកឃើញសំខាន់ៗ និងការវិភាគ ........ 41
**៤.១ ការបាត់បង់ម៉ោងបង្រៀនដោយសារថ្ងៃឈប់សម្រាកជាផ្លូវការបន្ថែមទៀត** ........ 41
**៤.២ ការបាត់ម៉ោងបង្រៀនដោយសារគ្រូបង្រៀនអវត្តមាន** ........ 43

៤.២.១ ការចុះទស្សនកិច្ចសាលារៀនដោយមិនផ្តល់ដំណឹងជាមុន ..... 43
**៤.២. គ្រូបង្រៀនផ្ទៀងផ្ទាត់ និងបញ្ជាក់ពីអវត្តមានរបស់ខ្លួន ..... 46**
៤.២.៣ មូលហេតុដែលគ្រូបង្រៀនបានបញ្ជាក់ចំពោះអវត្តមានរបស់ខ្លួន ..... 48
៤.២.៤ ការវិភាគ ៖ និន្នាការអវត្តមានរបស់គ្រូបង្រៀន ..... 52
៤.២.៥ ការវិភាគ ៖ ភាពខុសគ្នាចំពោះអវត្តមានរបស់គ្រូបង្រៀនទៅតាមទីតាំង កំរិតថ្នាក់ និងវេនបង្រៀន ..... 56
៤.២.៦ ការវិភាគ ភាពខុសគ្នានៃអវត្តមានគ្រូទៅតាមលក្ខណៈសម្បត្តិរបស់គ្រូបង្រៀន ..... 60
**៤.៣ ការបាត់ម៉ោងដោយសារគ្រូបង្រៀនតិចជាងម៉ោងកំនត់ ..... 63**
**៤.៤ ផលវិបាកនៃការបាត់ម៉ោងបង្រៀនចំពោះលទ្ធផលនៃការសិក្សារបស់សិស្ស ..... 70**
**៤.៥ ការត្រួតពិនិត្យតាមដានសាលារៀន និងគ្រូបង្រៀនដើម្បីធានាបាននូវការបង្រៀន ..... 77**
៤.៥.១ ការត្រួតពិនិត្យ និងអធិការកិច្ចរបស់ក្រសួងអប់រំ  មន្ទីរអប់រំខេត្ត និងការិយាល័យអប់រំស្រុក ..... 77
៤.៥.៣ វិធានការវិន័យដែលគេបានអនុវត្តក្នុងការឆ្លើយតបទៅនឹងអវត្តមានរបស់គ្រូបង្រៀន ..... 82
៤.៥.៤ ទស្សនៈរបស់នាយកសាលាស្តីពីការពង្រឹងវត្តមានរបស់គ្រូបង្រៀន ..... 85
V. សេចក្តីសន្និដ្ឋាន ..... 88
VI. អនុសាសន៍ ..... 98
**ឧបសម្ព័ន្ធ ..... 106**
ឯកសារយោង ..... 123

## បញ្ជីតារាង

តារាងទី១៖ រយៈពេលនៃឆ្នាំសិក្សានៅបណ្តាប្រទេសនៅអាស៊ី ..... 21
តារាងទី២៖ ទំហំសំណាកនៅតាមខេត្ត ..... 32
តារាងទី ៣ ៖ តំបន់ធ្វើការសិក្សាស្រាវជ្រាវ និងទំហំសំណាក ..... 32
តារាងទី៤ ៖ សំណាកគ្រូបង្រៀនតាមភេទ និងវេនបង្រៀន ..... 33
តារាងទី ៥៖ ថ្ងៃបិទសាលាឈប់សំរាកជាផ្លូវការបន្ថែមទៀតក្នុងឆ្នាំសិក្សា ២០១២-២០១៣ ..... 42
តារាងទី៦៖ ថ្ងៃឈប់សំរាកបន្ថែមទៀត នៅឆ្នាំសិក្សា ២០១៣/១៤ ..... 42
តារាងទី៧ ៖ ចំនួនដងនៃការចុះទស្សនកិច្ចសាលារៀនដោយពុំផ្តល់ដំណឹងជាមុនតាមខែនីមួយៗ ..... 44
តារាងទី៨ ៖ អត្រាអវត្តមានរបស់គ្រូបង្រៀនក្នុងអំឡុងពេលចុះទស្សនកិច្ចសាលា ដោយពុំមានផ្តល់ដំណឹងជាមុន ..... 45
តារាងទី៩៖ អត្រាអវត្តមានរបស់គ្រូបង្រៀន៖ ទិន្នន័យរួមបញ្ចូលគ្នាដែលគ្រូបង្រៀនខ្លួនឯងបានបញ្ជាក់ថាអវត្តមាន ..... 47

តារាងទី១០៖ អវត្តមានគ្រូទៅតាមរយៈចម្ងាយពីផ្ទះទៅសាលារៀន ....................................................63
តារាងទី ១២៖ ពិន្ទុតេស្តរបស់សិស្សទៅតាមទីតាំងសាលារៀន ....................................................72
តារាងទី១៤៖ ពិន្ទុតេស្តរបស់សិស្សនៅតំបន់ជនបទទៅតាមអត្រាអវត្តមានរបស់គ្រូ ....................................................73
តារាងទី១៥៖ ពិន្ទុជាមធ្យមរបស់សិស្ស ធៀបទៅនឹងចំនួននាទីដែលបានបង្រៀនដោយគ្រូ ....................................................74
តារាងទី១៦ ៖ វិធីសាស្ត្រនានាក្នុងការត្រួតពិនិត្យតាមដានដែលនាយកបានអនុវត្ត ....................................................80
តារាងទី១៦ ៖ ទស្សនៈរបស់នាយកសាលាស្តីពីផលប៉ះពាល់នៃការត្រួតពិនិត្យតាមដានគ្រូបង្រៀន ....................................................81
តារាងទី១៧៖ សកម្មភាពដែលនាយកសាលាបានធ្វើដើម្បីលើកទឹកចិត្តគ្រូឱ្យមកបង្រៀនទៀងទាត់ ....................................................82
តារាង១៩: ផលវិបាកមកលើគ្រូបង្រៀនប្រសិនបើពួកគាត់អវត្តមានដោយពុំមានការអនុញ្ញាត (មានចម្លើយច្រើន) ....................................................84
តារាងទី ២០៖ សំណូមពររបស់នាយកសាលាស្តីពីការកែលម្អអវត្តមានគ្រូបង្រៀន ....................................................86

## បញ្ជីរូបភាព

រូបទី១៖ មធ្យមភាគចំនួនម៉ោងបង្រៀនរំពឹងទុកជាសកលប៉ាន់ប្រមាណនៅឆ្នាំ២០០០និង២០១០ ....................................................20
រូបទី២៖ មធ្យមភាគម៉ោងបង្រៀនប្រចាំឆ្នាំជាសកលទៅតាមតំបន់និងកំរិតថ្នាក់ ....................................................20
រូបទី ៣ តំបន់ដែលធ្វើការសិក្សាស្រាវជ្រាវ ....................................................29
រូបទី៤៖ ដ្យាក្រាមវិធីសស្ត្រស្រាវជ្រាវ ....................................................34
រូបទី៥៖ វិធីសាស្ត្រស្រាវជ្រាវ និងពេលវេលា ....................................................34
រូបទី ៦ ៖ ចំនួននៃទស្សនកិច្ចសាលាដោយពុំមានផ្តល់ដំណឹងជាមុនទៅលើគ្រូបង្រៀននីមួយៗ ....................................................44
រូបទី៧៖ គ្រូបង្រៀនបញ្ជាក់ពីចំនួនថ្ងៃអវត្តមានក្នុង១ខែ ....................................................46
រូបទី ៨៖ របាយអត្រាអវត្តមានរបស់គ្រូ ....................................................48
រូបទី ៩៖ មូលហេតុដែលនាំឱ្យគ្រូអវត្តមាន ....................................................50
រូបទី១០ ៖ អវត្តមានរបស់គ្រូបង្រៀនតាមពេលវេលាក្នុងឆ្នាំ ....................................................53
រូបទី ១១ ៖ អវត្តមានរបស់គ្រូបង្រៀន និងវត្តមានរបស់នាយកសាលា ....................................................54
រូបទី១២៖ គ្រូអវត្តមាន ហើយសាលាទាំងមូលត្រូវបានបិទទ្វានៅតាមតំបន់នានា ....................................................55
រូបទី១៣ ៖ អត្រាអវត្តមានគ្រូបង្រៀនតាមទីតាំងសាលារៀន (ទិន្នន័យដែលបានរួមបញ្ចូលគ្នា) ....................................................56
រូបទី១៤ ៖ អវត្តមានរបស់គ្រូបង្រៀនដែលបានប៉ាន់ស្មានដោយគ្រូបង្រៀន ....................................................57
រូបទី ១៥ ៖ អវត្តមានគ្រូបង្រៀនតាមខេត្ត (ទិន្នន័យបញ្ចូលគ្នា) ....................................................58

រូបទី១៦ ៖ អវត្តមានរបស់គ្រូបង្រៀនតាមកម្រិតថ្នាក់ដែលបង្រៀន (ទិន្នន័យបញ្ចូលគ្នា) ........................59
រូបទី១៧៖ អត្រាអវត្តមានគ្រូទៅតាមវេនបង្រៀន ........................................................................60
រូបទី ១៨៖ អវត្តមានទៅតាមក្រុមអាយុរបស់គ្រូបង្រៀន ...............................................................60
រូបទី ១៩៖ អាយុរបស់គ្រូបង្រៀន ទៅតាមតំបន់........................................................................61
រូបទី ២០៖ អត្រាអវត្តមានទៅតាមយេនឌ័រ...............................................................................61
រូបទី២១៖ ទីតាំងបង្រៀន និងភេទរបស់គ្រូបង្រៀននៅក្នុងសំណាក ..............................................62
រូបទី២២៖ អត្រអវត្តមានគ្រូទៅតាមភេទ និងកន្លែងធ្វើការ...........................................................62
រូបទី ២៣៖ ចំនួននៃការសង្កេតថ្នាក់រៀន...................................................................................64
រូបទី ២៥៖ ចំនួនម៉ោងបង្រៀនក្នុងថ្នាក់ដែលត្រូវបានកាត់បន្ថយដោយសារទីតាំងសាលារៀន.....................65
រូបទី២៦៖ ចំនួននាទីជាមធ្យមដែលគេសង្កេតឃើញថាគ្រូបានបង្រៀនទៅតាមតំបន់ផ្សេងៗ .....................66
រូបទី ២៧៖ ចំនួម៉ោងដែលគ្រូបង្រៀនសិស្សប្រចាំថ្ងៃ (គិតជានាទី) ទៅតាមខេត្តនានា.............................67
រូបទី២៨៖ : ចំនួននាទីជាមធ្យមដែលគ្រូបានបង្រៀនទៅតាមទីតាំងសាលារៀន.......................................67
រូបទី ២៩៖ ចំនួនម៉ោងនៃការបង្រៀនសិស្សនៅក្នុងថ្នាក់ដែលបានកាត់បន្ថយទៅតាមកម្រិតថ្នាក់................68
រូបទី៣០៖ រយៈពេលបង្រៀនមេរៀនជាមធ្យមនៅតាមវេនបង្រៀន ......................................................68
រូបទី៣១៖ ប្រេកង់នៃការមកបង្រៀនយឺតរបស់គ្រូបង្រៀន ...............................................................69
រូបទី៣២៖ កត្តាដែលនាំឱ្យមានការកាត់បន្ថយម៉ោងបង្រៀនសិស្សនៅក្នុងថ្នាក់ (ការសង្កេតថ្នាក់រៀន) .........69
រូបទី៣៣៖គ្រូបង្រៀនដើរតួនាទីចម្បងក្នុងការមើលថែកូន .................................................................70
រូបទី ៣៨៖ ពិន្ទុភាសាខ្មែរ ធៀបនឹងចំនួននាទីដែលបានបង្រៀន..........................................................75
រូបទី៣៩៖ ទស្សនៈយល់ឃើញរបស់គ្រូបង្រៀនស្តីពីកម្មវិធីសិក្សាធៀបជាមួយ រយៈពេលនៃឆ្នាំសិក្សា ...........76
រូបទី៤០៖ បទពិសោធន៍គ្រូបង្រៀនកាលពីឆ្នាំកន្លងទៅក្នុងការបញ្ចប់មេរៀន ..........................................77
រូបទី៤១ ៖ ភាពញឹកញាប់នៃការត្រួតពិនិត្យតាមដានដែលបានធ្វើឡើងដោយក្រសួងអប់រំ មន្ទីរអប់រំខេត្ត និងការិយាល័យ អប់រំស្រុក..................................................................................................79
រូបទី៤២ ៖ ចំនួនដងនៃការត្រួតពិនិត្យតាមដានគ្រូបង្រៀនពីសំណាក់នាយកសាលា ...............................80
រូបទី៤៣ ៖ ពេលវេលាដែលនាយកសាលាចុះត្រួតពិនិត្យតាមដានថ្នាក់រៀន ...........................................81
រូបភាពទី៤៤: ចំណាត់ការដែលនាយកសាលាបានអនុវត្តចំពោះគ្រូបង្រៀនដែលអវត្តមាន ដោយពុំមានការអនុញ្ញាត.......................................................................................................85

## ពាក្យកាត់

គម ៖ គីឡូម៉ែត្រ

DoEs ៖ ការិយាល័យអប់រំ យុវជននិងកីឡាស្រុក

DTMT ៖ ក្រុមការងារពិនិត្យតាមដាន និងបំប៉នថ្នាក់ស្រុក

EMIS ៖ ស្ថិតិ និងសូចនករអប់រំ

MoEYS ៖ ក្រសួងអប់រំ យុវជន និងកីឡា

NEP ៖ ភាពជាដៃគូអប់រំនៃអង្គការមិនមែនរដ្ឋាភិបាល

PoEs ៖ មន្ទីរអប់រំ យុវជននិងកីឡា

SSC ៖ គណៈកម្មការទ្រទ្រង់សាលារៀន

**និយមន័យនៃពាក្យគន្លឹះ**

*ថ្ងៃឈប់សម្រាកជាផ្លូវការបន្ថែម៖* សំដៅទៅលើថ្ងៃឈប់សម្រាករបស់សាលារៀន ឬថ្ងៃមិនបង្រៀនដែលប្រកាសជាផ្លូវការដោយក្រសួងអប់រំ យុវជន និងកីឡា នៅក្នុងអំឡុងឆ្នាំសិក្សា ឧទាហរណ៍ការបិទសាលារៀនដើម្បីប្រារព្ធព្រឹត្តិការណ៍នានា របស់រដ្ឋ ឬដើម្បីគ្រូបង្រៀនជាប់រវល់ធ្វើមេប្រយោគប្រឡងជ្រើសរើសគ្រូបង្រៀន។

*វេនបង្រៀនពេលរសៀល៖* សំដៅទៅលើវេនបង្រៀនដែលធ្វើឡើងនៅពេលរសៀលចាប់ពីម៉ោង១ រសៀលដល់ម៉ោង៥ល្ងាច។

*ម៉ោងសិក្សា៖* សំដៅទៅលើរយៈពេលនៃការរៀនដែលគេបែងចែកសម្រាប់មុខវិជ្ជានីមួយៗក្នុងមួយថ្ងៃ។ មួយម៉ោងសិក្សាមានរយៈពេល ៤០ នាទីនៅក្នុងប្រទេសកម្ពុជា។

*គ្រូបង្រៀនពីរវេន៖* សំដៅទៅលើគ្រូដែលបង្រៀនទាំងវេនពេលព្រឹក និងពេលរសៀល។

*ម៉ោងសិស្សរៀនក្នុងថ្នាក់ជាមួយគ្រូបង្រៀន៖* គឺជាពាក្យមួយដែលគេប្រើប្រាស់សំដៅទៅលើពេលវេលាដែលគ្រូបង្រៀនសិស្សនៅក្នុងថ្នាក់។ វាជាពាក្យមួយដែលគេប្រើប្រាស់ជាទូទៅនៅក្នុងឯកសារថ្នាក់អន្តរជាតិដែលមានស្រាប់ និងសំដៅទៅលើម៉ោង ពិតប្រាកដមិនសំដៅទៅលើម៉ោងសិក្សាទេ។

*វេនបង្រៀនពេលព្រឹក៖* សំដៅទៅលើវេនបង្រៀនដែលបានធ្វើឡើងនៅពេលព្រឹកចាប់ពីម៉ោង៧-ម៉ោង១១ព្រឹក

*បង្រៀនឆ្លាស់វេន៖* សំដៅទៅលើការបង្រៀនដែលប្តូរវេនរវាងវេនពេលព្រឹក និងពេលរសៀលតាមខែនីមួយៗ។

*សាលារៀនតំបន់ជនបទ៖*សំដៅទៅលើសាលារៀនដែលស្ថិតនៅក្នុងស្រុកជនបទរបស់ខេត្តនីមួយៗ។ សាលារៀនទាំងអស់ដែលនៅតាមតំបន់ជនបទ ក្រសួងអប់រំ យុវជននិងកីឡា ចាត់ថ្នាក់ថាជាសាលារៀនជនបទ។

*អវត្តមានរបស់គ្រូបង្រៀន៖* សំដៅទៅលើកាលៈទេសៈនានាដែលគ្រូបង្រៀនពុំបានទៅសាលាដើម្បីបង្រៀនទៅតាមកាលវិភាគបង្រៀន មិនថាដោយសារហេតុផលណាមួយនោះទេ។

*ម៉ោងបង្រៀន៖* ត្រូវបានគេឱ្យនិយមន័យថា ជាម៉ោងនៃការទាក់ទងគ្នារបស់គ្រូបង្រៀន និងសិស្សដែលបានចំណាយនៅក្នុងថ្នាក់រៀន។ ពាក្យនេះមានលក្ខណៈធំទូលាយជាងអ្វីដែលគេហៅថា វគ្គនៃការរៀនសូត្រនៅតាមសាលារៀនបឋមសិក្សានៅក្នុងប្រទេសកម្ពុជាដែលសំដៅទៅលើវគ្គដែលមានរយៈពេល៤០នាទី។

*សាលារៀននៅទីប្រជុំជន៖* សំដៅទៅលើសាលារៀនដែលស្ថិតនៅក្នុងតំបន់នៅប្រជុំជនរបស់ខេត្តនីមួយៗ។ ក្រសួងអប់រំ យុវជន និងកីឡា បានចាត់ថ្នាក់សាលារៀនទាំងអស់នៅតាមតំបន់ក្នុងទីប្រជុំជនរបស់ខេត្តនីមួយៗ និងនៅគ្រប់ខណ្ឌទាំងអស់ក្នុងរាជធានីភ្នំពេញថាជាសាលារៀនទីប្រជុំជន។

# សេចក្តីសង្ខេបរួម

**របាយការណ៍ស្តីពីម៉ោងបង្រៀននៅសាលាបឋមសិក្សានៅក្នុងប្រទេសកម្ពុជានេះគឺជាលទ្ធផលដ៏សំខាន់នៃការចុះស្រាវជ្រាវតាមមូលដ្ឋានដែលបានអនុវត្តពេញមួយឆ្នាំសិក្សា២០១២-២០១៣។** ការសិក្សាស្រាវជ្រាវនេះតាមដាន មើលទៅលើវត្តមានរបស់គ្រូបង្រៀនចំនួន309នាក់នៅក្នុងសាលារៀនចំនួន91សាលា ដោយប្រើប្រាស់ប្រភពព័ត៌មានផ្សេងៗជាច្រើន ដើម្បីរកឱ្យឃើញថាតើគ្រូបង្រៀនអវត្តមានពីសាលារៀនញឹកញាប់កម្រិតណា មូលហេតុចំពោះអវត្តមានទាំងនោះ រយៈពេលបង្រៀនក្នុងម៉ោងសិក្សា និងលទ្ធផលសិក្សារបស់សិស្សរបស់គាត់។ ការសិក្សាស្រាវជ្រាវនេះ ត្រូវបានធ្វើឡើងនៅក្នុងខេត្តចំនួន៥របស់ប្រទេសកម្ពុជា និងរាជធានីភ្នំពេញ ដោយអង្គការ NEPជាអ្នកត្រួតពិនិត្យ មើលដំណើរនៃការសិក្សា ហើយបុគ្គលិកNGOដែលទទួលការបណ្តុះបណ្តាលជាអ្នកអនុវត្តការប្រមូលព័ត៌មាន។

**គោលបំណងនៃការសិក្សានេះគឺដើម្បីផ្តល់នូវទស្សនៈបច្ចុប្បន្នភាពមួយស្តីពីការប្រឈមមុខនានាចំពោះការផ្តល់ម៉ោងបង្រៅនឱ្យបាន តាមការកំណត់សម្រាប់សាលាបឋមសិក្សានៅក្នុងប្រទេសកម្ពុជា** និងប៉ាន់ប្រមាណពីពីមូលហេតុចំពោះការប្រឈមមុខទាំងនេះ ព្រមទាំងផលប៉ះពាល់ទៅលើលទ្ធផលនៃការសិក្សារបស់សិស្ស។ ក្នុងពេលដែលការសិក្សានេះរកឃើញថា គ្រូបង្រៀនជាច្រើនមានអត្រាវត្តមានល្អ ហើយសាលារៀន ជាច្រើនធ្លាប់បិទទ្វារក្រៅផ្លូវការតែពីរបីដងក៏ដោយ ក៏សាលារៀនមួយចំនួននៅតែមានបញ្ហាសំខាន់ៗមួយចំនួន។ ការសិក្សាទាំងអស់កន្លងមកនៅក្នុង ផ្នែកនេះប្រើប្រាស់វិធីសាស្រ្ត និងនិយមន័យខុសៗគ្នា ហើយហេតុដូច្នេះហើយគេពុំមានលទ្ធភាពបង្កើតនូវនិន្នាការដ៏រឹងមាំមួយបានទេ

> ការចុះទស្សនកិច្ចសាលាដោយពុំមានផ្តល់ដំណឹងជាមុនចំនួន ១៧៣៣ លើក
> ការសង្កេតរយៈពេលបង្រៀនចំនួន ៦៧០ លើក
> ការសំភាសគ្រូបង្រៀន និងនាយកសាលាចំនួន ៣៩០ នាក់
> ការធ្វើតេស្តភាសាខ្មែរ និងគណិតវិទ្យាទៅលើសិស្សចំនួន ២៩៥៧ នាក់

ប៉ុន្តែយើងមានលទ្ធភាពសន្និដ្ឋានថាការផ្តល់ម៉ោងបង្រៀនទៅតាមការកំនត់នៅក្នុងឆ្នាំសិក្សានៅក្នុងប្រទេសកម្ពុជានៅ តែជាឧបសគ្គដ៏ធំមួយក្នុងការសម្រេចបាននូវការអនុវត្តន៍ប្រព័ន្ធអប់រំកម្រិតខ្ពស់ដែលផ្តល់ឱកាសស្មើភាពគ្នានៅទូទាំងប្រទេស។

**ឯកសារនៃការស្រាវជ្រាវដែលមានស្រាប់កំរិតអន្តរជាតិបានបញ្ជាក់យ៉ាងច្បាស់ថា មានការជាប់ទាក់ទងគ្នាមួយរវាងម៉ោងបង្រៀន និងលទ្ធផលនៃការសិក្សារបស់សិស្ស** ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍដែលម៉ោងបង្រៀនមានចំនួនទាបរួចស្រេចហើយនោះ។ ការពិនិត្យមើលឯកសារដែលមានស្រាប់របស់យើងបង្ហាញថា ប្រទេសកម្ពុជាមិន អាចប្រៀបធៀបបានល្អជាពិសេសជាមួយមធ្យមភាគនៃម៉ោងបង្រៀនដែលគេបានកំណត់នៅថ្នាក់អន្តរជាតិ ឬថ្នាក់តំបន់ បានទេ ហើយដូចនឹងប្រទេសប្រហាក់ប្រហែលគ្នានេះជាច្រើនមានបញ្ហាដែលគេទទួលស្គាល់មួយទាក់ទងនឹងគម្លាតរវាង ឆ្នាំសិក្សាដែលគេបានកំណត់ និងអ្វីដែលសិស្សទទួលបានពិតប្រាកដនៅពេលដែលគេពិនិត្យមើលពីការបិទសាលារៀនក្រៅផ្លូវការ និងអវត្តមានរបស់គ្រូបង្រៀន។ ជាថ្មីម្តងទៀត ស្របគ្នានឹងបណ្តាប្រទេសកំពុងអភិវឌ្ឍផ្សេងៗទៀតដែរ បញ្ហានេះកើតមានជាពិសេសនៅក្នុងតំបន់ជនបទ។ ការពិនិត្យមើលឯកសារដែលមានស្រាប់បានពិភាក្សាពីការ ឆ្លើយតបនានាចំពោះបញ្ហានេះនៅ

ក្នុងប្រទេសផ្សេងៗជាច្រើន ដោយរាប់បញ្ចូលទាំងតាមរយៈការផ្តល់រង្វាន់លើកទឹកចិត្ត និងការត្រួតពិនិត្យតាមដានគ្រូបង្រៀន ព្រមទាំងការបង្កើតប្រព័ន្ធវាយតម្លៃគ្រូបង្រៀន។

**លទ្ធផលរកឃើញរបស់យើងបង្ហាញថា ម៉ោងក្នុងឆ្នាំសិក្សានៅក្នុងប្រទេសកម្ពុជានៅតែបាត់បង់យ៉ាងនៅឡើយតាមរយៈថ្ងៃឈប់សម្រាកជាផ្លូវការបន្ថែមរបស់សាលារៀន ការអវត្តមានរបស់គ្រូបង្រៀន និងការថយចុះនូវម៉ោងដែលសិស្សរៀនជាមួយគ្រូក្នុងថ្នាក់ ដោយសារម៉ោងបង្រៀនកាន់តែខ្លី។** លទ្ធផលរួមនៃមូលហេតុនៃម៉ោងបង្រៀន និងម៉ោងរៀនដែលបានកាត់បន្ថយទាំងនេះមានន័យថា ចំពោះគ្រូបង្រៀនយើងអនុវត្តតាមមធ្យមភាគឆ្នាំសិក្សាដែលបានបង្រៀនគឺមាន២៧% **ឬស្មើនឹង៥០,៥ថ្ងៃ តិចជាងចំនួនដែលគេត្រូវ**បង្រៀន។ ដោយសារគ្រូបង្រៀននៅក្នុងការសិក្សានេះដឹងថាពួកគាត់នឹងត្រូវបានគេពិនិត្យមើលក្នុងមួយឆ្នាំនេះហើយថា យើងបានដកចេញនូវម៉ោងបង្រៀនថ្ងៃព្រហស្បតិ៍ ការនេះទំនង ជានៅតែជាការប៉ាន់ស្មានដែលទាបជាងជាក់ស្តែង។

| សង្ខេបលទ្ធផល | ជនបទ | ទីប្រជុំជន | សរុបរួមគ្នា |
|---|---|---|---|
| អត្រាអវត្តមានរបស់គ្រូបង្រៀនជាមធ្យម | ១២% | ៨% | ១០.៥% |
| ការកាត់បន្ថយម៉ោងជាមធ្យមនូវរយៈពេលនៃការបង្រៀន | ១៤% | ៧% | ១២% |
| ការកាត់បន្ថយម៉ោងជាមធ្យមសម្រាប់ឆ្នាំសិក្សា២០១២/១៣ លទ្ធផលជារួម ដោយរាប់បញ្ចូលទាំងថ្ងៃឈប់សម្រាកជាផ្លូវការ | ៣០% | ២១% | ២៤% |
| ភាគរយនៃការបិទសាលារៀនទាំងមូលក្នុងអំឡុងពេលនៃការចុះទស្សនកិច្ចសាលារៀនដោយពុំមានផ្តល់ដំណឹងជាមុន | ១៤% | ៣% | ១០% |

យើងក៏បានរកឃើញថា **ម៉ោងបង្រៀននៅសាលាដែលបានផ្តល់ឱ្យក៏មានចំនួនកាន់តែទាបមែនទែនដែរនៅតាមតំបន់ជនបទ** ដែលមាននៅក្នុងវិសមភាពដែលគេទទួលស្គាល់ជាទូទៅរវាងតំបន់ជនបទ និងទីប្រជុំជននៅក្នុងប្រទេសកម្ពុជា។ **កុមារនៅក្នុងតំបន់ដាច់ស្រយ៉ាលមែនទែន មានលទ្ធភាពទទួលបានការសិក្សាតាមកម្មវិធីថ្នាក់បឋមសិក្សាកាន់តែតិច ហើយលទ្ធផលនៃការសិក្សានៅក្នុងការធ្វើតេស្ត**ភាសាខ្មែរ និងគណិតវិទ្យារបស់យើងមានកម្រិតទាបជាងលទ្ធផលរបស់សិស្សនៅទីប្រជុំជន។ នៅក្នុងតំបន់ជនបទ យើងសង្កេតឃើញថាលទ្ធផលនៃការធ្វើតេស្តរបស់សិស្សទាក់ទងនឹងអត្រាអវត្តមានរបស់គ្រូបង្រៀននៅក្នុងអំឡុងឆ្នាំ ដោយលទ្ធផលនៃការធ្វើតេស្តជាមធ្យមទាបបំផុតរបស់សិស្សទាក់ទងទៅនឹងទីតាំងសាលារៀននៅតំបន់ជនបទ និងអវត្តមានជាញឹកញាប់របស់បុគ្គលិកបង្រៀន។

ការកាត់បន្ថយចំពោះម៉ោងបង្រៀនបង្រៀននៅតំបន់ជនបទ គឺទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងការរកឃើញរបស់យើងដែលថា **ការបិទសាលារៀនដែលជា "ទម្លាប់ជាទូទៅ" មានន័យថាគ្រូបង្រៀន និងអ្នកគ្រប់គ្រងការងារអប់រំកំពុងមាន ភាពសកម្មក្នុងការជ្រើសរើសការកាត់បន្ថយម៉ោងរៀនប្រចាំឆ្នាំ និងមានផលប៉ះពាល់មកលើសិទ្ធទទួលបានការអប់រំរបស់កុមារ។** យើងប្រើប្រាស់ពាក្យការបិទសាលារៀនដែលជា "ទម្លាប់ជាទូទៅ" ដើម្បីភ្ជាប់ទៅនឹងការសម្រេចចិត្តនៅតាម មូលដ្ឋានក្នុងការបន្តរយៈពេលនៃថ្ងៃឈប់សម្រាក និងយកថ្ងៃមួយ

ចំនួនទៀតសម្រាប់ឈប់សម្រាក ដែលយើងបានរកឃើញថាមានលក្ខណៈទូទៅកាន់តែច្រើនឡើងនៅក្នុងតំបន់ជនបទ។ ជារួមគ្រូបង្រៀនដែលយើងបានធ្វើទស្សនៈសាលារៀនដោយ ដោយពុំមានផ្តល់ដំណឹងជាមុន ចំនួន១៧%បានអវត្តមានទាំងនៅមុន និងក្រោយថ្ងៃឈប់សម្រាកជាផ្លូវការ ហើយ ៤៧%អវត្តមាននៅក្នុងអំឡុងថ្ងៃបុណ្យចូលឆ្នាំចិន។ ចំណុចនេះបង្កឱ្យមានការចោទជាសំណួរអំពីគុណតម្លៃដែលមានទៅលើម៉ោងបង្រៀន។ គ្រូបង្រៀនចំនួន១/៥ដែលយើងបានសម្ភាសបានចង្អុលបង្ហាញថាពួកគាត់ពុំអាចបង្រៀនចប់តាមកម្មវិធីសិក្សាទាំងអស់ជាមួយនឹងម៉ោងបង្រៀនដែលមាននៅនៅក្នុងសាលា។

ជាទីបញ្ចប់ យើងសន្និដ្ឋានបានថា **ការអនុវត្តន៍ក្នុងការគ្រប់គ្រង ការជ្រើសរើស និងការពង្រាយគ្រូបង្រៀន** គឺជាកត្តាដែលសំខាន់ជាងគេបង្អស់ដែលរួមចំណែកដល់ការបាត់បង់ម៉ោងបង្រៀន។ ការសម្ភាសលម្អិតស្តីពីការអនុវត្តន៍ ការគ្រប់គ្រងគ្រូបង្រៀនលើកឡើងថា គោលនយោបាយបុគ្គលិកដែលត្រូវបានគេរៀបចំឡើងដើម្បីដាក់ទណ្ឌកម្មទៅលើគ្រូ បង្រៀនដែលអវត្តមានច្រើនពុំអាចដំណើរការប្រកបដោយប្រសិទ្ធិភាពទេ។ ដោយសារហេតុផលផ្សេងៗជាច្រើន នាយកសាលាហាក់ដូចជាមានការស្ទាក់ស្ទើរក្នុងការប្រើប្រាស់ទណ្ឌកម្មដែលមាន។ ហេតុផលមួយក្នុងចំណោមហេតុផលទាំងនេះគឺថា ការអនុវត្តន៍ក្នុងការជ្រើសរើស និងការពង្រាយគ្រូបង្រៀនធ្វើឱ្យពួកគាត់សម្រេចចិត្តថា ការមានគ្រូបង្រៀនអវត្តមានច្រើនគឺប្រសើរជាងការខ្វះគ្រូបង្រៀន។ ហេតុផលមួយផ្សេងទៀតគឺការយល់ឃើញជាទូទៅថា វាជាការចាំបាច់ចំពោះគ្រូបង្រៀនក្នុងការធ្វើការងារមួយចំនួននៅខាងក្រៅសាលារៀនដើម្បីបង្កើនប្រាក់ ចំណូលរបស់ពួកគាត់។

ជារួម យើងសន្និដ្ឋានថាការជម្នះលើឧបសគ្គនេះគឺការអនុវត្តតាម គោលនយោបាយឱ្យបានច្រើន។ ក្របខ័ណ្ឌគោលនយោបាយស្តីពីបញ្ហាជាក់លាក់នៃអវត្តមានរបស់គ្រូបង្រៀនមានភាពរឹងមាំមែនទែន ហើយចំណែកការសិក្សានេះ ពិតជាផ្តល់អនុសាសន៍ដើម្បីឱ្យមានការកែលម្អរមួយចំនួនចំពោះបញ្ហានេះ។ បញ្ហាសំខាន់គឺស្ថិតនៅលើការអនុវត្តន៍ នៅតាមមូលដ្ឋាននូវគោលនយោបាយ និងត្រូវប្រកាន់ខ្ជាប់នូវស្តង់ដារថ្នាក់ជាតិ។ គ្រូបង្រៀនជាច្រើននៅក្នុងការសិក្សា នេះបង្ហាញពីវត្តមាន និងភាពទៀងទាត់ ពេលវេលាក្នុងកម្រិតខ្ពស់។ ទោះជាយ៉ាងនេះក្តី គ្រូបង្រៀនជាច្រើនដែលអវត្តមាន និងពុំគោរពពេល វេលាឱ្យបានត្រឹមត្រូវនៅក្នុងសាលារៀន ហើយសាលារៀនជាច្រើនដែលបានបិទទ្វារក្រៅផ្លូវការដោយ ជះឥទ្ធិពលជាខ្លាំងដល់លទ្ធផលសិក្សារបស់សិស្ស ហើយ ការិយាល័យនិងមន្ទីរអប់រំស្រុកបានចាត់វិធានការ គ្រប់គ្រង និងដាក់ទណ្ឌកម្មដោយមានកម្រិត។ ទោះបីជាអនុសាសន៍របស់យើងផ្តោតភាគច្រើនទៅ លើថ្នាក់ជាតិក៏ដោយ ក៏វាមានសារៈសំខាន់ដែរជាពិសេសក្នុងការសង្កត់ធ្ងន់ទៅលើវិសាលភាពដែលការនេះធ្វើឱ្យ មានភាពខុសគ្នាកាន់តែច្រើនឡើងចំពោះឱកាសក្នុងជីវិតរវាងតំបន់ទីប្រជុំជន និងជនបទ ព្រមទាំងតម្រូវការចំពោះគោលនយោបាយ និងសកម្មភាពថ្មីនៅក្នុងវិស័យនេះដែលគេត្រូវរៀបចំឡើងដោយមានការចងចាំជាប់ជានិច្ចក្នុងការអនុវត្តន៍នៅតាមតំបន់ជនបទ។

យើងបានលើកឡើងនូវអនុសាសន៍ចំនួន៦នៅក្នុងការសិក្សានេះ

១. ក្រសួងអប់រំ យុវជន និងកីឡាត្រូវផ្តួចផ្តើមឱ្យមានការពិនិត្យមើលឡើងវិញជាមូលដ្ឋានមួយសម្រាប់ឆ្នាំសិក្សា និងថ្ងៃឈប់សំរាកតាមសាលា ដើម្បីឆ្លើយតបទៅនឹងទម្លាប់ជាទូទៅ ទាំងថ្ងៃឈប់សំរាកផ្លូវការបន្ថែមទៀត និងទាំង ឬការបិទសាលារៀននៅក្នុងឆ្នាំសិក្សា។

២. ក្រសួងអប់រំ យុវជន និងកីឡាចាំបាច់ត្រូវបន្តផ្តល់អាទិភាពដល់វិធានការស្តីពីការជ្រើសរើស ការរក្សាទុក និងការពង្រាយគ្រូបង្រៀន

ក្នុងគោលបំណងធ្វើឱ្យមានលទ្ធភាពពង្រឹងការគ្រប់គ្រងបុគ្គលិកឱ្យកាន់តែរឹងមាំថែមទៀត ដោយពុំនាំទៅរកការខ្វះគ្រូបង្រៀនកាន់តែច្រើនឡើងទេ។

៣. ក្រសួងអប់រំ យុវជន និងកីឡា និងមន្ត្រីអប់រំនៅថ្នាក់ក្រោមជាតិត្រូវពង្រឹងការគ្រប់គ្រងបុគ្គលិក និងការធ្វើអធិការកិច្ចសាលារៀន ដើម្បីលើកកម្ពស់វត្តមានរបស់គ្រូបង្រៀន និងកាត់បន្ថយការបិទសាលារៀន។

៤. នៅក្នុងរយៈពេលមធ្យម ជម្រើសកាន់តែច្រើន និងប្រសើរឡើងមួយសម្រាប់ការផ្តល់នូវ"ការបង្រៀនជំនួស"សម្រាប់គ្រូ បង្រៀនដែលអវត្តមាន ដើម្បីកុំមានផលប៉ះពាល់ច្រើនទៅលើលទ្ធភាពទទួលបានការអប់រំរបស់សិស្ស។

៥. ការចូលរួមរបស់សហគមន៍នៅក្នុងការត្រួតពិនិត្យសាលារៀន និងធ្វើឱ្យសាលារៀនបង្កើននូវគណនេយ្យភាពរបស់ខ្លួន។

៦. នៅក្នុងរយៈពេលវែង យើងត្រូវបង្កើនម៉ោងបង្រៀនដែលត្រូវផ្តល់នៅក្នុងប្រទេសកម្ពុជាដើម្បីឆ្លើយតបទៅនឹងបទដ្ឋានអន្តរជាតិ។

# I. សេចក្តីផ្តើម និងវត្ថុបំណងនៃការស្រាវជ្រាវ

ការកែលម្អគុណភាព និងប្រសិទ្ធផលនៃសេវាអប់រំនៅក្នុងប្រទេសកម្ពុជាគឺជាអាទិភាពដ៏ខ្ពស់មួយសម្រាប់រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា។ សកម្មភាពនៅក្នុងផែនការយុទ្ធសាស្រ្តវិស័យអប់រំឆ្នាំ២០១៤-២០១៨ បានដាក់ចេញនូវវិធានការជាច្រើនដើម្បីកែលម្អទាំងលទ្ធភាពទទួលបាននិងគុណភាពអប់រំនៅគ្រប់កម្រិត ហើយផែនការនេះបានទទួលការគាំទ្រពីសំណាក់ដៃគូអភិវឌ្ឍ និងសហគមន៍អង្គការមិនមែនរដ្ឋាភិបាល។ ផែនការយុទ្ធសាស្រ្តវិស័យអប់រំ(ESP) ទទួលស្គាល់នូវវឌ្ឍនភាពសំខាន់ៗដែលសម្រេចបានក្នុងការកែលម្អការអប់រំនៅក្នុងប្រទេសក៏ដូចជាការប្រឈមមុខនានាដែលនៅសេសសល់។

ការសិក្សាស្រាវជ្រាវ ការពិនិត្យមើលឡើងវិញ និងកិច្ចពិភាក្សានៅក្នុងអង្គសន្និបាតអប់រំថ្នាក់ជាតិកន្លងមកបានទទួលស្គាល់ថា ការប្រឈមមុខមួយក្នុងចំណោមការប្រឈមមុខទាំងនេះ គឺការធានានូវការផ្តល់ម៉ោងសិក្សាឱ្យបានគ្រប់គ្រាន់នៅក្នុងសាលារៀននៅកម្ពុជា។ ចំណុចនេះគឺជាបញ្ហាដ៏ស្មុគ្រស្មាញមួយ ហើយវារាប់បញ្ចូលទាំងសំណួរនានាស្តីពីចំនួនម៉ោងនៃការជួបគ្នារវាងគ្រូបង្រៀន និងសិស្សដែលគេត្រូវកំណត់ជាផ្លូវការនិងចំនួនម៉ោងជាក់ស្តែងដែលបានចំណាយនៅក្នុងថ្នាក់រៀននៅតាមសាលារៀននៅទូទាំងប្រទេសនាពេលបច្ចុប្បន្ន។

ការសិក្សាស្រាវជ្រាវដែលរបាយការណ៍នេះពឹងផ្អែកលើ គឺត្រូវបានរៀបចំឡើងដើម្បីរួមចំណែកជាពិសេសដល់ការយល់ដឹងពីម៉ោងបង្រៀនជាក់ស្តែងនៅតាមសាលារៀន ថាតើសាលារៀនបានផ្តល់នូវម៉ោងសិក្សាបានចំនួនប៉ុន្មានបើប្រៀបធៀបទៅនឹងម៉ោងសិក្សាដែលបានកំណត់ក្នុងគោលនយោបាយជាតិ។ ការសិក្សាកន្លងមកនៅក្នុងឆ្នាំ ១៩៩៩(MoEYS) ឆ្នាំ២០០៥(NEP)និងឆ្នាំ២០០៨(MoEYS) បានរកឃើញនូវការបាត់ម៉ោងសិក្សា ឬ ម៉ោងបង្រៀនដែលបានផ្តល់ឱ្យជាក់ស្តែងយ៉ាងច្រើន បើប្រៀបធៀបទៅនឹងការរំពឹងទុកនៅថ្នាក់ជាតិ។ ការសិក្សានេះមានបំណងធ្វើបច្ចុប្បន្នភាពភស្តុតាងរបស់យើងចំពោះបញ្ហានេះនិងពិចារណាពីសកម្មភាពឬផលវិបាកផ្នែកគោលនយោបាយឱ្យស្របទៅនឹង ផែនការយុទ្ធសាស្រ្តវិស័យអប់រំបច្ចុប្បន្ន និងការអភិវឌ្ឍ ធនធានមនុស្សនៅក្នុងប្រទេសកម្ពុជាព្រមទាំងដើម្បីស្វែងយល់ឱ្យបានស៊ីជម្រៅថែមទៀត ពីមូលហេតុនានាដែលនាំឱ្យមានការបាត់បង់ម៉ោងបង្រៀន និងផលវិបាកនៃការបាត់ម៉ោងនេះ។

វត្ថុបំណងខាងក្រោមនេះត្រូវបានកំណត់នៅពេលគម្រោងចាប់ផ្តើមៈ

- ដើម្បីកំណត់ពីវិសាលភាពនៃការបាត់ម៉ោងបង្រៀននៅថ្នាក់បឋមសិក្សានៅក្នុងប្រទេសកម្ពុជាដោយប្រៀបធៀបជាមួយនឹងម៉ោងសិក្សាដែលបានកំណត់សម្រាប់រយៈពេលមួយឆ្នាំដូចដែលបានចែងនៅក្នុងគោលនយោបាយសម្រាប់អភិវឌ្ឍកម្មវិធីសិក្សាចំណេះទូទៅឆ្នាំ២០០៥-២០០៩ របស់ក្រសួងអប់រំយុវជននិងកីឡា
- ដើម្បីពិនិត្យមើលថាតើមានកត្តាអ្វីខ្លះដែលទាក់ទងនឹងការបាត់ម៉ោងសិក្សា និង
- ដើម្បីសិក្សាស្វែងយល់ពីផលវិបាកនៃការបាត់ម៉ោងសិក្សាទៅលើលទ្ធផលនៃការសិក្សារបស់សិស្ស

ការចុះប្រមូលព័ត៌មាននៅក្នុងការសិក្សាស្រាវជ្រាវនេះត្រូវបានបញ្ចប់នៅក្នុងឆ្នាំសិក្សា២០១២/២០១៣

ទៅលើសាលាបឋមសិក្សាចំនួន៩១ និងគ្រូបង្រៀនចំនួន ៣០៩នាក់ នៅក្នុងខេត្តចំនួន៥ និងរាជធានី

ភ្នំពេញ។ ការសិក្សានេះត្រូវបានរៀបចំឡើងដើម្បីប្រមូលភស្តុតាងពីប្រភពផ្សេងៗគ្នាជាច្រើន ក្នុងគោលបំណង ទទួលបាននូវការយល់ដឹងកាន់តែស៊ីជម្រៅថែមទៀតទៅលើភាពខុសគ្នា ចំពោះម៉ោងសិក្សាដែលបាន បង្រៀននៅតាមសាលារៀន ដោយជ្រើសរើសនូវសំណាកដែលមានចំនួនច្រើនជាង និងការប្រមូលព័ត៌ មានដែលមានរយៈពេល យូរជាងការសិក្សាពីមុនៗ។

ការសិក្សានេះមានគោលបំណងវាយតម្លៃពីការបាត់ម៉ោងសិក្សាជាលក្ខណៈរូបវន្ត គឺមិនមែនទៅលើ ប្រសិទ្ធភាពនៃការបង្រៀនក្នុងថ្នាក់រៀន ឬវិធីសាស្ត្រនៃការបង្រៀនដែលផ្តល់ឱ្យសិស្សនោះទេ។ ដើម្បីឱ្យ សម្រេចបាននូវសិទ្ធិទទួលបានការអប់រំ គុណភាព បង្រៀនដែលគេផ្តល់ឱ្យនៅក្នុងថ្នាក់រៀន គឺជាមូលដ្ឋានគ្រឹះ ប៉ុន្តែវាក៏ជាមូលដ្ឋានគ្រឹះផងដែរដែលប្រព័ន្ធនៃការសិក្សាផ្តល់នូវម៉ោងបង្រៀនគ្រប់គ្រាន់ ហើយ ប្រកបដោយសមធម៌ចំពោះប្រជាជនទូទៅ។ ជាមួយគ្នានេះដែរ ដោយសារយើងធ្វើការនៅក្នុងប្រទេស កម្ពុជាដើម្បីកែលម្អគុណភាពនៃការបង្រៀន និងរៀនយើងក៏ចាំបាច់ត្រូវដឹងពីមូលដ្ឋានគ្រឹះនៃការផ្តល់នូវ ប្រព័ន្ធអប់រំមួយដែលអាចជឿជាក់បាន និងមានប្រសិទ្ធផល។

## II. ម៉ោងសិក្សានៅថ្នាក់បឋមសិក្សាក្នុងប្រទេសកម្ពុជា ៖ បរិបទ

ដោយផ្អែកលើជ្រុងមួយនៃគំនិតដែលគេយល់ថា រយៈពេលដែលកុមារចំណាយក្នុងថ្នាក់រៀនគឺមាន ទំនាក់ទំនងជាវិជ្ជមានជាមួយនឹងលទ្ធផលនៃការសិក្សា គឺត្រូវបានបញ្ជាក់នៅក្នុងការសិក្សានានាដែលគេទទួល យកនៅក្នុងវិស័យអប់រំ។ ប្រសិនបើគ្រូបង្រៀនអវត្តមានពីសាលារៀន ឬសាលារៀនត្រូវបានបិទទ្វារសិស្សនឹង មានឱកាសតិចតួចក្នុងការរៀនសូត្រ។ នៅក្នុងបរិបទនៃប្រទេសកម្ពុជាដែលពឹងផ្អែកទៅលើការរៀនសូត្រនៅក្នុង ថ្នាក់រៀនតាមរយៈការផ្ទេរចំណេះដឹង ដោយផ្ទាល់ពីគ្រូបង្រៀនទៅសិស្សនោះចំនួនម៉ោងបង្រៀនគឺកាន់តែមាន ផលប៉ះពាល់ខ្លាំងឡើងទៅលើការអប់រំរបស់សិស្ស។

ការលើកកម្ពស់គុណភាពអប់រំ គឺពឹងផ្អែកលើអន្តរាគមន៍ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយដែលរាប់ បញ្ចូលទាំងចំណុចសំខាន់ៗ ដូចជាផ្នែកគរុកោសល្យ កម្មវិធីសិក្សា ចំណេះដឹងរបស់គ្រូបង្រៀន ព្រមទាំងសម្ភារៈ បង្រៀន និងរៀន។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីធ្វើឱ្យការធ្វើអន្តរាគមន៍ផ្សេងទៀតមានប្រសិទ្ធភាពគេត្រូវ ផ្តល់ឱកាសឱ្យសិស្សរៀនសូត្រប្រកបដោយសង្គតភាព។ ចំណុចនេះមានន័យថា ត្រូវមានបុគ្គលិកបង្រៀនដែល មានការរៀបចំការបង្រៀនបានល្អក្នុងចំនួនគ្រប់គ្រាន់ដើម្បីបង្រៀនថ្នាក់រៀនត្រូវបង្រៀនទៅតាមពេលវេលាដែល ច្បាប់បានកំណត់ ហើយសាលារៀនត្រូវបើកទ្វារបង្រៀន ឱ្យគ្រប់ម៉ោងតាមកម្មវិធីដែលបានកំណត់។ បើគ្មានការ ផ្តល់ឱកាសឱ្យសិស្សបានរៀនសូត្រទេ ការធ្វើអន្តរាគមន៍ ដែលមានបំណងកែលម្អគុណភាពអប់រំនោះ ក៏នឹងមិន បានសម្រេចនូវលទ្ធផលរំពឹងទុករបស់ខ្លួនឡើយ។

ភស្តុតាងកម្រិតអន្តរជាតិដែលមានស្រាប់ បង្ហាញពីទំនាក់ទំនងទៅវិញទៅមករវាងម៉ោងបង្រៀន និង លទ្ធផលសិក្សារបស់សិស្ស។ Bellei នៅឆ្នាំ២០០៩ និងOrkin នៅឆ្នាំ២០១៣ បានបង្ហាញពីរបៀបដែលការ បង្កើនពេលវេលានៅក្នុងសាលារៀនបានធ្វើឱ្យលទ្ធផលសិក្សានៅក្នុងប្រទេសChile និងអេចូពីបានប្រសើរឡើង រៀងៗខ្លួន។ នៅក្នុងប្រទេសអេចូពី ម៉ោងសិក្សានៅតាមសាលារៀនត្រូវបានគេបង្កើនពី៤ម៉ោងទៅជា៦ម៉ោងក្នុង មួយថ្ងៃ។ នៅក្នុងឆ្នាំ១៩៩១ Lockheed និង Verspoor បានធ្វើការសន្និដ្ឋានដោយផ្អែកលើលទ្ធផលនៃការ សិក្សាស្រាវជ្រាវកម្រិតអន្តជាតិស្តីពីម៉ោងបង្រៀនថា “ប្រទេសកំពុងអភិវឌ្ឍគួរស្វែងរកមធ្យោបាយនានា ដើម្បី កែលម្អ និងបង្កើនពេលវេលាដែលគ្រូត្រូវលះបង់ដើម្បីបង្រៀន និងពេលវេលាដែលសិស្សត្រូវលះបង់ដើម្បីរៀន

ជាពិសេសនៅសាលាបឋមសិក្សា”។ អ្នកធ្វើអត្ថាធិប្បាយមួយចំនួនបានព្រមានថា ការផ្តោតទៅលើម៉ោងបង្រៀនតែមួយមុខអាចធ្វើឱ្យភ្លេចគិតទៅដល់ធាតុចូលសំខាន់ៗផ្សេងៗទៀត ដូចជាការបណ្តុះបណ្តាលគ្រូ សៀវភៅសិក្សាគោល និងខ្លឹមសាររបស់កម្មវិធីសិក្សា។ ទោះជាយ៉ាងណាក៏ដោយនៅមានមន្ទិលតិចតួចទៅលើតើរយៈពេលប៉ុន្មានដែលសិស្សត្រូវចំណាយក្នុងការរៀនសូត្រ គឺមានសារសំខាន់ចំពោះអ្នករៀបចំគោលនយោបាយអប់រំ។

នៅក្នុងផ្នែកនេះនឹងចាប់ផ្តើមដោយមានការពិនិត្យមើលឡើងវិញដោយសង្ខេបពីរបៀបដែលម៉ោងសិក្សាត្រូវបានកំណត់ជាផ្លូវការដោយរដ្ឋាភិបាលកម្ពុជា និងប្រៀបធៀបការកំណត់នេះជាលក្ខណៈអន្តរជាតិ។ បន្ទាប់មកគេពិនិត្យមើលឯកសារកម្រិតអន្តរជាតិដែលមានស្រាប់ស្តីពីភាពខុសគ្នា រវាងម៉ោងបង្រៀនដែលបានកំណត់ និងម៉ោងបង្រៀនជាក់ស្តែង ព្រមទាំងពិពណ៌នាពីហេតុផលផ្សេងៗដែលគម្លាតនេះមានភាពធំធេងនៅក្នុងប្រទេសជាច្រើន។ ចំណាប់អារម្មណ៍ជាពិសេសចំពោះការសិក្សានេះ គឺប្រធានបទទាក់ទងនឹងអវត្តមានរបស់គ្រូបង្រៀនដែលត្រូវបានគេបង្ហាញថាជាមូលហេតុដ៏ចម្បងមួយចំពោះការធ្លាក់ចុះម៉ោងបង្រៀនជាអន្តរជាតិ។ ហេតុដូច្នេះហើយចំណុចនេះក៏នឹងផ្តល់ផងដែរនូវការពិនិត្យមើលដោយសង្ខេបអំពីឯកសារដែលមានស្រាប់ស្តីពីអវត្តមានរបស់គ្រូបង្រៀនព្រមទាំងពិនិត្យមើលពីដំណោះស្រាយនានា ដែលគេស្នើឡើងនៅកន្លែងផ្សេងទៀតដោយរាប់បញ្ចូលទាំងការបង្កើតឱ្យមានប្រព័ន្ធគ្រប់គ្រងការបំពេញការងាររបស់គ្រូបង្រៀន។

## ២.១ម៉ោងសិក្សាដែលគេកំណត់ជាផ្លូវការ

នៅក្នុងប្រទេសកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡាបានកំណត់ជាផ្លូវការថាសិស្សនៅថ្នាក់បឋមសិក្សាត្រូវបានគេបង្រៀនពី ៦៨៤-៧៦០ ម៉ោងក្នុងមួយឆ្នាំសិក្សា។ ចំណុចនេះគឺផ្អែកលើរយៈពេលសិក្សាដែលមានពី ២៧ ទៅ៣០ ម៉ោងសិក្សាក្នុងមួយសប្តាហ៍ដែលក្នុង ១ម៉ោងសិក្សាមានថេរៈវេលា ៤០នាទី ហើយក្នុង ១ឆ្នាំ មានរយៈពេល៣៨សប្តាហ៍ ដោយដកថ្ងៃឈប់សម្រាកជាសាធារណៈនិងវិស្សមកាលតូចចេញ។ តម្រូវការទាំងនេះបានកំណត់នៅក្នុងគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សា។ គួរកត់សម្គាល់ផងដែរថា នៅសាលាបឋមសិក្សាប្រទេសកម្ពុជាពាក្យ “ម៉ោងសិក្សា” ជាទូទៅគឺសំដៅទៅលើ ពេលសិក្សាដែលមានរយៈពេល៤០នាទី។ នៅពេលដែលគេនិយាយពីម៉ោង គឺសំដៅទៅលើពេលវេលាដែលមានរយៈពេល ៦០នាទី។

រយៈពេលពី ៦៨៤ ទៅ ៧៦០ ម៉ោងនេះគឺបានមកពីភាពបត់បែននៅក្នុងការបង្រៀនកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន(LLSP)នៅតាមសាលារៀននីមួយៗ ដោយសារសាលារៀនមានសិទ្ធិផ្តល់មេរៀនបំណិនជីវិតពី២ ទៅ៥ មេរៀនក្នុងមួយសប្តាហ៍។ គោលបំណងនៃមេរៀនបំណិនជីវិតគឺជាការអនុញ្ញាតឱ្យ “សាលារៀនមានឱកាសផ្តល់វគ្គបណ្តុះបណ្តាលមុខវិជ្ជាបំណិនជីវិតជាក់លាក់ដែលជាប់ទាក់ទងជាពិសេសជាមួយសិស្សនៅតាមមូលដ្ឋានដោយធ្វើជាដៃគូជាមួយមាតាបិតាសិស្ស សហគមន៍នៅមូលដ្ឋានរបស់ខ្លួន អង្គការនៅសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល”ហើយ“ដើម្បីផ្តល់ឱ្យសាលារៀននូវពេលវេលានៅក្នុងកម្មវិធីសិក្សាសម្រាប់សកម្មភាពក្រៅកម្មវិធីសិក្សាបន្ថែមទៀត”។

| ការអប់រំថ្នាក់បឋមសិក្សា (ថ្នាក់ទី១-៦) | | |
|---|---|---|
| កម្មវិធីសិក្សាជាតិ | កម្មវិធីបំណិនជីវិតតាមមូលដ្ឋាន | មេរៀនសរុប |
| ៥ម៉ោងសិក្សាក្នុងមួយថ្ងៃ។ ១ ម៉ោងសិក្សាមាន ៤០នាទី។ (២៥ x ៤០ នាទីក្នុងមួយសប្តាហ៍) | ២-៥ម៉ោងសិក្សាក្នុងមួយសប្តាហ៍ មួយម៉ោងសិក្សាមាន ៤០ នាទី។ | ២៧-៣០ម៉ោងសិក្សា/ មេរៀនក្នុងមួយសប្តាហ៍ |

គោលនយោបាយតម្រូវឱ្យរៀនកម្មវិធីសិក្សាជាតិចំនួន ៥ថ្ងៃក្នុងមួយសប្តាហ៍ ហើយមួយថ្ងៃទៀត (គឺថ្ងៃព្រហស្បតិ៍)ត្រូវប្រើប្រាស់សម្រាប់កម្មវិធីបំណិនជីវិតតាមមូលដ្ឋាន និងថ្នាក់បំប៉ន។

ដូចគ្នានឹងប្រព័ន្ធអប់រំថ្នាក់បឋមសិក្សាជុំវិញពិភពលោកដែរពេលវេលាភាគច្រើនត្រូវបានគេបម្រុងទុកសម្រាប់មុខវិជ្ជាភាសា (ភាសាខ្មែរ) និងគណិតវិទ្យា ដោយមានទិសដៅសម្រេចឱ្យបាននូវការអានសរសេរភាសាខ្មែរ និងការគណនាលេខនៅពេលបញ្ចប់ថ្នាក់ទី៣។ នៅពេលសិស្សរៀនដល់ថ្នាក់ទី៤ ពួកគេត្រូវរៀនមេរៀនភាសាខ្មែរចំនួន ១០ម៉ោងសិក្សា គណិតវិទ្យាចំនួន ៦ម៉ោងសិក្សា សិក្សាសង្គមចំនួន ៤ម៉ោងសិក្សា វិទ្យាសាស្ត្រចំនួន ៣ម៉ោងសិក្សា និងអប់រំកាយចំនួន ២ម៉ោងសិក្សាក្នុងមួយសប្តាហ៍។ នៅពេលដែលសិស្សរៀនដល់ថ្នាក់ទី៥ និងទី៦ ការរៀនភាសាខ្មែរត្រូវថយចុះចំនួន២ម៉ោងសិក្សា ប៉ុន្តែបានកើនឡើងនូវមុខវិជ្ជាវិទ្យាសាស្ត្រ និងសិក្សាសង្គមវិញក្នុងមួយសប្តាហ៍។

វាមានសារៈសំខាន់ណាស់ក្នុងការកត់សម្គាល់ថា ថ្នាក់រៀនត្រូវបានគេបង្រៀននៅពេលព្រឹក ឬនៅពេលរសៀលបានន័យថាមានការបង្រៀនចំនួន ២វេនក្នុងមួយថ្ងៃ។ ជារឿយៗគ្រូបង្រៀនបង្រៀនទាំងវេនព្រឹក និងវេនរសៀលដែលនេះសំដៅទៅលើគ្រូបង្រៀនពីរវេន ឬពីរពេល។ យោងតាមក្រសួងអប់រំ យុវជន និងកីឡាគ្រូបង្រៀនដែលបង្រៀន២វេនមានចំនួន ១៧,០៣៥នាក់នៅក្នុងឆ្នាំ ២០១៤ ដែលស្មើនឹង ៣៨%នៃបុគ្គលិកបង្រៀនសរុបនៅក្នុងសាលាបឋមសិក្សា (របាយការណ៍សន្និបាតអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា ខែមីនា ឆ្នាំ២០១៥ ទំព័រទី១៨)។ វេននីមួយៗមានរយៈពេល៤ម៉ោង ដោយរាប់បញ្ចូលទាំងការសម្រាករយៈពេលខ្លីផងដែរ។ ថ្នាក់វេនព្រឹកចាប់ផ្តើមពីម៉ោង ៧ព្រឹកដល់ម៉ោង១១ព្រឹក។ ថ្នាក់វេនរសៀលចាប់ផ្តើមពីម៉ោង១រសៀលដល់ម៉ោង៥ល្ងាច។ ក្នុងការចុះតាមសាលារៀនកន្លងមក ក្រុមការងារស្រាវជ្រាវរបស់អង្គការNEP បានរកឃើញថា មានសាលារៀនមួយចំនួនតូចរៀបចំការបង្រៀន៣វេនក្នុងមួយថ្ងៃដែលជាទូទៅសិស្សរៀននៅក្នុងថ្នាក់មានរយៈពេលតិចជាង៤ម៉ោង។ ចំណុចនេះត្រូវបានគេកត់សំគាល់ជាពិសេសនៅតាមសាលារៀនមិនគ្រប់កម្រិត។ ការសិក្សានេះពុំមានរួមបញ្ចូលសាលារៀនណាមួយដែលមានរៀបចំការបង្រៀន៣វេនក្នុងមួយថ្ងៃនោះទេ តែមានសាលារៀនមួយចំនួនដែលដំណើរការបង្រៀន២វេនក្នុង១ថ្ងៃ។

បន្ថែមទៅលើម៉ោងប្រង្រៀនដែលបានកំណត់ គោលនយោបាយជាតិបង្ហាញពីសារៈសំខាន់របស់គ្រូបង្រៀនក្នុងការមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំមេរៀន និងការអនុវត្តន៍ការងារផ្នែករដ្ឋបាល។ អនុក្រិតលេខ ៣០៩ របស់រាជរដ្ឋាភិបាលកម្ពុជា ចុះខែធ្នូ ឆ្នាំ ២០១៤ បន្ទាប់ពីការប្រមូលព័ត៌មាននៅតាមសាលារៀនសម្រាប់ការសិក្សានេះត្រូវបានបញ្ចប់។ អនុក្រិតនេះបានបញ្ជាក់ថា គ្រូបង្រៀននៅសាលារៀនបឋមសិក្សាត្រូវធ្វើការ ៤០ម៉ោងក្នុងមួយសប្តាហ៍ ពោលគឺលើសពី៥ថ្ងៃ ដោយមានម៉ោងសិក្សាចំនួន ២៥សម្រាប់ថ្នាក់ទី១ដល់ទី៣

និង ២៧,៥ ម៉ោសិក្សាសម្រាប់ថ្នាក់ទី៤ដល់ទី៦។ ដោយសារមួយម៉ោងសិក្សាមានរយៈពេល ៤០នាទីតាមលក្ខណៈទ្រឹស្តីគ្រូមានពេលជាង២០ម៉ោងក្នុងមួយសប្តាហ៍សម្រាប់ការសម្រាក (ចេញលេង) ការរៀបចំកិច្ចតែងការបង្រៀនការវាយតម្លៃ និងការងាររដ្ឋបាល។ ចូរកត់ចំណាំថា សេចក្តីណែនាំនេះ ពុំដាក់បញ្ចូលនូវការបង្រៀនបំណិនជីវិតតាមមូលដ្ឋាននៅក្នុងម៉ោងបង្រៀនដែលច្បាប់បានកំណត់ជាទូទៅទេ គឺត្រូវបានរៀបចំឡើងផ្សេងៗគ្នាទៅតាមសាលារៀននីមួយៗ។

អនុក្រិតដែលនេះដែរក៏បានកំណត់ពីនីតិវិធីសម្រាប់ការឯកភាពគ្នាទៅលើការបង្រៀន ២វេន ដោយបញ្ជាក់ថាគេអាចពេញចិត្តក្នុងការប្រើប្រាស់គ្រូបង្រៀនបន្ថែម ឬគ្រូកិច្ចសន្យាជាជាងស្នើសុំឱ្យគ្រូបង្រៀន បង្រៀ ២វេន។ ភាពស្មុគ្រស្មាញគឺថាគ្រូបង្រៀនដែលបង្រៀន២វេនបានកាត់បន្ថយពេលវេលាក្នុងការរៀបចំកិច្ចតែងការបង្រៀន និងការងាររដ្ឋបាល។

## ២.១.១ ការប្រៀបធៀបជាលក្ខណៈអន្តរជាតិ

ការវិភាគថ្មីៗត្រូវបានគេធ្វើឡើងសម្រាប់របាយការណ៍ពិនិត្យតាមដានជាសកលឆ្នាំ២០១៥ ដែលចេញផ្សាយដោយអង្គការ UNESCO ដោយពិនិត្យមើលទៅលើមធ្យមភាគជាអន្តរជាតិសម្រាប់ម៉ោងបង្រៀនដែលគេបានកំណត់នៅក្នុងឆ្នាំ២០១០ ដោយប្រៀបធៀបនឹងឆ្នាំ២០០០។ របាយការណ៍នេះបានសន្និដ្ឋានថា ម៉ោងបង្រៀនដែលគេបានកំណត់ពិតជាបានកាត់បន្ថយជាសកលមែនសម្រាប់រយៈពេល១០ឆ្នាំកន្លងមកនេះ។ ចំនួនម៉ោងជាមធ្យមមានភាពខុសគ្នាយ៉ាងច្រើននៅគ្រប់កំរិតថ្នាក់ទាំងអសនៅបឋមសិក្សាដោយមានចាប់ពីប្រមាណពី ៧២០ម៉ោងក្នុងមួយឆ្នាំសម្រាប់ថ្នាក់ទី១ ដល់ប្រមាណជា៨២០ ម៉ោងសម្រាប់ថ្នាក់ទី៦ ដែលជាថ្នាក់ចុង បញ្ចប់នៅបឋមសិក្សានៅក្នុងប្រទេសកម្ពុជា។ នៅថ្នាក់តំបន់ចំនួនម៉ោងមានការប្រែប្រួលយ៉ាងច្រើន ហើយតារាងខាងក្រោមនេះចង្អុលបង្ហាញនូវទីតាំងនៃចំនួនម៉ោងរំពឹងទុករបស់ប្រទេសកម្ពុជាបច្ចុប្បន្នដែលមាន ចំនួនម៉ោងពី ៦៨៤-៧៦០ម៉ោង។ នៅតាមបណ្តាប្រទេសជាសមាជិករបស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) នៅក្នុងឆ្នាំ ២០១៤ ចំនួនម៉ោង ដែលគេកំណត់ជាមធ្យមសម្រាប់សិស្សថ្នាក់បឋមសិក្សា គឺជិត៨០០ ម៉ោងក្នុងមួយឆ្នាំ។ មធ្យមភាគស្រដៀងគ្នានេះត្រូវបានគេរកឃើញថាពិតប្រាកដសម្រាប់ប្រទេស អាស៊ីប៉ាស៊ីហ្វិក នៅចុងទសវត្សរ៍ ឆ្នាំ២០០០។ និយាយដោយសង្ខេបចំនួនម៉ោងដែលគេកំណត់ជាផ្លូវការនៅក្នុងប្រទេសកម្ពុជាគឺមានចំនួនតិចជាងមធ្យមភាគអន្តរជាតិយ៉ាងច្រើន ជាពិសេសនៅក្នុងកម្រិតទាបជាងគេបំផុតនៃចំណាត់ថ្នាក់ដែលគេបានកំណត់។ ចំពោះកម្រិតដែលខ្ពស់នៃចំណាត់ថ្នាក់នេះ ចំនួនម៉ោងដែលគេ កំណត់ជាផ្លូវការនៅក្នុងប្រទេសកម្ពុជាគឺខិតទៅជិតមធ្យមភាគអន្តរជាតិសម្រាប់កម្រិតតថ្នាក់ដំបូងៗ ប៉ុន្តែមានគម្លាតកាន់តែធំចាប់ពីថ្នាក់ទី៤ឡើងទៅ (របាយការណ៍ពិនិត្យតាមដានជាសកលឆ្នាំ ២០១៥ ទំព័រ២០៥-២០៦)។ វាមានសារៈសំខាន់ណាស់ក្នុងការកត់សម្គាលថា របាយការណ៍ពិនិត្យតាមដានជាសកលបានលើកឡើងសារជាថ្មីទៀតនូវអនុសាសន៍កន្លងមកដែលថាសាលារៀនត្រូវប្រតិបត្តិ ម៉ោងបង្រៀនរវាង ៨៥០ទៅ១០០០ ម៉ោងក្នុងមួយឆ្នាំ។

រូបទី១៖ មធ្យមភាគចំនួនម៉ោងបង្រៀនរំពឹងទុកជាសកលប៉ាន់ប្រមាណនៅឆ្នាំ២០០០និង២០១០




*Sources:* (1) Median annual hours *c.* 2000: Benavot (2004). (2) Median annual hours *c.* 2010: *EFA Global Monitoring Report* team calculations (2014) based on UIS database and World Database on Education, 7th edition.

រូបទី២៖ មធ្យមភាគម៉ោងបង្រៀនប្រចាំឆ្នាំជាសកលទៅតាមតំបន់និងកំរិតថ្នាក់




*Source: EFA Global Monitoring Report* team calculations (2014) based on UIS database and World Database on Education, 7th edition.

*តួលេខដែលផលិតឡើងវិញពីរបាយការណ៍ពិនិត្យតាមដានជាសកល ឆ្នាំ២០១៥ របស់អង្គការ UNESCO*

## ២.១.២ ឆ្នាំសិក្សា

ដូចដែលបានកត់សម្គាល់នៅខាងលើឆ្នាំសិក្សានៅក្នុងប្រទេសកម្ពុជាត្រូវបានគេកំណត់សម្រាប់ រយៈពេល ៣៨សប្តាហ៍ ដែលមួយសប្តាហ៍រៀនចំនួន៦ថ្ងៃ។ កាលវិភាគប្រចាំឆ្នាំត្រូវបានកំណត់ជារៀងរាល់ឆ្នាំដោយក្រសួងអប់រំ យុវជន និងកីឡា ព្រមជាមួយ នឹងថ្ងៃឈប់សម្រាកទូទាំងប្រទេសដែលនឹងត្រូវគេសង្កេតមើល។ នៅក្នុងឆ្នាំសិក្សា ២០១២/១៣ ដែលជារយៈពេលនៃការសិក្សាសម្រាប់របាយការណ៍នេះ ឆ្នាំសិក្សាចាប់ផ្តើមនៅថ្ងៃទី១ ខែតុលាឆ្នាំ ២០១២ និងបញ្ចប់នៅថ្ងៃទី ៣១ ខែកក្កដាឆ្នាំ២០១៣។ ចំណាប់អារម្មណ៍ជាពិសេស នៅក្នុងការសិក្សានេះគឺ ឆ្នាំសិក្សាត្រូវបានគេដំណើរការដោយគិតគូរពិចារណាទៅលើថ្ងៃឈប់

សម្រាកបុណ្យជាតិ ដ៏ញឹកញាប់នៅក្នុងប្រទេសកម្ពុជា។ ភស្តុតាងដែលគួរឱ្យចាប់អារម្មណ៍ និងការសិក្សាកន្លងមកបានលើកឡើងថា ការបិទសាលារៀន និងអវត្តមានរបស់គ្រូបង្រៀនមានលក្ខណៈទូទៅច្រើនក្នុងរយៈពេលមុន និងក្រោយថ្ងៃឈប់សម្រាកជាផ្លូវការ។ មានថ្ងៃឈប់សម្រាកចំនួន៤ដែលមានរយៈពេល៣ថ្ងៃជាប់ៗគ្នា( ពិធី បុណ្យ ភ្ជុំបិណ្ឌ បុណ្យអុំទូក បុណ្យចូលឆ្នាំខ្មែរ និងបុណ្យចម្រើនព្រះជនព្រះមហាក្សត្រ )។ ពិធីបុណ្យចូលឆ្នាំខ្មែរត្រូវបានប្រារព្ធធ្វើឡើងនៅក្នុងអំឡុងវិសមកាលតូច។ ភស្តុតាងកន្លងមកលើកឡើងថា នៅពេលដែលថ្ងៃឈប់សម្រាកមានរយៈពេល៣ថ្ងៃ សាលារៀនជាច្រើនទំនងជាបិទទ្វារសម្រាប់រយៈពេលមួយសប្តាហ៍ពេញ ដែលមានរយៈពេលបង្រៀនចំនួន៦ថ្ងៃ។ ជាងនេះទៅទៀតមានការជជែកពិភាក្សាមួយចំនួនអំពីការរៀបចំកាល វិភាគសិក្សាដោយប្រៀបធៀបជាមួយសកម្មភាពតាមរដូវកាល ដូចជាការធ្វើស្រែចំការដោយមានការសាកល្បង រៀបចំកាលវិភាគសិក្សាដែលមានលក្ខណៈបត់បែន នៅក្នុងខេត្តស្ទឹងត្រែងដោយសារវត្តមានរបស់គ្រូបង្រៀន និងសិស្សានុសិស្សមានកម្រិតទាបនៅក្នុងអំឡុងពេលខ្លះ។ ចំពោះការសាកល្បងនេះ ឆ្នាំសិក្សាមានរយៈពេលខ្លីជាងធម្មតា ប៉ុន្តែចំនួនម៉ោងសិក្សាសម្រាប់មួយថ្ងៃៗត្រូវបានបង្កើនឱ្យស្របទៅនឹងរដូវកាលដាំដុះដើម្បីឱ្យគ្រូបង្រៀន និងសិស្សអាចចូលរួមនៅ ក្នុងសកម្មភាពរកប្រាក់ចំណូលនៅក្នុងគ្រួសាររបស់ពួកគេបាន។

ដូចដែលបង្ហាញនៅខាងក្រោម រយៈពេលនៃឆ្នាំសិក្សានៅក្នុងប្រទេសកម្ពុជាមិនមែនខ្លីជាងគេនោះទេ បើប្រៀបធៀបទៅនឹងប្រទេសជិតខាង និងប្រទេសផ្សេងៗទៀតនៅក្នុងតំបន់អាស៊ី។ ក៏ប៉ុន្តែចំនួនថ្ងៃឈប់សម្រាកទាំងផ្លូវការ និងមិនផ្លូវការគឺជាកត្តាដ៏សំខាន់នៅក្នុងការកាត់បន្ថយម៉ោងបង្រៀន ដែលគេបានកំណត់ជាទូទៅ។ តារាងខាងក្រោមបង្ហាញពីរយៈពេលនៃឆ្នាំសិក្សានៅក្នុងប្រទេសមួយចំនួននៅទ្វីបអាស៊ី។

តារាងទី១៖ រយៈពេលនៃឆ្នាំសិក្សានៅបណ្ដាប្រទេសនៅអាស៊ី

| | ចំនួនឆមាស | ឆ្នាំសិក្សា (សប្ដាហ៍) | វិសមកាល (សប្ដាហ៍) | ចាប់ផ្ដើម - បញ្ចប់ |
|---|---|---|---|---|
| កម្ពុជា | | ៣៨ | ១៤ | ១ តុលា-៣១ កក្កដា |
| ប្រុយណេ | ៤ | ៣៣-៣៤(២០០-២១០ថ្ងៃ) | ១៨-១៩ | |
| ចិន | ២ | ៣៨-៣៩ | ១១-១៤ | កញ្ញា - |
| ឥណ្ឌូណេស៊ី | ២ | ៣៨ | ១៤ | |
| ជប៉ុន | ៣ | ៣៥ | ១៧ | ១ មេសា - ៣១មិនា |
| កូរ៉េ | ២ | ៣៤ | ១៨ | ១ មិនា - ចុងខែកុម្ភៈ |
| ឡាវ | ២ | ៣៣ | ១៩ | |
| ម៉ាឡេស៊ី | | ៣១-៣២ ( ១៩០ ថ្ងៃ ) | ២០-២១ | មករា – វិច្ឆិកា |
| ភូមា | ២ | ៣៦ | ១៦ | |
| ហ្វីលីពីន | | ៣៣ ( ២០២ ថ្ងៃ ) | ១៩ | ៦ មិថុនា - ៣០ មិនា |
| សឹង្ហបូរី | ២ | ៤០ | ១២ | |
| ថៃ | ២ | ៤០ | ១២ | ចុងខែឧសភា - ចុងខែកុម្ភៈ |

## ២.២ ការប៉ាន់ប្រមាណពីម៉ោងបង្រៀនជាក់ស្តែង

មានការប្រឈមមុខជាលក្ខណៈអន្តរជាតិមួយចំនួនក្នុងការវាយតម្លៃថាតើមានភាពខុសគ្នាដែរឬទេរវាងចំនួនម៉ោងបង្រៀនដែលគេកំណត់ជាផ្លូវការនៅថ្នាក់ជាតិ និងចំនួនម៉ោងជាក់ស្តែងដែលគេផ្តល់ឱ្យសិស្សនៅតាមសាលារៀន។ ទិន្នន័យរបស់ប្រទេសកម្ពុជាគឺនៅមានកម្រិត។ របាយការណ៍ស្តីពីវត្តមានរបស់គ្រូបង្រៀនជាគោលការណ៍ត្រូវបាននាយកសាលាជាក់ជូនទៅមន្ទីរអប់រំខេត្ត(PoE)ពិនិត្យមើលជារៀងរាល់ខែ។ របាយការណ៍ទាំងនេះមិនត្រូវបានគេចងក្រងជាប្រចាំនោះទេ ប៉ុន្តែដើម្បីវាស់វែងពីអវត្តមានរបស់គ្រូបង្រៀនការសិក្សាកន្លងមកបានពិនិត្យមើល និងផ្ទៀងផ្ទាត់របាយការណ៍ទាំងនោះតាមរយៈការសម្ភាសជាមួយគ្រូបង្រៀន និងនាយកសាលា។ ដោយផ្អែកលើការពិតដែលថារបាយការណ៍បង្ហាញពីកម្រិតអវត្តមានដ៏ខ្ពស់ របស់គ្រូបង្រៀននឹងឆ្លុះបញ្ចាំងពីការប្រតិបត្តិមិនបានល្អទាំងនាយកសាលា និងគ្រូបង្រៀនវាទំនងជាការពិតដែលព័ត៌មាននេះត្រូវរក្សាការសម្ងាត់។ ជាងនេះទៅទៀត របាយការណ៍មកពីប្រទេសផ្សេងៗបានរកឃើញថា បន្ទាប់ពីអនុវត្តវិធីសាស្ត្រតាមបែបផ្សេងទៀត ជាពិសេសការចុះត្រួតពិនិត្យ ដោយពុំមានជូនដំណឹងជាមុននោះតថភាពនៅតាមសាលារៀនជាធម្មតាមានលក្ខណៈផ្ទុយពីរបាយការណ៍ដែលបង្ហាញដោយផ្នែករដ្ឋបាល(Gillies, Quijada ២០០៨)។

ការសិក្សាពីមុនៗមកទៅលើការបាត់ម៉ោងបង្រៀន នៅក្នុងប្រទេសកម្ពុជាមានជាប់ទាក់ទងគ្នានឹងការសិក្សានេះ។ ការសិក្សាមួយដែលមានទ្រង់ទ្រាយធំត្រូវបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ ១៩៩៩ ដោយក្រសួងអប់រំ យុវជន និងកីឡា ដោយមានការគាំទ្រទាំងស្រុងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុរបស់ធនាគារពិភពលោក និងអង្គការ CARE អន្តរជាតិ។ របាយការណ៍នេះសន្និដ្ឋានថា ៥សប្តាហ៍ក្នុងចំណោម ៣៨ សប្តាហ៍នៅក្នុងឆ្នាំសិក្សានោះបានបាត់បង់ដោយសារការបិទសាលារៀន អវត្តមានរបស់គ្រូបង្រៀន និងការឈប់សម្រាក ដោយគ្មានការគ្រោងទុក។ ការសិក្សាបានលើកឡើងថា គ្រូបង្រៀននៅតាមតំបន់ជនបទអវត្តមានជាមធ្យមលើសពី ៤ថ្ងៃនៃថ្ងៃសិក្សាក្នុងរយៈពេល៣ខែ ខណៈដែលគ្រូបង្រៀននៅទីប្រជុំជនអវត្តមានជាមធ្យមតែ២ថ្ងៃនៃថ្ងៃសិក្សាប៉ុណ្ណោះក្នុងរយៈពេល៣ខែដូចគ្នា។ ភាពខុសគ្នារវាងម៉ោងសិក្សាដែលគេផ្តល់ឱ្យនៅតាមជនបទនិងទីប្រជុំជនដែលមាននៅក្នុងរបាយការណ៍នេះគឺគេនៅ តែបន្តរកឃើញទៀតនៅក្នុងការសិក្សាក្រោយៗមកទៀត។

ដោយប្រើប្រាស់វិធីសាស្ត្រមួយចំនួននៃការសិក្សាក្នុងឆ្នាំ១៩៩៩ NEP បានធ្វើការស្រាវជ្រាវនៅក្នុងខេត្តចំនួន៣នៅក្នុងឆ្នាំ២០០៤ ហើយបានបោះពុម្ពផ្សាយនូវរបាយការណ៍មួយដែលមានចំណងជើងថា "ប្រសិទ្ធភាពម៉ោងបង្រៀននៅសាលាបឋមសិក្សា" នៅក្នុងឆ្នាំ២០០៥។ របាយការណ៍បានរកឃើញថាចំនួនម៉ោងបង្រៀនសរុបប្រចាំសប្តាហ៍នៅក្នុងឆ្នាំសិក្សា២០០៤គឺមានប្រមាណជា២៦ម៉ោងសិក្សាសម្រាប់ថ្នាក់ទី៥និងទី៦ និងប្រមាណជា ២៥ ម៉ោងសិក្សាសម្រាប់ថ្នាក់ផ្សេងៗទៀត។ ចំនួនម៉ោងសិក្សាទាំងនេះគឺតិចជាងចំនួនម៉ោងសិក្សាដែលចែងនៅក្នុងគោលនយោបាយអភិវឌ្ឍន៍កម្មវិធីសិក្សាឆ្នាំចំណេះទូទៅឆ្នាំ២០០៥-២០០៩ច្រើន។ និន្នាការដែលបានបង្ហាញនេះមានន័យថា ម៉ោងសិក្សាប្រចាំសប្តាហ៍សម្រាប់ថ្នាក់ទី៦គឺមានចំនួនខ្ពស់ជាងថ្នាក់ទី៤តិចតួច។ ការស្រាវជ្រាវនេះបង្ហាញថាការបាត់ម៉ោងសិក្សានេះមាននៅគ្រប់មុខវិជ្ជាទាំងអស់លើកលែងតែសម្រាប់មុខវិជ្ជាគណិតវិទ្យានៅថ្នាក់ទី១-៣ប៉ុណ្ណោះ។ ក្នុងចំណោមមុខវិជ្ជាទាំងអស់ដែលដាក់បញ្ចូលក្នុងកម្មវិធីសិក្សាសម្រាប់ថ្នាក់បឋម មុខវិជ្ជាភាសាខ្មែរ និងរូបវិទ្យា គឺជាមុខវិជ្ជាដែលមានការបាត់បង់ម៉ោងសិក្សាច្រើនជាងគេបង្អស់។ ទោះជាយ៉ាងណាក៏ដោយ ចំណុចខ្សោយ២របស់របាយការណ៍នេះ គឺវិសាលភាពភូមិសាស្ត្រ

នៅមានកម្រិត(ចំនួនខេត្តដែលសិក្សាតិច) និងទិន្នន័យស្តីពីម៉ោងសិក្សាដែលយកមកប្រើប្រាស់គឺពឹងផ្អែកទៅលើការសម្ភាស និងបញ្ជីរសំណួរ ជាជាងការសង្កេតដោយឯករាជ្យមួយ។

ការសិក្សាមួយស្តីពីម៉ោងសិក្សា ដែលរៀបចំឡើងដោយនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជននិងកីឡា នៅក្នុង ឆ្នាំ២០០៨ បានផ្តល់នូវភស្តុតាងថា ប្រមាណជា៤៦ថ្ងៃ ដែលស្មើនឹង២៣០ម៉ោងសិក្សាបានបាត់បង់ក្នុងមួយឆ្នាំសិក្សា។ ចំណុចនេះបណ្តាលឱ្យបាត់បង់ម៉ោងសិក្សាប្រមាណជា២០%នៅក្នុងឆ្នាំសិក្សា (MoEYS នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា ម៉ោងសិក្សានៅក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៨ ទំព័រ៦ "ភាសាខ្មែរ")។ របាយការណ៍បានបង្ហាញនូវមូលហេតុចំបងនៃការបាត់ម៉ោងសិក្សាចំនួន៥គឺៈ ការបិទសាលារៀន គ្រូបង្រៀនអវត្តមាន គ្រូបង្រៀនមិនគ្រប់ម៉ោង (ម៉ោងរៀនតិច ឬម៉ោងរៀនខ្លី) គ្រូប្រជុំប្រចាំខែ និងការលុបចោលការបង្រៀនក្នុងទិវា បុណ្យសាសនា និង/ឬទិវាបុណ្យផ្សេងៗទៀត (MoEYS ឆ្នាំ២០០៨ ទំព័រ២៥និង២៦)។ វាមានលក្ខណៈខុសពីរបាយការណ៍នេះ ដោយការសិក្សាពេលនោះរាប់បញ្ចូលទាំងការបង្រៀនថ្ងៃព្រហស្បតិ៍ផងដែរ។ ជាថ្មីម្តងទៀត បញ្ហានៃម៉ោងសិក្សាត្រូវបានគេលើកឡើងនៅក្នុងសន្និបាតអប់រំឆ្នាំ២០១២។ ការគ្រប់គ្រងមិនបានល្អការពង្រាយគ្រូមិនបានស្មើគ្នា ព្រមទាំងការត្រួតពិនិត្យ និងវាយតម្លៃមិនបានទៀងទាត់នៅតាមសាលារៀន និងថ្នាក់រៀនត្រូវបានគេលើកឡើង ថាជាកត្តាដែលរួមចំណែកដល់ការបាត់បង់ម៉ោងសិក្សា។

ការបាត់ម៉ោងសិក្សាដែលមាននៅក្នុងប្រទេសកម្ពុជានេះប្រហែលមិនមែនជារឿងដែលត្រូវភ្ញាក់ផ្អើលនោះទេ ដោយសារការសិក្សាជាអន្តរជាតិនៅលើប្រធានបទនេះត្រូវបានគេជជែកពិភាក្សាដូចគ្នា។ឧទាហរណ៍ ការសិក្សាស្រាវជ្រាវមួយបានរកឃើញថានៅប្រទេសប៉េរូ (Peru) ទោះបីជាសិស្សនៅថ្នាក់បឋមសិក្សាត្រូវចំណាយពេលរៀនសរុបចំនួន៧២០ម៉ោង ក្នុងមួយឆ្នាំក៏ដោយ ក៏តាមការជាក់ស្តែងមានតែ៥០ទៅ៨០% នៃម៉ោងទាំងនេះប៉ុណ្ណោះត្រូវបានគេបង្រៀន។ នៅតាមតំបន់ជនបទចំនួននេះធ្លាក់ចុះរហូតដល់ក្រោម៣០%។ នៅក្នុងប្រទេសហ្គាណា សាលារៀន ដំណើរ ការតែ ៥៥,១% ក្នុងមួយឆ្នាំខណៈដែលអាត្រាខ្ពស់ជាងនេះខ្លាំងមាននៅក្នុងប្រទេស ទុយណេស៊ី ម៉ូរ៉ូកូ និងរដ្ឋ Pernambuco របស់ប្រេស៊ីលដែលមានចំនួន៨៩,៩% ៨៧,៣% និង៨៦,១% សម្រាប់ប្រទេស នី មួយៗ (Abadzi, ២០០៧)។

## ២.៣ អវត្តមានរបស់គ្រូបង្រៀន

អវត្តមានរបស់គ្រូបង្រៀននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ គឺជាការផ្តោតមួយនៃការសិក្សាដែលមានការរីកចម្រើនយ៉ាងឆាប់រហ័ស។ អវត្តមានគ្រូត្រូវបានគេមើលឃើញថាជាឧបសគ្គមួយក្នុងចំណោមឧបសគ្គចម្បងនានា ក្នុងការសម្រេចបានលទ្ធផលសិក្សារបស់សិស្សនៅក្នុងបរិបទជាច្រើន។ នៅក្នុងករណីមួយចំនួនវាត្រូវបានគេរកឃើញថា អត្រាអវត្តមាន ពោលគឺភាគរយរបស់គ្រូបង្រៀនដែលអវត្តមានដោយពុំមានការអនុញ្ញាតមានចំនួនច្រើនជាពិសេសនៅតំបន់ជនបទ។ ជាឧទាហរណ៍ ប្រទេសឥណ្ឌាត្រូវបានគេរកឃើញថាជាប្រទេសដែលមានអត្រាអវត្តមានគ្រូបង្រៀននៅទូទាំងប្រទេសចំនួន២៥% នៅក្នុងឆ្នាំ២០០៦ ទោះជាយ៉ាងនេះក្តីចំនួននេះឡើងដល់៤២% នៅតាមតំបន់ជនបទរបស់រដ្ឋ Jharkhand។ ការសិក្សាផ្សេងៗទៀតបានរកឃើញនូវអត្រាអវត្តមាន ជាមធ្យមចំនួន១៩% នៅតាមបណ្តាប្រទេសផ្សេងៗជាច្រើន (Chaudhury, Hammer, Kremer, Muralidharan, និង Rogers ឆ្នាំ២០០៦)។ សិស្សចំនួន១/៣ នៅក្នុងប្រទេសអាហ្សង់ទីន ប៉ារ៉ាហ្គាយ និងប្រទេសហ្វីលីពីន បានរាយការណ៍ពីបញ្ហានានាទាក់ទងនឹងការមកយឺត អវត្តមាន និងការមិនចូលបង្រៀនរបស់

គ្រូ (UIS, ២០០៨)។ ហេតុផលជាច្រើនត្រូវបានគេលើកឡើងដើម្បីពន្យល់ពីបាតុភូតនេះដោយរាប់បញ្ចូលទាំងលក្ខខណ្ឌការងារមិនល្អ ប្រាក់បៀវត្សទាប ឱកាសការងារផ្សេងទៀត កម្រិតអប់រំរបស់ឪពុកម្ដាយ និងកម្រិតវត្តមានរបស់សិស្ស។ ជាងនេះទៅទៀតអវត្តមានដែលស្របច្បាប់ជារឿយៗ អាចបណ្ដាលមកពីការចូលរួមវគ្គបណ្ដុះបណ្ដាលជាញឹកញាប់ ឬសុខភាពខ្សោយរបស់គ្រូបង្រៀន។

## ២.៤ ការស្រាវជ្រាវ ស្ដីពីវិធីសាស្ត្រក្នុងការកាត់បន្ថយអវត្តមានរបស់គ្រូបង្រៀន

នៅក្នុងឆ្នាំថ្មីៗកន្លងមកនេះ មានយុទ្ធសាស្ត្រដែលបានផ្ដួចផ្ដើមឡើងមួយចំនួនដែលរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល (NGOs) នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍បានអនុវត្ត ដើម្បីដោះស្រាយបញ្ហាអវត្តមានយ៉ាងច្រើនរបស់គ្រូបង្រៀន ដោយទទួលបានកម្រិតនៃភាពជោគជ័យខុសៗគ្នា។ គំនិតផ្ដួចផ្ដើមនានានេះមានចាប់ពីការផ្ដល់គ្រឿងលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុរហូតដល់ប្រព័ន្ធនៃការត្រួតពិនិត្យ និងគណនេយ្យភាពដែលកាន់តែមានលក្ខណៈស្មុគស្មាញ។ ក្នុងពេលដែលអង្គការ NEP បានតស៊ូមតិអស់ជាច្រើនឆ្នាំថាប្រាក់បៀវត្សរបស់គ្រូបង្រៀននៅក្នុងប្រទេសកម្ពុជាគួរត្រូវបានគេដំឡើងនោះ ភស្តុតាងជាអន្តរជាតិស្ដីពីឥទ្ធិពលនៃការដំឡើងប្រាក់បៀវត្សប្រចាំខែតែមួយមុខមានភាពច្របូកច្របល់។ Roger និង Vegus (២០០៩) បញ្ជាក់ថារចនាសម្ព័ន្ធនៃគ្រឿងលើកទឹកចិត្តដល់គ្រូបង្រៀន ដែលមានលក្ខណៈកាន់តែធំទូលាយឡើង ក៏ជាបញ្ហាសំខាន់ដែរ ដោយមិនគ្រាន់តែទាក់ទងទៅនឹងវត្តមានប៉ុណ្ណោះទេ ប៉ុន្តែក៏ទាក់ទងនឹងការជ្រើសរើស និងការបន្តការធ្វើការងាររបស់គ្រូបង្រៀនផងដែរ។ គ្រឿងលើកទឹកចិត្តដូចនេះមិនមែនគ្រាន់តែជាលុយនោះទេ ហើយវាអាចរាប់បញ្ចូលទាំងកត្តាផ្សេងៗទៀតដូចជា ការទទួលស្គាល់ផ្នែកវិជ្ជាជីវៈផលប្រយោជន៍ មិនមែនជាប្រាក់បៀវត្សដូចជាការថែរក្សាសុខភាព និងស្ថេរភាពការងារ ដោយស្របទៅនឹងលទ្ធភាពនៃការបាត់បង់ការងារផ្សេងទៀតរបស់ខ្លួន (Vegas និង Umansky ២០០៥)។

ដូចដែល Banjeree និង Duflo (២០០៩) ចង្អុលបង្ហាញ ចំណុចស្នូលចំពោះការពិភាក្សានេះគឺតួនាទីនៃការត្រួតពិនិត្យ ដោយមានការវាស់វែងពីស្នាដៃបំពេញការងារដែលជាមូលដ្ឋានគ្រឹះមួយសម្រាប់ផ្ដល់គ្រឿងលើកទឹកចិត្តដោយមានទាំងការផ្ដល់រង្វាន់ ឬការដាក់ពិន័យ។ នៅពេលដែលគ្រឿងលើកទឹកចិត្តទាំងនេះ ត្រូវបានគេកំណត់ ការត្រួតពិនិត្យពីខាងក្រៅពាក់ព័ន្ធនឹងការបង្កើតនូវច្បាប់មួយចំនួន និងការចាត់តាំងឱ្យនរណាម្នាក់ទទួលបន្ទុកការងារត្រួតពិនិត្យ។ ជំហ៊ានដំបូងបំផុតនោះ គឺគោលគំនិតនៃគ្រឿងលើកទឹកចិត្ត ផ្នែកហិរញ្ញវត្ថុដោយផ្ទាល់ដោយផ្អែកលើវត្តមាន។ ដូចដែល Duflo និង Hann (២00៥) បានគូសបញ្ជាក់ នៅក្នុងការវាយតម្លៃរបស់ខ្លួនទៅលើកម្មវិធីត្រួតពិនិត្យដោយប្រើម៉ាស៊ីនថតរបស់ Seva Mandir (Seva Mandir's camera) ជាការជាប់ពាក់ព័ន្ធដោយផ្ទាល់ពិតជាមានឥទ្ធិពលភ្លាមៗទៅលើអត្រាអវត្តមានរបស់គ្រូបង្រៀន។ នៅក្នុងកម្មវិធីនេះគ្រូបង្រៀនត្រូវបានគេផ្ដល់ប្រាក់បន្ថែមប្រចាំថ្ងៃប្រសិនបើពួកគាត់បង្ហាញរូបថត ដើម្បីបញ្ជាក់ពីវត្តមានរបស់ពួកគាត់នៅពេលចាប់ផ្ដើម និងចុងបញ្ចប់នៃថ្ងៃបង្រៀន។ ប្រាក់បន្ថែមប្រចាំថ្ងៃ ត្រូវបានគេបើកឱ្យចាប់ពីថ្ងៃទី១១ នៃថ្ងៃបង្រៀនដែលបង្ហាញជាភស្តុតាងនៅក្នុងខែ។ អវត្តមានរបស់គ្រូបង្រៀនបានកាត់បន្ថយចំនួនពាក់កណ្ដាលនៅតាមសាលារៀនដែលជាផ្នែកនៃការសិក្សានេះ ហើយមានការកែលម្អបើ ប្រៀបធៀបទៅនឹងក្រុមត្រួតពិនិត្យដែលគ្រូបង្រៀនត្រូវបានគេផ្ដល់ថវិកាឱ្យប្រហាក់ប្រហែលគ្នា ប៉ុន្តែមិនចាំបាច់ផ្ដល់ភស្តុតាងពីវត្តមានក្នុងគោល

បំណាងទទួលបានការផ្តល់ប្រាក់របស់ខ្លួននោះ។ អ្វីដែលធ្វើឱ្យគំនិតផ្តួចផ្តើម នេះទទួលជោគជ័យ គឺប្រហែលដោយសារការពិតដែលថា វាគឺជាប្រព័ន្ធដ៏សាមញ្ញមួយដែលត្រូវបានគេអនុវត្ត ដោយប្រើម៉ាស៊ីនដែលមានន័យថា ការឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យត្រូវមានលក្ខណៈជាប្រព័ន្ធជាជាងទៅតាមឆន្ទៈរបស់ថ្នាក់ដឹកនាំគ្រូបង្រៀន ដែលបន្ទាប់មកបើកឱ្យមានអំពើពុករលួយ ឬការគ្រប់គ្រងមិនបានត្រឹមត្រូវ (Kremer, Michael; Chen, Daniel. ២០០០)។ ទោះបីជាប្រព័ន្ធនេះបានកាត់បន្ថយអវត្តមានរបស់គ្រូបង្រៀនដោយគ្មានការសង្ស័យក៏ដោយ ក៏វាមិនបានគិតគូរពិចារណា ឬដោះស្រាយហេតុផលមួយ ចំនួនក្នុងចំណោមហេតុផលជាមូលដ្ឋាននានា ចំពោះការអវត្តមានដែលគេប្រហែលជាអាចដោះស្រាយបានយ៉ាងមានប្រសិទ្ធភាពថែមទៀតតាមរយៈគោលនយោបាយផ្សេងៗ។

គម្រោងនៃគ្រឿងលើកទឹកចិត្តផ្សេងៗទៀតមានទម្រង់ខុសៗគ្នា ចាប់ពីការផ្តល់រង្វាន់ដល់គ្រូបង្រៀនទៅតាមលទ្ធផលនៃការសិក្សារបស់សិស្ស ដែលមានការរីកចម្រើនរហូតដល់ការផ្តល់រង្វាន់ដល់សិស្សជាជាងដល់គ្រូបង្រៀន។ ឧទាហរណ៍ Muralidaran និង Sundararaman (២០០៩) បង្ហាញពីការវិភាគរបស់ខ្លួនទៅលើការវាយតម្លៃចោះៗមួយពីកម្មវិធីផ្តល់គ្រឿងលើកទឹកចិត្តដល់គ្រូបង្រៀន ដែលអនុវត្តនៅតាមសាលារៀនបឋមសិក្សាគំរូរបស់រដ្ឋទាំងអស់នៅ Andhra Pradesh ប្រទេសឥណ្ឌា។ កម្មវិធីនេះផ្តល់ប្រាក់បន្ថែមដល់គ្រូបង្រៀនដោយផ្អែកលើការរីកចម្រើនជាមធ្យម នៃពិន្ទុប្រឡងរបស់សិស្សនៅក្នុងការវាយតម្លៃលទ្ធផល នៃការសិក្សាដែលត្រូវបានគេរៀបចំឡើងដោយឯករាជ្យ។ ទោះបីជាលទ្ធផលនៃការសិក្សារបស់សិស្សពិតជាមានការកែលម្អក៏ដោយ ក៏វាពុំមានឥទ្ធិពលអ្វីទៅលើអវត្តមានរបស់គ្រូបង្រៀនដែរ។ ម្យ៉ាងវិញទៀត Kremer, Miguel និង Thornton (២០០៩) បានពិនិត្យមើលទៅលើឥទ្ធិពលនៃការផ្តល់រង្វាន់ដល់សិស្ស ដោយផ្អែកលើលទ្ធផលនៃការសិក្សារបស់ខ្លួនតាមរយៈការរៀបចំវាយតម្លៃចោះៗទៅលើកម្មវិធីអាហារូបករណ៍សម្រាប់សិស្សពូកែ ដែលតាមរយៈនេះកុមារីជនជាតិកេនយ៉ា ដែលបានពិន្ទុល្អនៅក្នុងការប្រលងបានទទួលការបង់ថ្លៃសាលាក៏ដូចជាការទទួលអំណោយផងដែរ។ គួរឱ្យចាប់អារម្មណ៍ គម្រោងនេះមិនត្រឹមតែមានឥទ្ធិពលទៅលើសិស្សប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងកាត់បន្ថយអវត្តមានរបស់គ្រូបង្រៀនទៀតផង។ ចំណុចនេះប្រហែលជាបញ្ជាក់ថាអ្វីៗទាំងអស់មិនមែនពឹងផ្អែកតែទៅលើប្រាក់លាភការផ្ទាល់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែបង្ហាញថាកត្តាផ្សេងៗទៀតក៏មានសារៈសំខាន់សម្រាប់ការលើកទឹកចិត្ត និងស្មារតីបំពេញការងាររបស់គ្រូបង្រៀនដែរ ដូចដែលបានគូសបញ្ជាក់តាមរយៈ Vegas និង Umansky (២០០៥)។

ទោះជាយ៉ាងណាក៏ដោយការត្រួតពិនិត្យត្រូវតែជាផ្នែកមួយសំខាន់នៃដំណោះស្រាយ ពោលគឺតាមរយៈការណែនាំប្រព័ន្ធគណនេយ្យភាពទៅក្នុងរចនាសម្ព័ន្ធរបស់សាលារៀន។ វិធីសាស្ត្រមួយចំពោះដំណោះស្រាយនេះ គឺការឱ្យសហគមន៍ចូលរួមនៅក្នុងការត្រួតពិនិត្យសាលារៀន។ ជាថ្មីម្តងទៀត វិធានការនានាដូចនេះត្រូវបានគេអនុវត្ត ដោយទទួលជោគជ័យក្នុងកម្រិតខុសៗគ្នា ហើយពឹងផ្អែកទៅលើការវិនិយោគពីសំណាក់អ្នកពាក់ព័ន្ធ។ ឧទាហរណ៍ Glewwe and Eugenie (២០១១) បានសរសេរអំពីការធ្វើពិសោធន៍ចោះៗនៅតាមសាលារៀនរដ្ឋនៅ Madagascar ដែលស្រុកមួយចំនួនបានណែនាំពីការធ្វើអន្តរាគមន៍នៅកម្រិតសាលារៀន ដែលគេអនុញ្ញាតឱ្យឪពុកម្តាយចូលរួមត្រួតពិនិត្យតាមរយៈការប្រជុំនៅតាមសាលារៀន។ ភ្នាក់ងារតាមមូលដ្ឋានផ្តល់ "ប័ណ្ណសម្រាប់រាយការណ៍" ដល់សាលារៀនដែលរាប់បញ្ចូលទាំងអត្រាបោះបង់ អត្រាឡើងថ្នាក់ និង អាត្រាត្រួតថ្នាក់

កាលពីឆ្នាំមុន។ បន្ទាប់មក ការប្រជុំនៅតាមសហគមន៍ចំនួនពីរលើកត្រូវបានគេរៀបចំឡើង ដោយការប្រជុំលើកទីមួយសម្រេចបាននូវផែនការសកម្មភាពមួយដោយផ្អែកលើប័ណ្ណរាយការណ៍។ សមាគម មាតាបិតា សិស្សត្រូវបានគេរំពឹងទុកថានឹងត្រួតពិនិត្យពីរបាយការណ៍វាយតម្លៃរបស់សិស្សដែលគេសន្មតថា គ្រូបង្រៀនត្រូវប្រាស្រ័យទាក់ទងជាមួយគាត់។ ឧបករណ៍ទាំងនេះអនុញ្ញាតឱ្យឪពុកម្តាយធ្វើការសម្របសម្រួលគ្នាទៅលើការចាត់វិធានការផ្សេងៗ ដើម្បីត្រួតពិនិត្យមើលទៅលើគុណភាពសេវាកម្ម និងដើម្បីអនុវត្តនូវការគាបសង្កត់ផ្នែកសង្គមទៅលើគ្រូបង្រៀន។ ទោះជាយ៉ាងណាក៏ដោយ ទោះបីជាវត្តមានរបស់សិស្សមានការកើនឡើងបន្តិចបន្តួចក៏ដោយ ក៏វត្តមានរបស់គ្រូនៅតែពុំមានការកែលម្អជាដុំកំភួនដដែល។ ដូចដែល Banjerre និង Duflo (២០០៦) បានចង្អុលបង្ហាញ "ការពន្យល់ដែលអាចធ្វើទៅបានមួយចំពោះភាពគ្មានឥទ្ធិពលនៃការត្រួតពិនិត្យរបស់សហគមន៍ គឺថាម្នាក់ៗ ដោយរាប់បញ្ចូលទាំងអ្នកផ្តល់សេវាកម្មដឹងថាសហគមន៍ពុំមានសិទ្ធិជាផ្លូវការណាមួយក្នុងការផ្តល់រង្វាន់ ឬដាក់ពិន័យទៅលើអ្នកផ្តល់សេវាកម្មទេ"។

ការមានសិទ្ធិគ្រប់គ្រាន់ដើម្បីអនុវត្តការដាក់ទណ្ឌកម្ម ឬផ្តល់រង្វាន់ត្រូវតែជាចំណុចសំខាន់ចំពោះប្រព័ន្ធត្រួតពិនិត្យណាមួយ។ Gillies and Quijada (២០០៨) កត់សម្គាល់ថាចំណុចស្នូលនៃប្រព័ន្ធនេះ គឺជាបញ្ហាដ៏សំខាន់នៃការគ្រប់គ្រងបុគ្គលិកនៅក្នុងសាលារៀន។ ឧបករណ៍ដ៏មានសារៈសំខាន់បំផុតនៃការគ្រប់គ្រង គឺប្រហែលជាអំណាចក្នុងការជ្រើសរើសនិងការបណ្តេញបុគ្គលិក។ ការផ្គត់ផ្គង់ និងតម្រូវការរបស់គ្រូបង្រៀននៅក្នុងប្រទេសកម្ពុជា ក្នុងពេលបច្ចុប្បន្ននេះត្រូវបានចាត់ចែងដោយថ្នាក់ជាតិតាមរយៈប្រព័ន្ធនៃការរាយការណ៍តាមលំដាប់លំដោយ ហើយសាលារៀនមានស្វ័យភាពតិចតួចក្នុងការធ្វើសេចក្តីសម្រេចចិត្តណាមួយ ទាក់ទងនឹងបុគ្គលិក។ ទោះជាយ៉ាងណាក៏ដោយផែនការនានាត្រូវបានគេរៀបចំឡើង ហើយការសាកល្បង ក៏ត្រូវបានគេអនុវត្តជាផ្នែកមួយនៃកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការទូទាំងប្រទេសដែលមើលឃើញថាតួនាទីទាំងនេះកំពុងត្រូវបានគេផ្ទេរទៅឱ្យសាលារៀនដែលជាផ្នែកមួយនៃ "ការគ្រប់គ្រងផ្អែកលើសាលារៀន"។ ប្រសិនបើអំណាចនៃការជ្រើសរើសគ្រូបង្រៀនមិនមែនជាជម្រើសទេនោះ ពេលនោះយន្តការផ្សេងៗទៀតចាំបាច់ត្រូវតែមាន ដើម្បីធានាបាននូវការគ្រប់គ្រង និងគណនេយ្យភាពកាន់តែប្រសើរឡើង សម្រាប់គ្រូបង្រៀន។

## ២.៥ ប្រព័ន្ធត្រួតពិនិត្យស្នាដៃបំពេញការងាររបស់គ្រូបង្រៀន

ប្រព័ន្ធវាយតម្លៃយ៉ាងទូលំទូលាយត្រូវបានគេដាក់ឱ្យប្រើប្រាស់ស្ទើរតែទូទាំងពិភពលោកនៅតាមអង្គការឯកជន និងសាធារណៈក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ហើយកំពុងចាប់ផ្តើមកើតមានជាលក្ខណៈប្រព័ន្ធ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ អវត្តមានរបស់គ្រូបង្រៀនមិនសមរម្យ ឬច្រើនហួសហេតុតាមធម្មតានឹងត្រូវបានដោះស្រាយទៅតាមនីតិវិធីនៃការវាយតម្លៃដូចនេះ។ នៅចក្រភពអង់គ្លេស បទបញ្ញត្តិនានាបញ្ជាក់ថា អង្គភាពគ្រប់គ្រងសាលារៀន និងអាជ្ញាធរដែនដី ដែលទទួលខុសត្រូវចំពោះសាលារៀន ត្រូវតែប្រើប្រាស់គោលនយោបាយវាយតម្លៃជាលាយលក្ខណ៍អក្សរដែលកំណត់ពីដំណើរការនៃការវាយតម្លៃប្រចាំឆ្នាំសម្រាប់គ្រូបង្រៀនរបស់ខ្លួន។ គេចង្អុលបង្ហាញថា ទិសដៅនានាគួរត្រូវបានគេកំណត់សម្រាប់គ្រូបង្រៀនម្នាក់ៗ ហើយត្រូវរួមចំណែកដល់ការលើកកម្ពស់ការអប់រំរបស់សិស្សនៅសាលារៀននោះ។ គេត្រូវតែវាយតម្លៃគ្រូបង្រៀនជាផ្លូវការ ដោយប្រៀបធៀប

ជាមួយនឹងទិសដៅរបស់ពួកគាត់ ក៏ដូចជាស្តង់ដារគ្រូបង្រៀនដែរ ហើយដែលចំណុចនេះ ក៏អាចរាប់បញ្ចូលទាំងវត្តមានដែរ។

ដោយផ្អែកលើគំរូស្រដៀងៗគ្នានេះដែរ ប្រព័ន្ធគ្រប់គ្រងស្នាដៃបំពេញការងារបានចាប់ផ្តើមលេចរូបរាងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន។ ទោះជាយ៉ាងណាក៏ដោយការសិក្សាជាអន្តរជាតិនានាបានរកឃើញបញ្ហាជាច្រើននៅក្នុងការអនុវត្ត។ ឧទាហរណ៍ Bulawa (2011) បានពិនិត្យមើលទៅលើការប្រើប្រាស់ប្រព័ន្ធវាយតម្លៃគ្រូបង្រៀនដែលទើបនឹងបង្កើតថ្មីនៅក្នុងប្រទេស Botswana ហើយបានសន្និដ្ឋានថា ពុំមានការកែលម្អណាមួយចំពោះការអនុវត្តសម្រាប់រយៈពេល៨ឆ្នាំ។ មានចំណុចបញ្ហាមួយចំនួនទាក់ទងនឹងភាពស្មុគ្រស្មាញ នៃការរៀបចំចងក្រងឯកសារ ការខ្វែងគំនិតគ្នាលើទស្សនៈស្តីពីតើស្តង់ដារអ្វីដែលគេត្រូវអនុវត្ត និងភាពខុសគ្នាទៅតាមតំបន់។ ទោះជាយ៉ាងណាក៏ដោយ របាយការណ៍របស់ Bulawa និងរបាយការណ៍របស់ Monyatsi, Steynand, និង Kamper's (2006) បង្ហាញថាអ្នកគ្រប់គ្រង និងគ្រូបង្រៀនពុំចង់ឱ្យគេរំលាយប្រព័ន្ធនេះចោលទេ។

គំរូនៃការគ្រប់គ្រងស្នាដៃបំពេញការងាររបស់បុគ្គលិកនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន បានសម្លឹងមើលទៅរកការវាយតម្លៃរបស់លោកខាងលិច។ Bulawa (២០១១)ទាញការយកចិត្តទុកដាក់ទៅលើការប្រុងប្រយ័ត្ននៅពេល "អនុវត្តតាម" គំរូអន្តរជាតិ ដោយកត់សម្គាល់ថា គំរូទាំងនោះត្រូវបានគេរៀបចំឡើងតាមបរិបទនៃមនោគមវិជ្ជារបស់អ្នកឧបត្ថម និងអ្នកគាំទ្រជាអន្តរជាតិ ហើយវាមិនសមស្របទាំងស្រុងសម្រាប់ការអនុវត្តដោយផ្ទាល់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ទេ។ ប្រាកដណាស់ វាមានភាពខុសគ្នាមួយចំពោះបរិបទ ទាំងផ្នែកនយោបាយ និងផ្លូវច្បាប់ ក៏ដូចជាវប្បធម៌ដែរ។ ប្រព័ន្ធនៃការវាយតម្លៃនៅក្នុងប្រទេសអភិវឌ្ឍន៍ត្រូវបានគាំទ្រដោយច្បាប់ ហើយជាយន្តការដ៏សំខាន់មួយនៃការជ្រើសរើស និងការធ្វើឱ្យមានវឌ្ឍនភាពរបស់គ្រូបង្រៀន។ ប្រព័ន្ធនានាដូចនេះក៏ត្រូវបានគាំទ្រដោយប្រព័ន្ធអធិការកិច្ច និងគណនេយ្យភាពរបស់សាលារៀនយ៉ាងល្អិតល្អន់ និងយ៉ាងទូលំទូលាយដែរ។ បរិបទ និងហេដ្ឋារចនាសម្ព័ន្ធបៀបនេះមិនមែនមានជានិច្ចកាលនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ទេ។ ទោះជាយ៉ាងណាក៏ដោយ ចំណុចនេះមិនមែនមានន័យថាតម្លៃនៃវិជ្ជាជីវៈ ស្នាដៃបំពេញការងារល្អ និងលក្ខខណ្ឌការងារមិនអាចអនុវត្តបាននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ឡើយ។ កត្តាជំរុញលើកទឹកចិត្តមានលក្ខណៈជាសកល ហើយប្រព័ន្ធមួយដែលផ្តល់រង្វាន់ ឬដាក់ទណ្ឌកម្មចំពោះអ្នកទាំងឡាយណាប្រតិបត្តិតាម និងអ្នកដែលមិនប្រតិបត្តិតាម គឺជាឧបករណ៍ជាសកលមួយ។ ការលំបាក គឺការយកវិធីសាស្ត្រមកកែតម្រូវឱ្យត្រូវទៅតាមបរិបទជាក់លាក់។ ការសិក្សាទាំងនេះបានបង្ហាញថា កត្តាជាគន្លឹះមួយក្នុងការសម្រេចបានកិច្ចការនេះ គឺការស្វែងរកការវិនិយោគទៅលើវិស័យនេះ ការពិគ្រោះយោបល់ជាមួយគ្រូបង្រៀន និងការធានាថា អ្នកគ្រប់គ្រងទទួលបានការបណ្តុះបណ្តាលយ៉ាងមានប្រសិទ្ធភាព។

នៅសាលារៀនបឋមសិក្សានៅក្នុងប្រទេសកម្ពុជា ក៏មានប្រព័ន្ធវាយតម្លៃស្នាដៃបំពេញការងាររបស់គ្រូបង្រៀនស្រដៀងគ្នានេះដែរ ហើយគេរំពឹងទុកថា នាយកសាលាអនុវត្តការវាយតម្លៃនេះជាទៀងទាត់ទៅលើបុគ្គលិករបស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តនូវការវាយ តម្លៃនេះត្រូវបានគេរាយការណ៍ថានៅមានភាពទន់ខ្សោយ និងពុំមានប្រសិទ្ធភាព។ មួយផ្នែកនៃចំណុចនេះគឺដោយសារគេយល់ឃើញថា ការវាយតម្លៃគ្រូបង្រៀនពុំមានឥទ្ធិពលទៅលើការដំឡើងឋានៈ ឬការដាក់ទណ្ឌកម្មទៅលើគ្រូបង្រៀនទេ។ ក្នុងពេលមានកិច្ចពិភាក្សាជា ក្រុមដែលរៀបចំឡើងដោយ NEP ជាមួយនាយកសាលា និងគ្រូបង្រៀនសម្រាប់រៀបចំផែនការ

សកម្មភាពគោលនយោបាយគ្រូបង្រៀនក្នុងឆ្នាំ២០១៤ នាយកសាលាបានរាយការណ៍ពីការដំឡើងឋានៈរបស់គ្រូបង្រៀនដោយប្រៀបធៀបជាមួយនឹងអនុសាសន៍របស់គាត់ នៅក្នុងការវាយតម្លៃប្រចាំឆ្នាំ ហើយគ្រូបង្រៀនបានរាយការណ៍ថាប្រព័ន្ធនេះមានភាពទូលំទូលាយយ៉ាងខ្លាំងចំពោះភាពលម្អៀង និងឥទ្ធិពលនៃទំនាក់ទំនងផ្ទាល់ខ្លួន។ គេពុំមានអារម្មណ៍ថាមានទំនាក់ទំនងរវាងប្រព័ន្ធវាយតម្លៃ និងគ្រឿងលើកទឹកចិត្ត ជាវិជ្ជមាន ឬអវិជ្ជមានទេ។ អធិការកិច្ចនៅតាមសាលាបឋមសិក្សានៅក្នុងប្រទេសកម្ពុជាកំពុងត្រូវបានគេរៀបចំឡើង និងកំពុងមានការកើនឡើង។ ផែនការបច្ចុប្បន្នរាប់បញ្ចូលទាំងការចុះពិនិត្យភ្លាមៗដោយពុំមានការជូនដំណឹងជាមុន ប៉ុន្តែនៅក្នុងរយៈពេលនៃការសិក្សានេះ អធិការកិច្ចជាផ្លូវការត្រូវបានគេប្រកាសឱ្យដឹងមុន ហើយហេតុដូច្នេះហើយវាមិនទំនងជាអាចរកឃើញនូវបញ្ហានៃអវត្តមានរបស់គ្រូបង្រៀនទេ។

## ២.៦ ការចូលរួមរបស់គ្រូបង្រៀនក្នុងការងារគ្រប់គ្រងការបំពេញការងារ

ដូចដែលបានកត់សម្គាល់ ភស្តុតាងជាអន្តរជាតិលើកឡើងថាប្រព័ន្ធគ្រប់គ្រងការបំពេញការងាររបស់គ្រូបង្រៀន គឺទំនងជាមានភាពសមស្រប និងប្រសិទ្ធភាព ប្រសិនបើប្រព័ន្ធទាំងនេះត្រូវបានគេរៀបចំនិងឯកភាពគ្នាដោយមានការពិគ្រោះយោបល់ជាមួយគ្រូបង្រៀន និងអ្នកតំណាងផ្នែកវិជ្ជាជីវៈរបស់គ្រូបង្រៀន។ អង្គការពលកម្មអន្តរជាតិបានបោះពុម្ពផ្សាយនូវ សេចក្តីណែនាំដ៏ទូលំទូលាយមួយស្តីពីគោលនយោបាយធនធានមនុស្សល្អសម្រាប់វិជ្ជាជីវៈគ្រូបង្រៀន (ILO, ២០១២) ដែលទទួលបានការគាំទ្រពីសំណាក់ទីភ្នាក់ងារអង្គការសហប្រជាជាតិផ្សេងៗទៀត។ សេចក្តីណែនាំនេះផ្តល់យោបល់ថា ទាំងម៉ោងបង្រៀនដែលគេរំពឹងទុកជាទូទៅនិងប្រព័ន្ធគ្រប់គ្រងបុគ្គលិក ដើម្បីដោះស្រាយការបំពេញការងាររបស់គ្រូបង្រៀនត្រូវស្របគ្នា ជាមួយនឹងវិជ្ជាជីវៈគ្រូបង្រៀន (អនុសាសន៍ទី ៨៩ ទី៤៩ និងទី៧១)។ សេចក្តីណែនាំនេះផ្តល់នូវការណែនាំ ជាក់លាក់ជាច្រើនស្តីពីប្រព័ន្ធគ្រប់គ្រងការប្រតិបត្តិការងារ និងរបៀបត្រូវដោះស្រាយការប្រតិបត្តិការងារមិនបានល្អ (អនុសាសន៍ទី៤៩-៥០) ដោយរាប់បញ្ចូលទាំងការប្រើប្រាស់នូវក្រមប្រតិបត្តិផ្នែកវិជ្ជាជីវៈ ច្បាស់លាស់ យន្តការបណ្តឹងតវ៉ាច្បាស់លាស់ដែលរាប់បញ្ចូលនូវភស្តុតាងបើកចំហរពេញលេញទាំងអស់ និងសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍។ ចំណុចនេះគឺជាផ្នែកក៏ស្មុគស្មាញមួយនៅក្នុងប្រទេសកម្ពុជា ដោយសារកង្វះការ ចូលរួមជាទូទៅរបស់សហភាពគ្រូបង្រៀននៅក្នុងការពិភាក្សាពីគោលនយោបាយអប់រំ ជាការប្រឈមមុខមួយដែលកាន់តែមានភាពធ្ងន់ធ្ងរឡើងដោយសារការជាប់ពាក់ព័ន្ធនឹងគណៈបក្សនយោបាយដែលគេបានដឹងឮយ៉ាងទូលំទូលាយ ចំពោះសមាគមគ្រូបង្រៀនឯករាជ្យបច្ចុប្បន្ន។ ក្រសួងអប់រំ យុវជន និងកីឡាក្នុងពេលថ្មីៗនេះបានព្យាយាមបង្កើតឱ្យមានការពិភាក្សាគ្នាច្រើនថែមទៀតជាមួយគ្រូបង្រៀនខ្លួនឯងផ្ទាល់ ឧទាហរណ៍ ការពិគ្រោះយោបល់ស្តីពីផែនការសកម្មភាពដើម្បីគាំទ្រការអនុវត្តគោលនយោបាយ គ្រូបង្រៀនដែលបានរៀបចំឡើងនៅក្នុងឆ្នាំ២០១៤ ដោយនៅក្នុងផែនការសកម្មភាពនោះ បានដាក់បញ្ចូលនូវការប្តេជ្ញាចិត្តក្នុងការពិគ្រោះយោបល់ច្រើនថែមទៀត ជាមួយគ្រូបង្រៀន។ ទោះជាយ៉ាងណាក៏ដោយ ចំណុចនេះមិនសមមូលទៅនឹងកម្រិតនៃការចរចាដែលគេរំពឹងទុកនៅក្នុងសៀវភៅណែនាំរបស់ ILO រវាងរដ្ឋាភិបាល និងអង្គការនានាដែលតំណាងឱ្យសំឡេងរួមរបស់គ្រូបង្រៀនទេ។

## III. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវរបស់អង្គការ NEP ស្តីពីម៉ោងបង្រៀននៅកម្រិតបឋមសិក្សានៅប្រទេសកម្ពុជាត្រូវបានធ្វើឡើងនៅក្នុង ខេត្តរាជធានី ចំនួន ៦ ដែលត្រូវបានជ្រើសរើសពីតំបន់ភូមិសាស្ត្រផ្សេងៗគ្នានៅទូទាំងប្រទេសកម្ពុជា មានដូចជា ខេត្តបាត់ដំបង ព្រះសីហនុ ព្រះវិហារ កំពង់ចាម មណ្ឌលគិរី និងរាជធានីភ្នំពេញ។ មានស្រុកចំនួនពី ២ ទៅ ៤ ស្រុក រួមទាំងស្រុកនៅទីប្រជុំជន ត្រូវបានជ្រើសរើសដើម្បីធ្វើការសិក្សាក្នុងខេត្តនីមួយៗ ដោយអាស្រ័យទៅតាមទំហំនៃខេត្ត។ ព័ត៌មានលម្អិតស្តីពីចំនួនសាលារៀនដែលត្រូវបានជ្រើសរើសសម្រាប់ការសិក្សាស្រាវជ្រាវ គឺមានបង្ហាញនៅក្នុងតារាងទី ២។ ខេត្តទាំងនេះត្រូវបានជ្រើសរើសដោយផ្អែកទៅលើៈ ១)ការខ្វះខាតព័ត៌មានទូលំទូលាយអំពីម៉ោងបង្រៀន ដែលកំពុងបានអនុវត្តនៅទីនោះ និង ២)តំណាងជាលក្ខណៈភូមិសាស្ត្រនៅតាមតំបន់ផ្សេងៗនៃប្រទេសកម្ពុជា។

ការសិក្សាស្រាវជ្រាវត្រូវបានរៀបចំឡើង និងគ្រប់គ្រងដោយក្រុមការងារស្រាវជ្រាវរបស់អង្គការ NEP ខណៈដែលការប្រមូលទិន្នន័យត្រូវបានធ្វើឡើងដោយអង្គការដៃគូ ដោយប្រើប្រាស់ឧបករណ៍ដែលបានបង្កើតឡើងនៅថ្នាក់ជាតិ។ អ្នកប្រមូលទិន្នន័យទាំងអស់បានទទួលការបណ្តុះបណ្តាលអំពីរបៀបប្រើប្រាស់ ឧបករណ៍ និងការរៀបចំការសិក្សា។ ក្រុមប្រឹក្សាយោបល់អំពីការស្រាវជ្រាវមួយដែលមានសមាជិក ៥ រូប ត្រូវបានបង្កើតឡើងដោយមានការចូលរួមពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដៃគូអភិវឌ្ឍន៍ ក្រសួងអប់រំ យុវជន និងងកីឡា និងអង្គការសមាជិករបស់ NEP ។ ឧបករណ៍ដែលបានសម្រេចចុងក្រោយត្រូវបានចែកជូនទៅដល់ប្រធាននាយកដ្ឋានបឋមសិក្សាដើម្បីធ្វើការផ្តល់យោបល់ និងសម្រេច។

រូបទី ៣ តំបន់ដែលធ្វើការសិក្សាស្រាវជ្រាវ



តំណាងមកពីនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា បានណែនាំមិនឱ្យបញ្ចូលការរៀននៅថ្ងៃព្រហស្បតិ៍ក្នុងការសិក្សានេះទេ។ មូលហេតុចំពោះការមិនដាក់បញ្ចូលនេះ គឺតាមការពិតដោយសារការប្រើប្រាស់ការបង្រៀននៅថ្ងៃព្រហស្បតិ៍មានភាពខុសគ្នាពី សាលារៀនមួយទៅសាលារៀនមួយទៀត។ សាលារៀនមួយចំនួនប្រើប្រាស់ការបង្រៀននៅថ្ងៃព្រហស្បតិ៍ សម្រាប់សកម្មភាពបំណិនជីវិត ឬសកម្មភាពបោសសម្អាតសាលារៀន ដោយឡែកសាលារៀនមួយចំនួន ទៀតប្រើប្រាស់ថ្ងៃព្រហស្បតិ៍សម្រាប់ថ្នាក់បំប៉ន។ ការបង្រៀននៅថ្ងៃព្រហស្បតិ៍ គឺមានចំនួនបីថ្ងៃក្នុងមួយខែ ហើយនៅព្រហស្បតិ៍សប្តាហ៍ទី ៤ ត្រូវបានប្រើប្រាស់សម្រាប់ការប្រជុំបច្ចេកទេស។ ពួកគាត់ក៏បានកត់សម្គាល់ថា ការបង្រៀននៅថ្ងៃព្រហស្បតិ៍គឺផ្អែកទៅលើការមានថវិកាដំណើរការសាលារៀន (PB) សម្រាប់ផ្តល់ប្រាក់បន្ថែមឱ្យគ្រូដែលបង្រៀនក្នុងតម្លៃ ១០០០០ រៀល (២.៥ ដុល្លា) ក្នុងមួយសប្តាហ៍។ ដោយហេតុថាការអនុវត្តន៍ការបង្រៀនថ្ងៃព្រហស្បតិ៍ពុំមានសង្គតភាពពីសាលារៀនមួយទៅសាលារៀនមួយ ទើបធ្វើឱ្យមានក្តី កង្វល់ថាការសង្កេតមើលការបង្រៀនថ្ងៃព្រហស្បតិ៍នឹងផ្តល់នូវទិន្នន័យដែលមិនអាចជឿទុកចិត្តបាន។

ដូចដែលបានកត់សម្គាល់ខាងលើ គ្រូត្រូវចំណាយពេលដើម្បីធ្វើកិច្ចតែងការបង្រៀន និងការងាររដ្ឋបាលថ្នាក់រៀនផងដែរ។ គ្រូបឋមធ្វើការចំនួន ៤០ម៉ោង ក្នុង១សប្តាហ៍ ត្រូវបានបញ្ជាក់នៅក្នុងអនុក្រិតលេខ ៣០៩ កាលពីខែធ្នូ ឆ្នាំ២០១៤។ គួរឱ្យកត់សម្គាល់ផងដែរថា កាសិក្សានេះ គឺធ្វើឡើងដើម្បីពិនិត្យមើលតែម៉ោងបង្រៀនប៉ុណ្ណោះ ដោយមិនបានពិនិត្យមើលទៅលើម៉ោងបំពេញការងារទាំងអស់របស់គ្រូបង្រៀននោះទេ។

## ៣.១ ទំហំនៃសំណាក និងវិធីសាស្ត្រជ្រើសរើសសំណាក

ការសិក្សានេះ គឺពឹងផ្អែកទៅលើការសង្កេត និងការសម្ភាសគ្រូបង្រៀនតាមជំនាន់ដាក់លាក់មួយ ក្នុងចំណោមសាលារៀនដែលបានកំណត់យក។ ការជ្រើសរើសសំណាកគឺអាស្រ័យទៅលើចំនួនសាលារៀន និងលក្ខណៈសម្បត្តិរបស់សាលារៀន។

### ៣.១.១ ការរៀបចំ

នៅក្នុងដំណាក់កាលនៃការរៀបចំវិធីសាស្ត្រ សាលារៀនបឋមសិក្សាចំនួន ៩៥ នៅក្នុងខេត្តចំនួន៥ និងរាជធានីភ្នំពេញ ត្រូវបានជ្រើសរើសដើម្បីចូលរួមក្នុងការសិក្សានេះ។ ការជ្រើសរើសសំណាក នេះគឺបានកំណត់ដោយរូបមន្ត Slovin $n= N/(1+(Nxe^2))$ ។

ដែលក្នុងនោះ៖

n: ជាទំហំសំណាក

N: ជាចំនួនប្រជាជន

e: ជាកម្រិតលម្អៀង

ចំនួនសាលារៀនសរុបរបស់រាជធានី/ខេត្តដែលបានជ្រើសរើសមាន ១៨៨៧ សាលារៀន។ ក្រុមការងារស្រាវជ្រាវប្រើសំណាកដែលមានកម្រិតលម្អៀង ១០%។ ការគណនាទំហំសំណាកគឺមានដូចខាងក្រោម៖

= ១៨៨៧/(១+(១៨៨៧x0.១$^{២}$))= ១៨៨៧/(១+(១៨៨៧x0.0១))

= ១៨៨៧/១៩.៨៧=៩៤.៩៦ = ៩៥ សាលារៀន

ក្នុងចំណោមសាលារៀនដែលបានជ្រើសរើសមានថ្នាក់ទី៤ ទី៥ និងទី ៦ ចំនួន ៨៣២១ថ្នាក់។ ដូច្នេះ ការអនុវត្តតាមរូបមន្ត Slovin ដែលមានកម្រិតលម្អៀង ៥% នៅកម្រិតសាលារៀន តម្រូវឱ្យមានសំណាកថ្នាក់រៀនចំនួន ៣៧៤ ថ្នាក់ គឺមានថ្នាក់រៀនចំនួន ៣,៩៤ ក្នុងសាលារៀនមួយ។ ជាក់ស្តែង គឺមានថ្នាក់រៀនចំនួន ៤ ត្រូវបានជ្រើសរើសក្នុងសាលារៀននីមួយៗដែលត្រូវបានជ្រើសរើស។

មូលហេតុដែលផ្តោតការសិក្សាទៅលើថ្នាក់ទី៤ ដល់ទី៦ គឺផ្អែកលើការវាយតម្លៃថាសិស្សរៀននៅថ្នាក់ទី ១ ដល់ទី៣ គឺនៅមានវ័យក្មេងពេកមិនអាចផ្តល់ជាប្រភពព័ត៌មានដែលជឿទុកចិត្តបានចំពោះប្រធានបទនេះ។ ដោយសារតែវិធីសាស្ត្រនៃការសិក្សានេះ មានពាក់ព័ន្ធទៅនឹងការពិនិត្យមើលសៀវភៅសរសេររបស់សិស្ស និង ការធ្វើតេស្តសមត្ថភាពលើមុខវិជ្ជាគណិតវិទ្យា និងភាសាខ្មែរ ទើបធ្វើឱ្យមានក្តីកង្វល់ថា កុមាររៀនថ្នាក់ទី១ ដល់ទី៣ អាចមិនទាន់ចេះកត់ត្រាមេរៀនជាប្រព័ន្ធបាន និងពួកគេអាចមានអារម្មណ៍មិនជឿជាក់ក្នុងចូលរួមធ្វើតេស្ត នៅចំពោះវត្តមានអ្នកដែលប្លែកមុខ។

### ៣.១.២ ការអនុវត្តជាក់ស្តែង

នៅដំណាក់កាលប្រមូលទិន្នន័យ សាលារៀនចំនួន ៩១ សាលាត្រូវបានក្រុមការងារស្រាវជ្រាវ ជ្រើសរើសតាមលក្ខណៈចោះៗ ដោយស្រង់ពីបញ្ជីសាលារៀនបឋមសិក្សាដែលបានបំពេញរួចនៅតាមស្រុក។ បញ្ជីនេះ គឺគេទទួលបានពីមន្ទីរអប់រំ យុវជន និងកីឡា និងអង្គការសោម៉ីនៅក្នុងខេត្តគោលដៅ។

ជាង ៣០% នៃសាលារៀនដែលបានជ្រើសរើសក្នុងខេត្តបាត់ដំបង ព្រះសីហនុ និងមណ្ឌលគិរី គឺស្ថិតនៅក្នុងទីប្រជុំជន ចំណែកសាលារៀនតិចជាង ៧០% ទៀតត្រូវបានជ្រើសរើសពីតំបន់ជនបទ ឬតំបន់ដាច់ស្រយាល។ នៅខេត្តព្រះវិហារ អ្នកប្រមូលទិន្នន័យរបស់អង្គការសាម៉ីមិនមានលទ្ធភាព ចុះទៅប្រមូលព័ត៌មានពីសាលារៀនដែលនៅជនបទបានទេ ដោយសារតែមមាញឹកនៅក្នុងការងាររបស់អង្គការ។ ដូចដែលបានបង្ហាញនៅក្នុងតារាងទី២ ចំនួនសាលារៀននៅទីប្រជុំជននៅក្នុងខេត្តគឺមានចំនួនតិច។ ការសិក្សានេះចង់កំណត់ថា តើទីតាំងសាលារៀនមានចំណែកក្នុងអត្រាអវត្តមានគ្រូដែរ ឬទេ។ ដើម្បីឱ្យការប្រៀបធៀបនេះអាចធ្វើទៅបាន យើងដាក់បញ្ចូលសាលារៀន នៅទីប្រជុំជនឱ្យបានច្រើន។ សម្រាប់រាជធានីភ្នំពេញ សាលារៀនទាំងអស់ត្រូវបានចាត់ថ្នាក់ជាសាលារៀន[1]នៅទីប្រជុំជន ដូច្នេះហើយពុំមាន សាលារៀនជនបទក្នុងទីតាំងនេះ ដើម្បីដាក់បញ្ចូលក្នុងការសិក្សានេះឡើយ។ ចំពោះខេត្តកំពង់ចាមវិញ សាលារៀននៅទីប្រជុំជនចំនួន៧ ដែលបានជ្រើសរើសនៅក្នុងក្រុងសួង ត្រូវបានដកចេញវិញ ដោយសារ តែសមត្ថភាពរបស់អង្គការសាមីមិនអាចធ្វើទៅបាន។ ផ្ទុយមកវិញ សាលារៀនជនបទចំនួន៧ ត្រូវបានជ្រើសរើសជំនួសវិញ។ ថ្វីត្បិតតែទំហំសំណាកនៃសាលារៀននៅទីប្រជុំជនក្នុង ខេត្តកំពង់ចាម មានចំនួនតិចជាងសាលារៀនជនបទក៏ដោយ ក៏ចំណុចនេះនឹងមិនធ្វើឱ្យមានផលប៉ះពាល់ដល់ការរកឃើញអំពីចំនួនម៉ោងបង្រៀនដែលបាត់នោះទេ ដោយសារចំនួនសាលារៀននៅជនបទមានច្រើនជាងនៅក្នុងតំបន់នេះ។

នៅខេត្តព្រះវិហារ ការប្រមូលព័ត៌មាន បានប្រព្រឹត្តទៅតាមផែនការនោះទេ គឺមានតែសាលាចំនួន៣ ទេ ដែលបានធ្វើការសិក្សា។ ដោយសារហេតុផលនេះ គឺខេត្តព្រះវិហារមិនបានដាក់បញ្ចូលនៅក្នុងការវិភាគទិន្នន័យ

---

[1] ដោយផ្អែកលើយោបល់របស់បុគ្គលិកផ្នែកបច្ចេកទេសនៃនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សាដែលបានចូលរួមក្នុងការស្រាវជ្រាវនេះ

កម្រិតខេត្ត តែទោះជាដូច្នេះក៏ដោយ ក៏ទិន្នន័យដែលបានប្រមូលគឺដាក់បញ្ចូលនៅក្នុងការវិភាគ ជារួមផ្សេងៗទៀត។

តារាងទី២៖ ទំហំសំណាកនៅតាមខេត្ត

| ខេត្ត | សាលារៀនទាំងអស់ | | | | សំណាកសាលារៀន | | | |
|---|---|---|---|---|---|---|---|---|
| | ប្រជុំជន | | ជនបទ | | ប្រជុំជន | % | ជនបទ | % |
| បាត់ដំបង | ៣៥ | ៦% | ៥៤៣ | ៩៤% | ១០ | ៣៦% | ១៨ | ៦៤% |
| ព្រះសីហនុ | ១៧ | ៥% | ៥៦ | ៩៥% | ៤ | ៣៦% | ៧ | ៦៤% |
| កំពង់ចាម | ២២ | ៣% | ៧៦៥ | ៩៧% | ៣ | ៩% | ២៨ | ៩១% |
| ព្រះវិហារ | ១៣ | ៧% | ១៧២ | ៩៣% | ៣ | ១០០% | ០ | |
| មណ្ឌលគិរី | ៨ | ១១% | ៦៨ | ៨៩% | ៣ | ៣៣% | ៦ | ៦៧% |
| ភ្នំពេញ | ១១៥ | ១០០% | ០ | ០% | ៩ | ១០០% | ០ | |
| ទូទាំងប្រទេស | ៦៣៥ | ៩% | ៦២៧៥ | ៩១% | ៣២ | ៣៥% | ៥៩ | ៦៥% |

នៅក្នុងសាលារៀននីមួយៗ មានគ្រូបង្រៀនចំនួន ៣ ទៅ ៤ នាក់ មកពីថ្នាក់ទី ៤ ដល់ទី ៦ ត្រូវបានជ្រើសរើស ដើម្បីចូលរួមក្នុងការសិក្សានេះនៅដើមឆ្នាំសិក្សា។ អ្នកស្រាវជ្រាវប្រើបច្ចេកទេសក្នុងការជ្រើសរើសសំណាក ដោយផ្អែកលើគោលបំណងជាក់លាក់ដើម្បីជ្រើសរើសគ្រូដែលបានចាប់ផ្តើមបង្រៀនមុនគេ ចាប់ផ្តើមឃើតបន្តិច និងចាប់ផ្តើមឃើតមែនទែន នៅថ្ងៃដំបូងនៃការចុះពិនិត្យដោយមិនផ្តល់ដំណឹងជាមុន។ អាស្រ័យទៅលើថ្នាក់ ដែលគ្រូទាំងនោះបានបង្រៀន គ្រូដែលនៅសល់ត្រូវបានជ្រើសរើសដោយធ្វើឱ្យប្រាកដ ថាកម្រិតថ្នាក់នីមួយៗ និងវេនបង្រៀនពេលសៀលត្រូវបានជ្រើសរើសជាតំណាងទាំងអស់នៅក្នុងសំណាករបស់យើង។ សរុបមានគ្រូបង្រៀនចំនួន ៣០៩ នាក់ត្រូវបានជ្រើសរើសជាផ្នែកនៃការសិក្សានេះ។

តារាងទី ៣ ៖ តំបន់ធ្វើការសិក្សាស្រាវជ្រាវ និងទំហំសំណាក

| ខេត្ត | ចំនួនសាលារៀនបឋមសិក្សា | | | ចំនួនថ្នាក់ទី ៤ ៥ និង៦ | | | |
|---|---|---|---|---|---|---|---|
| | សរុប | ជ្រើសរើស | % | ប្រជុំជន | % ប្រជុំជន | ជនបទ | % ជនបទ |
| បាត់ដំបង | ៥៧៨ | ២៨ | ៥% | ៣៩ | ៣៧% | ៦៦ | ៦៣% |
| ព្រះវិហារ | ២០៥ | ៣ | ១% | ៩ | ១០០% | ០ | ០% |
| ព្រះសីហនុ | ៧២ | ១១ | ១៥% | ១៤ | ៣៩% | ២២ | ៦១% |
| ភ្នំពេញ | ១៦៤ | ៩ | ៥% | ៣១ | ១០០% | ០ | ០% |
| កំពង់ចាម | ៧៩២ | ៣១ | ៤% | ១១ | ១០% | ៩៥ | ៩០% |
| មណ្ឌលគិរី | ៧៦ | ៩ | ១២% | ១០ | ៤៨% | ១១ | ៥២% |
| **សរុប** | **១៨៨៧** | **៩១** | **៥%** | **១១៤** | **៣៨%** | **១៩៥** | **៦២%** |

តារាងទី៤ ៖ សំណាកគ្រូបង្រៀនតាមភេទ និងវេនបង្រៀន

| កម្រិតថ្នាក់ | ភេទ | | | វេនបង្រៀន | | | |
|---|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ខកខាន | ព្រឹក | រសៀល | បង្រៀន ២ ពេល | បង្រៀនឆ្លាស់វេន |
| ៤ | ៤៥ | ៦០ | ២ | ៤១ | ១៧ | ២១ | ២៨ |
| ៥ | ៤១ | ៥០ | ៤ | ៤០ | ១៧ | ២៨ | ១០ |
| ៦ | ៦៤ | ២៩ | ៥ | ៤៦ | ១៦ | ២៥ | ១១ |
| ថ្នាក់ផ្គួប | ៦ | ២ | ១ | ៥ | ៤ | ០ | ០ |
| សរុប | ១៥៦ | ១៤១ | ១២ | ១៣២ | ៥៤ | ៧៤៥ | ៤៩ |

## ៣.២ វិធីសាស្ត្រប្រមូលទិន្នន័យ

ការសិក្សានេះធ្វើឡើងអស់រយៈពេល ៩ខែ ក្នុងកំឡុងឆ្នាំសិក្សា ២០១២/២០១៣។ ក្រសួងអប់រំ យុវជន និងកីឡាបានចេញលិខិតអនុញ្ញាតឱ្យអង្គការ NEP ធ្វើការសិក្សានេះឡើង។ បុគ្គលិកក្រសួងអប់រំបាន ចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ ចាប់តាំងពីការរៀបចំវិធីសាស្ត្ររហូតដល់ចុងបញ្ចប់នៃការប្រមូលទិន្នន័យ។ អង្គការសមាជិករបស់ NEP ដែលមានទីតាំងនៅក្នុងខេត្ត/រាជធានីគោលដៅសម្រាប់ការស្រាវជ្រាវ ត្រូវបាន ជ្រើសរើស និងគាំទ្រក្នុងការអនុវត្តសកម្មភាពប្រមូលព័ត៌មានជាក់ស្តែងនៅក្នុងខេត្តរបស់ខ្លួនក្នុងកំឡុងពេល ស្រាវជ្រាវ។

ការសិក្សាស្រាវជ្រាវនេះបានប្រើប្រាស់វិធីសាស្ត្រផ្សេងៗក្នុងការប្រមូលទិន្នន័យបឋម និងទិន្នន័យបន្ទាប់ បន្សំ។ ទិន្នន័យបន្ទាប់បន្សំត្រូវបានប្រមូលតាមរយៈការពិនិត្យមើល ការសិក្សាស្រាវជ្រាវដែលមានស្រាប់ របាយ ការណ៍ដែលពាក់ព័ន្ធ និងគោលនយោបាយដែលមានរួមទាំងគោលការណ៍ណែនាំផ្សេងៗ ទាក់ទងនឹងម៉ោង បង្រៀន។ វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យបឋម រួមមាន៖

- ការពិនិត្យមើលសៀវភៅសរសេររបស់សិស្សដើម្បីរកឱ្យឃើញអវត្តមានគ្រូបង្រៀនដែលអាចកើតមាន
- ការចុះពិនិត្យសាលារៀនដោយមិនផ្តល់ដំណឹងជាមុន( ការធ្វើតាមសាលារៀន )ដើម្បីត្រួត ពិនិត្យមើលពីវត្តមានរបស់គ្រូបង្រៀន
- ការធ្វើសង្កេតថ្នាក់រៀនដើម្បីកំណត់នូវរយៈពេលបង្រៀន
- ការសម្ភាសជាមួយគ្រូបង្រៀនដើម្បីរាយការណ៍ និងពន្យល់អំពីអវត្តមាន
- ការសម្ភាសជាមួយនាយកសាលារៀនដើម្បីរកឱ្យឃើញនូវការអនុវត្តនានាក្នុងការគ្រប់គ្រងគ្រូបង្រៀន
- ការធ្វើតេស្តសិស្សដើម្បីកំណត់ពីសមត្ថភាពរបស់ពួកគេក្នុងមុខវិជ្ជាគណិតវិទ្យា និងភាសាខ្មែរ

ប្រភពទាំងអស់នេះ គឺមានបំណងចង់ឱ្យមានតុល្យភាពរវាងភស្តុតាងជាក់ស្តែង និងភស្តុតាងតាមការ សន្មតពេញមួយឆ្នាំសិក្សា។ ប្រភពទិន្នន័យមួយចំនួនឆ្លើយទៅនឹងសំណួរសម្រាប់ការស្រាវជ្រាវនេះលើសពីមួយ សំណួរ។ គោលបំណងនៃសកម្មភាពផ្សេងៗគឺមានបង្ហាញក្នុងដ្យាក្រាមខាងក្រោម ៖

រូបទី៤៖ ដ្យាក្រាមវិធីសាស្ត្រស្រាវជ្រាវ




សកម្មភាពនានាដែលបានធ្វើឡើងក្នុងរយៈពេល ៩ ខែនៃការស្រាវជ្រាវនេះមានដូចតទៅ ៖

រូបទី៥៖ វិធីសាស្ត្រស្រាវជ្រាវ និងពេលវេលា



ប្រភពទិន្នន័យបឋមនីមួយៗ និងឧបករណ៍ដែលបានប្រើប្រាស់គឺមានបរិយាយពិស្តារដូចខាងក្រោម ៖

### ៣.២.១ ការពិនិត្យតាមដានសៀវភៅសរសេររបស់សិស្ស និងរបាយការណ៍សាលារៀន

អ្នកស្រាវជ្រាវបានពិនិត្យតាមដានសៀវភៅសរសេរមុខវិជ្ជាគណិតវិទ្យា និងភាសាខ្មែរ ចំនួន ៦ក្បាល របស់សិស្សចំនួន ៣ នាក់ក្នុងមួយថ្នាក់ ដើម្បីកំណត់រកថ្ងៃណាខ្លះដែលសិស្សមិនបានកត់ត្រាមេរៀន។ សិស្សទាំងបីនាក់នៅក្នុងថ្នាក់នីមួយៗ ដែលត្រូវបានជ្រើសរើសគឺសិស្សរៀនពូកែនៅក្នុងថ្នាក់តាមរយៈការផ្តល់ ព័ត៌មានពីគ្រូបង្រៀន ដោយផ្អែកតាមការសន្មតថាសិស្ស ដែលរៀនពូកែគឺជាសិស្សដែលភាគច្រើនមករៀនទៀងទាត់។

អ្នកស្រាវជ្រាវពិនិត្យតាមដានសៀវភៅសរសេររបស់សិស្ស ដើម្បីរកមើលថ្ងៃដែលគ្រូអវត្តមាន ដោយផ្អែកតាមកាលបរិច្ឆេទដាក់លាក់ដែលសិស្សកត់ត្រាក្នុងសៀវភៅមេរៀន។ កាលបរិច្ឆេទទាំងនោះ ត្រូវបានត្រួតពិនិត្យដោយប្រៀបធៀប ជាមួយនឹងប្រភពព័ត៌មានពីរផ្សេងទៀត គឺសៀវភៅសម្រង់វត្តមានគ្រូ និងសៀវភៅវេន[2]។ ប្រសិនបើប្រភពណាមួយ ឬទាំងអស់ (សៀវភៅសរសេររបស់សិស្ស សៀវភៅវេន ឬ សៀវភៅសម្រង់វត្តមានគ្រូ) បង្ហាញថាគ្រូមកបង្រៀន ថ្ងៃនោះគឺមិនដាក់ក្នុងបញ្ជីកាលបរិច្ឆេទដែលគ្រូអាចអវត្តមានទេ។ នៅតាមសាលារៀនភាគច្រើនយើងមិនអាចរកសៀវភៅសម្រង់វត្តមានរបស់គ្រូ និងសៀវភៅវេន បានទេ ដូច្នេះហើយការវិនិច្ឆ័យភាគច្រើនធ្វើឡើងដោយផ្អែកតាមសៀវភៅសរសេររបស់សិស្ស។

កាលបរិច្ឆេទដែលសង្ស័យថា មិនមានការបង្រៀនដែលបានរកឃើញពីការពិនិត្យតាមដានសៀវភៅសរសេររបស់សិស្ស ត្រូវបានប្រមូលចងក្រងសម្រាប់គ្រូបង្រៀនម្នាក់ៗ។ នៅក្នុងការសម្ភាសជាលក្ខណៈបុគ្គលជាមួយគ្រូបង្រៀន អ្នកប្រមូលព័ត៌មានបានបង្ហាញកាលបរិច្ឆេទដែលបានចងក្រងថាមិនមានការបង្រៀនរបស់គ្រូបង្រៀនរូបនោះ ព្រមទាំងស្នើសុំឱ្យគាត់បញ្ជាក់ពីកាលបរិច្ឆេទដែលគាត់បានអវត្តមាន ហើយប្រសិនបើពួកគាត់ទទួលស្គាល់ថាពួកគាត់មិនបានមកសាលារៀនក្នុងថ្ងៃទាំងនោះមែន គាត់ត្រូវបានគេស្នើសុំឱ្យបញ្ជាក់ពីមូលហេតុចំពោះការអវត្តមាននោះ។ ការសម្ភាសទាំងនេះត្រូវបានធ្វើឡើងដោយរក្សាការសម្ងាត់។

ចំនួនថ្ងៃក្នុងមួយឆ្នាំសិក្សាដែលបានពិនិត្យមើលតាមរយៈមធ្យោបាយនេះគឺមានចន្លោះពី ១៤៧ ទៅ ១៦៥ ថ្ងៃ ដោយយោងទៅតាមពេលវេលានៃការសម្ភាសចុងក្រោយជាមួយគ្រូបង្រៀនម្នាក់ៗ។ នៅក្នុងរបាយការណ៍នេះ យើងភាគច្រើនសំដៅទៅលើភាគរយនៃអវត្តមានដែលបានគណនាដោយប្រើប្រាស់ចំនួននៃអវត្តមានរបស់គ្រូបង្រៀនម្នាក់ៗនៅក្នុងកំឡុងពេលនៃការសិក្សាស្រាវជ្រាវ។

ដំណើរការនៃការពិនិត្យតាមដានសៀវភៅសរសេររបស់សិស្ស និងការសម្ភាសគ្រូបង្រៀន ដើម្បីបញ្ជាក់ពីថ្ងៃគ្រូអវត្តត្រូវបានធ្វើឡើង ២ ឬ ៣ដង ក្នុងមួយថ្នាក់/គ្រូម្នាក់ ក្នុងមួយឆ្នាំសិក្សា។ ហេតុផលចំពោះការធ្វើដូចនេះគឺដើម្បីឱ្យបានកំនត់ត្រាពីកាលបរិច្ឆេទគ្រូអវត្តមានក្នុងពេលថ្មីៗ ដែលគ្រូអាចចាំបាន និងងាយនឹកឃើញពីមូលហេតុនៃការអវត្តមានរបស់ខ្លួន។ លទ្ធផលពីការធ្វើបែបនេះ គឺបាននូវបណ្តុំទិន្នន័យដែលបង្ហាញពីចំនួនថ្ងៃអវត្តមាន ដោយបានធ្វើការផ្ទៀងផ្ទាត់ចំពោះគ្រូបង្រៀនចំនួន ៣០៩ នាក់ នៅក្នុងការសិក្សាស្រាវជ្រាវនេះ ហើយគ្រូទាំងនោះទទួលស្គាល់ថាខ្លួនបានឈប់មែន ដោយមានបញ្ជាក់ពីមូលហេតុនៃការអវត្តមាននៅថ្ងៃនីមួយៗក្នុងចំណោមថ្ងៃអវត្តមានទាំងអស់។

២ សៀវភៅនេះត្រូវបានគេកត់ត្រាជារៀងរាល់ថ្ងៃពីចំណងជើងមេរៀនដែលគ្រូបានបង្រៀនក្នុងថ្នាក់

### ៣.២.២ ការធ្វើទស្សនកិច្ចសាលារៀនដោយមិនផ្តល់ដំណឹងជាមុន

ការធ្វើសាលារៀនដោយមិនផ្តល់ដំណឹងជាមុន ត្រូវបានធ្វើឡើងដោយអង្គការដៃគូ ដើម្បីទទួលបានព័ត៌មានបន្ថែមជាក់ស្តែងស្តីពីវត្តមានរបស់គ្រូបង្រៀន។ ការធ្វើសាលារៀនដោយមិនផ្តល់ដំណឹងជាមុននេះបានធ្វើឡើងសរុបចំនួន ១៧៣៣ លើកនៅក្នុងកំឡុងពេលនៃការសិក្សានេះ ហើយសាលារៀនទាំងអស់ផ្តោតទៅលើថ្នាក់រៀន ឬ គ្រូដែលបានជ្រើសរើសសម្រាប់ការសិក្សានេះ។ ដោយមានថ្នាក់រៀនមួយចំនួនត្រូវបានត្រួតពិនិត្យក្នុងសាលារៀននីមួយៗ ដូច្នេះសាលាដោយ មិនមានផ្តល់ដំណឹងជាមុនគឺបានធ្វើឡើងជាច្រើនដងក្នុងថ្ងៃតែមួយ។ សាលារៀន និងគ្រូបង្រៀនមិនត្រូវបានផ្តល់ ព័ត៌មានជាមុនអំពីពេលវេលាដែលត្រូវធ្វើនោះទេ។ សាលាភាគច្រើន គឺធ្វើឡើងនៅក្រៅបរិវេណសាលារៀន និងកត់ត្រាថាតើគ្រូបង្រៀនមានវត្តមាន ឬអវត្តមាន ហើយថាតើមានការរៀបចំការបង្រៀនជំនួសដែរ ឬទេប្រសិនបើគ្រូអវត្តមានថាតើនាយកសាលាមានវត្តមានដែរ ឬទេ និងថាតើថ្នាក់រៀននៅក្នុងសាលាបើកទ្វារដែរ ឬទេ។

ការជ្រើសរើសថ្ងៃត្រូវធ្វើសាលារៀនដោយមិនផ្តល់ដំណឹងជាមុន គឺធ្វើឡើងទៅតាមគោលបំណងដោយផ្អែកតាមសម្មតិកម្ម ដែលថាគ្រូបង្រៀនទំនងជាអវត្តមាន ជាពិសេសនៅជុំវិញថ្ងៃឈប់សម្រាក ជាផ្លូវការមួយចំនួន ថ្ងៃចុងសប្តាហ៍ និងក្នុងកំឡុងថ្ងៃឈប់សម្រាកមិនផ្លូវការ ដូចជា ទិវាបុណ្យនៃក្តីស្រឡាញ់ និងបុណ្យចូលឆ្នាំចិន។ ភាគរយភាគច្រើននៃសាលារៀនដោយពុំជូនដំណឹងជាមុន គឺកើតមានឡើង ក្នុងកំឡុងពេលទាំងនេះដើម្បីធ្វើតេស្តមើលអំពីសម្មតិកម្មនេះ ប៉ុន្តែក៏មានការធ្វើសាលារៀននៅថ្ងៃ ដែលនៅក្នុងការសិក្សានេះសំដៅថាជាថ្ងៃរៀន "ធម្មតា" ដែរ។

### ៣.២.៣ ការសង្កេតមើលដំណើរការរៀននៅក្នុងថ្នាក់

ការសង្កេតពីរយៈពេលរៀននៅក្នុងថ្នាក់ត្រូវបានធ្វើឡើងរវាង ១ ទៅ ៣ ដងក្នុងមួយថ្នាក់ដោយប្រើបញ្ជីពិនិត្យផ្ទៀងផ្ទាត់ដើម្បីកត់ត្រាពីរយៈពេលជាទូទៅដែលគ្រូ និងសិស្សស្ថិតនៅក្នុងថ្នាក់រៀន។ ការសង្កេតត្រូវបានធ្វើឡើងពីខាងក្រៅបរិវេណសាលារៀន និងដោយពុំមានផ្តល់ព័ត៌មានជាមុនដល់គ្រូបង្រៀន និងនាយកសាលាឡើយ ដើម្បីកាត់បន្ថយជាអប្បរមានូវការផ្លាស់ប្តូរអាកប្បកិរិយារបស់គ្រូបង្រៀនដោយសារសកម្មភាព នៃការសង្កេត។ នៅក្នុងករណីខ្លះទៀតដែលបរិវេណសាលារៀនមានទំហំធំ អ្នកសង្កេតឯករាជ្យមិនអាចរកទីតាំងសមរម្យដើម្បីសង្កេតមើលរយៈពេលបង្រៀនពីខាងក្រៅបរិវេណសាលារៀនបានទេ។ ហេតុដូច្នេះហើយការសង្កេតត្រូវបានធ្វើឡើងនៅក្នុងបរិវេណសាលារៀនតែម្តង។ ការសង្កេតទាំងនេះបានកត់ត្រាពីម៉ោងចាប់ផ្តើមបង្រៀន រយៈពេលចេញលេងនីមួយៗ និងម៉ោងបញ្ចប់ការបង្រៀនដើម្បីគណនារយៈពេលបង្រៀនទូទៅ។

### ៣.២.៤ ការសម្ភាសគ្រូ

ការសម្ភាសដោយផ្ទាល់ ត្រូវបានធ្វើឡើងជាមួយគ្រូបង្រៀនដែលបានជ្រើសរើសក្នុងការសិក្សា ដោយប្រើប្រាស់កម្រងសំណួរដែលបានរៀបចំទុក។ កាលបរិច្ឆេទដែលគ្រូបង្រៀនអាចអវត្តមានដែលបានរកឃើញតាមរយៈការពិនិត្យតាមដានសៀវភៅសរសេររបស់សិស្ស ត្រូវបានដាក់បញ្ចូលទៅក្នុងកម្រងសំណួរដើម្បីសុំឱ្យគ្រូបង្រៀនពិនិត្យមើលថាបានអវត្តមានមែនឬទេ និងពន្យល់ពីមូលហេតុនៃការអវត្តមាននោះ។ គ្រូបង្រៀនក៏អាចលើកឡើង ផងដែរពីថ្ងៃដទៃដែលខ្លួនបានអវត្តមាន ប្រសិនបើមិនបានរកឃើញតាមរយៈ ការពិនិត្យតាមដាន

សៀវភៅសរសេររបស់សិស្ស។ នៅពេលដែលក្រុមការងារស្រាវជ្រាវផ្ទៀងផ្ទាត់កាលបរិច្ឆេទនៃអវត្តមានដែលបានបញ្ជាក់ដោយគ្រូបង្រៀនម្នាក់ៗ និងកាលបរិច្ឆេទដែលគាត់អវត្តមានដែលគេបានរកឃើញ តាមរយៈការចុះសាលារៀនដោយមិនផ្តល់ដំណឹងជាមុន គឺមានកាលបរិច្ឆេទមួយចំនួនតូចនៃអវត្តមានរបស់គ្រូបង្រៀនដែលបានរកឃើញតាមរយៈការចុះសាលារៀនដោយមិនផ្តល់ដំណឹងជាមុន តែមិនត្រូវបានគ្រូបង្រៀនទាំងនោះរាយការណ៍ទេ ក្នុងកំឡុងពេលសម្ភាសជាមួយពួកគាត់។ កាលបរិច្ឆេទអវត្តមានមួយចំនួនតូចរបស់គ្រូបង្រៀនដែលបានរកឃើញតាមរយៈការពិនិត្យតាមដានសៀវភៅសរសេររបស់សិស្សត្រូវបានគ្រូបង្រៀនបដិសេធថាខ្លួនមិនបានឈប់។

គ្រូបង្រៀនត្រូវបានគេសម្ភាសចំនួនពីរ ឬបីលើក ដែលលើកទីមួយ ត្រូវបានធ្វើឡើងនៅក្នុងខែមករា ឆ្នាំ២០១៣ ដើម្បីពិនិត្យមើលពីអវត្តមានគ្រូបង្រៀនចាប់តាំងពីដើមឆ្នាំសិក្សា និងលើកទី២ ត្រូវបានធ្វើឡើងនៅក្នុងខែមីនា ឆ្នាំ២០១៣ ហើយលើកទី៣ ត្រូវបានធ្វើឡើងនៅខែមិថុនា ឆ្នាំ២០១៣។ ការសម្ភាសជាមួយគ្រូបង្រៀនក៏បានសួរនូវសំណួរមួយចំនួនផងដែរ ដើម្បីឱ្យបានដឹងសាវតាគ្រូបង្រៀន និងពីគំនិតយោបល់របស់ពួកគាត់ទៅលើបញ្ហាមួយចំនួន ដូចជាការគ្រប់គ្រងបុគ្គលិក សម្ភារៈបរិក្ខាសាលារៀន និងរយៈពេលនៃកម្មវិធីសិក្សា។

### ៣.២.៥ ការសម្ភាសនាយកសាលា

ការសម្ភាសដោយផ្ទាល់ត្រូវបានធ្វើឡើងជាមួយនាយកសាលានៅតាមសាលារៀន ដែលបានជ្រើសរើសដោយប្រើប្រាស់បញ្ជីសំណួរដាច់ដោយឡែកពីកម្រងសំនួរសម្រាប់គ្រូបង្រៀន ដើម្បីរកឱ្យឃើញពីភាពញឹកញាប់និងមធ្យោបាយនៃការត្រួតពិនិត្យតាមដានគ្រូបង្រៀនដែលបានធ្វើឡើងដោយនាយកសាលា មន្ត្រីការិយាល័យអប់រំស្រុក និងមន្ត្រីមន្ទីរអប់រំខេត្ត វិធានការនានាដែលនាយកសាលាបានអនុវត្ត ដើម្បីដាក់វិន័យទៅលើគ្រូបង្រៀនដែលអវត្តមានញឹកញាប់ និងទស្សនៈ របស់ពួកគាត់ស្តីពីបញ្ហានៃការគ្រប់គ្រងបុគ្គលិក។

### ៣.២.៦ ការធ្វើតេស្តសមត្ថភាពសិស្ស

សិស្សចំនួន ១០ នាក់ ក្នុងមួយថ្នាក់ត្រូវបានជ្រើសរើសដោយចៃដន្យជាលក្ខណៈប្រព័ន្ធដោយ ផ្អែកទៅលើទីកន្លែងអង្គុយរបស់ពួកគេ ដើម្បីធ្វើតេស្តលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា។ សំណួរសម្រាប់ ការធ្វើតេស្តទៅលើមុខវិជ្ជាទាំងពីរត្រូវបានបង្កើតឡើងដោយក្រុមការងារស្រាវជ្រាវរបស់អង្គការ NEP ដោយ បានសហការជាមួយបុគ្គលិកបច្ចេកទេសរបស់នាយកដ្ឋានបឋមសិក្សា និងនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា របស់ក្រសួងអប់រំ យុវជន និងកីឡា។ សៀវភៅសិក្សាគោល និងតេស្តស្តង់ដារថ្នាក់ទី៦ ដែលបានបង្កើត ដោយក្រសួងអប់រំ យុវជន និង កីឡាត្រូវបានប្រើប្រាស់ ជាឯកសារគោលដើម្បីបង្កើតសំណួរ ឱ្យបានសមស្រប សម្រាប់កម្រិតថ្នាក់នីមួយៗ ទៅតាមចំនួនមេរៀនដែលបានរៀនគិតត្រឹមពេលវេលាដែលត្រូវធ្វើតេស្ត។ យើងប្រើប្រាស់តេស្តខុសៗគ្នាសម្រាប់កម្រិតថ្នាក់នីមួយៗ។

## ៣.៣ ការវិភាគទិន្នន័យ

កស្តុតាងបានពីប្រភពទិន្នន័យស្តីពីអវត្តមានរបស់គ្រូបង្រៀន រយៈពេលនៃការបង្រៀន និងលទ្ធផលនៃការធ្វើតេស្តសិស្សត្រូវបានដាក់បញ្ចូលគ្នា ដើម្បីមានលទ្ធភាពវិភាគនូវលំនាំ ស្វែងរកកម្រិតមធ្យមភាគ និងសង្ខេបពីលទ្ធផលនៃការបាត់ម៉ោង។ ដើម្បីគណនាអត្រាអវត្តមានជាមធ្យមរបស់គ្រូបង្រៀនម្នាក់ៗ ព័ត៌មានបានពីការចុះសាលារៀន ដោយមិនផ្តល់ដំណឹងត្រូវបានគេដាក់បញ្ចូលគ្នាជាមួយអវត្តមាន របស់គ្រូដែលបានផ្ទៀងផ្ទាត់នៅក្នុងកម្រងសំណួរ។ ការធ្វើដូចនេះបានបង្កើតឱ្យមានជាបណ្តុំទិន្នន័យ ដែលមានរួមបញ្ចូលនូវថ្ងៃនីមួយៗក្នុងកំឡុងពេលសិក្សាទៅតាមគ្រូបង្រៀនម្នាក់ៗ ព្រមទាំងមានបញ្ជាក់ ពីថ្ងៃណាដែលគ្រូនីមួយៗអវត្តមានខ្លះ និងមូលហេតុនៃអវត្តមាននោះ។ ការធ្វើបែបនេះអាចធានាបានថា ថ្ងៃដែលគ្រូអវត្តមានមិនត្រូវបានរាប់ទ្វេរដងនោះទេ។ បណ្តុំទិន្នន័យនេះក៏បានដាក់បញ្ចូលលក្ខណៈ ប្រជាសាស្ត្ររបស់គ្រូបង្រៀន និងការឆ្លើយរបស់ពួកគាត់ទៅនឹងសំណួរបើកផងផ្សេងៗដែរ។

ក្រុមការងារបានចំណាយពេលយ៉ាងច្រើន ដើម្បីធ្វើចំណាត់ថ្នាក់ចម្លើយដែលបានពីសំណួរបើកនានាដោយរាប់បញ្ចូលទាំងមូលហេតុផ្សេងៗនៃអវត្តមានរបស់គ្រូបង្រៀន និងការពិពណ៌នាផ្សេងៗ ដែលទទួល បានពីកិច្ចសម្ភាស។ ផ្នែកនានានៃទិន្នន័យបន្ថែមត្រូវបានដាក់បញ្ចូល ហើយកម្រងសំណួរ និងបញ្ជីពិនិត្យផ្ទៀង ផ្ទាត់ត្រូវបានគេដាក់លេខកូដនៅក្នុងបណ្តុំទិន្នន័យក្នុងគោលបំណងធ្វើការវិភាគ។ លើសពីនេះទៀត ទិន្នន័យ ដែលបានមកពីការចុះសាលារៀនដោយមិនមានផ្តល់ដំណឹងជាមុននោះ ត្រូវបានគេវិភាគដាច់ដោយឡែក ដើម្បីបង្កើតលំនាំ និងនិន្នាការអវត្តមានគ្រូដែលទទួលបានពីប្រភពដាក់ស្តែងនេះ។

វិធីសាស្ត្រវិភាគទិន្នន័យជាច្រើនត្រូវបានប្រើប្រាស់ ដើម្បីស្វែងរកលំនាំនិងទំនាក់ទំនងរវាងអថេរនានានៅក្នុងទិន្នន័យ។ ដោយយោងទៅលើភាពចម្រុះនៃប្រភពទិន្នន័យ មធ្យោបាយនៃការវាយតម្លៃជាលក្ខណៈស្ថិតិគឺចាំបាច់ និងត្រូវបានប្រើប្រាស់។ លទ្ធផលនឹងត្រូវបានគេបង្ហាញក្នុងជំពូកក្រោយស្តីពីលទ្ធផលរកឃើញ និងការវិភាគ។

សិក្ខាសាលាពិគ្រោះយោបល់ជាមួយអង្គការសមាជិករបស់អង្គការ NEP ក្រសួងអប់រំ យុវជន និងកីឡាលោកគ្រូ អ្នកគ្រូ និងនាយកសាលារៀនមួយចំនួនស្ថិតនៅក្នុងតំបន់ដែលធ្វើការសិក្សាត្រូវបានប្រារព្ធធ្វើឡើង នៅចុងបញ្ចប់នៃការសិក្សានេះដើម្បីពិភាក្សាពីលទ្ធផលដែលបានរកឃើញនានា។ បន្ទាប់ពីបានបញ្ចប់ការវិភាគទិន្នន័យនិងរបាយការណ៍ពង្រាងលើកទី១ សិក្ខាសាលាពិគ្រោះយោបល់តូចមួយត្រូវបានធ្វើឡើង ដើម្បីបង្ហាញពីលទ្ធផលរកឃើញព្រមទាំងបើកឱ្យមានការសួរសំណួរ និងការឯកភាពគ្នាទៅលើទិសដៅអនុសាសន៍។

## ៣.៤ ឥទ្ធិពលនៃការសង្កេត

ភាពលម្អៀងចម្បងមួយដែលអាចកើតមាននៅក្នុងការសិក្សានេះ គឺថាអាកប្បកិរិយារបស់គ្រូបង្រៀនមានលក្ខណៈខុសប្លែកពីមុនដោយសារតែពួកគេបានដឹងថាមានគេកំពុងតែសង្កេតមើលពួកគាត់។ អាកប្បកិរិយារបស់គ្រូ អាចប្រែប្រួលពីព្រោះពួកគាត់បានដឹងថាពួកគាត់គឺជាផ្នែកមួយនៃការសិក្សានេះ ហើយពួកគាត់អាច

យល់បានយ៉ាងងាយ ថាតើពួកគាត់ត្រូវប្រកាន់អាកប្បកិរិយាជាវិជ្ជមាន (ឧទាហរណ៍ ការមកបង្រៀនទៀងពេល) និងអវិជ្ជមាន (ការអវត្តមានជាប្រចាំ)។ ហើយបែបនេះគេហៅថា ផលប៉ះពាល់ Hawthorne។

ក្រសួងអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំនៅមូលដ្ឋានមិនបានដឹងថាសាលារៀនណាមួយត្រូវបានដាក់បញ្ចូលក្នុងការសិក្សានេះទេ។ នៅចុងខែធ្នូ មុនពេលការចុះធ្វើសាលារៀនដោយមិនផ្តល់ព័ត៌មានជាមុន ក្រុមការងារស្រាវជ្រាវបានចុះតាមសាលានីមួយៗដែលត្រូវធ្វើការសិក្សា ហើយផ្តល់ព័ត៌មានដល់នាយកសាលាថាសាលារបស់គាត់ត្រូវបានជ្រើសរើសនៅក្នុងការសិក្សានេះ ប៉ុន្តែគ្រូបង្រៀនដែលត្រូវបានជ្រើសរើសមិនត្រូវបានគេជូនដំណឹងទេ។ ដូច្នេះ ហើយវាអាចកើតឡើងបាន ដែលថានាយកសាលាអាចលើកទឹកចិត្តឱ្យគ្រូបង្រៀនរបស់គាត់យកចិត្តទុកដាក់ថែមទៀតលើវត្តមាន និងរយៈពេលបង្រៀនរបស់ខ្លួន។ ពីដំបូងគ្រូបង្រៀនខ្លួនឯងយល់ថាពួកគាត់ចូលរួមនៅក្នុងការសិក្សានេះតែក្នុងរវាងខែមករា និងខែមីនា ឆ្នាំ២០១៣ ប៉ុណ្ណោះ នៅពេលដែលមានការពិនិត្យសៀវភៅសរសេររបស់សិស្ស និងការសម្ភាសពួកគាត់នៅលើកដំបូង។ នេះអាចធ្វើឱ្យមានផលប៉ះពាល់ក្នុងកម្រិតណាមួយទៅដល់អាកប្បកិរិយារបស់គ្រូចាប់តាំងពីពេលនោះមក។

វាក៏អាចកើតឡើងផងដែរ ថាអាកប្បកិរិយាមានការផ្លាស់ប្តូរក្នុងកំឡុងពេលចុះសាលារៀនដោយពុំមានការជូនដំណឹងនីមួយ។ អ្នកសង្កេតភាគច្រើនធ្វើកិច្ចការរបស់ខ្លួនពីខាងក្រៅបរិវេណសាលារៀន និងធ្វើឡើងដោយមិនឱ្យគេចាប់អារម្មណ៍ ប៉ុន្តែពួកគេខ្លួនឯងអាចត្រូវបានគេសង្កេតឃើញ និងដឹងថាមកមើលសកម្មភាពសាលា ហេតុដូច្នេះហើយទើបបណ្តាលឱ្យអាកប្បកិរិយារបស់គ្រូបង្រៀន ឬនាយកសាលាមានការផ្លាស់ប្តូរ។ នេះទំនងជាមានផលប៉ះពាល់បំផុតទៅលើការសិក្សាពីរយៈពេលបង្រៀនប្រចាំថ្ងៃ ប៉ុន្តែក៏អាចមានផលប៉ះពាល់ទៅលើវត្តមានរបស់គ្រូបង្រៀននៅវេនបង្រៀនពេលរសៀលដែរប្រសិនបើពួកគាត់បានកត់សម្គាល់ថាមានការចុះសាលារៀនដោយពុំមានជូនដំណឹងជាមុន និងការសង្កេតការបង្រៀននៅក្នុងថ្នាក់រៀន នៅវេនបង្រៀនពេលព្រឹក។ ថ្វីត្បិតតែគ្មានភស្តុតាងបង្ហាញក៏ដោយ វាក៏អាចទៅរួចផងដែរដែលថាគ្រូបង្រៀន ឬនាយកសាលាបានផ្តល់ព័ត៌មានដល់សហសេវិករបស់ខ្លួន ដើម្បីឱ្យពួកគាត់ដឹងថាមានគេចុះសាលារៀនដោយពុំមានជូនដំណឹង ដែលជាហេតុធ្វើឱ្យគ្រូបង្រៀនមានវត្តមានច្រើននៅវេនបង្រៀន ពេលរសៀល ឬបានចុះក្នុងកំនត់សម្គាល់របស់អ្នកប្រមូលព័ត៌មានថា គ្រូមកយឺតជាជាងការដាក់ថាគ្រូអវត្តមាន។

នៅក្នុងការរៀបចំការសិក្សា យើងបានប្រឹងប្រែងកាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់នៃ "ការរំពឹងទុករបស់អ្នកសង្កេត (observer-expectancy)" តាមរយៈមធ្យោបាយផ្សេងៗជាច្រើន។ ក្នុងកំឡុងពេលសន្ទនាដំបូង គ្រូបង្រៀន និងនាយកសាលា ត្រូវបានគេធានាអំពីការមិនបញ្ចេញឈ្មោះ នៅក្នុងការសិក្សានោះទេ។ ដើម្បីជៀសវាងនូវភាពលម្អៀងនៃសុពលភាពរបស់ព័ត៌មាន អ្នកស្រាវជ្រាវបានពិនិត្យផ្ទៀងផ្ទាត់ ទិន្នន័យបានពីប្រភពផ្សេងៗគ្នា ដូចជាការពិនិត្យតាមដានសៀវភៅសរសេររបស់សិស្ស របាយការណ៍ សាលារៀន និងការចុះសាលារៀន ដោយមិនជូនដំណឹងជាមុន។ គ្រូបង្រៀនក៏បាន ចូលរួមក្នុងការបញ្ជាក់ទិន្នន័យអំពីអវត្តមានរបស់ខ្លួនដែរ។ ចុងបញ្ចប់ ការរៀបចំការស្រាវជ្រាវត្រូវបានធ្វើឡើង ដោយផ្អែកទៅលើការតាមដានអាកប្បកិរិយានៃវត្តមានរបស់គ្រូបង្រៀនក្នុងរយៈពេល ៩ខែ ដែលក្នុងរយៈពេលនោះ ការចុះសាលារៀនដោយមិនផ្តល់ដំណឹងជាមុនត្រូវបានធ្វើឡើងជាច្រើនដងដោយមិនកំណត់ចំនួនជាក់លាក់។ ប្រសិនបើអ្នកចូលរួមផ្លាស់ប្តូរអាកប្បកិរិយារបស់ខ្លួន (ឧទាហរណ៍ខិតខំប្រឹងប្រែងមកបង្រៀនបានទៀងទាត់ជាងមុន ឬក៏

ចំណាយពេលបង្រៀនប្រចាំថ្ងៃវែងជាងមុន) នោះទន្លាប់ខិតខំប្រឹងប្រែងបង្រៀនទាំងនេះនឹងត្រូវនៅបន្តក្នុងរយៈពេលដ៏សំខាន់មួយ។

ដោយមើលឃើញច្បាស់ថា ការសិក្សានេះនឹងចាត់ទុកថាអត្រាវត្តមានរបស់គ្រូខ្ពស់គឺជាការល្អ និងអត្រាវត្តមានទាប គឺជាការមិនល្អយើងអាចធ្វើការសន្មតដោយជឿជាក់ថាអាកប្បកិរិយាណាមួយ ដែលគ្រូបង្រៀនបានផ្លាស់ប្តូរ និងនាំទៅរកការកែលម្អវត្តមានរបស់គ្រូក្នុងកំឡុងពេលនៃការសិក្សានេះ។ ដូច្នេះហើយចំណុចនេះ អាចបណ្តាលឱ្យមានអត្រាអវត្តមានរបស់គ្រូបង្រៀន ដែលរកឃើញក្នុងការសិក្សានេះនឹងមានលក្ខណៈទាបជាជាងមានលក្ខណៈខ្ពស់ជាងអ្វីដែលជាការពិតជាក់ស្តែង ។

## IV. លទ្ធផលរកឃើញសំខាន់ៗ និងការវិភាគ

ផ្នែកខាងក្រោមនេះបង្ហាញ និងវិភាគទៅលើលទ្ធផលរកឃើញសំខាន់ៗអំពីការបាត់ម៉ោងបង្រៀននៅថ្នាក់បឋមសិក្សាពីថ្នាក់ទី ៤ ដល់ទី ៦ នៅក្នុងឆ្នាំសិក្សា ២០១២/២០១៣ ស្ថានភាព និងមូលហេតុនៃការបាត់ម៉ោងបង្រៀន ព្រមទាំង ផលប៉ះពាល់ទៅលើការសិក្សារបស់សិស្សដូចដែលបានបង្ហាញនូវពិន្ទុក្នុងការ ធ្វើតេស្តមុខវិជ្ជាគណិតវិទ្យា និងភាសាខ្មែរ។ ការត្រួតពិនិត្យតាមដានគ្រូបង្រៀនពីសំណាក់នាយកសាលា និងថ្នាក់គ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា នឹងលើកយកមកពិភាក្សាផងដែរ។ ការពិភាក្សាអំពីបរិបទ ក៏ត្រូវបានធ្វើផងដែរ ដើម្បីផ្ដល់ជាពន្លឺបន្ថែមទៀតក្នុងការពិភាក្សាបញ្ហាបាត់ម៉ោងបង្រៀនក្នុងប្រទេសកម្ពុជា។

ការបាត់ម៉ោងបង្រៀនដែលបង្ហាញនៅក្នុងការសិក្សានេះនឹងចាត់ថ្នាក់ ជាបីប្រភេទខុសៗគ្នានៃការបាត់ម៉ោងបង្រៀនរបស់គ្រូបង្រៀន។

ប្រភេទទី ១: ការបាត់ម៉ោងបង្រៀនដោយសារថ្ងៃឈប់សម្រាកជាផ្លូវការបន្ថែមទៀត
ប្រភេទទី ២: ការបាត់ម៉ោងបង្រៀនដោយសារគ្រូបង្រៀនអវត្តមាន
ប្រភេទទី ៣: ការបាត់ម៉ោងបង្រៀនដោយសារគ្រូបង្រៀនមកបង្រៀនយឺត និង/ឬ ចេញមុនម៉ោង ហេតុដូច្នេះហើយពួកគាត់បង្រៀនមេរៀនតែក្នុងរយៈពេលខ្លី។ នៅក្នុងការសិក្សានេះ ការបាត់ម៉ោងប្រភេទនេះត្រូវបានចាត់ទុកថា "ម៉ោងបង្រៀនខ្លីជាងម៉ោងដែលបានកំនត់ (lessened contact hours)"។

ការបាត់ម៉ោងបង្រៀនសរុបនៅក្នុងការសិក្សានេះ ត្រូវបានគណនាដោយការបូកបញ្ចូលនូវចំនួនម៉ោងដែលបាត់នៅក្នុងចំណោមប្រភេទទាំងបីនេះ។ របៀបដែលយើងគណនាការបាត់ម៉ោងបង្រៀននឹងមានបង្ហាញនៅក្នុងផ្នែកខាងក្រោម។

### ៤.១ ការបាត់បង់ម៉ោងបង្រៀនដោយសារថ្ងៃឈប់សម្រាកជាផ្លូវការបន្ថែមទៀត

នៅឆ្នាំសិក្សា ២០១២/២០១៣ ថ្ងៃឈប់សំរាកមួយចំនួនដែលត្រូវបានបន្ថែមពីលើថ្ងៃឈប់សម្រាកសាធារណៈដែលបានកំណត់ប្រចាំឆ្នាំ គឺជាមូលហេតុចំបងមួយក្នុងចំណោមមូលហេតុចំបងនានាដែលធ្វើឱ្យមានការបាត់ម៉ោងបង្រៀននៅប្រទេសកម្ពុជា។ នៅក្នុងគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សា ២០០៥-២០០៩ គឺក្នុងមួយឆ្នាំសិក្សាមានចំនួន៣៨សប្ដាហ៍ ដែលត្រូវបានបែងចែកសម្រាប់ការបង្រៀន និងរៀន។ គ្រប់ថ្នាក់ទាំងអស់ត្រូវដំណើការពីថ្ងៃច័ន្ទ ដល់សៅរ៍ ដោយកំណត់យកថ្ងៃព្រហស្បតិ៍សម្រាប់សកម្មភាពបន្ថែមលើ កម្មវិធីសិក្សាមានដូចជាៈ កីឡា ដេរប៉ាក់ ពោងជាង ។ល។ ថ្ងៃព្រហស្បតិ៍មិនត្រូវបានចាត់ទុកជាម៉ោងបង្រៀន និងរៀនជាផ្លូវការនោះទេនៅក្នុងការសិក្សានេះ។ ដូច្នេះហើយ គេរំពឹងថាសិស្សត្រូវរៀនជាផ្លូវការតែរយៈពេល៥ថ្ងៃប៉ុណ្ណោះក្នុងមួយសប្ដាហ៍ ដែលសមមូលទៅនឹង១៩០ថ្ងៃក្នុងមួយឆ្នាំសិក្សា (៣៨ x ៥ថ្ងៃ)។ គេបានកត់សម្គាល់ឃើញថាចំនួនថ្ងៃបង្រៀនពិតប្រាកដដែលបានកំណត់ក្នុងប្រតិទិនសិក្សាឆ្នាំ២០១២/២០១៣ មានត្រឹមតែ១៨៦ ថ្ងៃប៉ុណ្ណោះ។

ទោះជាយ៉ាងណាក៏ដោយ ចំនួនថ្ងៃដែលសិស្សរៀនជាក់ស្តែងនៅក្នុងថ្នាក់ក្នុងមួយឆ្នាំសិក្សា គឺមានចំនួនតិចជាងនេះយ៉ាងខ្លាំងដោយសារតែមានថ្ងៃឈប់សម្រាកជាផ្លូវការបន្ថែមទៀតបន្ទាប់ពីបានកំនត់កាលបរិច្ឆេទឆ្នាំសិក្សារួច។ យោងតាមការពិនិត្យមើលប្រតិទិនសិក្សា (២០១២-២០ ១៣) បានបង្ហាញថា មានចំនួន១៤ថ្ងៃដែលសមមូលទៅនឹង៧០ម៉ោងសិក្សា (១៤ x ៥ម៉ោងសិក្សា/មួយថ្ងៃ) ឬស្មើនឹង៤៧ម៉ោង ត្រូវបានបាត់ដោយសារមានព្រឹត្តិការណ៍មួយចំនួនដូចជា កិច្ចប្រជុំអាស៊ាន ពិធីបុណ្យព្រះសពអតីតព្រះមហាក្សត្រ ប្រឡងឆមាសរបស់សិស្សថ្នាក់ទី៦ ប្រឡងជ្រើសរើសគ្រូនៅថ្នាក់ជាតិ និងការឈប់សម្រាកនៅមុនថ្ងៃបោះឆ្នោតជាតិ។ សាលាមួយចំនួនធំនៅតំបន់ទីក្រុងបានបិទទ្វាដោយសារគេយកធ្វើជាមណ្ឌលប្រឡង។

សិស្សពុំបានរៀននៅក្នុងថ្ងៃទាំងនោះទេ ដោយមានការឯកភាពក្នុងការបិទសាលារៀនជាផ្លូវការ។ ចំនួនថ្ងៃដែលបាត់ច្រើនជាងគេបំផុតគឺបិទសាលារៀនរយៈពេល៧ថ្ងៃក្នុងការបោះឆ្នោតជាតិឆ្នាំ២០១៣។ តារាងទី២បង្ហាញពីព្រឹត្តិការណ៍ និងរយៈពេលនៃថ្ងៃឈប់សម្រាកពេញមួយឆ្នាំសិក្សា ២០១២-២០១៣។ ឆ្នាំសិក្សា ២០១២/២០១៣ ត្រូវបានកាត់បន្ថយសល់តែ១៧២ថ្ងៃ (១៨៦ថ្ងៃ - ១៤ថ្ងៃ = ១៧២ថ្ងៃ)។ នេះគឺជាការកាត់បន្ថយចំនួន៨% នៃថ្ងៃសិក្សាប្រចាំឆ្នាំ។

តារាងទី ៥៖ ថ្ងៃបិទសាលាឈប់សំរាកជាផ្លូវការបន្ថែមទៀតក្នុងឆ្នាំសិក្សា ២០១២-២០១៣

| **ព្រឹត្តិការណ៍** | **កាលបរិច្ឆេទ** | **ខែ** | **ឆ្នាំ** | **សរុប** |
|---|---|---|---|---|
| កិច្ចប្រជុំអាស៊ាន | ១៩-២០ | វិច្ឆិកា | ២០១២ | ២ |
| ពិធីបុណ្យព្រះសពអតីតព្រះមហាក្សត្រ | ១ &៤ | កុម្ភៈ | ២០១៣ | ២ |
| ប្រឡងឆមាសសិស្សថ្នាក់ទី ៦ | ២២ | កុម្ភៈ | ២០១៣ | ១ |
| ប្រឡងជ្រើសរើសគ្រូនៅថ្នាក់ជាតិ | | វិច្ឆិកា | ២០១២ | ២ |
| ការឈប់សម្រាកនៅមុនថ្ងៃបោះឆ្នោតជាតិ | | កក្កដា | ២០១៣ | ៧ |
| **សរុប** | ១៤ | | | |

ជាការកត់សម្គាល់ផងដែរថា នៅពេលខ្លះមានការបិទសាលារៀនដោយសារថ្ងៃឈប់សំរាកជាផ្លូវការបន្ថែមនៅរៀងរាល់ឆ្នាំសិក្សានៅប្រទេសកម្ពុជា។ ចំនួនថ្ងៃសរុបនៃការឈប់សម្រាកដោយការបិទសាលារៀនដោយសារថ្ងៃឈប់សំរាកជាផ្លូវការ បន្ថែមនេះមានលក្ខណៈខុសគ្នាពីឆ្នាំសិក្សាមួយទៅឆ្នាំសិក្សាមួយទៀតអាស្រ័យទៅលើព្រឹត្តិការណ៍ផ្សេងៗដែលកើតមានក្នុងឆ្នាំសិក្សានីមួយៗ។ នៅក្នុងឆ្នាំសិក្សា ២០១១-២០១២ នាយកសាលាមួយចំនួនបានរាយការណ៍ថាមានការការបិទសាលារៀនដោយសារគ្រោះទឹកជំនន់ និងការឆ្លងរាលដាលជំងឺផ្តាសសាយបក្សី (H1N1)។ នៅក្នុងឆ្នាំសិក្សា ២០១៣/២០១៤ ការបិទសាលារៀនដោយមិនបានគ្រោងទុកនៅទូទាំងប្រទេសបានកើតឡើងដូចដែលបង្ហាញនៅក្នុងតារាងខាងក្រោម៖

តារាងទី៦៖ ថ្ងៃឈប់សំរាកជាផ្លូវការបន្ថែមទៀត នៅឆ្នាំសិក្សា ២០១៣/១៤

| **ព្រឹត្តិការណ៍** | **កាលបរិច្ឆេទ** | **ខែ** | **ឆ្នាំ** | **សរុប** |
|---|---|---|---|---|
| ប្រឡងឆមាសរបស់សិស្សថ្នាក់ទី ៦ | | កុម្ភៈ | ២០១៤ | ១ |
| បូកសរុបពិន្ទុប្រឡងសិស្សថ្នាក់ទី ៦ | | កុម្ភៈ | ២០១៤ | ១ |
| ប្រឡងជ្រើសរើសគ្រូនៅថ្នាក់ជាតិ | | | ២០១៣ | ២ |
| ប្រឡងថ្នាក់ជាតិសិស្សថ្នាក់ទី៩[3] | | កក្កដា | ២០១៤ | ២ |
| **សរុប** | **៦** | | | |

[3] សាលាបឋមសិក្សាមួយចំនួនដែលនៅជាមួយសាលាអនុវិទ្យាល័យត្រូវបានបិទទ្វា នៅពេលប្រឡងថ្នាក់ទី ៩ថ្នាក់ជាតិ ទោះជាមានសេចក្តីណែនាំលេខ ២១ ចេញដោយក្រសួងអប់រំ យុវជននិងកីឡា កាលពីឆ្នាំ២០១០ ហាមប្រាមមិនឱ្យប្រើប្រាស់សាលាដែលនៅជាប់ ឬជាមួយសាលាបឋមសិក្សាធ្វើជាមណ្ឌលប្រឡង។

ការប្រឡងឆមាសរបស់សិស្សថ្នាក់ទី៦ និងការប្រឡងជ្រើសរើសគ្រូថ្នាក់ជាតិគឺមានជារៀងរាល់ឆ្នាំ ដោយធ្វើឱ្យមានការបាត់ម៉ោងបង្រៀនអស់រយៈពេល៣ថ្ងៃ។ គេគួរតែរៀបចំធ្វើផែនការប្រតិទិនសិក្សា ប្រកបដោយប្រសិទ្ធភាពដើម្បីរៀបចំថ្ងៃឈប់សម្រាកជាផ្លូវការឱ្យត្រូវនឹងព្រឹត្តិការណ៍ដែលយើងដឹងជាមុន ដើម្បីធានាបានថាចំនួននៃថ្ងៃសិក្សាសរុបមាន ១៩០ថ្ងៃក្នុងមួយឆ្នាំសិក្សា។

## ៤.២ ការបាត់ម៉ោងបង្រៀនដោយសារគ្រូបង្រៀនអវត្តមាន

អវត្តមានរបស់គ្រូសំដៅលើស្ថានភាពដែលគ្រូមិនមកបង្រៀនសិស្សទៅតាមកាលវិភាគ ដោយមិនគិតពីមូលហេតុនៃអវត្តមានឡើយ។ ផ្នែកដ៏ធំបំផុតនៃការសិក្សាស្រាវជ្រាវនេះ គឺផ្តោតទៅលើការបាត់ម៉ោងបង្រៀននេះឯង។ តាមរយៈការពិនិត្យតាមដានសៀវភៅសរសេររបស់សិស្ស ការចុះទស្សនកិច្ចសាលារៀនដោយមិនផ្តល់ដំណឹងជាមុន និងការសម្ភាសជាមួយគ្រូ ក្រុមការងារអង្គការNEP តាមដានអត្រាអវត្តមានរបស់គ្រូដែលបានជ្រើសរើសជាផ្នែកមួយនៃការសិក្សានេះ។ គ្រូបង្រៀនត្រូវបានស្នើសុំឱ្យបញ្ជាក់អំពីចំនួនថ្ងៃដែលពួកគាត់មិនបានបង្រៀនតាមកាលវិភាគរបស់សាលារៀន និងផ្ទៀងផ្ទាត់អវត្តមានដែលបានបង្ហាញតាមរយៈការពិនិត្យ តាមដាន សៀវភៅសរសេររបស់សិស្ស និងការចុះទស្សនកិច្ចសាលារៀនដោយមិនផ្តល់ដំណឹងជាមុនរបស់អ្នកស្រាវជ្រាវ។ ប្រភពទិន្នន័យទាំងនេះត្រូវបានដាក់បញ្ចូលគ្នាដើម្បីគណនាអត្រាអវត្តមានរបស់គ្រូម្នាក់ៗ និងអត្រាអវត្តមាន ជាមធ្យមរបស់គ្រូបង្រៀននៅតាមក្រុមខុសៗគ្នា។ ទិន្នន័យនៃអត្រាអវត្តមានរបស់គ្រូដែលបានរកឃើញតាមរយៈការចុះពិនិត្យសាលារៀនដោយមិនផ្តល់ដំណឹងជាមុន និងតាមរយៈការសម្ភាសបានផ្តល់ជាលទ្ធផលខុសគ្នាបន្តិចបន្តួច ដោយសារតែការចុះទស្សនកិច្ចសាលារៀនដោយមិនផ្តល់ដំណឹងជាមុនត្រូវបានធ្វើឡើងជាញឹកញាប់នៅក្នុងពេលដែលសាលារៀនទំនងជាមិនសូវមានគ្រូមកបង្រៀន។

### ៤.២.១ ការចុះទស្សនកិច្ចសាលារៀនដោយមិនផ្តល់ដំណឹងជាមុន

ការចុះទស្សនកិច្ចសាលារៀនដោយមិនផ្តល់ដំណឹងជាមុនចំនួន១៧៣៣ដង ត្រូវបានធ្វើឡើងទៅលើថ្នាក់រៀនដែលបានជ្រើសរើស ដើម្បីផ្តល់ភស្តុតាងជាក់ស្តែងដែលជាផ្នែកមួយនៃការសិក្សានេះ។ ការចុះទស្សនកិច្ចសាលារៀន ដោយមិនផ្តល់ដំណឹងជាមុនបានចាប់ផ្តើមនៅខែធ្នូ ឆ្នាំ២០១២ និងបន្តពេញមួយឆ្នាំសិក្សារហូតដល់ខែកក្កដា ឆ្នាំ២០១៣ ដែលថ្ងៃនៃការចុះទស្សនៈសាលារៀនត្រូវបានជ្រើសរើសដាក់លាក់ ចំពោះថ្ងៃដែលមានភស្តុតាងបញ្ជាក់ថាសាលារៀនប្រហែលជាមិនបើកទ្វារដំណើរការ។ ដូច្នេះហើយភាគរយខ្ពស់ជាងគេនៃការធ្វើទស្សនកិច្ចសាលារៀន គឺមាននៅក្នុងខែកុម្ភៈ ក្នុងកំឡុងពេលបុណ្យចូលឆ្នាំចិន និងបុណ្យនៃក្តីស្រឡាញ់ និងនៅក្នុងខែឧសភា ចន្លោះរវាងបុណ្យចូលឆ្នាំខ្មែរ និងបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ ដូចដែលបង្ហាញក្នុងតារាងខាងក្រោម៖

តារាងទី៧ ៖

ចំនួនដងនៃការចុះទស្សនកិច្ចសាលារៀនដោយពុំផ្តល់ដំណឹងជាមុនតាមខែនីមួយៗ

| ឆ្នាំ | កាលបរិច្ឆេទ | ចំនួននៃការចុះទស្សនកិច្ចសាលារៀនដោយពុំផ្តល់ដំណឹងជាមុន | ភាគរយនៃការចុះទស្សនកិច្ចសាលារៀនដោយពុំមានផ្តល់ដំណឹងជាមុន |
|---|---|---|---|
| ២០១២ | ធ្នូ | ២៧៩ | ១៦% |
| ២០១៣ | មករា | ៤៦ | ៣% |
| | កុម្ភៈ | ៣៦២ | ២១% |
| | មីនា | ១៨៨ | ១១% |
| | មេសា | ៥៩ | ៣% |
| | ឧសភា | ៥៥២ | ៣២% |
| | មិថុនា | ២៤៤ | ១៤% |
| | កក្កដា | ៣ | 0% |
| សរុបរួម | | ១៧៣៣ | ១០០% |

ចំនួននៃការចុះទស្សនកិច្ចសាលារៀនដោយពុំមានជូនដំណឹងមានភាពខុសគ្នាពីគ្រូបង្រៀនម្នាក់ទៅម្នាក់ទៀត។ ក្នុងចំណោមគ្រូបង្រៀនចំនួន៣០៩នាក់នៅក្នុងសំណាកនេះ មានគ្រូចំនួន២៩១នាក់គឺដែលអ្នកសង្កេត បានចុះធ្វើទស្សនកិច្ច ដោយពុំមានផ្តល់ដំណឹងជាមុនចំនួនលើសពី៣ដង។ គ្រូចំនួន៦០%ត្រូវបានគេចុះទស្សនកិច្ចចំណួន៦ដង ឬលើសពីនេះ ដើម្បីពិនិត្យមើលពីវត្តមានរបស់ពួកគាត់។

រូបទី ៦ ៖ ចំនួននៃទស្សនកិច្ចសាលាដោយពុំមានផ្តល់ដំណឹងជាមុនទៅលើគ្រូបង្រៀននីមួយៗ




អត្រាអវត្តមានរបស់គ្រូបង្រៀនម្នាក់ៗមានភាពខុសប្លែកគ្នាយ៉ាងខ្លាំង។ គ្រូបង្រៀនចំនួន១៣៦នាក់ ឬស្មើនឹង៤៤%មានវត្តមាននៅរាល់ពេលការចុះទស្សនកិច្ចសាលារៀនដោយពុំមានផ្តល់ដំណឹងជាមុន។

គ្រូបង្រៀនចំនួន៥៦%ផ្សេងទៀតបានអវត្តមានយ៉ាងហោចណាស់ក៏ម្តងដែរ ដែលក្នុងនោះគ្រូបង្រៀនមួយចំនួនតូចបានអវត្តមាននៅរាល់ពេលចុះទស្សនកិច្ចសាលា។

តារាងទី៨ ៖ អត្រាអវត្តមានរបស់គ្រូបង្រៀនក្នុងអំឡុងពេលចុះទស្សនកិច្ចសាលាដោយពុំមានផ្តល់ដំណឹងជាមុន

| អត្រាអវត្តមាន | ចំនួនគ្រូបង្រៀន | ភាគរយសរុប | ភាគរយសរុបរួមទាំងអស់ |
|---|---|---|---|
| មិនដែលអវត្តមាន | ១៣៦ | ៤៤% | ៤៤% |
| ០ - ១០% | ០ | ០% | ៤៤% |
| ១១ - ២០% | ៥៨ | ១៩% | ៦៣% |
| ២១ - ៣០% | ៣១ | ១០% | ៧៣% |
| ៣១ - ៤០% | ២៦ | ៨% | ៨១% |
| ៤១ - ៥០% | ៣២ | ១០% | ៩២% |
| ៥១ - ៦០% | ៩ | ៣% | ៩៤% |
| ៦១ - ៧០% | ៦ | ២% | ៩៦% |
| ៧១ - ៨០% | ៣ | ១% | ៩៧% |
| ៨១ - ៩០% | ០ | ០% | ៩៧% |
| ៩១ - ១០០% | ៨ | ៣% | ១០០% |
| ៣០៩ | | | |

ក្នុងអំឡុងពេលនៃការចុះពិនិត្យភ្លាមៗដោយពុំមានជូនដំណឹង ១៩%គ្រូបង្រៀនបានអវត្តមានពីសាលារៀន។ វាមានសារៈសំខាន់ណាស់ក្នុងការចងចាំថាការជ្រើសរើសសំណាកសម្រាប់ការចុះទស្សនកិច្ចសាលារៀនដោយពុំមានផ្តល់ដំណឹងជាមុនត្រូវបានគេធ្វើឡើងដោយមានគោលបំណងច្បាស់លាស់។ ការចុះទស្សនៈកិច្ចសាលារៀនដោយពុំមានផ្តល់ដំណឹងជាមុន ជាញឹកញាប់ត្រូវបានគេរៀបចំឡើងនៅតាមថ្ងៃនានានៅពេលដែលគេសង្ស័យថាគ្រូបង្រៀននឹងអវត្តមាន ជាពិសេសក្នុងអំឡុងពេលជិតដល់ថ្ងៃឈប់សំរាកជាផ្លូវការដូចជាបុណ្យភ្ជុំបិណ្ឌ និងក្នុងអំឡុងពេល នៃពិធីបុណ្យផ្សេងៗដែលមិនមែនជាថ្ងៃឈប់សំរាករបស់សាលារៀនដូចជាបុណ្យចូលឆ្នាំចិន និងបុណ្យឆេងម៉េង[4]។ ទោះជាយ៉ាងណាក៏ដោយចំនួនដ៏ច្រើននៃការចុះទស្សនកិច្ចសាលារៀនក៏ត្រូវបានធ្វើឡើងនៅថ្ងៃរៀន"ធម្មតា"ដែរ ហើយគ្រូបង្រៀនចំនួន១២%ក្នុងចំណោមគ្រូបង្រៀន ទាំងអស់នេះត្រូវបានគេរកឃើញថាអវត្តមាននៅថ្ងៃធម្មតាទាំងនេះ។

គួរឱ្យកត់សំគាល់ផងដែរថា ក្នុងចំណោមគ្រូអវត្តមាននៅពេលក្រុមងារចុះទស្សនៈសាលា ដោយពុំមានផ្តល់ដំណឹងជាមុន គឺមានតែ២ដងទេដែលអ្នកស្រាវជ្រាវជឿជាក់ថា ថ្នាក់ដែលគ្រូអវត្តមានគឺបានបង្រៀនជំនួស

[4] ឆេងម៉េងគឺជាបុណ្យប្រពៃណីសែនជូនតារបស់ជនជាតិចិន

ដោយដោយគ្រូម្នាក់ផ្សេងទៀត។ បទពិសោធន៍ដែលមានលក្ខណៈទូទៅបំផុតនោះគឺថា ប្រសិនបើគ្រូបង្រៀនអវត្តមាន ពេលនោះថ្នាក់របស់គាត់ពុំមានអ្នកណាម្នាក់បង្រៀនជំនួសឡើយ។

រូបភាពខាងក្រោមនេះបង្ហាញពីកស្តុតាងនៃការបិទសាលារៀនក្នុងពេលបុណ្យចូលឆ្នាំចិននៅថ្ងៃទី៩ខែកុម្ភៈឆ្នាំ ២០១៣។

*រូបថតទី១៖ការចុះទស្សនកិច្ចសាលារៀនដោយពុំមានផ្តល់ដំណឹងជាមុននៅក្នុងថ្ងៃបុណ្យចូលឆ្នាំចិន ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ ២០១៣*



## ៤.២. គ្រូបង្រៀនផ្ទៀងផ្ទាត់ និងបញ្ជាក់ពីអវត្តមានរបស់ខ្លួន

ក្នុងពេលសម្ភាសន៍ជាមួយគ្រូបង្រៀន ដំបូងគ្រូបង្រៀនត្រូវបានគេស្នើសុំឱ្យប៉ាន់ស្មានពីកម្រិតនៃអវត្តមានរបស់ខ្លួន។ ជារួមគ្រូបង្រៀនភាគច្រើន(៥៨%)បានឱ្យដឹងថា ពួកគាត់អវត្តមានពីសាលារៀនម្តងក្នុងមួយខែ ឬ តិចជាងនេះ។ គ្រូបង្រៀនជិត១ភាគ៣ប្រាប់ឱ្យដឹងថាពួកគាត់មិនដែលអវត្តមានទេរៀងរាល់ខែ ប៉ុន្តែថាពួកគាត់អាចអវត្តមាននៅពេលណាមួយនៅក្នុងឆ្នាំសិក្សា។ ភាគរយគ្រូមួយចំនួនតូចបានឱ្យដឹងថាបានអវត្តមានមួយថ្ងៃរៀងរាល់សប្តាហ៍។

រូបទី៧៖ គ្រូបង្រៀនបញ្ជាក់ពីចំនួនថ្ងៃអវត្តមានក្នុង១ខែ



បន្ទាប់ពីគ្រូបង្រៀនបានប៉ាន់ស្មាននូវចំនួនថ្ងៃដែលបានឈប់ក្នុង១ខែរួចមក អ្នកស្រាវជ្រាវបានស្នើរឱ្យពួកគាត់បញ្ជាក់ ពីថ្ងៃឈប់ជាក់ស្តែងដែលគេប្រមូលបានតាមរយៈការពិនិត្យតាមដានសៀវភៅសរសេររបស់សិស្សដែលបង្ហាញពីថ្ងៃដែលគាត់បានអវត្តមាននៅក្នុងរយៈពេល៣ខែកន្លងមក។ ពួកគាត់ក៏ត្រូវបានគេស្នើសុំឱ្យបញ្ជាក់នូវមូលហេតុចំពោះអវត្តមានរបស់ខ្លួននៅក្នុងថ្ងៃទាំងនោះដែរប្រសិនបើពួកគាត់ទទួលស្គាល់ថា ពួកគាត់ពិតជាពុំមានវត្តមាននៅក្នុងសាលារៀននៅថ្ងៃទាំងនោះមែន។ **នៅពេលដែលទិន្នន័យនៃការចុះទស្សនកិច្ចសាលាដោយពុំមានផ្តល់ដំណឹងជាមុនត្រូវបានគេដាក់បន្ថែម ទៅលើទិន្នន័យនៃការសម្ភាសន៍គ្រូបង្រៀនរួចមក យើងបានរកឃើញថាជាមធ្យមគ្រូបង្រៀនអវត្តមានពីសាលារៀនចំនួន១៦ថ្ងៃ ដោយស្មើនឹងចំនួន១០.៥០%** នៃចំនួនថ្ងៃបង្រៀនដែលគេបានសង្កេតនៅក្នុងឆ្នាំសិក្សា ២០១២-១៣។ ហេតុដូច្នេះហើយអវត្តមានដែលបានបញ្ជាក់ដោយគ្រូបង្រៀននៅក្នុងការសិក្សានេះមានចំនួនខ្ពស់ជាងអត្រាអវត្តមានដែលគ្រូបង្រៀនបានប៉ាន់ស្មានពីដំបូងឆ្ងាយណាស់។ បើយកតាមអត្រាអវត្តមានជាមធ្យម ១០.៥% ក្នុងមួយឆ្នាំសិក្សាដែលមានចំនួនថ្ងៃបង្រៀន ១៨៦ថ្ងៃនៅក្នុងឆ្នាំសិក្សា២០១៣-១៤នោះ ពេលនោះ**អវត្តមានរបស់គ្រូនឹងមានចំនួននៃការបាត់បង់ថបង្រៀនជាមធ្យមចំនួន១៩.៥ថ្ងៃ ឬម៉ោងបង្រៀនចំនួន៧៨ម៉ោង។**

តារាងខាងក្រោមបង្ហាញពីភាពខុសគ្នាយ៉ាងច្រើនក្នុងចំណោមគ្រូបង្រៀនដែលគេបានសង្កេត។ គ្រូបង្រៀនចំនួន២៣% បានអវត្តមានតិចជាង៥% នៃកាលវិភាគបង្រៀនរបស់ខ្លួន។ ចំណុចនេះគឺជាសញ្ញាវិជ្ជមានមួយដែលចង្អុលបង្ហាញថាមេរៀនភាគច្រើនត្រូវបានគេបង្រៀនដល់សិស្ស។ ទោះជាយ៉ាងណាក៏ដោយការព្រួយបារម្ភមួយបានកើតមានឡើងដោយសារតែគ្រូបង្រៀនចំនួន៣២នាក់(១១%) បានបញ្ជាក់ពីអវត្តមានពីថ្នាក់របស់ខ្លួនចំនួន១ភាគ៥នៃកាលវិភាគឆ្នាំសិក្សា ហើយគ្រូបង្រៀន២នាក់បានបញ្ជាក់ពីការខកខានបង្រៀនស្មើរតែ១ភាគ៣នៃកាលវិភាគថ្នាក់របស់ខ្លួន។

តារាងទី៩៖ អត្រាអវត្តមានរបស់គ្រូបង្រៀន៖ ទិន្នន័យរួមបញ្ចូលគ្នាដែលគ្រូបង្រៀនខ្លួនឯងបានបញ្ជាក់ថាអវត្តមាន

| អវត្តមានរបស់គ្រូបង្រៀន | ភាគរយ |
|---|---|
| អត្រាអវត្តមានរបស់គ្រូបង្រៀនជាមធ្យម | ១០.៥០ % |
| អត្រាអវត្តមានរបស់គ្រូបង្រៀនជាអតិបរមា | ៣១% |
| អត្រាអវត្តមានរបស់គ្រូបង្រៀនជាអប្បបរមា | ១% |
| % នៃអត្រាអវត្តមានរបស់គ្រូបង្រៀន <៥% | ២៣ % |
| % របស់គ្រូបង្រៀនដែលមានអត្រាអវត្តមាន >២០% | ១១% |

រូបទី ៨៖ របាយអត្រាអវត្តមានរបស់គ្រូ




### ៤.២.៣ មូលហេតុដែលគ្រូបង្រៀនបានបញ្ជាក់ចំពោះអវត្តមានរបស់ខ្លួន

នៅពេលដែលទិន្នន័យបញ្ជាក់ពីអវត្តមានរបស់គ្រូបង្រៀនម្នាក់ៗ ត្រូវបានប្រមូលរួចមក គ្រូបង្រៀនត្រូវបានគេសម្ភាសន៍និងសុំឱ្យបញ្ជាក់ពីមូលហេតុដែលបណ្តាលឱ្យអវត្តមាននៅថ្ងៃទាំងអស់ដែលគ្រូបានទទួលស្គាល់ថាពិតជាបានអវត្តមានមែន។ ការសម្ភាសន៍គ្រូបង្រៀនក៏បានសួរព័ត៌មានពីស្ថានភាពប្រជាសាស្ត្រផងដែរ ដែលពត៌មានទាំងនោះគឺសម្រាប់ប្រើប្រាស់នៅក្នុងការវិភាគបន្តបន្ទាប់មកទៀត ព្រមទាំងសួរពីការយល់ឃើញផ្ទាល់របស់គ្រូបង្រៀនចំពោះអត្រាអវត្តមានរបស់ខ្លួនពីសាលារៀន។

## មូលហេតុក្នុងការអវត្តមានរបស់គ្រូបង្រៀន

នៅក្នុងការសម្ភាសន៍ជាមួយគ្រូបង្រៀនស្តីពីអវត្តមានរបស់ពួកគាត់ពីសាលារៀន មានមូលហេតុលំអិតជាច្រើនដែលគ្រូបានលើកឡើង។ មូលហេតុទាំងនេះត្រូវបានគេចាត់ចំណាត់ថ្នាក់ជាបន្តបន្ទាប់ទៅតាមប្រភេទធំៗចំនួន៧ ដូចតទៅ ៖

- មូលហេតុដែលអវត្តមានទាក់ទងនឹងសកម្មភាពរកប្រាក់ចំណូល៖ គឺសំដៅទៅលើគ្រូបង្រៀនអវត្តមានពីសាលា ដើម្បីចូលរួមក្នុងសកម្មភាពរកប្រាក់ចំណូល ឬធ្វើការងារទី២ - ឧទាហរណ៍ ដកស្ទូង ការប្រមូលផល និងការចាត់ចែងមុខជំនួញផ្សេងទៀត។
- ការទទួលខុសត្រូវក្នុងគ្រួសារ ៖ គឺសំដៅទៅលើគ្រូបង្រៀនអវត្តមានពីសាលាដើម្បីមើលថែសមាជិកគ្រួសារដូចជា មើលថែកូន នាំសមាជិកគ្រួសារទៅមន្ទីរពេទ្យ ឬនាំកូនទៅសាលារៀន។
- បេសកកម្មជាផ្លូវការ ៖ គឺសំដៅទៅលើគ្រូបង្រៀនអវត្តមានពីសាលាដើម្បីបំពេញភារកិច្ចផ្នែកវិជ្ជាជីវៈផ្សេងៗទៀតរបស់ខ្លួនក្រៅពីការបង្រៀន។ ចំណុចនេះរាប់បញ្ចូលទាំងការចូលរួមប្រជុំ វគ្គបណ្តុះ

បណ្ណាល សិក្ខាសាលា ទស្សនកិច្ចសិក្សា ទទួលបដិសណ្ឋារកិច្ចគណៈប្រតិភូនានា និងភារកិច្ចផ្សេងៗ ទៀតដែលត្រូវបានចាត់តាំងដោយនាយកសាលា ឬ គណៈគ្រប់គ្រងសាលារៀន។

- មូលហេតុផ្ទាល់ខ្លួន៖ គឺសំដៅទៅលើគ្រូបង្រៀនអវត្តមានជាបឋមដោយសារផលប្រយោជន៍ ឬហេតុផលផ្ទាល់ខ្លួន ដូចជាការបន្តការសិក្សារបស់គាត់ ឈឺទៅពិនិត្យសុខភាព និងប្រឡងចូលមហាវិទ្យា-ល័យជាដើម។ នៅតំបន់មួយចំនួន គ្រូបង្រៀនបានអវត្តមានដើម្បីដំណើរការប្លង់ដីរបស់ខ្លួន ឬរៀបការ។
- ពិធីបុណ្យផ្សេងៗ៖ គឺសំដៅទៅលើគ្រូបង្រៀនអវត្តមានដើម្បីទៅចូលរួមពិធីបុណ្យផ្សេងៗដូចជាពិធីមង្គលការរបស់មិត្តភ័ក្រឬសាច់ញាតិ ពិធីបុណ្យសព បុណ្យកឋិនទាន[5] និងពិធីបុណ្យសាសនាផ្សេងៗទៀត។ សាលារៀនភាគច្រើនដែលបានសិក្សានៅរាជធានីភ្នំពេញបានរៀបចំពិធីសូត្រមន្តនៅសាលារៀននៅមុនពេលចាប់ផ្តើម វិសមកាលតូចនៅក្នុងខែមេសា។ ពិធីសូត្រមន្តដូចនេះក៏ត្រូវបានចាត់ទុកជាពិធីបុណ្យដែរ។
- ទម្លាប់ជាទូទៅ ៖ គឺសំដៅទៅលើគ្រូបង្រៀនអវត្តមានដោយយល់ឃើញថាសាលារៀនរបស់ខ្លួននឹងមិនបើកទ្វារ ឬ ថាមានគ្រូបង្រៀន និងសិស្សតែ២-៣នាក់ប៉ុណ្ណោះនៅសាលារៀននៅក្នុងថ្ងៃមួយជាក់លាក់មួយចំនួន។ ចំណុចនេះរាប់បញ្ចូលទាំងការចាប់ផ្តើមឆ្នាំសិក្សាយឺត (បន្ទាប់ពីពិធីបុណ្យភ្ជុំបិណ្ឌ) ពិធីបុណ្យ នានាដែលមិនមែនជាថ្ងៃឈប់សម្រាកជាផ្លូវការរបស់សាលារៀន និងការបន្តការបិទសាលារៀននៅជុំវិញថ្ងៃឈប់សម្រាកជាផ្លូវការ - ឧទាហរណ៍ ការបិទសាលារៀននៅថ្ងៃច័ន្ទ ប្រសិនបើថ្ងៃឈប់សម្រាក ត្រូវនឹងថ្ងៃអង្គារ៍។ វាមានសារៈសំខាន់ណាស់ក្នុងការកត់សម្គាល់ថា គ្រូបង្រៀនអាចប្រើប្រាស់ថ្ងៃអវត្តមានទាំងនេះដើម្បីធ្វើសកម្មភាពផ្សេងៗទៀតដូចជា ការដាំដុះ ការចូលរួមពិធីបុណ្យផ្សេងៗទៀត ឬការមើលថែសមាជិកគ្រួសារ។
- មិនដឹង ៖ គឺសំដៅទៅលើគ្រូបង្រៀនអវត្តមាន តែមិនអាចចាំបានពីមូលហេតុដែលខ្លួនបានអវត្តមាននោះ ឬ ពុំចង់បញ្ជាក់ពីមូលហេតុដែលខ្លួនអវត្តមាន។

ការសម្ភាសបានបង្ហាញថាអវត្តមានរបស់គ្រូបង្រៀនភាគច្រើនលើកឡើងពួកគាត់ផ្ទាល់ គឺអនុវត្តជាទូទៅក្នុងចំណោមគ្រូបង្រៀន(៤៨%នៃអវត្តមាន) បន្ទាប់មកគឺហេតុផលផ្ទាល់ខ្លួន(១៦%) មិនដឹងហេតុផល(១៣%) បេសកកម្មជាផ្លូវការ(១០%) និងពីធីបុណ្យផ្សេងៗ(៨%) (សូម មើលរូបទី៩)។

[5] បុណ្យកឋិនគឺជាបុណ្យដែលគេរៀបចំធ្វើឡើងដើម្បីវេរអង្គាសចីវរកាកសាងវត្តអារាម

រូបទី ៩៖ មូលហេតុដែលនាំឱ្យគ្រូអវត្តមាន




ដូចដែលបានបង្ហាញនៅក្នុងរូបទី៩ "ទម្លាប់ជាទូទៅ" គឺជាមូលហេតុដែលគេបានលើកឡើងញឹកញាប់បំផុត ចំពោះអវត្តមានរបស់គ្រូបង្រៀន។ "ទម្លាប់ជាទូទៅ" ចង្អុលបង្ហាញនូវស្ថានភាពមួយដែលគ្រូបង្រៀន និងតាមការអះអាងរបស់សហគមន៍យល់ឃើញថាសាលារៀនមិនបើកទ្វានៅតាមថ្ងៃជាក់លាក់នានានៅមុន ឬក្រោយពិធីបុណ្យ ឬព្រឹត្តិការណ៍ពិសេសៗផ្សេងៗទោះបីជាពិធីបុណ្យសាសនាឬ មិនមែនសាសនាក៏ដោយ ដូចជាពិធីបុណ្យភ្ជុំបិណ្ឌ និងពិធីបុណ្យចូលឆ្នាំខ្មែរ។ គ្រូបង្រៀនបានពន្យល់ថានៅក្នុងអំឡុងពេលទាំងនេះ សិស្សប្រហែលជាអាចឈប់សំរាក ហើយថាសិស្សជាច្រើនមិនមករៀនទេ។ ចំណុចនេះមានផលប៉ះពាល់ជាខ្លាំងទៅលើវត្តមានរបស់គ្រូបង្រៀននិងសិស្សនៅសាលារៀន ហើយការសម្ភាសជាមួយគ្រូបង្រៀនបានរកឃើញថា អវត្តមាននេះគឺជាការអនុវត្ត ដែលបានចាក់ឫសគល់យ៉ាងជ្រៅ។ ភស្តុតាងដែលបានពីទិន្នន័យបង្ហាញថាអវត្តមានរបស់គ្រូបង្រៀនដែលជា "ទម្លាប់ជាទូទៅ" គឺទំនងជាកើតមានឡើងនៅក្នុងអំឡុងពេលជាក់លាក់ ៖

- ថ្នាក់រៀនជាទូទៅមិនត្រូវបានគេបង្រៀនទេនៅមុនពេលពិធីបុណ្យភ្ជុំបិណ្ឌ។ទិន្នន័យបង្ហាញថា ថ្នាក់រៀនដែលគេសង្កេតចំនួន១៩%បានបិទទ្វារហូតដល់៥ថ្ងៃឬលើសពីនេះក្នុងអំឡុងពេល២សប្តាហ៍ដំបូងនៃឆ្នាំសិក្សា (ពោលគឺនៅមុនពិធីបុណ្យភ្ជុំបិណ្ឌបន្តិច)។
- វិស្សមកាលតូចក្នុងខែមេសាតាមធម្មតាមានរយៈពេលយូរជាងរយៈពេលកំណត់នៅក្នុងគោលនយោបាយរបស់រដ្ឋាភិបាលស្តីពីថ្ងៃឈប់សំរាករបស់ជាតិ។ ថ្នាក់រៀនដែលបានសង្កេតចំនួន៨១% បានបន្តការឈប់សម្រាកយ៉ាងហោចណាស់ក៏២ថ្ងៃដែរ។
- ម៉ោងបង្រៀននៅថ្ងៃដែលនៅចន្លោះរវាងថ្ងៃឈប់សំរាកនានាជាពិសេសត្រូវនឹងថ្ងៃសៅរ៍ត្រូវបានគេលុបចោលជារឿយៗ។
- ពិធីបុណ្យចូលឆ្នាំចិនមិនមែនជាថ្ងៃឈប់សម្រាកជាផ្លូវការទេ ប៉ុន្តែជារឿយៗសាលារៀនត្រូវបានបិទ្វា

លទ្ធផលនានាបានបង្ហាញថា ហេតុផលផ្ទាល់ខ្លួនត្រូវបានគេលើកពណ៌ឡើងថា ជាមូលហេតុចំពោះអវត្តមានរបស់គ្រូបង្រៀន ញឹកញាប់បំផុតលំដាប់ទី២។ គ្រូបង្រៀនក៏រាយការណ៍ដែរពីអវត្តមាន ពីសាលារៀនទាំងដោយសារហេតុផលទាក់ទងនឹងការសិក្សា ឬដោយសារមានជម្ងឺ ឬទៅពិនិត្យសុខភាព។ នៅតាមតំបន់មួយចំនួន គ្រូបង្រៀនអវត្តមាន ដើម្បីទៅធ្វើប័ណ្ណកម្មសិទ្ធិដីធ្លីរបស់ខ្លួន និងរៀបមង្គលការ។ ការសិក្សាពីប្រសិទ្ធិភាពនៃម៉ោងបង្រៀនដែលអង្គការNEP បានចេញផ្សាយនៅឆ្នាំ២០០៥ បានរកឃើញថា ហេតុផលដែលគេលើក

ឡើងជាញឹកញាប់បំផុតចំពោះអវត្តមានគ្រូ គឺដោយសារគ្រូបង្រៀន មានជម្ងឺ ដែលចំណុចនេះស្ថិតនៅក្រោមប្រភេទ"ហេតុផលផ្ទាល់ខ្លួន" នៅក្នុងការសិក្សានេះ។ ទោះជាយ៉ាងណាក៏ដោយ ការសិក្សាពីមុនមកបានពិនិត្យមើលនៅក្នុងរយៈពេលតែ៣ខែប៉ុណ្ណោះ ហើយមិនបានសិក្សាពីខែតុលា និងខែមេសាដែលយើងបានរកឃើញនូវការបិទសាលារៀន ដោយសារមូលហេតុ "ទម្លាប់ជាទូទៅ" យ៉ាងច្រើននៅក្នុងការសិក្សាថ្មីនេះទេ។

គ្រូបង្រៀនមួយចំនួនក៏បានលើកឡើងថាបានអវត្តមានដោយសារចុះ បេសកកម្មជាផ្លូវការ ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលបច្ចេកទេស ឬសិក្ខាសាលាផ្សេងៗ។ ទោះជាយ៉ាងណាក៏ដោយ ការអវត្តមានដោយសារហេតុផលនេះហាក់ដូចជា មានកម្រិតទាបមែនទែន ដោយមានប្រមាណជា១០% ប៉ុណ្ណោះនៃអវត្តមាន គ្រូទាំងអស់។ ទោះជាយ៉ាងណាក៏ដោយ វាមានសារៈសំខាន់ណាស់ក្នុងការកត់សំគាល់ផងដែរ ថានៅពេលវេលាទាំងនេះមិនមែនជាពេលវេលាធម្មតាសម្រាប់ការចុះឧស្សនកិច្ចសាលារៀនដោយពុំមានផ្តល់ដំណឹងជាមុន ដើម្បីរកឱ្យឃើញថាមានការរៀបចំការបង្រៀនជំនួសផ្សេងទៀតត្រូវបានគេធ្វើឡើងសម្រាប់ថ្នាក់បង្រៀននានានោះទេ។

នៅពេលដែលគ្រូបង្រៀនត្រូវបានគេបញ្ជូនឱ្យទៅបំពេញបេសកកម្មជាផ្លូវការ ជាទូទៅថ្នាក់រៀនរបស់ពួកគាត់គឺត្រូវបានបិទទ្វារ។

លទ្ធផលបានបង្ហាញឱ្យឃើញ អវត្តមានគ្រូដែលទាក់ទងនឹងសកម្មភាពរកប្រាក់ចំណូលគឺមានតែ២%ប៉ុណ្ណោះ ។ វាមានសារៈសំខាន់ណាស់ក្នុងការបញ្ជាក់ថា ការមានការងារបន្ថែមមួយទៀតគឺត្រូវបានគេហាមឃាត់ជាផ្លូវការចំពោះគ្រូបង្រៀននៅក្នុងប្រទេសកម្ពុជា ហេតុដូច្នេះហើយគ្រូបង្រៀនអាចជំរុញទឹកចិត្តក្នុងការលើកយកនូវមូលមូលហេតុផ្សេងៗទៀតមកបញ្ជាក់ថាជាមូលហេតុនៃអវត្តមានរបស់ខ្លួន។ ភស្តុតាងពីការសម្ភាសលើកឡើងថា ការរកចំណូលផ្សេងទៀតគឺជាអទិភាពមួយសម្រាប់គ្រូបង្រៀនជាច្រើននៅក្នុងការសិក្សានេះ។ អត្រាប្រេវ៉ាឡង់ទាបនៃអវត្តមានរបស់គ្រូបង្រៀនដោយសារកត្តាទាក់ទងនឹងប្រាក់ចំណូលមាន ភាពខុសគ្នាពីការរកឃើញតាមរយៈការស្រាវជ្រាវរបស់អង្គការNEPនៅឆ្នាំ២០០៥ ដែលការស្រាវជ្រាវនោះបានរកឃើញថា កត្តានេះគឺជាហេតុផលចំបងទី២ចំពោះអវត្តមានរបស់គ្រូបង្រៀន។ ដោយសាររបៀបនៃការចាត់ថ្នាក់ពត៌មានមានភាពខុសគ្នាត្រូវបានគេប្រើប្រាស់នៅក្នុងការសិក្សាទាំងពីរនេះ ដូច្នេះយើងមិនអាចសន្និដ្ឋានថាអវត្តមានដោយសារកត្តាដែលទាក់ទងនឹងសកម្មភាពរកប្រាក់ចំណូលបានថយចុះនោះទេ ជាពិសេសការសិក្សានៅឆ្នាំ២០០៥ពុំបានដាក់បញ្ចូលការបិទទ្វារសាលារៀនទាំងមូលទៅក្នុងមូលហេតុ "ទម្លាប់ជាទូទៅ" ទេ។ មានភស្តុតាងផ្សេងទៀត ឧទាហរណ៍ការសិក្សារបស់អង្គការNEP នៅឆ្នាំ២០១២ ទៅផលប៉ះពាល់នៃគ្រឿងលើកទឹកចិត្តគ្រូបង្រៀន បានបង្ហាញថាវាគឺជារឿងទូទៅបំផុតមួយ ដែលគ្រូបង្រៀននៅកម្ពុជាមានមុខរបរទី២បន្ថែមទៀត។ នៅក្នុងការសិក្សានេះ គ្រូចំនួន៦៥%បានឱ្យដឹងថាពួកគាត់មានមុខរបរផ្សេងទៀត ឬក៏ធ្វើអាជីវកម្មទន្ទឹមនឹងការងារបង្រៀនរបស់គាត់។ភាគរយអវត្តមានគ្រូដោយសារកត្តាដែលទាក់ទងនឹងសកម្មភាពរកប្រាក់ចំណូល គឺទំនងជាទាបជាងការពិត ទោះជាយ៉ាងណាក៏ដោយ វាជាការគួឱ្យចាប់អារម្មណ៍ដែលមានគ្រូបង្រៀនចំនួនតិចតួចប៉ុណ្ណោះដែលបានរាយការណ៍ពីអវត្តមានពីសាលារៀន ដើម្បីស្វែងរកប្រាក់ចំណូលផ្សេងៗទៀត។

មានភាពខុសគ្នាតិចតួចរវាងហេតុផលនានាដែលគេផ្តល់ឱ្យចំពោះអវត្តមានគ្រូនៅតាមតំបន់ជនបទនិងទីប្រជុំជនទោះបីជាគ្រូបង្រៀននៅតំបន់ទីប្រជុំជនមួយចំនួនតូចបានរាយការណ៍ពីអវត្តមានចំពោះមូលហេតុទាក់ទងទៅនឹងសកម្មភាពរកប្រាក់ចំណូល (០,៤%នៃអវត្តមាននៅក្នុងតំបន់ទីប្រជុំជនដោយប្រៀបធៀបទៅនឹង ៣,៣% នៃអវត្តមាននៅតំបន់ជនបទ)។ ភស្តុតាងពីការសម្ភាសបានលើកឡើងថាគ្រូបង្រៀននៅទីប្រជុំជនមានលទ្ធភាពច្រើន ក្នុងការរកប្រាក់ចំណូលបន្ថែមតាមរយៈការបង្រៀនគួរនៅក្នុងសាលារៀន ដែលទំនងជាមាន

វត្តមានច្រើននៅក្នុងសាលារៀន ហើយដែលខុសពីការដាំដុះ ឬ សកម្មភាពមុខជំនួញផ្សេងៗទៀតនៅតំបន់ជនបទ។

**ការទទួលខុសត្រូវនៅក្នុងគ្រួសារ**មានចំនួន៣%នៃអវត្តមានគ្រូ។ គ្រូបង្រៀនដែលបានសម្ភាសចំនួន៣៨% បាននិយាយថា ពួកគាត់គឺជាអ្នកមើលថែកូនជាចំបងនៅក្នុងគ្រួសារ។ មានគ្រូបង្រៀនជាងពាក់កណ្ដាលបន្ដិច តែប៉ុណ្ណោះក្នុងចំណោមគ្រូបង្រៀនទាំងនេះបាននិយាយថា ការមើលថែកូនជាចម្បងនេះធ្វើឱ្យមានផលប៉ះពាល់ខ្លះៗទៅដល់វត្តមាន និងពេលវេលាមកបំពេញការងាររបស់គាត់នៅក្នុងកម្រិតណាមួយដែរ។ ហើយថាពួកគាត់អាចមកបង្រៀនយឺតដោយសារត្រូវជូនកូនៗទៅសាលារៀន ហើយត្រូវចេញមុនម៉ោងដើម្បីទៅទទួលកូនៗទៅផ្ទះវិញ។

### ៤.២.៤ ការវិភាគ ៖ និន្នាការអវត្តមានរបស់គ្រូបង្រៀន

និន្នាការច្បាស់លាស់ចំនួន២ត្រូវបានគេរកឃើញទាក់ទងនឹងលក្ខណៈនៃអវត្តមានរបស់គ្រូបង្រៀននៅក្នុងការសិក្សានេះ។ និន្នការទី១ទាក់ទងនឹងពេលវេលានៃអវត្តមានគ្រូគឺទៅតាមព្រឹត្តិការណ៍នានា និងទី២ទាក់ទងនឹងអវត្តមានព្រមគ្នាក្នុងពេលតែមួយរវាងនាយកសាលា និងគ្រូបង្រៀន។

### អវត្តមានក្នុងថ្ងៃដែលមិនមែនជាថ្ងៃឈប់សម្រាកក្រៅផ្លូវការ និងក្នុងរយៈពេល"ជិតដល់ថ្ងៃឈប់សម្រាក"

ទិន្នន័យដែលបានមកពីការចុះទស្សនកិច្ចសាលាដោយពុំផ្ដល់ដំណឹងជាមុន បានរកឃើញថាគ្រូបង្រៀនទំនងជាអវត្តមានជាពិសេសនៅក្នុងអំឡុងពេលបុណ្យចូលឆ្នាំចិន និងនៅក្នុងពេល"ជិតដល់ថ្ងៃឈប់សម្រាក"($\chi^២$= ១៣១.៥០, df = ៤, p< .០០១) (សូមមើលរូបទី១០)។ ក្នុងរយៈពេល "ជិតដល់ថ្ងៃឈប់សម្រាក" គឺយើងសំដៅទៅលើថ្ងៃរៀនជាផ្លូវការដែលកៀកទៅនឹងថ្ងៃឈប់សម្រាករបស់សាលារៀន។ ថ្ងៃដែលគ្រូបង្រៀន អវត្តមានច្រើនបំផុតក្នុងពេលចុះទស្សនកិច្ចដោយពុំមានការផ្ដល់ដំណឹងជាមុន គឺនៅថ្ងៃបុណ្យចូលឆ្នាំចិន ពោលគឺជាថ្ងៃដែលមិនមែនជាថ្ងៃឈប់សម្រាកជាផ្លូវការនៅក្នុងប្រទេសកម្ពុជាទេ។ អវត្តមានរបស់គ្រូបង្រៀនក៏កើតឡើងជាញឹកញាប់ផងដែរនៅថ្ងៃផ្សេងៗកៀកនឹងថ្ងៃឈប់សម្រាកដូចជាថ្ងៃបុណ្យសែនផ្នូរ និងពិធីបុណ្យចូលឆ្នាំខ្មែរ ដែលជាពិធីបុណ្យប្រារព្ធធ្វើឡើងនៅពាក់កណ្ដាលខែដំបូងនៃខែមេសា។ នេះឆ្លុះបញ្ចាំងនូវទិន្នន័យទទួលបានពីការសម្ភាសគ្រូបង្រៀន ដែលបានចង្អុលបង្ហាញថា ទម្លាប់ជាទូទៅគឺជាហេតុផលញឹកញាប់បំផុតចំពោះអវត្តមានរបស់គ្រូបង្រៀន ហើយកាលបរិច្ឆេទដែលគ្រូបង្រៀនលើកឡើងថាជាទម្លាប់ទូទៅគឺកាលបរិច្ឆេទកៀកនឹងថ្ងៃឈប់សម្រាកជាផ្លូវការ ឬមិនផ្លូវការនៅក្នុងប្រទេសកម្ពុជា។ គ្រូបង្រៀនជិតពាក់កណ្ដាលបានអវត្តមាននៅថ្ងៃដែលគេចុះទស្សនកិច្ចសាលារៀនទដោយពុំមានផ្ដល់ដំណឹងជាមុនក្នុងអំឡុងពេលបុណ្យចូលឆ្នាំចិន (អវត្តមានចំនួន៧៤ក្នុងចំណោមការចុះទស្សនកិច្ចសាលាដោយពុំមានផ្ដល់ដំណឹងជា មុន ចំនួន១៥៨លើក)។ ៣០%នៃការចុះទស្សនកិច្ចសាលាដោយពុំមានដំណឹងជាមុនបានរកឃើញថា សាលារៀនទាំងមូលត្រូវបានបិទទ្វារ។

ក្នុងអំឡុងពេលថ្ងៃរៀនធម្មតា ចំនួនគ្រូបង្រៀនដែលអវត្តមាននៅថ្ងៃដែលគេចុះទស្សនកិច្ចសាលាដោយពុំមានផ្តល់ដំណឹងជាមុន គឺមានកម្រិតទាប ដោយមានតែ១២%[6] ប៉ុណ្ណោះ ។ ទោះជាយ៉ាងនេះក្តី ភាគរយនៃអវត្តមាននេះនៅតែមានកម្រិតខ្ពស់នៅឡើយ ប៉ុន្តែមានបញ្ហាច្បាស់លាស់មួយចំពោះវត្តមានរបស់គ្រូបង្រៀននៅថ្ងៃជាក់លាក់នានានៅក្នុងឆ្នាំ។

រូបទី១០ ៖ អវត្តមានរបស់គ្រូបង្រៀនតាមពេលវេលាក្នុងឆ្នាំ




| | ចូលឆ្នាំចិន | ថ្ងៃគ្រីស្តម៉ាស | កៀកថ្ងៃសំរាក | ថ្ងៃធម្មតា | ថ្ងៃនៃក្តីស្រឡាញ់ |
|---|---|---|---|---|---|
| គ្រូអវត្តមាន | 47% | 10% | 16% | 12% | 5% |
| គ្រូមកបង្រៀន | 53% | 90% | 84% | 88% | 95% |

## អវត្តមានរបស់នាយកសាលា និងសាលារៀនបិទទ្វា

វាមានសារៈសំខាន់ដូចគ្នាដែរ ការចុះទស្សនកិច្ចសាលាដោយពុំមានផ្តល់ដំណឹងជាមុនបានរកឃើញថា អវត្តមានក្នុងចំណោមគ្រូបង្រៀន មានខ្ពស់នៅពេលដែលនាយកសាលាពុំមានវត្តមាននៅសាលារៀន($\chi^{២}$= ៦៤៥.៤១, df= ១, p<.០០១)(សូមមើល រូបទី១១)។ នៅក្នុងការចុះទស្សនកិច្ចសាលាដែលគេបានធ្វើឡើង គ្រូបង្រៀនដែលអវត្តមានមានចំនួន៦%នៅក្នុងពេលដែលនាយកសាលាមានវត្តមាននៅសាលា។ គ្រូបង្រៀនចំនួន៦៨% បានអវត្តមាននៅថ្ងៃដែលគេចុះធ្វើទស្សនកិច្ចសាលាដោយមិនមានផ្តល់ដំណឹងជាមុន ហើយពេលនោះនាយកសាលាក៏អវត្តមានដែរ។

---

[6] អ្នកប្រមូលទិន្នន័យពុំបានកត់ត្រាទុកនូវប្រភេទថ្ងៃមួយចំនួនដែលខ្លួនបានចុះទស្សនកិច្ចសាលារៀនដោយពុំមានផ្តល់ដំណឹងជាមុន។ ដូច្នេះថ្ងៃទាំងនោះពុំបានដាក់បញ្ចូលនៅក្នុងការវិភាគនេះទេ។

រូបទី ១១ ៖ អវត្តមានរបស់គ្រូបង្រៀន និងវត្តមានរបស់នាយកសាលា




| | នាយកអវត្តមាន | នាយកនៅសាលា |
|---|---|---|
| គ្រូអវត្តមាន | 68% | 6% |
| គ្រូមកបង្រៀន | 32% | 94% |

នាយកសាលាខ្លួនឯងអវត្តមានពីសាលារៀនក្នុងពេលដែលអ្នកប្រមូលទិន្នន័យចុះទស្សនកិច្ចសាលារៀនដោយពុំមានផ្តល់ដំណឹងជាមុនចំនួន១៦% ក្នុងចំណោមទស្សនកិច្ចសាលារៀនទាំងអស់ ដោយចំនួននេះទាបជាងអវត្តមានគ្រូបង្រៀនតែបន្តិចប៉ុណ្ណោះ ហើយអវត្តមានរបស់នាយកមួយចំនួនអាចដោយសារកិច្ចការជាផ្លូវការនៅខាងក្រៅសាលារៀន។ នាយកសាលាចំនួន៣៨% អវត្តមានក្នុងពេលចុះទស្សនកិច្ចសាលាដោយពុំមានផ្តល់ដំណឹងជាមុនក្នុងពេលបុណ្យចូលឆ្នាំចិន ជាថ្មីម្តងទៀតចំនួននេះមានកម្រិតទាបជាងអវត្តមានគ្រូបង្រៀន។ អវត្តមានបែបនេះ ប្រហែលជាមិនមែនដោយសារកិច្ចការផ្លូវការក្រៅសាលារៀននោះទេ។

នៅក្នុងពេលដែលគ្រូបង្រៀនអវត្តមាននៅក្នុងពេលដែលនាយកសាលាអវត្តមានដែរ ប៉ុន្តែគ្រូបង្រៀនផ្សេងទៀតមានវត្តមាន នេះមានន័យថាសាលារៀននៅតែបើកទ្វារដំណើរការ។ នេះអាចចង្អុលបង្ហាញបានថាមានការជាប់ទាក់ទងគ្នាមួយរវាងកម្រិតនៃការត្រួតពិនិត្យរបស់នាយកសាលា និងវត្តមានរបស់គ្រូបង្រៀន។ នៅក្នុងពេលខ្លះទៀត ទាំងគ្រូបង្រៀន និងនាយកសាលាអវត្តមានទាំងអស់គ្នា ហើយសាលារៀនទាំងមូលត្រូវបានបិទទ្វារតែម្តង។

នៅក្នុងការចុះទស្សនកិច្ចសាលារៀនដោយពុំមានផ្តល់ដំណឹងជាមុនរបស់យើង យើងរកឃើញថាការបិទសាលារៀនទាំងមូល គឺកើតមានទូទៅដោយការចុះទស្សនកិច្ចសាលារៀនដោយពុំមានផ្តល់ដំណឹងជាមុន ចំនួន១០%រកឃើញថាសាលារៀនទាំងមូលត្រូវបានបិទទ្វារនៅថ្ងៃនោ[7]។ ៦១% នៃការចុះទស្សនកិច្ចសាលាដោយពុំមានផ្តល់ដំណឹងជាមុនដែលរកឃើញថាគ្រូបង្រៀនអវត្តមាននោះ សាលារៀនរបស់ពួកគាត់ទាំង

[7] ស្ថានភាពនៃការបើក ឬបិទសាលារៀនមិនត្រូវបានគេកត់ត្រាទុកទេនៅក្នុងការចុះទស្សនៈកិច្ចសាលារៀនដោយពុំមានផ្តល់ដំណឹងជាមុនចំនួន៥៤លើក នៅក្នុងចំណោមទស្សនៈកិច្ចចំនួន១៧៣៣លើក។ លទ្ធផលនានានៅក្នុងផ្នែកនេះ គឺនៅក្នុងចំណោមការចុះទស្សនៈកិច្ច ចំនួន១៦៧៩ដែលស្ថានភាពសាលាត្រូវបានកត់ត្រាទុក។

មូលក៏ត្រូវបានបិទទ្វារដែរ។ នៅក្នុងការសម្ភាសន៍ នាយកសាលាម្នាក់បានលើកឡើងថា កាលពីឆ្នាំមុនសាលារៀនរបស់គាត់បានបិទទ្វារទាំងស្រុងប្រហែល១៥ថ្ងៃដោយសារអវត្តមានសិស្ស និង គ្រូបង្រៀន។

យើងបានរកឃើញភាពខុសគ្នាយ៉ាងច្រើនទៅតាមតំបន់នៅក្នុងការវិភាគនេះ ដោយការបិទសាលារៀនមិនត្រូវបានគេរកឃើញនៅក្នុងទីក្រុងភ្នំពេញទេហើយការចុះទស្សនកិច្ចសាលារៀនដោយពុំមានផ្តល់ដំណឹងជាមុនចំនួន១៦%នៅក្នុងខេត្តមួយបានរកឃើញថាសាលារៀនទាំងមូលត្រូវបានបិទទ្វារ។ ជាងនេះទៅទៀតមានភាពខុគ្នាយ៉ាងច្រើនរវាងតំបន់ជនបទ និង ទីប្រជុំជនដូចដែលនឹងបង្ហាញនៅក្នុងរូបទី១២។ ៦៦%នៃអវត្តមានរបស់ គ្រូបង្រៀនដែលបានរកឃើញនៅក្នុងការចុះទស្សនកិច្ចសាលារៀនដោយពុំមានផ្តល់ដំណឹងជាមុននៅតំបន់ជនបទគឺព្រមគ្នាជាមួយនឹងការបិទសាលារៀនទាំងមូល ដោយប្រៀបធៀបនឹងនៅតំបន់ទីប្រជុំជនគឺមានតែចំនួន៣៧%ប៉ុណ្ណោះដែលគ្រូអវត្តមាន ហើយសាលាទាំងមូលបានបិទទ្វា។ នៅតំបន់ជនបទដោយសារសាលារៀនមានទំហំតូចជាង ហើយបុគ្គលិក និងថ្នាក់រៀនមានចំនួនតិចជាងច្រើន អវត្តមានរបស់គ្រូបង្រៀនម្នាក់ ឬ២នាក់អាចមានន័យថា សាលារៀនទាំងមូលត្រូវបានបិទទ្វារតែម្តង ខណៈដែលសាលារៀននៅតំបន់ទីប្រជុំជនដែលមានទំហំធំជាង ការបិទសាលារៀនអាចធ្វើទៅបានទាល់តែគ្រូបង្រៀនមានចំនួនច្រើនត្រូវអវត្តមាន។

រូបទី១២៖ គ្រូអវត្តមាន ហើយសាលាទាំងមូលត្រូវបានបិទទ្វានៅតាមតំបន់នានា



### ៤.២.៤ ការវិភាគ ៖ ភាពខុសគ្នាចំពោះអវត្តមានរបស់គ្រូបង្រៀននៅតាមទីតាំង កំរិតថ្នាក់ និងវេនបង្រៀន

### ភាពខុសគ្នាទៅតាមទីតាំងរបស់សាលារៀន

ទាំងនៅក្នុងការចុះទស្សនកិច្ចសាលារៀនដោយពុំមានផ្តល់ដំណឹងជាមុន និងប្រភពទិន្នន័យដែលបានបញ្ចូលគ្នាមានភាពខុសគ្នាខ្លាំងរវាងអត្រាអវត្តមានរបស់គ្រូបង្រៀននៅតាមសាលារៀននៅតាមតំបន់ជនបទ និងទីប្រជុំជន។ អត្រាអវត្តមានរបស់គ្រូបង្រៀននៅតាមសាលារៀនជនបទក្នុងពេលចុះទស្សនកិច្ចសាលារៀនដោយពុំមានផ្តល់ដំណឹងជាមុនមានកម្រិតខ្ពស់រហូតដល់២៤% បើប្រៀបធៀបនឹងអត្រាអវត្តមានជាមធ្យមដែលមាន១២%នៅតំបន់ទីប្រជុំជន។ ទិន្នន័យអវត្តមានដែលបានរួមបញ្ចូលគ្នាក៏ចង្អុលបង្ហាញដែរថាគ្រូបង្រៀននៅតំបន់ជនបទអវត្តមានញឹកញាប់ ជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជន ($t(240)= -6.18$, $p< .00១$ (មធ្យមភាគទីប្រជុំជន = ១២; មធ្យមភាគទីជនបទ=19))។ នៅពេលដែលយើងបំលែងទៅជា ភាគរយអត្រាអវត្តមានជាមធ្យមក្នុង១ឆ្នាំសិក្សាក្នុងចំណោមគ្រូបង្រៀននៅតាមតំបន់ជនបទគឺ១២% ហើយក្នុងចំណោមគ្រូបង្រៀននៅតាមទីប្រជុំជនគឺ៨%។ លទ្ធភាពអវត្តមានរបស់គ្រូបង្រៀនគឺទាក់ទងនឹងទីតាំងសាលាដែលគ្រូបង្រៀន ដោយចំនួនវិសមមាត្រនៃអវត្តមានគ្រូត្រូវបានគេកត់សំគាល់នៅតាមតំបន់ជនបទ។ ចំណុចនេះ ឆ្លុះបញ្ចាំងពីកស្តុតាងស្តីពីភាពខុសគ្នារវាងតំបន់ជនបទ និង ទីប្រជុំជនចំពោះអវត្តមានរបស់គ្រូបង្រៀននៅក្នុងប្រទេសឥណ្ឌា និង បណ្តាប្រទេសផ្សេងៗជាច្រើនទៀត (Chaudhury et al., ២០០៦)។ ហេតុដូច្នេះហើយ យើងអាចសន្និដ្ឋានបានថា អវត្តមានរបស់គ្រូបង្រៀនគឺជាបញ្ហាចោទមួយនៅតាមសាលារៀនក្នុងតំបន់ជនបទនៅក្នុងប្រទេសកម្ពុជា។

រូបទី១៣ ៖ អត្រាអវត្តមានគ្រូបង្រៀនតាមទីតាំងសាលារៀន (ទិន្នន័យដែលបានរួមបញ្ចូលគ្នា)




ភាពខុសគ្នានេះត្រូវបានគាំទ្របន្ថែមទៀតតាមរយៈទិន្នន័យនៃការសម្ភាសគ្រូបង្រៀន។ នៅពេលដែលគេសួរគ្រូបង្រៀនអំពីកម្រិតនៃអវត្តមានជាទូទៅរបស់គាត់ គ្រូបង្រៀននៅតាមសាលារៀនជនបទបានប៉ាន់ស្មានពីកម្រិតអវត្តមានរបស់ខ្លួនខ្ពស់ ដូចដែលបានបង្ហាញនៅក្នុងតារាងខាងក្រោម។ នៅពេលដែលទិន្នន័យត្រូវបានគេបំបែកទៅតាមទីតាំងភូមិសាស្ត្រសាលារៀន ពោលគឺទីប្រជុំជន និងជនបទ វាមានសារៈសំខាន់ណាស់ក្នុង

ការកត់សំគាល់ថា ចំនួនគ្រូបង្រៀនដែលបានបញ្ជាក់ថា ពួកគាត់មិនដែលអវត្តមាន[8]ទេនៅសាលារៀនតាមទីប្រជុំជនគឺមានចំនួនខ្ពស់ជាង ស្ទើរតែទ្វេដងនៃចំនួនគ្រូបង្រៀននៅតាមសាលារៀនក្នុងតំបន់ជនបទខណៈដែលភាគរយដ៏ច្រើនរបស់គ្រូបង្រៀននៅតាមតំបន់ជនបទត្រូវបានគេរកឃើញថា អវត្តមាន២-៣ដងក្នុងមួយខែ។ ៥៥%នៃគ្រូបង្រៀននៅតាមតំបន់ជនបទបានលើកឡើងថាបានអវត្តមានចំនួន២ដង ឬច្រើនជាងនេះ ក្នុងមួយខែៗ ដោយប្រៀបទៅនឹងគ្រូបង្រៀនចំនួន២៣%នៅទីប្រជុំជនដែលមានកម្រិតអវត្តមានបែបនេះ។ ការសិក្សាស្រាវជ្រាវរបស់NEPនៅក្នុងឆ្នាំ២០០៥ស្តីពី"ប្រសិទ្ធិភាពម៉ោងបង្រៀននៅថ្នាក់បឋមសិក្សា"បានរកឃើញនូវនិន្នាការដូចគ្នានៃអត្រាអវត្តមានរបស់គ្រូបង្រៀន នៅក្នុងតំបន់ទីប្រជុំជនមានចំនួនទាបជាងនៅតំបន់ជនបទ និងតំបន់ដាច់ស្រយ៉ាលយ៉ាងខ្លាំង[9]។

រូបទី១៤ ៖ អវត្តមានរបស់គ្រូបង្រៀនដែលបានប៉ាន់ស្មានដោយគ្រូបង្រៀន




ខេត្តខុសគ្នាក៏បានបង្ហាញនូវភាពខុសគ្នាយ៉ាងច្រើនចំពោះចំនួននៃអវត្តមានរបស់គ្រូបង្រៀនដែរ( $F$ (5, 281) = 8.39, $p$<.001 (សូមមើលរូបទី១៥))។ ការវិភាគពីភាពខុសគ្នានៃអវត្តមានគ្រូ បានបង្ហាញថា អវត្តមានរបស់គ្រូបង្រៀននៅ ក្នុងទីក្រុងភ្នំពេញមានចំនួនទាបជាងអវត្តមានរបស់គ្រូបង្រៀន នៅតាមបណ្តាខេត្តនានាច្រើនណាស់ ដោយគ្រូបង្រៀនអវត្តមានជាមធ្យមតែ៧ដងប៉ុណ្ណោះក្នុងមួយឆ្នាំសិក្សា ចំណែកឯនៅតាមបណ្តាខេត្តនានាដែលបានសិក្សាវិញ គ្រូបង្រៀនបានរាយការណ៍ពីអវត្តមានស្ទើរតែ២០ថ្ងៃនៅក្នុងអំឡុង១ឆ្នាំសិក្សាដូចគ្នា។

[8] ទោះបីជាមានគ្រូបង្រៀនជាច្រើនបានលើកឡើងថាមិនដែលអវត្តមានក្នុងមួយខែ តែពួកគេបានទទួលស្គាល់ថាបានអវត្តមានខ្លះក្នុងមួយឆ្នាំសិក្សា។

[9] នៅក្នុងការសិក្សានេះ ទីតាំងសាលារៀនត្រូវបានវិភាគតាមការចាត់ចំណាត់ថ្នាក់របស់ក្រសួងអប់រំ យុវជន និងកីឡា ទៅតាមទីប្រជុំជន និងជនបទ ចំណែកការសិក្សានៅឆ្នាំ២០០៥ប្រើប្រាស់ការចាត់ចំណាត់ថ្នាក់សាលារៀនចំនួន៣ គឺ ទីប្រជុំជន ជនបទ និងដាច់ស្រយ៉ាល។

នៅក្នុងរូបខាងក្រោម ភាពខុសគ្នានៅតាមខេត្តត្រូវបានគេបង្ហាញថាទទួលរងឥទ្ធិពលយ៉ាងខ្លាំងដោយសារភាពខុសគ្នារវាងអវត្តមានគ្រូនៅតំបន់ទីប្រជុំជន និងជនបទ។ ករណីលើកលែងគឺនៅក្នុងខេត្តព្រះសីហនុ ដែលភាពខុសគ្នារវាងអវត្តមាននៅតាមតំបន់ជនបទ និងទីប្រជុំជនពុំមានចំនួនច្រើនទេ។

រូបទី ១៥ ៖ អវត្តមានគ្រូបង្រៀនតាមខេត្ត (ទិន្នន័យបញ្ចូលគ្នា)[10]




## ភាពខុសគ្នាតាមកម្រិតថ្នាក់ដែលបង្រៀននៅតាមសាលារៀន

អត្រាអវត្តមានជាមធ្យមរបស់គ្រូបង្រៀនមានការប្រែប្រួលតិចតួចពីកម្រិតថ្នាក់មួយទៅកម្រិតថ្នាក់មួយទៀត។ ទោះជាយ៉ាងណាក៏ដោយ តាមរយៈទិន្នន័យបញ្ចូលគ្នា លទ្ធផលបង្ហាញថាអត្រាដែលគ្រូអាចនឹងអវត្តមាន គឺពុំមានភាពខុសគ្នាច្រើននោះទេពីកម្រិតថ្នាក់ មួយទៅកម្រិតថ្នាក់មួយទៀត។

[10] ទិន្នន័យនៅខេត្តព្រះវិហារមិនត្រូវបានដាក់បញ្ចូលនៅក្នុងការវិភាគនេះទេ ដោយសារចំនួនសំណាកតិចនៅក្នុងខេត្តនេះ

រូបទី១៦ ៖ អវត្តមានរបស់គ្រូបង្រៀនតាមកម្រិតថ្នាក់ដែលបង្រៀន (ទិន្នន័យបញ្ចូលគ្នា)




## ភាពខុសគ្នាទៅតាមវេនបង្រៀនរបស់គ្រូបង្រៀន

យើងបានធ្វើតេស្តទៅលើលទ្ធភាពដែលថា តើថ្នាក់រៀនដែលត្រូវបង្រៀននៅពេលព្រឹក ឬនៅពេលរសៀល(វេនបង្រៀន) អាចមានឥទ្ធិពលទៅលើអវត្តមានរបស់គ្រូបង្រៀនដែរឬទេ។ នៅពេលដែលទិន្នន័យនៃការចុះឧស្សនកិច្ចសាលាដោយពុំមានផ្តល់ដំណឹងជាមុនត្រូវបានគេចាត់ថ្នាក់ទៅតាមវេនបង្រៀន ទិន្នន័យបានបង្ហាញថាអត្រាអវត្តមានរបស់គ្រូបង្រៀនសម្រាប់ការបង្រៀនវេនព្រឹកមាន១៩% ពោលគឺ៣%ខ្ពស់ជាងការបង្រៀនវេនរសៀលដែលមានចំនួនតែ១៦%ប៉ុណ្ណោះ។ ការពន្យល់ដែលអាចធ្វើទៅបានមួយចំពោះចំណុចនេះអាចថា នៅពេលដែលការចុះឧស្សនកិច្ចសាលារៀនដោយពុំមានផ្តល់ដំណឹងជាមុននៅពេលព្រឹក គ្រូបង្រៀននៅវេនរសៀលប្រហែលជាបានដឹងពីវត្តមានរបស់អ្នកស្រាវជ្រាវ ហើយក៏មកបង្រៀនជាធម្មតា។ ទោះជាយ៉ាងណាក៏ដោយ ការវិភាគស្ថិតិបង្ហាញថាភាពខុសគ្នានេះមិនជាធំដុំអ្វីទេ។

នៅក្នុងប្រទេសកម្ពុជា គ្រូបង្រៀនមួយចំនួនត្រូវបានគេចាត់តាំងឱ្យបង្រៀនឆ្លាស់វេនគ្នាជារៀងរាល់ខែ ពោលគឺ បង្រៀនថ្នាក់របស់គាត់នៅពេលព្រឹក ឬនៅពេលរសៀល។ វាមានតម្លៃនៅក្នុងការកត់សម្គាល់ថាគ្រូបង្រៀនដែលត្រូវបានគេចាត់តាំងឱ្យប្តូរវេនគ្នាបង្រៀនជារៀងរាល់ខែ តាមស្ថិតិគឺមានអវត្តមានតិចជាងសមភាគីរបស់ពួកគាត់ ($F(3, 279) = 10.19$, $p < .001$ (សូមមើល រូបទី១៧))។ ទោះជាយ៉ាងណាក៏ដោយ គ្រូបង្រៀនដែលបង្រៀនឆ្លាស់វេនគឺបង្រៀននៅតាមសាលាបឋមសិក្សានានានៅក្នុងទីក្រុងភ្នំពេញ ដែលអត្រាអវត្តមានរបស់គ្រូបង្រៀនជាទូទៅមានចំនួនទាបជាងតំបន់ដទៃទៀត។ ហេតុដូច្នេះហើយ គេពុំអាចធ្វើការសន្និដ្ឋានជាទូទៅចំពោះការរកឃើញនេះឡើយ។

រូបទី១៧៖ អត្រាអវត្តមានគ្រូទៅតាមវេនបង្រៀន




### ៤.២.៦ ការវិភាគ ភាពខុសគ្នានៃអវត្តមានគ្រូទៅតាមលក្ខណ:សម្បត្តិរបស់គ្រូបង្រៀន

ទិន្នន័យលំអិតអំពីគ្រូបង្រៀន អាចឱ្យយើងធ្វើការវិភាគទៅលើថាតើមានក្រុមគ្រូបង្រៀនជាក់ណាមួយមានអត្រាអវត្តមានខ្ពស់ដែរឬទេ។ នៅពេលដែលគេឃើញថាមានភាពខុសគ្នាគួរឱ្យកត់សម្គាល់នោះ កត្តានានា និងលក្ខណៈសម្បត្តិរបស់គ្រូបង្រៀនមានទំនាក់ទំនងគ្នាទៅវិញទៅមក ហើយនៅក្នុងសំណាកដែលបានសិក្សានេះ គឺយើងមិនអាចធ្វើការសន្និដ្ឋានលក្ខណៈសម្បត្តិជាក់លាក់ណាមួយ គ្រប់គ្រងលើកត្តាផ្សេងទៀតនោះទេ។

## អាយុរបស់គ្រូបង្រៀន

ទិន្នន័យបញ្ចូលគ្នាត្រូវបានគេប្រើប្រាស់ដើម្បីពិនិត្យមើលថាតើ អាយុរបស់គ្រូបង្រៀនអាចជាកត្តាដែលជះឥទ្ធិពលដល់អត្រាអវត្តមានគ្រូដែរឬទេ។ ភស្តុតាងបង្ហាញថា គ្រូបង្រៀនវ័យក្មេងទំនងជាអវត្តមានពីសាលារៀនញឹកញាប់ជាងសហសេវិករបស់ខ្លួនដែលមានវ័យចំណាស់ (សូមមើលរូបទី ១៨)។ ទោះជាដូច្នេះក៏ដោយ គ្រូដែលមានវ័យក្មេងជាងនៅក្នុងការសិក្សានេះ ទំនងជាបង្រៀននៅតាមសាលាជនបទ ($\chi^2 = 24.38$, $df = 2$, $p < .001$ (មើលរូបទី ១៩)) ដែលយើងបានរកឃើញហើយថាជាកត្តាចម្បងធ្វើឱ្យមានអត្រាអវត្តមានមានភាពខុសគ្នា។

រូបទី ១៨៖ អវត្តមានទៅតាមក្រុមអាយុរបស់គ្រូបង្រៀន



រូបទី ១៩៖ អាយុរបស់គ្រូបង្រៀន ទៅតាមតំបន់




នៅពេលដែលពិនិត្យមើលពីអត្រាអវត្តមានរបស់គ្រូទៅតាមយេនឌ័រ ទិន្នន័យបានបង្ហាញឱ្យឃើញថា គ្រូបង្រៀនភេទប្រុសនៅក្នុងការសិក្សានេះ អវត្តមានពីសាលារៀនញឹកញាប់ជាងគ្រូបង្រៀនជាស្ត្រី។ អត្រាអវត្តមានជាមធ្យមរបស់លោកគ្រូគឺ១១,៥% ដែលមាន២%ខ្ពស់ជាងអត្រាអវត្តមានរបស់អ្នកគ្រូគឺ៩,៥%។ រូបទី២០ បង្ហាញពីរបាយអវត្តមានគ្រូបង្រៀនដែលបានសិក្សាទៅតាមយេនឌ័រ។ ៦៨%នៃអ្នកគ្រូមានអត្រាអវត្តមានក្រោម ១០% ធៀបទៅនឹង៥៤%នៃលោកគ្រូ។

រូបទី ២០៖ អត្រាអវត្តមានទៅតាមយេនឌ័រ




ជាថ្មីម្តងទៀត ការពន្យល់មួយដែលអាចធ្វើបានគឺអាចទាក់ទងទៅនឹងទីតាំងនៅជនបទ ដោយសារលោកគ្រូ ទំនងជាត្រូវបានគេពង្រាយទៅជនបទដាច់ស្រយាលជាងអ្នកគ្រូ យោងទៅតាមគោលនយោបាយពង្រាយគ្រូបង្រៀនរបស់ក្រសួងអប់រំ យុវជននិងកីឡា។ នៅក្នុងសំណាកសិក្សានេះ លោកគ្រូមួយចំនួនធំបង្រៀននៅជនបទ ដូចដែលបង្ហាញនៅក្នុងរូបទី២១ ហើយភស្តុតាងពីភាពខុសគ្នានៃអត្រាអវត្តមានរបស់គ្រូ

ទាំងពីរភេទនៅតំបន់ជនបទ និងទីប្រជុំជនក៏មានបង្ហាញផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ទោះជានៅតំបន់ជនបទក៏ដោយ ក៏លោកគ្រូមានអត្រាអវត្តមានជាមធ្យមខ្ពស់ជាងអ្នកគ្រូដែរ ដូចដែលមានបង្ហាញក្នុងរូបទី២២។

រូបទី២១៖ ទីតាំងបង្រៀន និងភេទរបស់គ្រូបង្រៀននៅក្នុងសំណាក[11]




រូបទី២២៖ អត្រាអវត្តមានគ្រូទៅតាមភេទ និងកន្លែងធ្វើការ




| | ជនបទ | ទីប្រជុំជន |
|---|---|---|
| ស្រី | 11.20% | 6.80% |
| ប្រុស | 12.80% | 8.60% |

## ការវិភាគ៖ ភាពខុសគ្នានៃអវត្តមានគ្រូបង្រៀនទៅតាមរយៈចម្ងាយពីផ្ទះទៅសាលារៀន និងទីកន្លែងកំណើត

យើងបានរកមើលថាតើ ចម្ងាយពីទីកន្លែងដែលគ្រូរស់នៅទៅសាលារៀន មានទំនាក់ទំនងជាមួយអត្រាអវត្តមានរបស់គ្រូឬទេ។ សម្មតិកម្មមួយអាចថាគ្រូនៅជនបទត្រូវធ្វើដំណើរឆ្ងាយដើម្បីទៅសាលារៀន ហើយដែលអាចមានផលប៉ះពាល់ ដល់អត្រាអវត្តមានរបស់ពួកគាត់។ ទោះជាយ៉ាងណាក៏ដោយគ្រូមួយចំនួន

[11] ភេទមិនត្រូវបានគេកត់ត្រាសម្រាប់គ្រូបង្រៀនចំនួន១៣រូប ការបរិយាយគឺរាប់តែអ្នកដែលគេកត់ត្រាពីភេទប៉ុណ្ណោះ

តូចដែលត្រូវធ្វើដំណើររយៈចម្ងាយឆ្ងាយ (ជាង២៥គីឡូម៉ែត្រ) ត្រូវបានគេកត់សម្គាល់ថាមានអត្រាអវត្តមានខ្ពស់តែមិនមានភាពខុសគ្នាគួរឱ្យកត់សម្គាល់ផ្នែកស្ថិតិនោះទេ។

តារាងទី១០៖ អវត្តមានគ្រូទៅតាមរយៈចម្ងាយពីផ្ទះទៅសាលារៀន

| រយៈចម្ងាយពីផ្ទះរបស់គ្រូបង្រៀនទៅសាលារៀន | អត្រាអវត្តមានជាមធ្យម | ចំនួនគ្រូបង្រៀន | គម្លាតស្តង់ដារ |
|---|---|---|---|
| តិចជាង ឬស្មើ ១គម | 10.24% | 95 | .07 |
| ជាង១គម ដល់ ៥គម | 10.06% | 65 | .07 |
| ជាង៥គម ដល់ ១០គម | 10.49% | 96 | .07 |
| ជាង១០ គម ដល់១៥ គម | 10.28% | 29 | .06 |
| ជាង១៥គមដល់ ២០គម | 9.00% | 11 | .04 |
| ជាង២០គមដល់២៥គម | 8.40% | 5 | .04 |
| ជាង២៥គម | 15.50% | 2 | .09 |

មានសម្មតិកម្មបន្ថែមទៀតមួយទៀតក្នុងអំឡុងពេលស្រាវជ្រាវ គឺគ្រូបង្រៀនដែលត្រូវបានគេពង្រាយ ឬពង្រាយឡើងវិញទៅកាន់តំបន់ដែលមិនមានសាច់ញាត្តិរស់នៅ អាចមានអត្រាអវត្តមានខ្ពស់។ ការពន្យល់សម្មតិកម្មបន្ថែមទាំងនោះ បានស្នើឡើងថាអាចដោយសារមកពីពួកគេមានការតាំងចិត្តតិចតួចចំពោះការបង្រៀននៅតាមសហគមន៍ ឬក៏ដោយសារមកពីពួកគេត្រូវចំណាយពេលច្រើនអវត្តមានពីសាលារៀនដើម្បីទៅលេងផ្ទះដែលនៅតំបន់ ផ្សេងទៀតក្នុងប្រទេស។

## ៤.៣ ការបាត់ម៉ោងដោយសារគ្រូបង្រៀនតិចជាងម៉ោងកំនត់

ទម្រង់មួយផ្សេងទៀតនៃការបាត់ម៉ោងសិក្សា គឺទាក់ទងជាមួយនឹងរយៈពេលជាក់ស្តែងដែលគ្រូបានបង្រៀនមេរៀននៅក្នុងថ្នាក់។ ការចុះសង្កេតថ្នាក់រៀនរបស់គ្រូបង្រៀន៣០៣នាក់[12]បានធ្វើឡើងចំនួន៦៧០ លើកដែលជាផ្នែកមួយនៃសិក្សាស្រាវជ្រាវនេះ។ លទ្ធផលបានបង្ហាញថាម៉ោងសិក្សាដែលបានផ្តល់ឱ្យសិស្សគឺមិនស្របគ្នា ទៅនឹងអ្វីដែលគេបានកំណត់ជាផ្លូវការនៅក្នុងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡាទេ។ តាមការកំណត់ ក្នុងមួយថ្ងៃសិស្សត្រូវរៀនក្នុងថ្នាក់ចំនួនប្រាំម៉ោងសិក្សា ដោយក្នុងមួយម៉ោងសិក្សាមានរយៈពេល៤០នាទី។ ដូច្នេះហើយ នៅក្នុងថ្ងៃសិក្សាធម្មតា សិស្សត្រូវសិក្សានៅក្នុងថ្នាក់រយៈពេល ២០០នាទីក្នុងមួយថ្ងៃ។ លទ្ធផលនៃការសង្កេតថ្នាក់រៀនបានបង្ហាញថាការបាត់ម៉ោងបង្រៀនដោយសារគ្រូបង្រៀនមិនគ្រប់ម៉ោងគឺមានចំនួនច្រើន ហើយដែលជាមធ្យមគ្រូបង្រៀនបានត្រឹមតែ១៧៦នាទីប៉ុណ្ណោះក្នុងមួយថ្ងៃ។ យោងតាមការសង្កេតថ្នាក់រៀនបានបង្ហាញឱ្យដឹងថាភាគរយដ៏ធំបំផុតនៃការបង្រៀនមិនគ្រប់ម៉ោងគឺមកពីគ្រូបង្រៀនចូលបង្រៀនយឺត ប៉ុន្តែយើងក៏បានសង្កេតឃើញផងដែរថាមានគ្រូបង្រៀនដែលចេញមុនម៉ោង និងការចេញលេងអូសបន្លាយពេលយូរ។ ជាមធ្យម ម៉ោងបង្រៀនត្រូវបានបាត់អស់រយៈពេល២៤នាទី ឬស្មើនឹង ១២% នៃចំនួនម៉ោងបង្រៀននៅក្នុងមួយថ្ងៃ។

[12] គ្រូបង្រៀនសរុបដែលបានដាក់បញ្ចូលក្នុងការសិក្សានេះមានចំនួន ៣០៩ នាក់ ប៉ុន្តែគ្រូបង្រៀនដែលបានសង្កេតថ្នាក់រៀនមានចំនួនតែ ៣០៣ នាក់ ដោយសារគ្រូបង្រៀនមួយចំនួនបានអវត្តមាននៅថ្ងៃចុះសង្កេត និងគ្រូបង្រៀនមួយចំនួនទៀតបង្រៀន ថ្នាក់គួប។

ដើម្បីទុកជាការពិចារណា យើងឃើញថាប្រសិនបើគ្មានអវត្តមានផ្សេងៗទៀត ឬគ្មានការឈប់សម្រាកបន្ថែមផ្លូវការទេនោះ ការបាត់ម៉ោងសិក្សាដោយសារតែគ្រូបង្រៀនមិនគ្រប់ម៉ោងនៅក្នុងថ្នាក់អាចមានចំនួនរហូតដល់២២ថ្ងៃក្នុងចំណោមថ្ងៃសិក្សាដែលមានចំនួន១៨៦ថ្ងៃក្នុងមួយឆ្នាំសិក្សា។

រូបទី ២៣៖ ចំនួននៃការសង្កេតថ្នាក់រៀន




ដូចដែលបានបង្ហាញនៅក្នុងអវត្តមានរបស់គ្រូបង្រៀន បរិមាណនៃពេលវេលាក្នុងការបង្រៀនសិស្សនៅក្នុងថ្នាក់មានភាពខុសគ្នាច្រើនពីគ្រូបង្រៀនម្នាក់ទៅគ្រូបង្រៀនម្នាក់ទៀត។ គួរឱ្យកត់សម្គាល់ផងដែរថា ស្ទើរតែមួយភាគបីនៃគ្រូបង្រៀនដែលត្រូវបានគេសង្កេតបានកាត់បន្ថយម៉ោងបង្រៀនអស់រយៈពេល៣០នាទី ឬច្រើនជាងនេះ។ ជាចំណុចវិជ្ជមានដែលយើងបានកត់សម្គាល់ឃើញថាមួយភាគបីនៃគ្រូបង្រៀនដែលត្រូវបានគេសង្កេតបានបង្រៀនសិស្សលើសពីរយៈពេល១៩០ នាទី។

រូបទី ២៤៖ អ៊ីស្តូក្រាមចំនួននាទីជាមធ្យមដែលគ្រូបានបង្រៀននៅក្នុងថ្នាក់ក្នុង១ថ្ងៃ



### ចំនួនម៉ោងនៃការបង្រៀនសិស្សនៅក្នុងថ្នាក់ត្រូវបានកាត់បន្ថយនៅតាមទីតាំងសាលារៀន

ទិន្នន័យនៃការសង្កេតថ្នាក់រៀនបានបង្ហាញថាគ្រូបង្រៀននៅតំបន់ជនបទបានបង្រៀនតិចម៉ោងជាងគ្រូបង្រៀននៅទីប្រជុំជន។ គ្រូបង្រៀននៅតំបន់ជនបទបានបង្រៀនក្នុងរយៈពេលជាមធ្យមចំនួន១៨៧នាទី ( $t\,(301) = -6.05,\ p < .001$ )។ ដូច្នេះហើយការបាត់ម៉ោងសិក្សាជាមធ្យមនៅតំបន់ជនបទ មានរយៈពេល ២៨នាទីក្នុងមួយថ្ងៃ បើធៀបជាមួយនឹងទីប្រជុំជនដែលការបាត់ម៉ោងសិក្សាជាមធ្យមមានរយៈពេល១៤នាទីក្នុងមួយថ្ងៃ។

រូបទី ២៥៖ ចំនួនម៉ោងបង្រៀនក្នុងថ្នាក់ដែលត្រូវបានកាត់បន្ថយដោយសារទីតាំងសាលារៀន




នៅពេលដែលគេចាត់ថ្នាក់ទិន្នន័យតាមទីតាំងសាលារៀន ស្ថិតិបានបង្ហាញថាមានគ្រូបង្រៀនចំនួនស្ទើរតែ៤០% នៅក្នុងតំបន់ជនបទបានកាត់បន្ថយម៉ោងសិក្សាអស់រយៈពេល៣០នាទី ឬលើសពីនេះ។ នេះគឺមានភាគរយស្ទើនឹងពីរដងនៃចំនួនគ្រូបង្រៀនដែលនៅទីប្រជុំជន។ គ្រូបង្រៀននៅទីប្រជុំជនប្រមាណជា៧៣% បានបង្រៀនសិស្សនៅក្នុងថ្នាក់យ៉ាងហោចណាស់មានរយៈពេល១៨០នាទីក្នុងមួយថ្ងៃ បើធៀបទៅនឹងគ្រូបង្រៀននៅតំបន់ជនបទដែលបានបង្រៀនរយៈពេលដូចគ្នានេះមានចំនួនតែ៤៤%ប៉ុណ្ណោះ។

រូបទី២៦៖ ចំនួននាទីជាមធ្យមដែលគេសង្កេតឃើញថាគ្រូបានបង្រៀនទៅតាមតំបន់ផ្សេងៗ




| | ជាង200នាទី | 191 ទៅ 200 | 181 ទៅ 190 | 171 ទៅ 180 | 161 ទៅ 170 | 151 ទៅ 160 | 131 ទៅ 150 | 100 ទៅ 130 | តិចជាង100 |
|---|---|---|---|---|---|---|---|---|---|
| ចំនួនគ្រូនៅជនបទ | 18 | 41 | 26 | 36 | 13 | 25 | 17 | 15 | 3 |
| ចំនួនគ្រូនៅទីប្រជុំជន | 8 | 40 | 34 | 9 | 10 | 3 | 1 | 2 | 5 |
| %បូកយោងនៅជនបទ | 9% | 30% | 44% | 62% | 69% | 82% | 91% | 98% | 100% |
| %បូកយោងនៅទីប្រជុំជន | 7% | 43% | 73% | 81% | 90% | 93% | 94% | 96% | 100% |

### ចំនួនម៉ោងនៃការបង្រៀនសិស្សនៅក្នុងថ្នាក់ត្រូវបានកាត់បន្ថយនៅតាមខេត្ត

ការវិភាគបន្ថែមទៀតបានរកឃើញថាចំនួនម៉ោងនៃការបង្រៀនសិស្សនៅក្នុងថ្នាក់ដែលត្រូវបានកាត់បន្ថយ មានភាពខុសប្លែកគ្នាយ៉ាងខ្លាំងនៅទូទាំងខេត្ត ($F(5, 295) = 3.62$, $p < .01$ (មើលរូបទី ២៧))។ ទីក្រុងភ្នំពេញមានការបាត់ម៉ោងបង្រៀនដោយសារមូលហេតុនេះតិចតួចបំផុត បន្ទាប់មកគឺខេត្តព្រះសីហនុ។ ខេត្តកំពង់ចាម និងបាត់ដំបងមានការបាត់ម៉ោងប្រហាក់ប្រហែលគ្នា ដោយសារការបង្រៀនមិនគ្រប់ម៉ោងនេះ។ ។ នៅខេត្តមណ្ឌលគិរី ចំនួនម៉ោងបង្រៀនសិស្សនៅក្នុងថ្នាក់គឺមានចំនួនតិចជាងគេបំផុត ដោយម៉ោងបង្រៀនជាមធ្យមមានរយៈពេល១៦៦នាទីក្នុងមួយថ្ងៃ ដោយផ្អែកតាមការសង្កេតថ្នាក់រៀនជាក់ស្តែង។ ដោយសារការបាត់ម៉ោងនេះបានធ្វើឱ្យម៉ោងបង្រៀននៅថ្នាក់បឋមសិក្សាក្នុងខេត្តនេះមានភាពខុសប្លែកយ៉ាងខ្លាំងពីខេត្តផ្សេងៗទៀតដែលមានការបាត់ម៉ោងតែបន្តិចបន្តួច ដាក់ស្តែងដូចជានៅខេត្តព្រះសីហនុ និងទីក្រុងភ្នំពេញ។

រូបទី ២៧៖ ចំនួនម៉ោងដែលគ្រូបង្រៀនសិស្សប្រចាំថ្ងៃ (គិតជានាទី) ទៅតាមខេត្តនានា[13]




នៅពេលយើងពិនិត្យមើលទិន្នន័យនៅតាមសាលារៀននៅតំបន់ជនបទ និងទីប្រជុំជនយើងអាចមើលឃើញអំពីលំនាំស្រដៀងគ្នាមួយចំពោះអវត្តមានគ្រូបង្រៀន។ គ្រូបង្រៀននៅសាលារៀននៅទីប្រជុំជននៅគ្រប់ខេត្តទាំងអស់ត្រូវ បានគេរកឃើញថាបានបង្រៀនសិស្សក្នុងរយៈពេលវែងជាងនៅតាមជនបទ។ ភាគច្រើនបំផុតលទ្ធផលបានបង្ហាញនូវភាពខុសគ្នាយ៉ាងខ្លាំងនៅក្នុងតំបន់ជនបទដែលមានស្តង់ដារលំអៀងខ្ពស់ ចំណែកនៅតាមទីប្រជុំជនវិញគឺមានលក្ខណៈប្រកបដោយសង្គតភាព។ ជាការគួរឱ្យកត់សម្គាល់ ថ្វីត្បិតតែនៅខេត្តមណ្ឌលគីរី ការបង្រៀនមេរៀនមានរយៈពេលខ្លីជាងគេក៏ដោយ ក៏សាលារៀននៅទីប្រជុំជនក្នុងខេត្តនេះត្រូវបានគេ សង្កេតឃើញថាការបង្រៀនមេរៀនជាមធ្យមមានរយៈពេលវែងជាងខេត្តផ្សេងៗទៀត។

រូបទី២៨៖ : ចំនួននាទីជាមធ្យមដែលគ្រូបានបង្រៀនទៅតាមទីតាំងសាលារៀន




[13] ដូចដែលមាននៅក្នុងការវិភាគតាមខេត្តពីខាងដើម លទ្ធផលសម្រាប់ខេត្តព្រះវិហារមិនត្រូវបានបង្ហាញទេដោយសារតែសំណាកមានទំហំតូច។

## ចំនួនម៉ោងនៃការបង្រៀនសិស្សនៅក្នុងថ្នាក់ដែលបានកាត់បន្ថយ ទៅតាមកម្រិតថ្នាក់

ការបាត់ម៉ោងបង្រៀនប្រចាំថ្ងៃដោយសារការបង្រៀនមិនគ្រប់ម៉ោងមិនសូវមានភាពខុសប្លែកគ្នាខ្លាំងទេពីកម្រិតថ្នាក់មួយទៅកម្រិតថ្នាក់មួយ ($F(3, 299) = 1.98, p > .05$))។ ទិន្នន័យបានបង្ហាញថានៅថ្នាក់ទី៤ ទី ៥ និងទី៦ ត្រូវបានគេសង្កេតឃើញថាមានការបាត់ម៉ោងបង្រៀនប្រហាក់ប្រហែលគ្នាដោយជាមធ្យមម៉ោងបង្រៀនមានរយៈពេល១៧៤នាទី ១៧៦នាទី និង ១៧៨នាទីរៀងគ្នា។

រូបទី ២៩៖ ចំនួនម៉ោងនៃការបង្រៀនសិស្សនៅក្នុងថ្នាក់ដែលបានកាត់បន្ថយទៅតាមកម្រិតថ្នាក់




ការធ្វើតេស្តដូចគ្នានេះត្រូវបានគេអនុវត្តក្នុងគោលបំណងដើម្បីលើកកម្ពស់ការយល់ដឹងអំពីការបាត់ម៉ោងបង្រៀនប្រចាំថ្ងៃនៅតាមវេនបង្រៀន។ ដោយសារតែរយៈពេលនៃការបង្រៀនមេរៀននៅវេនពេលព្រឹកមានរយៈពេលតិចជាងគេបន្តិច តែនេះមិនមែនគួរឱ្យកត់សម្គាល់ផ្នែកស្ថិតិឡើង។

រូបទី៣០៖ រយៈពេលបង្រៀនមេរៀនជាមធ្យមនៅតាមវេនបង្រៀន




## ចម្លើយពីការសម្ភាសគ្រូបង្រៀនពីចំនួនម៉ោងនៃការបង្រៀនសិស្សនៅក្នុងថ្នាក់ដែលត្រូវបានកាត់បន្ថយ

នៅពេលដែលថ្នាក់រៀនមិនត្រូវបានបង្រៀនពេញម៉ោងទេនោះ គ្រូបង្រៀនបានប្រាប់ឱ្យដឹងថានេះជារឿយៗ គឺមកពីគ្រូចូលបង្រៀនយឺត។ គ្រូបង្រៀនចំនួន៦២% នៃគ្រូបង្រៀនដែលត្រូវបានគេសម្ភាសបាននិយាយ

ថា ពួកគាត់មកបង្រៀនយឺតយ៉ាងហោចណាស់មួយថ្ងៃក្នុងមួយសប្តាហ៍ និងមួយភាគបីទៀតបានប្រាប់ឱ្យដឹងថា ពួកគាត់មកបង្រៀនយឺតចំនួនពីរថ្ងៃ ឬច្រើនជាងនេះក្នុងមួយសប្តាហ៍។ តាមការប៉ាន់ប្រមាណរបស់គ្រូបង្រៀន បានឱ្យដឹងថារយៈពេលនៃការយឺតនោះគឺប្រហែលជា១០ នាទី។

រូបទី៣១៖ ប្រេកង់នៃការមកបង្រៀនយឺតរបស់គ្រូបង្រៀន




ការសង្កេតថ្នាក់រៀនក៏បានរកឃើញផងដែរថាការចាប់ផ្តើមបង្រៀនយឺតគឺជាមូលហេតុដែលញឹកញាប់ជាងគេបំផុតក្នុងការបង្រៀនមេរៀនមិនបានគ្រប់ម៉ោង។ រូបទី៣២ខាងក្រោមបង្ហាញពីភាគរយនៃអាកប្បកិរិយានីមួយៗដែលនាំឱ្យមានការថយចុះម៉ោងបង្រៀនសិស្សនៅក្នុងថ្នាក់។

រូបទី៣២៖ កត្តាដែលនាំឱ្យមានការកាត់បន្ថយម៉ោងបង្រៀនសិស្សនៅក្នុងថ្នាក់ (ការសង្កេតថ្នាក់រៀន)




ការមើលថែសមាជិកក្នុងគ្រួសារគឺត្រូវបានគេលើកឡើងជាពិសេសថាជាមូលហេតុមួយដែលនាំឱ្យគ្រូបង្រៀនមេរៀនមិនបានគ្រប់ម៉ោង។ គ្រូបង្រៀនចំនួន៣០% ដែលបានទទួលស្គាល់ថាពួកគាត់ជួនកាលមកបង្រៀនយឺត បានមានប្រសាន៍ថានេះគឺដោយសារពួកគាត់ជាប់រវល់ជាមួយការទទួលខុសត្រូវក្នុងគ្រួសារ។ ក្នុងចំណោមគ្រូបង្រៀនចំនួន២០២នាក់ ដែលមានកូនរស់នៅក្នុងបន្ទុក គ្រូបង្រៀនចំនួន១០៦ នាក់ត្រូវបានគេរកឃើញថាគឺជាអ្នកដើរតួចម្បងក្នុងការមើលថែកូន។ ប្រហែលជា៣០% នៃពួកគាត់បានប្រាប់ឱ្យដឹងថាការមើលថែកូននេះ គឺធ្វើឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់វត្តមាន និងការមកបង្រៀនទៀងពេលរបស់ពួកគាត់។

រូបទី៣៣៖គ្រូបង្រៀនដើរតួនាទីចម្បងក្នុងការមើលថែកូន




ចម្ងាយផ្លូវក្នុងការធ្វើដំណើរទៅសាលារៀនក៏ត្រូវបានគេរាយការណ៍ផងដែរថាជាមូលហេតុដ៏សំខាន់ក្នុងការមកសាលារៀនមិនទាន់ម៉ោង និងបង្រៀនមេរៀនមិនបានគ្រប់ម៉ោង។ ទិន្នន័យនៃការសម្ភាសគ្រូបង្រៀនបានបង្ហាញថាប្រហែលជា១៥% នៃគ្រូបង្រៀនដែលបានលើកឡើងថាមកសាលារៀនមិនទាន់ម៉ោងបានមានប្រសាសន៍ថានេះគឺបណ្តាលមកពីផ្ទះពួកគាត់ស្ថិតនៅឆ្ងាយពីសាលារៀន។ នៅក្នុងខេត្តមណ្ឌលគិរី ត្រូវបានគេសង្កេតឃើញថាចំនួននាទីនៃការបង្រៀនមានរយៈពេលខ្លីជាងគេនោះ គ្រូបង្រៀនបានលើកឡើងជាពិសេសអំពីចំណុចនេះ និងបានបន្ថែមអំពីក្តីកង្វល់ជុំវិញចម្ងាយផ្លូវដែលសិស្សត្រូវធ្វើដំណើរពីផ្ទះមកសាលារៀនផងដែរ។

## ៤.៤ ផលវិបាកនៃការបាត់ម៉ោងបង្រៀនចំពោះលទ្ធផលនៃការសិក្សារបស់សិស្ស

ការសន្មត់ជាគន្លឹះ ដែលគេបានផ្ទៀងផ្ទាត់នៅក្នុងការសិក្សានេះគឺថាចំនួនម៉ោងដែលសិស្សប្រាស្រ័យទាក់ទងជាមួយគ្រូនៅក្នុងថ្នាក់រៀន និងចំនួនម៉ោងដែលគ្រូបានបង្រៀនសិស្សគឺជាប់ពាក់ព័ន្ធជាមួយនឹងការសិក្សារបស់សិស្ស។ នៅពេលដែលចំនួនម៉ោងដែលសិស្សប្រាស្រ័យទាក់ទងជាមួយគ្រូនៅក្នុងថ្នាក់រៀនមានតិច និងម៉ោងបង្រៀនមិនទៀងទាត់អាចមានផលប៉ះពាល់ផងដែរទៅលើទស្សនៈទានរបស់សហ-គមន៍ និងតម្លៃនៃការសិក្សា គេក៏សន្មត់ថាវាមានទំនាក់ទំនងដ៏សំខាន់ជាមួយលទ្ធផលនៃការសិក្សារបស់សិស្សដែរ។

ដើម្បីពិនិត្យមើលទំនាក់ទំនងនេះឱ្យច្បាស់ ការសិក្សាស្រាវជ្រាវបានដាក់បញ្ចូលការធ្វើតេស្តអំពីសមត្ថភាពរបស់សិស្សនៅក្នុងមុខវិជ្ជាចំនួនពីរ គឺគណិតវិទ្យា និងភាសាខ្មែរ។ សិស្សចំនួន២៩៥៧ បានធ្វើតេស្តដែលត្រូវបានឯកភាពជាមួយនាយកដ្ឋានបឋមសិក្សា និងនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា។ ការធ្វើតេស្តត្រូវបានរៀបចំ និងគ្រប់គ្រងដោយអ្នកស្រាវជ្រាវ ហើយសំនួរនៅក្នុងតេស្តនោះក៏មិនបានចែករំលែកជាមួយគ្រូបង្រៀននៅមុនពេលធ្វើតេស្តឡើយ។ គ្មានក្រុមធ្វើសាកពិសោធត្រូវបានគេប្រើប្រាស់ឡើយដោយសារតែការប្រៀបធៀបត្រូវបានគេធ្វើឡើងរវាងសិស្សនិងសិស្ស ដោយផ្អែកតាមអត្រាអវត្តមានគ្រូបង្រៀនរបស់ពួកគេ។ ចំពោះគោលបំណងនៃការវិភាគ យើងប្រើពិន្ទុសិស្សនៅក្នុងថ្នាក់របស់គ្រូបង្រៀននីមួយៗនៅក្នុងការសិក្សានេះ។ ពិន្ទុជាមធ្យមរបស់សិស្ស គឺ៦៦%នៃចម្លើយត្រឹមត្រូវនៅក្នុងតេស្តទាំងពីរមុខវិជ្ជា ប៉ុន្តែមានភាពខុសគ្នាអាស្រ័យទៅលើគ្រូបង្រៀនរបស់ពួកគេ និងទៅតាមទីតាំងសាលារៀន ។

### ពិន្ទុតេស្តរបស់សិស្ស និងអវត្តមានគ្រូបង្រៀន (Student test scores and teacher absence)

លទ្ធផលនៃការធ្វើតេស្តរបស់សិស្សត្រូវបានគេដាក់បញ្ចូលជាមួយអវត្តមានរបស់គ្រូបង្រៀន ហើយទិន្នន័យនេះបានបង្ហាញថាអវត្តមានរបស់គ្រូបង្រៀនជាប់ទាក់ទងជាអវិជ្ជមានជាមួយពិន្ទុតេស្តរបស់សិស្សនៅក្នុងមុខវិជ្ជាទាំង

ពីរ ( $r_{Math} = -0.22$, $p < .001$; $r_{Khmer} = -0.21$, $p < .001$ ) ។ សិស្សដែលបានរៀនជាមួយគ្រូបង្រៀន ដែលអវត្តមានច្រើនទំនងជាមិនសូវពូកែដូចសិស្សដែលបានរៀនជាមួយគ្រូបង្រៀនដែលអវត្តមានតិចតួចនោះទេ។ នៅពេលអត្រាអវត្តមានរបស់គ្រូបង្រៀនត្រូវបានចាត់ថ្នាក់ជាបីប្រភេទ លំនាំនេះលេចចេញកាន់តែច្បាស់។ ភាពខុសប្លែកគ្នានេះកើតមានឡើងនៅពេលណាដែលអវត្តមានរបស់គ្រូបង្រៀនបានកើនឡើងលើសពី ៥%។

តារាង:ទី១១៖ ពិន្ទុតេស្តសិស្សប្រៀបធៀបទៅនឹងអត្រាអវត្តមានគ្រូបង្រៀន

| អវត្តមានគ្រូបង្រៀន | ពិន្ទុគណិតវិទ្យា | | ពិន្ទុភាសាខ្មែរ | | មុខវិជ្ជាទាំងពីរ | |
|---|---|---|---|---|---|---|
| | ជាមធ្យម | គម្លាតស្តង់ដារ | ជាមធ្យម | គម្លាតស្តង់ដារ | ជាមធ្យម | គម្លាតស្តង់ដារ |
| **៥% និងតិចជាង** | 77% | .19 | 73% | .20 | 75% | .19 |
| **៦% ទៅ ១០%** | 63% | .22 | 63% | .19 | 63% | .17 |
| **១១%ឡើងទៅ** | 62% | .24 | 62% | .19 | 62% | .17 |

រូបទី៣៤៖ ពិន្ទុតេស្តជាមធ្យមរបស់សិស្សទៅតាមអវត្តមានគ្រូ




ព័ត៌មានលម្អិតបន្ថែមទៀតគឺមានបង្ហាញក្នុងក្រាហ្វិក(scatterplot chart) ខាងក្រោមដែលបង្ហាញអំពីរបាយពិន្ទុសិស្សជាមធ្យមជាមួយនឹងអត្រាអវត្តមានរបស់គ្រូបង្រៀន និងនិន្នាការពិន្ទុថយចុះនៅពេលដែលអវត្តមានរបស់គ្រូកាន់តែកើនឡើង។

រូបទី ៣៥៖ របាយពិន្ទុតេស្តរបស់សិស្សទៅតាមអត្រាអវត្តមានរបស់គ្រូ




យោងតាមការសង្កេតពីភាពខុសប្លែកគ្នាយ៉ាងច្រើនរវាងការផ្តល់អប់រំនៅទីប្រជុំជន និងជនបទ ភាពខុសគ្នានៃលទ្ធផលសិក្សាសិក្សារបស់សិស្សអាចទទួលរងផលប៉ះពាល់ច្រើនដោយសារទីតាំងសាលារៀន និងបញ្ហាដែលពាក់ព័ន្ធផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងកម្រិតគុណវឌ្ឍរបស់គ្រូបង្រៀនជាជាងវត្តមានរបស់គ្រូបង្រៀន។ តាមពិត សិស្សនៅតំបន់ទីប្រជុំជនគឺធ្វើតេស្តបានពិន្ទុខ្ពស់ជាងសិស្សដែលរៀននៅទីជនបទច្រើន ( $p$< .001 )។

តារាងទី ១២៖ ពិន្ទុតេស្តរបស់សិស្សទៅតាមទីតាំងសាលារៀន

| ពិន្ទុតេស្ត | គណិតវិទ្យា(ភាគរយ នៃចម្លើយត្រឹមត្រូវ) | ភាសាខ្មែរ (ភាគរយ នៃចម្លើយត្រឹមត្រូវ) | មុខវិជ្ជាទាំងពីរ |
|---|---|---|---|
| ពិន្ទុជាមធ្យមរួម | ៦៥.៦២ % | ៦៥.៧០ % | ៦៥.៧២ % |
| ពិន្ទុជាមធ្យមរបស់សិស្សរៀននៅទីប្រជុំជន | ៧១.៦៤ % | ៧៣.៦១ % | ៧២.៦០ % |
| ពិន្ទុជាមធ្យមរបស់សិស្សរៀននៅជនបទ | ៦១.៩៥ % | ៦០.៩០ % | ៦១.៥២ % |

ទោះបីយ៉ាងណាក៏ដោយ នៅពេលយើងពិនិត្យមើលតែសិស្សដែលនៅជនបទ គឺមានការជាប់ទាក់ទងគ្នារវាងវត្តមានរបស់គ្រូបង្រៀន និងសមត្ថភាពរបស់សិស្ស។ តំបន់ជនបទ វត្តមានរបស់គ្រូបង្រៀនមានកម្រិតកាន់តែខ្ពស់គឺបានរួមចំណែកធ្វើឱ្យលទ្ធផលនៃការធ្វើតេស្តរបស់សិស្សកាន់តែប្រសើរឡើង។ វាជាការគួរឱ្យកត់សម្គាល់ដែរថាស្តង់ដារលំអៀងគឺមានកាន់តែខ្ពស់ក្នុងចំណោមសិស្សដែលរៀននៅជនបទ ដែលបញ្ជាក់ពីលទ្ធផលតេស្តរបស់សិស្សម្នាក់ៗមានភាពខុសប្លែកគ្នាយ៉ាងខ្លាំង។

តារាងទី១៤៖ ពិន្ទុតេស្តរបស់សិស្សនៅតំបន់ជនបទទៅតាមអត្រាអវត្តមានរបស់គ្រូ

| **អវត្តមានគ្រូបង្រៀន** | **ពិន្ទុគណិតវិទ្យា** | | **ពិន្ទុភាសាខ្មែរ** | | **មុខវិជ្ជាទាំងពីរ** | |
|---|---|---|---|---|---|---|
| | ជាមធ្យម | គម្លាតស្តង់ដារ | ជាមធ្យម | គម្លាតស្តង់ដារ | ជាមធ្យម | គម្លាតស្តង់ដារ |
| **៥% ចុះ** | 74% | .23 | 66% | .21 | 70% | .20 |
| **6% ទៅ 10%** | 63% | .24 | 60% | .19 | 62% | .18 |
| **11% ឡើងទៅ** | 59% | .25 | 60% | .18 | 60% | .18 |

រូបទី ៣៦៖ ពិន្ទុតេស្តជាមធ្យមរបស់សិស្សនៅជនបទ ទៅតាមអវត្តមានគ្រូ




## ពិន្ទុតេស្តរបស់សិស្ស និងការបង្រៀនមេរៀនមិនគ្រប់ម៉ោង

នៅពេលដែលអត្រាអវត្តមានេរបស់គ្រូត្រូវបានគេចាត់ចំណាត់ថ្នាក់ជាបួនក្រុម ស្ថិតិបានបង្ហាញឱ្យឃើញថា សិស្សដែលរៀនជាមួយគ្រូដែលបង្រៀនច្រើននាទីធ្វើតេស្តបានល្អខ្លាំងជាងសិស្សដែលរៀនជាមួយគ្រូដែលបង្រៀនតិចនាទី ទាំងមុខវិជ្ជាទាំងពីគឺភាសាខ្មែរ និងគណិតវិទ្យា។ នៅពេលដែលពិន្ទុតេស្តរបស់សិស្សត្រូវបានគេពិនិត្យទៅលើភាពជាប់ពាក់ព័ន្ធ ជាមួយរយៈពេលនៃការបង្រៀនមេរៀនដែលត្រូវបានគេសង្កេត គេបានរក

ឃើញនូវទំនាក់ទំនងគួរឱ្យកត់សម្គាល់សម្រាប់ទាំងមុខវិជ្ជាគណិតវិទ្យា និងភាសាខ្មែរក្នុងកំរិត 0.01 (2-tailed)។សិស្សដែលបានរៀនជាមួយគ្រូបង្រៀន ដែលបានបង្រៀនពេញម៉ោង – មិនចាប់ផ្តើមបង្រៀនយឺត ឬមិនចេញមុនម៉ោង មានសមត្ថភាពប្រសើរជាងសិស្សដែលមិនទទួលបានការបង្រៀនពេញម៉ោង ដោយសារគ្រូមកបង្រៀនមិនទាន់ម៉ោង និង/ឬចេញមុនម៉ោង។

តារាងទី១៥៖ ពិន្ទុជាមធ្យមរបស់សិស្ស ធៀបទៅនឹងចំនួននាទីដែលបានបង្រៀនដោយគ្រូ

| ចំនួននាទីដែលបង្រៀន | ពិន្ទុគណិតវិទ្យា | | ពិន្ទុភាសាខ្មែរ | | ពិន្ទុទាំងពីរមុខវិជ្ជា | |
|---|---|---|---|---|---|---|
| | មធ្យមភាគ | គម្លាតស្តង់ដារ | មធ្យមភាគ | គម្លាតស្តង់ដារ | មធ្យមភាគ | គម្លាតស្តង់ដារ |
| **លើសពី 191** | 72% | .20 | 68% | .20 | 70% | .17 |
| **171 ដល់ 190** | 67% | .24 | 67% | .20 | 67% | .19 |
| **151 ដល់ 170** | 58% | .27 | 62% | .18 | 60% | .19 |
| **150 ឬតិចជាង** | 49% | .23 | 55% | .21 | 52% | .19 |

រូបទី ៣៧៖ ពិន្ទុជាមធ្យមរបស់សិស្ស ទៅតាមរយៈពេលនាទីបង្រៀនរបស់គ្រូក្នុងមួយថ្ងៃ




នៅពេលដែលយើងចាត់ថ្នាក់ទិន្នន័យទៅតាមតំបន់ជនបទ និងទីប្រជុំជន នោះការវិភាគបានបង្ហាញពីទំនាក់ទំនងរវាងរយៈពេលដែលគ្រូបានបង្រៀនក្នុងថ្នាក់ប្រចាំថ្ងៃជាមួយនឹងលទ្ធផលសិក្សារបស់សិស្សទាំងនៅសាលារៀនតំបន់ជនបទ និងទីប្រជុំជន។ រយៈពេលគ្រូបង្រៀនក្នុងថ្នាក់កាន់តែ

វែងគឺ នាំឱ្យលទ្ធផលសិក្សារបស់សិស្សតាមរយៈការធ្វើតេស្តនៅក្នុងការសិក្សានេះកាន់តែប្រសើរ មិនថានៅសាលារៀនជនបទ ឬទីប្រជុំជនឡើយ។

រូបភាពចំណុចៗខាងក្រោមបង្ហាញពីទំនាក់ទំនងរវាងពិន្ទុភាសាខ្មែរ និងរយៈពេលជាមធ្យមដែលគ្រូបង្រៀននៅក្នុងថ្នាក់។

រូបទី ៣៨៖ ពិន្ទុភាសាខ្មែរ ធៀបនឹងចំនួននាទីដែលបានបង្រៀន




ទំនាក់ទំនងរវាងពិន្ទុតេស្តរបស់សិស្ស និងវត្តមានតិចតួចរបស់គ្រូបង្រៀនមិនអាចបញ្ជាក់អំពីហេតុ និងផលរបស់វាបានទេ ហើយក៏ពុំមានការជាប់ពាក់ព័ន្ធជាចាំបាច់រវាងគុណភាពនៃការបង្រៀន និងវត្តមានរបស់គ្រូបង្រៀនដែរ។ ទោះបីជាយ៉ាងណាក៏ដោយ លទ្ធផលទាំងនេះផ្តល់នូវភស្តុតាងមួយចំនួនក្នុងប្រទេសកម្ពុជាស្របគ្នាជាមួយនឹងការសិក្សាស្រាវជ្រាវនៅថ្នាក់អន្តរជាតិស្តីពីសារៈសំខាន់នៃម៉ោងបង្រៀន និងរៀនចំពោះលទ្ធផលនៃការសិក្សារបស់សិស្ស។ នេះមិនមែនជាការមួយគួរឱ្យភ្ញាក់ផ្អើលនោះទេដោយសារតែការរៀន និងបង្រៀននៅក្នុងប្រទេសកម្ពុជាគឺកើតមានតែនៅក្នុងថ្នាក់រៀនតែប៉ុណ្ណោះ។ ការសិក្សាថ្មីៗបានបង្ហាញថាគ្រូបង្រៀនដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់ការសិក្សារបស់សិស្ស ដោយហេតុថាសិស្សកម្រនឹងមានការធ្វើស្វ័យសិក្សា និងការសិក្សាដោយឯករាជ្យណាស់(Heng, ២០១៣)។ លើសពីនេះទៀតកម្មវិធីសិក្សាគំរូដែលបានប្រើប្រាស់ក្នុងប្រទេសកម្ពុជា ដែលស្ថិតក្នុងការគ្រប់គ្រងពីថ្នាក់កណ្តាល គេបានកំណត់ចំនួនមេរៀនដែលត្រូវបង្រៀនសម្រាប់មុខវិជ្ជានីមួយៗ និងមានការបត់បែនតិចតួចតែប៉ុណ្ណោះ។ នៅពេលដែលមានការថយចុះនូវម៉ោងបង្រៀន ជាពិសេសនៅពេលដែលមេរៀនទាំងមូល ឬថ្ងៃសិក្សាទាំងមូលត្រូវបានបាត់ នេះគឺបានបង្កើននូវសម្ពាធលើការបង្រៀនមេរៀនឱ្យទាន់កម្មវិធីសិក្សា ហើយយើងអាចសន្និដ្ឋានបានថាគ្រូបង្រៀនទំនងជាមិនអាចបង្រៀនមេរៀនឱ្យបានពេញលេញទៅតាមកម្មវិធីសិក្សាដែលបានកំណត់នោះទេ។

ក្នុងកំឡុងពេលនៃការសម្ភាសជាមួយគ្រូបង្រៀនដែលបានចូលរួមក្នុងការសិក្សានេះ គេបានសួរសំណួរថា តើកម្មវិធីសិក្សាបច្ចុប្បន្ននៅថ្នាក់បឋមសិក្សា ជាក់ស្តែងគ្រូបង្រៀនអាចបង្រៀនបានដល់ត្រឹមមេរៀនណា នៅក្នុងរយៈ ពេលនៃឆ្នាំសិក្សាដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។ នៅគ្រប់មុខវិជ្ជាទាំងអស់ គ្រូបង្រៀនប្រមាណជា២០% បានមានប្រសាសន៍ថាកម្មវិធីសិក្សាវែងពេកហើយមិន អាចបញ្ចប់នៅក្នុងរយៈ ពេលនៃឆ្នាំសិក្សាដែលបានកំណត់ទេ។ គ្រូបង្រៀនក៏បានពន្យល់ផងដែរថាពួកគាត់ យល់ឃើញថាមេរៀននីមួយៗនៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាគណិតវិទ្យាត្រូវចំណាយពេលយូរជាងនេះពីព្រោះ ត្រូវមានការពន្យល់សិស្សឱ្យបានពិស្តារ។ របាយការណ៍ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ១៩៩៩ ស្តីពីម៉ោង បង្រៀនបានបញ្ជាក់ថា៖ "ចំនួនម៉ោងបង្រៀនដែលសិស្សនៅថ្នាក់បឋមសិក្សាបានទទួលនៅក្នុងប្រទេសកម្ពុជា មិនទាន់គ្រប់គ្រាន់នោះទេ ដើម្បីឱ្យឆ្លើយតបជាមួយកម្មវិធីសិក្សា ហើយស្ថិតនៅក្រោមស្តង់ដារអន្តរជាតិយ៉ាងខ្លាំង ចំពោះចំនួនម៉ោងបង្រៀនដែលចាំបាច់ត្រូវធ្វើឱ្យស្របគ្នាជាមួយស្តង់ដារដែលបានកំណត់"។

រូបទី៣៩៖ ទស្សនៈយល់ឃើញរបស់គ្រូបង្រៀនស្តីពីកម្មវិធីសិក្សាធៀបជាមួយរយៈពេលនៃឆ្នាំសិក្សា




ជាលទ្ធផល គម្លាតរវាងចំនួនម៉ោងបង្រៀនជាក់ស្តែង និងចំនួនម៉ោងបង្រៀនដែលគេបានកំណត់ គ្រូបង្រៀនបានបញ្ជាក់ឱ្យដឹងថាពួកគាត់មានការលំបាកក្នុងការបញ្ចប់ឱ្យបានគ្រប់មេរៀនទាំងអស់នៅក្នុងកម្មវិធីសិក្សា ដែលធ្វើឱ្យមានផលប៉ះពាល់ជាពិសេសទៅលើមុខវិជ្ជាសិក្សាសង្គម និងវិទ្យាសាស្ត្រ ដែលគ្រូបង្រៀនជាងមួយភាគប្រាំបានរាយការណ៍ថាពួកគាត់មិនបានបញ្ចប់តាមកម្មវិធីសិក្សាទេ។ គ្រូបង្រៀនជាញឹកញាប់បានមានប្រសាសន៍ថាពួកគាត់ត្រូវការពេលវេលាច្រើនបន្ថែមទៀតដើម្បីពន្យល់ខ្លឹមសារមេរៀនក្នុងកម្មវិធីសិក្សាលើសពីពេលវេលា ដែលគេបានកំនត់នៅក្នុងសៀវភៅសិក្សាគោលរបស់សិស្ស និងសៀវភៅណែនាំសម្រាប់គ្រូបង្រៀន។

ប្រឈមទៅនឹងការជ្រើសរើសថាតើត្រូវផ្តោតលើមុខវិជ្ជាណាមួយ គ្រូបង្រៀនបានរាយការណ៍ថាពួកគាត់បានចំណាយពេលវេលាច្រើនទៅលើមុខវិជ្ជាគណិតវិទ្យា និងភាសាខ្មែរ ដែលធ្វើឱ្យពួកគាត់នៅសល់ចំនួនម៉ោងតិចតួចដើម្បីបង្រៀនមេរៀនទាំងអស់នៅក្នុងមុខវិជ្ជាសិក្សាសង្គម និងវិទ្យាសាស្ត្រ។

រូបទី៤០៖ បទពិសោធន៍គ្រូបង្រៀនកាលពីឆ្នាំកន្លងទៅក្នុងការបញ្ចប់មេរៀន




បញ្ហាថាតើកម្មវិធីសិក្សាថ្នាក់ជាតិអាចត្រូវបានគ្រូបង្រៀនចប់ឬទេក្នុងចំនួនម៉ោងដែលមានសម្រាប់គ្រូ និងសិស្សគឺជាចំណុចមួយដ៏សំខាន់មួយ។ ការពុំបានគ្របដណ្តប់ខ្លឹមសារមេរៀនឱ្យបានពេញលេញធ្វើឱ្យសិស្សជួបការលំបាកក្នុងការធ្វើតេស្ត និងការប្រឡង ជាពិសេសការធ្វើតេស្តស្តង់ដារ និងតេស្តថ្នាក់ជាតិ ហើយជាទ្រឹស្តីវាធ្វើឱ្យសិស្សមិនសូវចាប់បានខ្លឹមសារមេរៀននៅពេលដែលពួកគេបន្តទៅរៀននៅថ្នាក់បន្ទាប់ទៀត ដោយសារពួកគេមិនបានយល់ពីខ្លឹមសារមេរៀនពីមុន។

## ៤.៤ ការត្រួតពិនិត្យតាមដានសាលារៀន និងគ្រូបង្រៀនដើម្បីធានាឱ្យបាននូវការបង្រៀន

តាមរយៈការសម្ភាសទាំងជាមួយគ្រូបង្រៀន និងនាយកសាលា យើងបានពិនិត្យមើលវិធីសាស្ត្រនានាក្នុងការត្រួតពិនិត្យសាលារៀន និងការបង្រៀនដែលបានរួមចំណែកដល់ការធានាបាននូវវត្តមានជាប្រចាំរបស់គ្រូបង្រៀន និងការបើកទ្វារសាលារៀនដើម្បីដំណើរការបង្រៀនតាមម៉ោងជាទៀតទាត់។ គ្រូបង្រៀន និងនាយកសាលាត្រូវបានគេសម្ភាសយ៉ាងលម្អិតអំពីយន្តការនៃការអនុវត្តម៉ោងបង្រៀន អវត្តមានគ្រូ និងការត្រួតពិនិត្យតាមដានដែលមានស្រាប់។ ចំណុចនេះរាប់បញ្ចូលទាំងការប្រើប្រាស់គោលនយោបាយបុគ្គលិកដែលមាននាពេលបច្ចុប្បន្នដើម្បីមានលទ្ធភាពគ្រប់គ្រងបុគ្គលិកនៅសាលារៀនបឋមសិក្សាឱ្យបានល្អ។

### ៤.៤.១ ការត្រួតពិនិត្យ និងអធិការកិច្ចរបស់ក្រសួងអប់រំ មន្ទីរអប់រំខេត្ត និងការិយាល័យអប់រំស្រុក

អធិការកិច្ចសាលារៀន គឺជាអាទិភាពមួយក្នុងចំណោមអាទិភាពកំណែទម្រង់នាពេលបច្ចុប្បន្នរបស់ក្រសួងអប់រំ យុវជន និងកីឡា ហើយប្រព័ន្ធអធិការកិច្ចផ្ទៃក្នុង និងពីខាងក្រៅត្រូវបានគេបង្កើតឡើងថ្មី

មានលក្ខណៈទូលំទូលាយ ហើយដែលប្រព័ន្ធថ្មីនេះកំពុងត្រូវបានគេអនុវត្ត។ ការងារប្រមូលព័ត៌មាននៅតាមសាលារៀនសម្រាប់ការសិក្សានេះ ត្រូវបានធ្វើឡើងមុនពេលប្រព័ន្ធនេះត្រូវបានបង្កើតឡើង ប៉ុន្តែអាចផ្តល់នូវការគិតគូពិចារណាមួយចំនួនសម្រាប់ការអនុវត្តក្របខ័ណ្ឌការងារថ្មីនេះ។

នៅក្នុងឆ្នាំ២០១០ ក្រសួងអប់រំ យុវជន និងកីឡា បានចេញនូវសេចក្តីណែនាំមួយក្នុងគោលបំណងពង្រឹងការអនុវត្តនូវសេចក្តីប្រកាសស្តីពីបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រឹះស្ថានបឋមសិក្សាសាធារណៈ ដើម្បីធានាបាននូវគុណភាពនៃសេវាអប់រំដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងផែនការសកម្មភាពជាតិដើម្បីការអប់រំសម្រាប់ទាំងអស់គ្នា (សេចក្តីណែនាំរបស់ក្រសួងអប់រំលេខ២១ ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ2010)។ សេចក្តីណែនាំនេះបញ្ជាក់ថា *"គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ទាំងអស់ "ត្រូវអនុវត្តម៉ោងបង្រៀនដោយផ្អែកលើប្រតិទិនសិក្សារបស់សាលារៀន"*។ ជាងនេះទៅទៀត ក្រសួងអប់រំ យុវជននិងកីឡាក៏បានណែនាំឱ្យ ៖

- *"រៀបចំយន្តការបន្ថែមដោយប្រើប្រាស់ក្រុមការងាររបស់មន្ទីរ រួមជាមួយក្រុមបំប៉ន និងពិនិត្រតាមដានថ្នាក់ក្រុង ស្រុក ខ័ណ្ឌ(DTMT) ចុះពិនិត្យតាមដានតំណើរការ សាលារៀន រៀងរាល់ពេលចាប់ផ្តើមបវេសនកាលរហូតដល់មហាវិស្សមកាល ជាពិសេសនៅមុន និងក្រោយពេលវិស្សមកាលតូច និងក្នុងអំឡុងពេលរៀបចំសម័យប្រឡង ដោយមានវិធានការទប់ស្កាត់បាតុភាពអសកម្មដែលអាចកើត មានឡើងឱ្យបានទាន់ពេលវេលា។*
- *ធ្វើការសម្របសម្រួលជាបន្ទាន់ ជាមួយអ្នកពាក់ព័ន្ធក្នុង (អាជ្ញាធរភូមិ ឃុំ សង្កាត់ សហគមន៍ មាតាបិតា សិស្ស និងគ្រូបង្រៀន) ក្នុងករណីដែលសាលារៀនមានដំណើរការមិនប្រក្រតីដោយប្រការណាមួយ ដើម្បីបញ្ចៀស និងទប់ស្កាត់បានទាន់ពេលវេលានូវការផ្អាក ឬបិទសាលារៀនខុសគោលការណ៍ ដែលនាំដល់ការបោះបង់ការសិក្សា និងផលប៉ះពាល់ដល់គុណភាពនៃការសិក្សារបស់សិស្ស។*

សេចក្តីណែនាំនេះបានទទួលស្គាល់យ៉ាងច្បាស់លាស់ ពីហានិភ័យនៃការបិទសាលារៀននៅស្របពេលដែលការសិក្សានេះក៏បានរកឃើញថាមានការបិទសាលារៀនជាញឹកញាប់។ នាយកសាលាដែលបានសម្ភាសបានប្រាប់ឱ្យដឹងថា មានការត្រួតពិនិត្យមួយចំនួនត្រូវបានធ្វើឡើងនៅសាលារៀនរបស់ពួកគាត់ ពីសំណាក់ក្រុមការងារនៅថ្នាក់កណ្តាលរបស់ក្រសួងអប់រំ មន្ទីរអប់រំខេត្ត ឬការិយាល័យអប់រំស្រុក។ នាយកសាលាចំនួន៥៦%បានលើកឡើងថា ការចុះត្រួតពិនិត្យតាមដានត្រូវបានធ្វើឡើងចំនួន២ដងក្នុងមួយឆ្នាំ។ រូបខាងក្រោមបង្ហាញពីភាពញឹកញាប់នៃការការត្រួតពិនិត្យសាលារៀនពីសំណាក់មន្ត្រីថ្នាក់ក្រសួង មន្ទីរអប់រំខេត្ត និងការិយាល័យអប់រំស្រុក តាមការបញ្ជាក់របស់នាយកសាលា ។

ទោះជាយ៉ាងណាក៏ដោយ ពុំមាននាយកសាលាណាម្នាក់ដែលបានសម្ភាសបាននិយាយថា សាលារៀនរបស់ពួកគាត់ត្រូវបានត្រួតពិនិត្យ ឬទស្សនកិច្ចពីសំណាក់ក្រុមការងារពិនិត្យតាមដាន និងបំប៉នថ្នាក់ស្រុក (DTMT) នៅក្នុងអំឡុងពេលមុន និងក្រោយវិស្សមកាលតូចនៅក្នុងខែមេសា ឆ្នាំ២០១៣ទៅតាមសេចក្តីណែនាំខាងលើទេ។ ចំណុចនេះមានន័យថា DTMT ពុំបានកំនត់នូវសាលារៀនដែលដំណើរការមិនទៀងទាត់នៅក្នុងអំឡុងពេលទាំងនេះទេ ហើយក៏មិនបានប្រមូលនូវភស្តុតាងសម្រាប់ធ្វើសកម្មភាពជាបន្តដែរ។ វាក៏មានសារៈសំខាន់ក្នុងការកត់សម្គាល់ថាក្នុងកំឡុងពេលកំពុងសរសេររបាយការណ៍នេះ ការចុះអធិការកិច្ចរបស់DTMTទៅកាន់សាលារៀនត្រូវបានគេប្រកាសឱ្យដឹងជាមុន ហេតុដូច្នេះហើយវាទំនងជាមិនមានការរកឃើញអំពីបញ្ហាទាំងនេះទេ។

រូបទី៤១ ៖ ភាពញឹកញាប់នៃការត្រួតពិនិត្យតាមដានដែលបានធ្វើឡើងដោយក្រសួងអប់រំ មន្ទីរអប់រំខេត្ត និងការិយល័យ អប់រំស្រុក




បើយោងតាមចម្លើយរបស់គ្រូបង្រៀន ការត្រួតពិនិត្យតាមដាន និងអធិការកិច្ចពីសំណាក់មន្ត្រីក្រសួងអប់រំ មន្ទីរអប់រំ ខេត្ត និងការិយាល័យអប់រំស្រុក ភាគច្រើនគឺផ្តោតទៅលើបរិស្ថានថ្នាក់រៀន ការធ្វើកិច្ចតែងការមេរៀន និងវិធីសាស្ត្របង្រៀន។ មានតែគ្រូបង្រៀនតែ២-៣នាក់ប៉ុណ្ណោះដែលបាននិយាយថា អនុសាសន៍នានាក្នុងពេលចុះពិនិត្យតានដានបានដាក់បញ្ចូលនូវការពង្រឹងវត្តមាន និងការគោរពម៉ោងពេលរបស់គ្រូបង្រៀន។ នាយកសាលាបានលើកឡើងថាចំពោះការត្រួតពិនិត្យតាមដានផ្នែកគ្រប់គ្រងបុគ្គលិក គឺត្រូវបានគេប្រគល់កិច្ចការនេះជូនគាត់។

វាជាសញ្ញាវិជ្ជមានមួយដែលការត្រួតពិនិត្យ និងអធិការកិច្ចសាលារៀនផ្តោតទៅលើបញ្ហាគុណភាព ប៉ុន្តែវាក៏មាន សារៈសំខាន់ដែរដែលគេត្រូវពិនិត្យមើលទៅលើបញ្ហាគន្លឹះដូចជា ការបង្រៀនទៅតាមប្រតិទិនសិក្សារបស់សាលារៀន និងវត្តមានរបស់គ្រូបង្រៀនដូចដែលបានកំណត់នៅក្នុងសេចក្តីណែនាំថ្នាក់ជាតិ។ ចំណុចនេះបង្កឱ្យមានការព្រួយបារម្ភមួយថាវត្តមានរបស់គ្រូបង្រៀន និងការប្រកាន់ខ្ជាប់តាមម៉ោងបង្រៀនដែលបានកំនត់ ពុំត្រូវបានមន្ត្រី និងអ្នកគ្រប់គ្រងការងារអប់រំមើលឃើញថាជាបញ្ហាអាទិភាពទេ ហេតុដូច្នេះហើយទើបគ្រូបង្រៀន និង នាយកសាលាខ្លួនឯងពុំផ្តល់អាទិភាពទៅលើចំណុចទាំងនេះ។

### ៤.៨.២ ការត្រួតពិនិត្យគ្រូបង្រៀនពីសំណាក់នាយកសាលា

ក្រៅពីការត្រួតពិនិត្យដែលធ្វើឡើងដោយក្រសួងអប់រំ មន្ទីរអប់រំខេត្ត និងការិយាល័យអប់រំស្រុក នាយកសាលាបានបញ្ជាក់ពីការអនុវត្តត្រួតពិនិត្យតាមដានគ្រូបង្រៀនរបស់ពួកគាត់តាមវិធីសាស្ត្រផ្សេងៗ។ អធិការកិច្ចទៅលើថ្នាក់រៀន និងការបង្រៀនគឺជាវិធីសាស្ត្រទូទៅបំផុតនៃការត្រួតពិនិត្យតាមដាន ដែលត្រូវបានគេលើកឡើង។ តារាងខាងក្រោមនេះ ពិពណ៌នាពីវិធីសាស្ត្រខុសៗគ្នានៃការត្រួតពិនិត្យតាមដានគ្រូបង្រៀនពីសំណាក់នាយកសាលាដែលត្រូវបានគេលើឡើងក្នុងពេលសម្ភាស។ នាយកសាលាមួយចំនួនបានលើកឡើងពីការប្រើប្រាស់វិធីសាស្ត្រលើសពីមួយ។

តារាងទី១៦ ៖ វិធីសាស្រ្តនានាក្នុងការត្រួតពិនិត្យតាមដានដែលនាយកបានអនុវត្ត

| មធ្យោបាយនានាដែលនាយកសាលាត្រួតពិនិត្យគ្រូបង្រៀន | ចំនួនអ្នកឆ្លើយតប |
|---|---|
| ការធ្វើអធិការកិច្ចថ្នាក់រៀន និងការបង្រៀន | ២៩ |
| ពិនិត្យមើលបញ្ជីវត្តមានរបស់គ្រូបង្រៀន និងថ្នាក់រៀន | ១៣ |
| ត្រួតពិនិត្យកិច្ចតែងការបង្រៀន និងរដ្ឋបាលថ្នាក់រៀន | ១៣ |
| ដើរពិនិត្យសាលារៀន | ៧ |
| សង្កេតពីខាងក្រៅថ្នាក់រៀន | ៧ |
| ធ្វើអធិការកិច្ចថ្នាក់រៀន និងការផ្តល់យោបល់ត្រឡប់ | ៥ |
| ការវាយតម្លៃការបង្រៀន | ៤ |
| ការប្រជុំ | ២ |
| ពិនិត្យមើលរបាយការណ៍ស្វ័យវាយតម្លៃរបស់គ្រូបង្រៀន | ២ |

ចំនួនដងនៃការត្រួតនិត្យតាមដានគ្រូបង្រៀនដែលនាយកសាលាបានលើកឡើង មានភាពប្រែប្រួលយ៉ាងច្រើនដោយផ្អែកទៅលើវិធីសាស្រ្តនៃការត្រួតពិនិត្យដែលគេប្រើប្រាស់។ នាយកសាលាភាគច្រើនមានប្រសាសន៍ថា ពួកគាត់បានធ្វើអធិការកិច្ចថ្នាក់រៀនចំនួនមួយ ឬពីរដងក្នុងមួយខែ។ អធិការកិច្ចថ្នាក់រៀនត្រូវបាន គេផ្តោតទៅលើវិធីសាស្រ្តនៃការបង្រៀន និងការគ្រប់គ្រងថ្នាក់រៀន ក្នុងគោលបំណងផ្តល់នូវព័ត៌មានត្រឡប់ ក្នុងន័យស្ថាបនា ដែលនឹងជួយឱ្យគ្រូបង្រៀនមានការរីកចម្រើន។ នាយកសាលាចំនួន១៣នាក់មានប្រសាសន៍ថា ពួកគាត់ត្រួតពិនិត្យអវត្តមានរបស់គ្រូបង្រៀនរបស់ខ្លួនតាមរយៈការពិនិត្យបញ្ជីវត្តមាន និងការអង្កេតថ្នាក់រៀន។

ចំនួនដងនៃការត្រួតពិនិត្យគ្រូបង្រៀនមានភាពខុសគ្នាយ៉ាងខ្លាំងពីសាលារៀនមួយទៅសាលារៀនមួយដោយផ្អែកលើការគ្រប់គ្រង។ នាយកសាលាចំនួន៣៤%បាននិយាយថាបានត្រួតពិនិត្យបុគ្គលិករបស់ខ្លួនមួយ ឬពីរដងក្នុងមួយខែ ចំណែកឯ៥៤%ផ្សេងទៀតបាននិយាយថាពួកគាត់បានធ្វើដូច្នេះញឹកញាប់ជាងនេះទៅទៀត។ ចំនួនដងនៃការត្រួតពិនិត្យដែលនាយកសាលាបានលើកឡើង ពុំមានភាពខុសប្លែគ្នាជាដុំកំភួនពីតំបន់ជនបទទៅទីប្រជុំជនទេ។

រូបទី៤២ ៖ ចំនួនដងនៃការត្រួតពិនិត្យតាមដានគ្រូបង្រៀនពីសំណាក់នាយកសាលា



គួរកត់សម្គាល់ថា នាយកសាលាជាង៥០%បានលើកឡើងថា បានចុះត្រួតពិនិត្យតាមដានថ្នាក់រៀន នៅពេលណាមួយនៅម៉ោងទី២ ឬនៅមួយម៉ោងមុនពេលចេញទៅផ្ទះ។ ចំណុចនេះមានន័យថា ប្រសិនបើគ្រូបង្រៀនចាប់ផ្តើមថ្នាក់រៀនយឺត ឬចេញទៅផ្ទះមុនម៉ោង ពួកគាត់មិនត្រូវបានគេសង្កេតនៅក្នុងសកម្មភាពត្រួតពិនិត្យតាមដានឡើយ។ ជាថ្មីម្តងទៀត ចំណុចនេះបង្ហាញថា ប្រព័ន្ធត្រួតពិនិត្យតាមដានអវត្តមាន និងការគោរពម៉ោងពេលរបស់គ្រូបង្រៀន គឺមិនមានអាទិភាពទាប។

រូបទី៤៣ ៖ ពេលវេលាដែលនាយកសាលាចុះត្រួតពិនិត្យតាមដានថ្នាក់រៀន




ស្រដៀងគ្នាទៅនឹងការត្រួតពិនិត្យតាមដានពីក្រសួងអប់រំ មន្ទីរអប់រំខេត្ត និងការិយាល័យអប់រំស្រុកដែរ គ្រូបង្រៀនបានលើកឡើងថា ការត្រួតពិនិត្យពីសំណាក់នាយកសាលាក៏មានប្រយោជន៍ដើម្បីលើកកម្ពស់ការអនុវត្តន៍របស់ខ្លួនដែរ ជាពិសេស ការតុបតែងថ្នាក់រៀន ជំនាញក្នុងការបង្រៀន និងការផលិតសម្ភារបង្រៀន។ គ្រូបង្រៀនតែ២-៣នាក់ប៉ុណ្ណោះបាននិយាយថា អនុសាសន៍របស់នាយកសាលារួមមាន បញ្ហាអវត្តមាន និងការគោរពម៉ោងពេលរបស់គ្រូបង្រៀន និងសិស្ស។ ទោះជាយ៉ាងណាក៏ដោយ នាយកសាលាបានផ្តល់នូវទស្សនៈយល់ឃើញផ្ទុយគ្នាពីគ្រូបង្រៀន។ នាយកសាលាចំនួន៦៥%បានប្រាប់ឱ្យដឹងថា ការត្រួតពិនិត្យតាមដានរបស់ពួកគាត់ រួមចំណែកដល់ការកែលម្អការគោរពម៉ោងពេលនិងវត្តមានរបស់គ្រូបង្រៀន ចំណែកឯ ២៥%ទៀតបានបញ្ជាក់ថា បានរួមចំណែកដល់ការកែលម្អជំនាញក្នុងការបង្រៀន និងការគ្រប់គ្រងថ្នាក់រៀន។

តារាងទី១៦ ៖ ទស្សនៈរបស់នាយកសាលាស្តីពីផលប៉ះពាល់នៃការត្រួតពិនិត្យតាមដានគ្រូបង្រៀន

| ផលប៉ះពាល់ | ចំនួនអ្នកឆ្លើយតប |
|---|---|
| ធ្វើឱ្យប្រសើរឡើងនូវការគោរពម៉ោងពេល និងវត្តមានរបស់គ្រូបង្រៀន | ៥៨ |
| ធ្វើឱ្យប្រសើរឡើងនូវជំនាញនៃការបង្រៀន និងការគ្រប់គ្រងថ្នាក់រៀន | ២២ |
| គ្រូបង្រៀនយកចិត្តទុកដាក់ថែមទៀតទៅលើការបង្រៀនរបស់ខ្លួន | ១៤ |
| ពុំមានការកែលម្អទេដោយសារគ្រូបង្រៀនជាប់រវល់នៅក្នុងការងារទី២របស់ខ្លួន | ៤ |
| គ្រូបង្រៀនយកចិត្តទុកដាក់ថែមទៀតទៅលើសិស្សរៀនយឺត | ២ |

បន្ថែមទៅលើការត្រួតពិនិត្យតាមដានជាផ្លូវការ នាយកសាលាបានប្រាប់ឱ្យដឹងថា ពួកគាត់បានជំរុញនិងលើកទឹកចិត្តគ្រូបង្រៀនឱ្យមកបង្រៀនបានទៀងទាត់ថែមទៀតទៅតាមមធ្យោបាយផ្សេងៗមួយចំនួន។

តារាងទី១៧៖ សកម្មភាពដែលនាយកសាលាបានធ្វើដើម្បីលើកទឹកចិត្តគ្រូឱ្យមកបង្រៀនទៀងទាត់

| សកម្មភាព | ចំនួនអ្នកឆ្លើយតប |
| --- | --- |
| ត្រួតពិនិត្យតាមដាន ផ្តល់ដំបូន្មាន និងលើកទឹកចិត្តគ្រូបង្រៀន | ៣១ |
| ផ្តល់លិខិតសរសើរដល់គ្រូបង្រៀនដែលមានស្នាដៃបំពេញការងារល្អ | ១២ |
| ផ្តល់គ្រឿងលើកទឹកចិត្ត | ៩ |
| ការប្រជុំប្រចាំខែ (ស្វែងយល់ពីបញ្ហា និងរកដំណោះស្រាយ) | ៨ |
| ការវាយតម្លៃប្រចាំឆ្នាំដើម្បីជ្រើសរើសគ្រូបង្រៀនល្អ | ៦ |
| ផ្តល់ឱកាស (ចូលរួមទស្សនកិច្ច សិក្ខាសាលា ឬតម្លើងកាំប្រាក់) | ៣ |
| ចូលរួមនៅក្នុងការងារសាលារៀន | ២ |
| នាយកដើរតួនាទីជាគម្រូសម្រាប់គ្រូបង្រៀន | ២ |
| ផ្តល់នូវព័ត៌មានត្រឡប់ដល់គ្រូបង្រៀនម្នាក់ៗ | ២ |

### ៤.៥.៣ វិធានការវិន័យដែលគេបានអនុវត្តក្នុងការឆ្លើយតបទៅនឹងអវត្តមានរបស់គ្រូបង្រៀន

តាមរយៈការសម្ភាសជាមួយគ្រូបង្រៀន និងនាយកសាលា ក្រុមការងារស្រាវជ្រាវបានព្យាយាមពិនិត្យមើលពីដំណើរការគ្រប់គ្រងបុគ្គលិកបច្ចុប្បន្ន ក្នុងការជានាបាននូវវត្តមានរបស់គ្រូបង្រៀន។ លទ្ធផលរកឃើញបង្ហាញពីភាពខុសគ្នាចំពោះយោបល់ និងការយល់ឃើញរវាងនាយកសាលា និងគ្រូបង្រៀន។ មួយផ្នែកនៃបញ្ហានេះគឺទាក់ទងទៅនឹងថាតើគ្រូបង្រៀនបានសុំច្បាប់អនុញ្ញាតសំរាកនៅពេលដែលខ្លួនអវត្តមានដែរឬទេ។ ឧទាហរណ៍ នាយកសាលា ៩០% (៣៥នាក់) បានប្រាប់ឱ្យដឹងថាគ្រូបង្រៀនបានអវត្តមានដោយពុំមានសុំការអនុញ្ញាត ឬច្បាប់ទេ ចំណែកឯគ្រូបង្រៀនវិញមានតែ១០% (២៩នាក់) ប៉ុណ្ណោះបានលើកឡើងថាពួកគាត់ធ្លាប់អវត្តមានដោយពុំមានសុំការអនុញ្ញាត ឬច្បាប់ពីនាយកសាលា។

នៅក្នុងប្រទេសកម្ពុជា អវត្តមានរបស់គ្រូបង្រៀនត្រូវបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡាតាមរយៈច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល សេចក្តីណែនាំស្តីពីការគ្រប់គ្រងបុគ្គលិក និងសេចក្តីប្រកាសផ្សេងៗទៀត ដែលត្រូវបានគេធ្វើឡើងរៀងរាល់ឆ្នាំសិក្សា។

ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា លេខ០៦ ន.ស.៩៤ អនុម័ត្រកាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ បានចែងថា៖

*"អ្នករាជការទាំងឡាយមិនអាចឈប់ធ្វើការដោយគ្មានទទួលបានការអនុញ្ញាតជាមុនពីថ្នាក់លើរបស់ខ្លួន ឬដោយគ្មានមូលហេតុត្រឹមត្រូវ។ ការឈប់ធ្វើការ ឬខកខានទៅធ្វើការដោយគ្មានការអនុញ្ញាត ឬដោយគ្មានមូលហេតុត្រឹមត្រូវ អាចបង្ខំឱ្យអ្នករាជការនោះនៅទំនេរគ្មានបៀវត្ស ឬត្រូវផ្អាកបៀវត្ស។ អ្នករាជការនោះអាចនឹងត្រូវទទួលទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា៤០ នៃច្បាប់នេះ"។*

ក្រោយមកក្រសួងបានចេញលិខិតលេខ ៧៣៨ នៅថ្ងៃទី ៩ខែឧសភា ឆ្នាំ១៩៩៤ ស្តីការពីការលុបឈ្មោះបុគ្គលិកអប់រំ ដែលកថាខ័ណ្ឌទី១ មានខ្លឹមសារដូចតទៅ:

*" ដើម្បីជានាឱ្យមានការឯកភាពក្នុងការលុបឈ្មោះបន្ត្រីរាជការ បុគ្គលិកសិក្សាចេញពីបញ្ជីក្របខ័ណ្ឌបុគ្គលិកកម្មការ ត្រូវផ្អែកលើល័ក្ខណ្ឌដូចតទៅ៖*

- *មន្ត្រីរាជការ បុគ្គលិកសិក្សាអវត្តមានលើសពី១៥ថ្ងៃដោយគ្មានការអនុញ្ញាត និងមូលហេតុត្រឹមត្រូវ*
- *មន្ត្រីរាជការ បុគ្គលិកសិក្សាចូលបំរើការងារថ្មី ហើយមិនព្រមទៅបំរើការងារតាមការចាត់តាំង និងរយៈពេលដែលមានចែងក្នុងប្រកាស ឬលិខិតឧទ្ទេសនាមរបស់ក្រសួង។*

មាត្រាទី ៤០: មាត្រានេះបរិយាយអំពីប្រភេទ និងកម្រិតនៃទណ្ឌកម្មដែលត្រូវអនុវត្តចំពោះគ្រូបង្រៀន ដូចតទៅនេះ៖

ទណ្ឌកម្មខាងវិន័យមានដូចតទៅ:

**ទណ្ឌកម្មថ្នាក់ទី ១:**

ក. ការស្តីបន្ទោស

ខ.ការស្តីបន្ទោសដោយមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន

គ. ផ្លាស់ដោយបង្ខំតាមវិធានការវិន័យ

ឃ. លុបឈ្មោះចេញពីតារាងឡើងឋានន្តរសក្តិ ឬថ្នាក់

**ទណ្ឌកម្មថ្នាក់ទី ២:**

ក) ការស្តីបន្ទោសជាទម្ងន់បណ្តាលឱ្យលុបឈ្មោះចេញពីតារាងឡើងឋានន្តរសក្តិ ឬថ្នាក់ បើសិនជាមានឈ្មោះហើយ ឬធ្វើឱ្យយឺតក្នុងការតម្លើងឋានន្តរសក្តិ ឬថ្នាក់ ក្នុងថេរវេលាមួយមានកំនត់ តែមិនត្រូវឱ្យលើសពី២ឆ្នាំក្នុងការតម្លើងឋានន្តរសក្តិ ឬថ្នាក់តាមវេនជ្រើសរើស ឬតាមវេនអតីតភាព។

ខ) ដាក់ឱ្យនៅទំនេរគ្មានប្រាក់បៀវត្សមិនលើសពីឆ្នាំ។

គ) បន្ថយឋានន្តរសក្តិ ឬថ្នាក់មួយថ្នាក់ ឬច្រើនថ្នាក់។

ឃ) ដាក់ឱ្យចូលនិវត្តន៍មុនកំណត់ ឬបញ្ឈប់ពីការងារដោយបង្ខំ។

ង) ការបណ្តេញចេញពីមុខតំណែងរាជការ។

ក្របខណ្ឌគោលនយោបាយធនធានមនុស្ស ចាត់ទុកនាយកសាលាថ្នាក់លើរបស់គ្រូបង្រៀន ដែលមានសិទ្ធិក្នុងការកាត់បន្ថយ ឬព្យួរប្រាក់បៀវត្សរបស់គ្រូបង្រៀនក្នុងករណីមានអវត្តមានឥតច្បាប់ ឬដើម្បីដាក់ពិន័យដល់គ្រូបង្រៀន។

ក្នុងពេលដែលសម្ភាសគ្រូបង្រៀន យើងបានសួរថាតើមានចំណាត់ការអ្វីខ្លះដែលគេនឹងអនុវត្តប្រសិនបើពួកគ្រូអវត្តមានពីសាលារៀនដោយពុំមានការអនុញ្ញាត។ គ្រូបង្រៀនចំនួន ៤០% បានមានប្រសាសន៍ថាពួកគាត់អាចទទួលបានការស្តីបន្ទោស ឬព្រមានជាលាយលក្ខអក្សរពីគណៈគ្រប់គ្រងសាលា។ មានគ្រូបង្រៀនតែពីរនាក់ប៉ុណ្ណោះបានលើកឡើងអំពីការកាត់បន្ថយប្រាក់បៀវត្ស ហើយគ្រូបង្រៀនស្ទើរតែមួយភាគប្រាំបានមានប្រសាសន៍ថាគ្មានចំណាត់ការអ្វីទាំងអស់។

គ្រូបង្រៀនចំនួន ៣៣នាក់ (១៣%) បានលើកឡើងថាពួកគាត់នឹងត្រូវបង្រៀនសងជំនួសនូវថ្ងៃដែលពួកគាត់បានអវត្តមាន។ ទោះបីយ៉ាងណាក៏ដោយ ពួកគាត់បានទទួលស្គាល់ថានេះគឺទំនងជាពុំអាចធ្វើទៅបានទេ ដោយហេតុថាពុំមានថ្ងៃបន្ថែមគ្រប់គ្រាន់សម្រាប់គ្រូយកមកបង្រៀនសងនោះទេ។

តារាង១៩: ផលវិបាកមកលើគ្រូបង្រៀនប្រសិនបើពួកគាត់អវត្តមានដោយពុំមានការអនុញ្ញាត (មានចម្លើយច្រើន)

| ផលវិបាកដែលអាចកើតមានចំពោះគ្រូបង្រៀនដោយសារអវត្តមានគ្មានការអនុញ្ញាត | ចំនួនចម្លើយ | % នៃចម្លើយ |
|---|---|---|
| គ្មានចំណាត់ការអ្វីទាំងអស់ | ៤៥ | ១៨% |
| កាត់ប្រាក់បៀវត្សរ៍ | ២ | ១% |
| បង្រៀនសងជំនួសវិញ | ៣៣ | ១៣% |
| ទទួលការព្រមាន | ១១៤ | ៤៦% |
| នាយកសាលាសួររកមូលហេតុ | ៥៣ | ២១% |

ការសម្ភាសជាមួយនាយកសាលា បានបង្ហាញអំពីចំណាត់ការមួយចំនួនដែលបានអនុវត្តចំពោះគ្រូបង្រៀនដែលអវត្តមានដោយពុំមានការអនុញ្ញាត រួមមានការដាក់ទណ្ឌកម្ម ដូចជាការស្តីបន្ទាស និងការណែនាំ ដូចដែលមានក្នុងតារាងខាងក្រោម។ ការស្តីបន្ទោសគឺត្រូវបានគេលើកឡើងជាញឹកញាប់បំផុតថាជាចំណាត់ការរបស់នាយកសាលាក្នុងការឆ្លើយតបទៅនឹងអវត្តមានគ្រូបង្រៀន។ ចំណុចនេះគឺវាមានសង្គតភាពជាមួយនឹងទស្សនៈរបស់គ្រូបង្រៀនប្រមាណជា ៤៦% ដែលបានលើកឡើងថាពួកគាត់នឹងទទួលបានការស្តីបន្ទោសប្រសិនបើពួកគាត់អវត្តមានដោយពុំមានការអនុញ្ញាតពីនាយកសាលានោះទេ។ ស្រដៀងគ្នានេះផងដែរ គ្រូបង្រៀនចំនួន ៣៣នាក់ (១៣%) បានរាយការណ៍ថាពួកគាត់ត្រូវបានគេស្នើឱ្យបង្រៀនសងជំនួសវិញនូវថ្ងៃដែលពួកគាត់ខកខានមិនបានបង្រៀន ស្របពេលដែលមាននាយកសាលាចំនួន ១១នាក់បានលើកឡើងថាពួកគាត់បានប្រើប្រាស់ការដាក់ទណ្ឌកម្មបែបនេះ។ មាននាយកសាលាតែពីរនាក់ប៉ុណ្ណោះ នៅក្នុងការសិក្សានេះ បានលើកឡើងថាបានចាត់វិធានការព្យួរ ឬកាត់ប្រាក់បៀវត្សគ្រូបង្រៀន ហើយគ្រូបង្រៀនចំនួនពីរនាក់ក្នុងចំណោម ៣០៩ នាក់និយាយផងដែរថាពួកគាត់បានទទួលនូវការកាត់ប្រាក់បៀវត្ស។

រូបភាពទី៤៤: ចំណាត់ការដែលនាយកសាលាបានអនុវត្តចំពោះគ្រូបង្រៀនដែលអវត្តមានដោយពុំមានការអនុញ្ញាត




## ៤.៥.៤ ទស្សនៈរបស់នាយកសាលាស្តីពីការពង្រឹងវត្តមានរបស់គ្រូបង្រៀន

នៅក្នុងកិច្ចសម្ភាស នាយកសាលាបានកត់សម្គាល់នូវបញ្ហាប្រឈមជាច្រើនក្នុងការកាត់បន្ថយអវត្តមានរបស់គ្រូបង្រៀន។ បញ្ហាដែលត្រូវបានគេលើកឡើងជាញឹកញាប់បំផុតគឺគ្រូបង្រៀនមញ្ញាញឹកក្នុង ការងារផ្ទាល់ខ្លួនរបស់គាត់ មានដូចជា ការមើលថែកូន ការរកប្រាក់ចំណូលផ្សេងទៀត និងការទៅសិក្សាបន្ត។ នាយកសាលាបានសំដែងនូវក្តីបារម្ភថាមានពិបាកក្នុងការពង្រឹងវត្តមានរបស់គ្រូបង្រៀន និងមិនអាចបង្ខំគ្រូបង្រៀនមួយចំនួនឱ្យខិតខំបង្រៀនជាងនេះទៀតបានទេ ដោយហេតុថាគ្រូបង្រៀនត្រូវរកចំណូលបន្ថែមទៀតដើម្បីទ្រទ្រង់ក្រុមគ្រួសាររបស់ពួកគាត់។ នាយកសាលាក៏មានមនោសញ្ចេតនាចំពោះគ្រូបង្រៀនមកពីខេត្តផ្សេងដែលត្រូវធ្វើដំណើរឆ្ងាយក្នុងកំឡុងពេលថ្ងៃឈប់សម្រាក។ ដោយសារសមត្ថភាពផ្នែកការងារគ្រប់គ្រងនៅមានកម្រិត និងប្រឈមទៅនឹងកត្តាជីវភាពដូចជាគ្រូបង្រៀនដែរ អាចរារាំងនាយកសាលាមិនឱ្យចាត់ វិធានការណ៍ដ៏តឹងតែងចំពោះអវត្តមានរបស់គ្រូបង្រៀន(Teaching Matters: របាយការណ៍ថ្នាក់គោលនយោបាយស្តីពីការលើកទឹកចិត្ត និងសីលធម៌គ្រូបង្រៀននៅប្រទេសកម្ពុជា ឆ្នាំ ២០០៨)។ គួរឱ្យកត់សម្គាល់ផងដែរថានាយកសាលាចំនួន ៧៦% មានការងារ ឬមុខរបរផ្សេងបន្ថែមទៀត។

ការសម្ភាសជាលក្ខណៈស៊ីជម្រៅបន្ថែមទៀតជាមួយនាយកសាលាមួយចំនួនតូច បានបង្ហាញថាពួកគាត់មានភាពស្ទាក់ស្ទើរក្នុងការដាក់ទណ្ឌកម្ម ឬមានចំណាត់ការដាក់លាក់ចំពោះគ្រូបង្រៀនដោយសារតែមនោសញ្ចេតនាយោគយល់ និងទំនាក់ទំនងការងារជាមួយគ្រូបង្រៀនជាយូរមកហើយ។ នាយកសាលាមានការបារម្ភក្នុងការបង្ខំគ្រូបង្រៀនឱ្យលាឈប់ពីការងារពីព្រោះវាបណ្តាលឱ្យមានបញ្ហាខ្វះបុគ្គលិក និង ចំនួនសិស្សច្រើនក្នុង១ថ្នាក់ច្រើនពេក។ ករណីនេះគឺកើតមានឡើងជាពិសេសនៅសាលារៀននៅតំបន់ជនបទជាពិសេសពេលដែលគ្រូបង្រៀនទើបចេញថ្មីត្រូវបានគេពង្រាយមកពីស្រុកផ្សេង។ គួរកត់សម្គាល់ផងដែរថានាយកសាលាពុំមានអំណាចក្នុងការជ្រើសរើសគ្រូបង្រៀនថ្មីនោះទេ ដូច្នេះហើយនៅពេលដែលខ្វះគ្រូបង្រៀនគឺមានតែត្រូវរងចាំរហូតដល់ឆ្នាំក្រោយ។

នៅក្នុងកិច្ចសម្ភាស យើងក៏បានសួរនាយកសាលាផងដែរថាតើមានសកម្មភាពគោលនយោបាយអ្វីខ្លះដែលអាចជួយកាត់បន្ថយអវត្តមានគ្រូបង្រៀន និងផលប៉ះពាល់ទៅលើការសិក្សារបស់សិស្ស។ ៤៦%នៃ

នាយកសាលាដែលត្រូវ បានសម្ភាសបានមានប្រសាសន៍ថាការតំឡើងប្រាក់បៀវត្សរ៍គ្រូបង្រៀន នឹងជួយពួកគាត់ក្នុងការពង្រឹងគោលនយោបាយ និងកាត់បន្ថយអវត្តមានគ្រូបង្រៀន។ សូមបញ្ជាក់ថា ថាចម្លើយទាំងនេះគឺទទួលបាននៅមុនពេលដែលក្រសួងអប់រំ យុវជន និងកីឡា ចេញសេចក្តីប្រកាសអំពីការតំឡើងប្រាក់ខែជាបន្តបន្ទាប់ដល់គ្រូបង្រៀននៅឆ្នាំ ២០១៤។ ស្រដៀងគ្នានេះដែរ ការបើកប្រាក់ខែឱ្យគ្រូបង្រៀនបានទាន់ពេល គឺជាបញ្ហាផ្សេងមួយទៀតដែលនាយកសាលាបានលើកឡើង ពីព្រោះពួកគាត់យល់ឃើញថា ការទទួលបានបៀវត្សរ៍យឺតធ្វើឱ្យគ្រូបាក់ទឹកចិត្ត និងជម្រុញឱ្យគ្រូបង្រៀនត្រូវរកប្រាក់ចំណូលបន្ថែម។ ជាថ្មីម្តងទៀត បញ្ហានេះត្រូវបានដោះស្រាយរួចហើយនៅក្នុងគោលនយោបាយជាតិ ដោយរៀបចំឱ្យមានការបើកប្រាក់ខែគ្រូបង្រៀនតាមរយៈប្រព័ន្ធធនាគារ។ សំណូមពរផ្សេងទៀតរបស់នាយកសាលាមានបង្ហាញនៅក្នុងតារាងខាងក្រោម។

តារាងទី ២០៖ សំណូមពររបស់នាយកសាលាស្តីពីការកែលម្អអវត្តមានគ្រូបង្រៀន

| សំណូមពររបស់នាយកសាលា | # នៃចម្លើយ |
|---|---|
| តំឡើងប្រាក់ខែគ្រូបង្រៀន លើកកម្ពស់ជីវភាពរស់នៅរបស់គ្រូបង្រៀន | ៤២ |
| ពង្រឹងវិន័យគ្រូបង្រៀន | ១៤ |
| ការលើកទឹកចិត្ត (ផ្តល់ប្រាក់រង្វាន់ លិខិតសរសើរ ការបណ្តុះបណ្តាល ការគាំទ្រផ្នែកបច្ចេកទេស ទស្សនកិច្ចសិក្សា) | ១៣ |
| បើកប្រាក់ខែឱ្យបានទាន់ពេល | ៩ |
| ការចុះពិនិត្យតាមដានឱ្យបានញឹកញាប់ពីមន្ទីរ និងការិយាល័យអប់រំ យុវជន និងកីឡា | ៩ |
| ការពិនិត្យតាមដានថ្នាក់រៀន កិច្ចប្រជុំ | ៩ |
| កែលម្អសម្ភារៈបរិក្ខាសាលារៀន (បណ្ណាល័យ បង្គន់ សម្ភារៈបង្រៀន និងរៀន) | ៧ |
| កំណត់អំពីបញ្ហារបស់គ្រូបង្រៀន និងជួយដោះស្រាយពួកគាត់ | ៦ |

នាយកសាលាមួយចំនួនបានលើកឡើងថា នាយកសាលាគប្បីធ្វើជាគម្រូល្អចំពោះគ្រូបង្រៀនទៅលើផ្នែកវត្តមាន និងការគោរពម៉ោងការងារ។ នេះគឺមានភាពស៊ីគ្នាជាមួយនឹងលទ្ធផលរកឃើញតាមរយៈការចុះទស្សនកិច្ចសាលារៀនដោយមិនផ្តល់ដំណឹងជាមុន ដែលបានបង្ហាញថាវត្តមានរបស់នាយកសាលាគឺមានការជាប់ពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយវត្តមានរបស់គ្រូបង្រៀន។

ការលើកទឹកចិត្តតាមរយៈការបណ្តុះបណ្តាលសម្ថភាព និងទស្សនកិច្ចសិក្សាទៅកាន់សាលារៀនដទៃទៀតត្រូវបានគេលើកឡើងផងដែរថាជាការជម្រុញទឹកចិត្តដល់គ្រូបង្រៀន។ តាមរយៈវិធីសាស្ត្រទាំងនេះ គ្រូបង្រៀនអាចបង្កើនចំណេះដឹង និងជំនាញរបស់ពួកគាត់ដើម្បីជួយឲ្យពួកគាត់បំពេញការងារបានប្រសើរ។ ទស្សនកិច្ចសិក្សាត្រូវបានគេយល់ថា ជាការផ្តល់ឱកាសឲ្យគ្រូបង្រៀនមើលឃើញនូវគម្រូល្អពីសាលារៀន គ្រូបង្រៀន និងនាយកសាលាដទៃទៀត ហើយជួយឲ្យពួកគាត់ មានគំនិតទូលំទូលាយដើម្បីអភិវឌ្ឍសាលារៀន និងរៀនសូត្រពីគ្នាទៅវិញទៅមក។ ទោះបីយ៉ាងណាក៏ដោយ លទ្ធផលរកឃើញតាមរយៈការសម្ភាសគ្រូបង្រៀន

បានបង្ហាញថា១០%នៃអវត្តមានគ្រូបង្រៀនគឺដោយសារមូលហេតុបេសកកម្មផ្លូវការ។ ការចូលរួមរបស់គ្រូបង្រៀនកាន់តែច្រើននៅក្នុងបេសកកម្មផ្លូវការ មានន័យថាអវត្តមានគ្រូបង្រៀនកាន់តែច្រើន និងធ្វើឱ្យបាត់ម៉ោងបង្រៀនកាន់តែច្រើន ប្រសិនបើមិនមានប្រព័ន្ធគ្រប់គ្រងការបង្រៀនសងប្រកបដោយប្រសិទ្ធភាពសម្រាប់ប្រើប្រាស់នោះទេ។ សំណូមពរមួយ គឺលើកឡើងឲ្យរៀបចំការបណ្តុះបណ្តាលនៅចុងសប្តាហ៍ ឬក្នុងកំឡុងពេលវិស្សមកាល ឬរៀបចំការបណ្តុះបណ្តាលតែពាក់កណ្តាលថ្ងៃ ដើម្បីឲ្យគ្រូអាចទៅបង្រៀននៅវេនមួយផ្សេងទៀតបានដូចធម្មតា។

ដោយផ្អែកលើទិន្នន័យបានមកពីការសម្ភាសនៅតាមសាលារៀននៅក្នុងការសិក្សានេះ វាហាក់ដូចជាមានហេតុផលត្រឹមត្រូវក្នុងការសន្និដ្ឋានថា គេមិនបានដាក់ទណ្ឌកម្មធ្ងន់ធ្ងរ ឬ មានចំណាត់ការផ្ទែកបុគ្គលិកដល់គ្រូដែលអវត្តមានញឹកញាប់នោះទេ។ ស្របពេលដែលនាយកសាលាមួយចំនួនអាចកំពុងអនុវត្តតាមគោលនយោបាយថ្នាក់ជាតិ មានភស្តុតាងតិចតួចដែលបង្ហាញអំពីការមានចំណាត់ការធ្ងន់ធ្ងរដូចជា ការកាត់បន្ថយប្រាក់ខែ ឬការបណ្តេញចេញ ពីសាលារៀនត្រូវបានគេអនុវត្ត។ នាយកសាលាបានបញ្ជាក់អំពីកង្វះចំណាត់ការនេះ គឺដោយសារដើម្បីរក្សាទុកគ្រូឲ្យបាននៅបង្រៀន ជៀសវាងកុំឲ្យមានកង្វះគ្រូបង្រៀន និងដោយសារស្ថានភាពជាក់ស្តែងដែលគ្រូបង្រៀនត្រូវការរកប្រាក់ចំណូលបន្ថែម។ អាទិភាពដែលគេឱ្យទៅលើអវត្តមានគ្រូបង្រៀននៅក្នុងការគ្រប់គ្រងសាលារៀន អាចពន្យល់បានខ្លះអំពីអវត្តមានរបស់គ្រូបង្រៀនដែលបានរកឃើញនៅក្នុងការសិក្សានេះ។ នៅពេលដែលគ្រូបង្រៀនរវល់ ពួកគាត់ហាក់ដូចជា ហ៊ានឈប់ដោយពុំមានការភ័យខ្លាចអំពីការដាក់ទណ្ឌកម្មធ្ងន់ធ្ងរអ្វីឡើយ។ ដូចដែលយើងបានដឹងរួចមកហើយមាន ឧទាហរណ៍ជាច្រើនអំពីអវត្តមានគ្រូបង្រៀនដែលបានកើតឡើងក្នុងកំឡុងពេលនាយកសាលាមិននៅ ឬសាលារៀនទាំងមូលត្រូវបានបិទដោយសារ ទម្លាប់ដែលមានជាយូរមកហើយក្នុងការអូសបន្លាយថ្ងៃឈប់សម្រាក ឬបិទសាលារៀននៅថ្ងៃពិសេសៗមួយចំនួន។

## V. សេចក្តីសន្និដ្ឋាន

របាយការណ៍នេះផ្តល់នូវភស្តុតាងយ៉ាងច្រើនថា ការអនុវត្តម៉ោងបង្រៀនទៅតាមការកំណត់នៅប្រទេសកម្ពុជានៅតែជាការព្រួយបារម្ភដ៏សំខាន់មួយ។ គម្លាតរវាងម៉ោងបង្រៀនដែលច្បាប់បានកំណត់ និងម៉ោងដែលគ្រូបានបង្រៀនជាក់ស្តែង បានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិទទួលបានការអប់រំសម្រាប់កុមារជាច្រើននៅក្នុងប្រទេសកម្ពុជា និងប៉ះពាល់ដល់ទិសដៅសំខាន់ៗនៃផែនការយុទ្ធសាស្ត្រអប់រំ ២០១៤-១៨។ ជាពិសេសសិស្សនៅតាមតំបន់ជនបទពុំសូវបានទទួលផលប្រយោជន៍ទេ បើប្រៀបធៀបនឹងសិស្សនៅតាមទីប្រជុំជនដែលធ្វើឱ្យមានវិសមភាពកាន់តែធំឡើង ហើយសិស្សទាំងអស់ក៏ពុំបានទទួលផលប្រយោជន៍ច្រើនដែរ បើប្រៀបធៀបទៅនឹងសិស្សដែលធំពេញវ័យនៅក្នុងតំបន់ ដែលមានសេដ្ឋកិច្ចរីកចម្រើនក្បែរខាងដែលចំណាយពេលវេលាច្រើនជាងនៅក្នុងសាលារៀន។ ជាងនេះទៅទៀត ភស្តុតាងរបស់យើងចង្អុលបង្ហាញថា អវត្តមានរបស់គ្រូបង្រៀនខ្លួនឯងផ្ទាល់មានផលប៉ះពាល់ជាអវិជ្ជមានទៅលើការអប់រំរបស់សិស្ស។ នៅក្នុងផ្នែកនេះ យើងនឹងពិនិត្យមើលទៅលើខ្លឹមសារ (theme) សំខាន់ៗដែលមានប្រភពភស្តុតាងផ្សេងៗគ្នាដែលប្រមូលបាននៅក្នុងការសិក្សានេះ និងអនុសាសន៍នានា ដែលទាក់ទងនឹងខ្លឹមសារទាំងនោះ ព្រមទាំងវាយតម្លៃពីផលប៉ះពាល់ដែលបានរួមបញ្ចូលគ្នានូវប្រភេទនៃការបាត់ម៉ោងបង្រៀនដែលបានសិក្សាស្វែងយល់នៅក្នុងការសិក្សានេះ។

### ម៉ោងបង្រៀនពិតប្រាកដប្រៀបធៀបនឹងម៉ោងបង្រៀនដែលច្បាប់បានកំណត់នៅក្នុងឆ្នាំសិក្សា ២០១២-១៣

នៅក្នុងរបាយការណ៍នេះ យើងបានពិនិត្យមើលទៅលើមូលហេតុ ចំនួន៣ គឺ ថ្ងៃឈប់សម្រាករបស់សាលារៀនផ្លូវការបន្ថែមទៀត អវត្តមានរបស់គ្រូបង្រៀន និងការបង្រៀនរយៈពេលមានខ្លីដោយសារតែគ្រូបង្រៀនរយៈពេលខ្លីជាងម៉ោងកំនត់ក្នុងថ្ងៃនីមួយៗ ដែលតាមរយៈនេះម៉ោងបង្រៀនពិតប្រាកដដែលគេផ្តល់ឱ្យ មានភាពខុសគ្នាពីម៉ោងបង្រៀនដែលជាការរំពឹងទុករបស់ថ្នាក់ជាតិ ។ យើងត្រូវចងចាំថា ដោយសារគ្រូបង្រៀននៅក្នុងការសិក្សាបានដឹងថាពួកគាត់នឹងត្រូវបានគេពិនិត្យមើល ដូច្នេះលទ្ធផលរកឃើញក្នុងការសិក្សានេះ គឺទំនងជាមានលក្ខណៈវិជ្ជមានជាងករណីទូទៅ។

ជាមួយគ្នានេះដែរ មូលហេតុទាំងនេះគឺជាហេតុផលនៃការកាត់បន្ថយយ៉ាងច្រើនចំពោះម៉ោងបង្រៀននៅក្នុងសាលារៀនមួយចំនួនក្នុងចំណោមសាលារៀនដែលយើងសិក្សា ហើយគេអាចប្រើប្រាស់វាដើម្បីគណនានូវម៉ោងបង្រៀនដែលបានបាត់ជាមធ្យមនៅគ្រប់សាលារៀន និងខេត្តដែលជាសំណាករបស់យើងនៅក្នុងឆ្នាំសិក្សា២០១២-១៣។ ចូរកត់ចំណាំថា ការគណនាទាំងនេះគឺត្រូវបានធ្វើឡើងដោយផ្អែកទៅលើម៉ោងនៅក្នុងកម្មវិធីសិក្សារបស់ជាតិដោយមិនរាប់បញ្ចូលម៉ោងបង្រៀនថ្ងៃព្រហស្បតិ៍/បំណិនជីវិតទេ ដោយសារចំណុចនេះស្ថិតនៅក្រៅវិសាលភាពនៃការសិក្សានេះ។

ដើម្បីធ្វើការវិភាគនេះ ជាដំបូង យើងដកចេញនូវថ្ងៃឈប់សម្រាកបន្ថែមជាផ្លូវការរបស់សាលារៀនជាផ្លូវការពីឆ្នាំសិក្សាដែលបានកំណត់ដោយច្បាប់[14] - ការកាត់បន្ថយមានចំនួន៨% ៖

[14] ចូរកត់សំគាល់ថា ថ្ងៃសិក្សាពិតប្រាកដក្នុងឆ្នាំ២០១២/១៣គឺមានចំនួន ១៨៦ថ្ងៃដែលគេប្រើប្រាស់ ជាជាង ១៩០ថ្ងៃដែលកំណត់ នៅក្នុងគោលនយោបាយជាតិ

| | កាត់បន្ថយ (%) | ចំនួនថ្ងៃ | ម៉ោងសិក្សា (5 ក្នុងមួយថ្ងៃ) | ម៉ោងពិតប្រាកដ (3.33 ក្នុងមួយថ្ងៃ) |
|---|---|---|---|---|
| ម៉ោងបង្រៀននៅក្នុងឆ្នាំសិក្សា ២០១២-១៣ | | 186 | 930 | 619 |
| ការកាត់បន្ថយដោយសារថ្ងៃឈប់សម្រាកជាផ្លូវការបន្ថែម | 8 % | 14 | 70 | 47 |
| ចំនួនម៉ោងបង្រៀនដែលនៅសល់ | | 172 | 860 | 573 |

គ្រូបង្រៀននៅក្នុងការសិក្សានេះអវត្តមានជាមធ្យមចចំនួន ១០.៥% នៃថ្ងៃបង្រៀនដែលនៅសល់ចំនួន ១៧២ ថ្ងៃ ដែលនាំឱ្យមានការកាត់បន្ថយជាមធ្យមដូចខាងក្រោមចំពោះថ្ងៃ និងម៉ោងរៀននៅក្នុងកម្មវិធីសិក្សារបស់ជាតិ៖

| | កាត់បន្ថយ (%) | ចំនួនថ្ងៃ | ម៉ោងសិក្សា (5 ក្នុងមួយថ្ងៃ) | ម៉ោងពិតប្រាកដ (3.33 ក្នុងមួយថ្ងៃ) |
|---|---|---|---|---|
| ម៉ោងបង្រៀនជាផ្លូវការ ២០១២-១៣ | | 172 | 860 | 573 |
| ការកាត់បន្ថយដោយសារអវត្តមានរបស់គ្រូបង្រៀនជាមធ្យម | 10.5 % | 18 | 90 | 60 |
| ម៉ោងបង្រៀនដែលនៅសល់ | | 154 | 769.7 | 513 |

ក្នុងចំណោមថ្ងៃបង្រៀនដែលនៅសល់ចំនួន ១៥៤ថ្ងៃ គ្រូបង្រៀនដដែលបានបង្រៀនតិចជាងរយៈពេលកំនត់ជាមធ្យម គឺចំនួន២៤នាទី (ស្មើនឹង១២%) ក្នុង១ថ្ងៃ ដែលនេះធ្វើឱ្យមានការបាត់ម៉ោងច្រើនថែមទៀត ៖

| | កាត់បន្ថយ (%) | ចំនួនថ្ងៃ | ម៉ោងសិក្សា (5 ក្នុងមួយថ្ងៃ) | ម៉ោងពិតប្រាកដ (3.33 ក្នុងមួយថ្ងៃ) |
|---|---|---|---|---|
| ម៉ោងបង្រៀនជាផ្លូវការ ២០១២-១៣ ដកចេញនូវថ្ងៃអវត្តមានរបស់គ្រូបង្រៀនជាមធ្យម | | 154 | 769.7 | 513 |
| ការកាត់បន្ថយដោយសារគ្រូបង្រៀនរយៈពេលខ្លីជាងកំនត់គិតជាមធ្យម | 12 % | 18.5 | 92 | 61.5 |
| ម៉ោងបង្រៀនដែលនៅសល់ | | 135 | 677 | 451 |

ដោយការប្រើប្រាស់វិធីសាស្ត្រនៃការគណនានេះ គ្រូបង្រៀនដែលយើងបានសិក្សា បានបង្រៀនតិចជាងម៉ោងកំនត់នៅក្នុងគោលនយោបាយរបស់ក្រសួងអប់រំ ជាមធ្យមចំនួន២៧% ដោយនេះបានកាត់បន្ថយថ្ងៃរបស់សាលារៀនចំនួន ៥០.៥ថ្ងៃ ស្មើនឹង២៥៣ ម៉ោងសិក្សា ឬ ១៦៨ម៉ោងក្នុងឆ្នាំនោះ។

| | ចំនួនថ្ងៃ | ម៉ោសិក្សា (5 ក្នុងមួយថ្ងៃ) | ម៉ោងពិតប្រាកដ (3.33 ក្នុងមួយថ្ងៃ) |
|---|---|---|---|
| ឆ្នាំសិក្សាដែលបានកំណត់ ២០១២-១៣ | 186 | 930 | 619 |
| ការបាត់ម៉ោងបង្រៀនជាមធ្យមសរុប | 50.5 | 253 | 168 |
| ការបាត់ម៉ោងគិតជាភាគរយ | 27 % | 27% | 27% |

គេអាចមានទឡ្ហីករថា ការគណនានេះមានលក្ខណៈខ្ពស់ហួសពីការពិតដោយសារព្រឹត្តិការណ៍ផ្សេងៗច្រើន ដែលធ្វើឱ្យមានថ្ងៃឈប់សម្រាកនៅតាមសាលារៀនជាផ្លូវការបន្ថែមទៀតនៅក្នុងឆ្នាំជាក់លាក់នោះ។ ទោះជាយ៉ាងណាក៏ដោយប្រសិនបើយើងសន្មតថាពុំមានថ្ងៃឈប់សម្រាកបន្ថែមទៀតនៅក្នុងឆ្នាំសិក្សាជាស្តង់ដារដែលមានថ្ងៃបង្រៀនចំនួន១៩០ថ្ងៃ នោះការកាត់បន្ថយដោយសារអវត្តមានរបស់គ្រូបង្រៀន និងម៉ោងបង្រៀនខ្លីជាងរយៈពេលកំនត់ គឺមានចំនួន២១% ដែលនេះលើសពី១ភាគ៥–នៃឆ្នាំសិក្សាអាចនឹងនៅតែបាត់ជាមធ្យម៖

| ឆ្នាំតាមលក្ខណៈទ្រឹស្តី | ការកាត់បន្ថយ | ចំនួនថ្ងៃដកចេញ | ចំនួនថ្ងៃដែលមាន | ចំនួនម៉ោងសិក្សាដែលមាន | ចំនួនម៉ោងពិតប្រាកដដែលមាន |
|---|---|---|---|---|---|
| ឆ្នាំសិក្សាដែលកំណត់ដោយច្បាប់ | | | 190 | 950 | 633 |
| មធ្យមភាគនៃអវត្តមានរបស់គ្រូបង្រៀន | 10.50% | 20 | 170 | 850.25 | 566 |
| ម៉ោងបង្រៀនខ្លីជាងម៉ោងកំនត់ជាមធ្យម | 12% | 20.4 | 150 | 748 | 498 |
| | | | | | |
| ការបាត់ម៉ោងសរុប | | 40.4 | | 202 | 134 |
| ការបាត់ម៉ោងគិតជា % | | 21% | | 21% | 21% |

ដូចដែលបានបញ្ជាក់យ៉ាងលម្អិតនៅក្នុងការវិភាគខាងលើ យើងសង្កេតឃើញនូវភាពខុសគ្នាគួរឱ្យកត់សំគាល់ទាំងចំពោះអវត្តមានរបស់គ្រូបង្រៀន និងរយៈពេលបង្រៀនរបស់គ្រូម្នាក់ៗ ទាំងនៅតាមសាលារៀននីមួយៗ និងទាំងនៅតំបន់ទីប្រជុំជន និងជនបទ។ ភាគខុសគ្នាធំបំផុត គឺរវាងមធ្យមភាគនៅតំបន់ទីប្រជុំជន និងជនបទ។ ប្រសិនបើយើងប្រើប្រាស់ការគណនាដូចខាងលើសម្រាប់តែសាលារៀនតាមតំបន់ជនបទប៉ុណ្ណោះ មធ្យមភាគនៃការបាត់ម៉ោងបង្រៀននៅក្នុងឆ្នាំសិក្សាស្តង់ដារមួយ (ដោយមិនដាក់បញ្ចូលថ្ងៃឈប់សម្រាកជាផ្លូវ

ការបន្ថែមដែលមានផលប៉ះពាល់ដូចគ្នា) យើងនឹងឃើញមានចំនួន ២៤% ពោលគឺជិតស្មើនឹង ១ភាគ៤ នៃថ្ងៃសិក្សាក្នុង១ឆ្នាំ។

| ឆ្នាំតាមលក្ខណៈទ្រឹស្តី(ជនបទ) | ការកាត់បន្ថយ | ចំនួនថ្ងៃដែលមាន | ម៉ោងសិក្សាដែលមាន | ម៉ោងពិតប្រាកដដែលមាន |
|---|---|---|---|---|
| ឆ្នាំសិក្សាដែលកំណត់ដោយច្បាប់ | | 190 | 950 | 633 |
| ការកាត់បន្ថយ(បាត់)ដោយសារអវត្តមានរបស់គ្រូបង្រៀនគិតជាមធ្យម (ជនបទ) | 12% | 167 | 836 | 557 |
| ការកាត់បន្ថយដោយសារការបង្រៀនតិចជាងម៉ោងកំនត់គិតជាមធ្យម (ជនបទ) | 14% | 144 | 719 | 479 |
| ការបាត់ម៉ោងសរុប | | | 231 | 154 |
| ការបាត់ម៉ោងគិតជា % | | | 24% | 24% |

នៅក្នុងឆ្នាំ២០១២-១៣ ប្រសិនបើយើងដាក់បញ្ចូលថ្ងៃឈប់សម្រាកជាផ្លូវការបន្ថែម ឆ្នាំសិក្សាជាមធ្យមនៅតាមសាលារៀនតាមតំបន់ជនបទដែលបានសិក្សា គឺមានចំនួន៣០% ទាបជាងឆ្នាំសិក្សាដែលបានកំណត់ដោយច្បាប់។ ចំនួននេះ បើប្រៀបធៀបជាមួយឆ្នាំសិក្សាដូចគ្នានៅតំបន់ទីប្រជុំជនគឺមានរយៈពេលខ្លីជាងចំនួនថ្ងៃសិក្សាដែលកំនត់ដោយក្រសួងអប់រំចំនួន ២១%។

| ២០១២-១៣ - ជនបទ | ចំនួនថ្ងៃដែលបាត់ | ចំនួនថ្ងៃនៅសល់ | ចំនួនម៉ោងសិក្សានៅសល់ | ម៉ោងពិតប្រាកដនៅសល់ |
|---|---|---|---|---|
| ឆ្សិក្សាដែលបានកំណត់ដោយច្បាប់ ២០១២-១៣ | | 186 | 930 | 619 |
| ថ្ងៃឈប់សម្រាកជាផ្លូវការបន្ថែម | 8% | 172 | 860 | 573 |
| ការបាត់ម៉ោងដោយសារអវត្តមានរបស់គ្រូបង្រៀនជាមធ្យម(ជបបទ) | 12% | 151 | 756.8 | 504 |
| ការបាត់ម៉ោងជាធ្យមដោយសារគ្រូបង្រៀនតិចជាងម៉ោងកំនត់ប្រចាំថ្ងៃ (ជនបទ) | 14% | 130 | 651 | 433 |
| ការបាត់ម៉ោងសរុប | | | 279 | 186 |
| ការបាត់ម៉ោងគិតជា % | | | 30% | 30% |

**សេចក្តីសន្និដ្ឋានទី១: ការបាត់ម៉ោងសិក្សានៅក្នុងប្រទេសកម្ពុជានៅតែជាបញ្ហាមួយដ៏ចម្បង ក្នុងការផ្តល់នូវប្រព័ន្ធអប់រំសាធារណៈដែលប្រកបដោយប្រសិទ្ធផល**

ការសិក្សានេះ បានបង្ហាញថាភាគរយដ៏ធំមួយនៃម៉ោងបង្រៀន ដែលបានបាត់នៅក្នុងឆ្នាំសិក្សា ២០១២-១៣ បណ្តាលមកពីមូលហេតុសំខាន់ៗចំនួនបីគឺ ថ្ងៃឈប់សម្រាកផ្លូវការបន្ថែម អវត្តមានគ្រូបង្រៀន និងការបង្រៀននៅក្នុងថ្នាក់តិចជាងម៉ោងកំនត់។

ថ្វីត្បិតតែគេអាចបដិសេធបានថាឆ្នាំដែលបានធ្វើការសិក្សានេះ គឺជាឆ្នាំពិសេស ដោយសារមានថ្ងៃឈប់សម្រាកបន្ថែមច្រើន ហើយដែលថ្ងៃឈប់បន្ថែមនេះធ្វើឱ្យមានផលប៉ះពាល់ច្បាស់ណាស់ទៅលើចំនួនម៉ោងដែលត្រូវបង្រៀនសិស្ស។ លើសពីនេះទៀត ក៏មានព្រឹត្តិការណ៍ជាច្រើនដែលបណ្តាលឱ្យមានថ្ងៃឈប់សម្រាកជាផ្លូវការបន្ថែមទៀតកើតឡើងនៅរាល់ឆ្នាំផងដែរ ហើយថ្ងៃសំរាកបន្ថែមទាំងនោះ គឺគេអាចស្មានដឹងជាមុននៅពេលរៀបចំការវិភាគសិក្សាប្រចាំឆ្នាំ។ ហេតុដូចនេះហើយហេតុអ្វីគេមិនគិតទុកជាមុននូវការបិទសាលារៀននៅពេលប្រឡងគ្រូ ជាឧទាហរណ៍ ការប្រឡងជ្រើសរើសគ្រូបង្រៀន គឺធ្វើឡើងជារៀងរាល់ឆ្នាំ។ ថ្ងៃសម្រាកផ្លូវការបន្ថែមក៏អាចនាំឱ្យមានការបិទសាលារៀនផងដែរ បើពិនិត្យមើលទៅលើការអនុវត្ត (ទម្លាប់) ជាទូទៅដែលការសិក្សានេះបានរកឃើញថា មានការបិទសាលារៀនបន្ថែមលើសពីចំនួនថ្ងៃដែលត្រូវឈប់សម្រាកប្រសិនណាបើថ្ងៃឈប់សម្រាកនោះចំថ្ងៃសុក្រ ឬនៅចំពាក់កណ្តាលសប្តាហ៍។

ការបាត់ម៉ោងសិក្សាដោយសារអវត្តមានរបស់គ្រូបង្រៀនក៏មានភាពធ្ងន់ធ្ងរដូចគ្នាដែរ ដោយសារតែវាបានធ្វើឱ្យមានការថយចុះបរិមាណនៃម៉ោងសិក្សានៅក្នុងថ្នាក់រៀន។ ភស្តុតាងជាអន្តរជាតិបង្ហាញថានេះគឺធ្វើឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើលទ្ធផលនៃការសិក្សារបស់សិស្ស ហើយនៅក្នុងការសិក្សានេះបង្ហាញថាអវត្តមានញឹកញាប់របស់គ្រូបង្រៀន គឺមានការជាប់ទាក់ទងជាមួយនឹងពិន្ទុតេស្តទាបរបស់សិស្ស។ យើងដឹងថាគ្រូអាចនឹងអវត្តមានខ្លះ ឧទាហរណ៍ដូចជា នៅពេលគ្រូបង្រៀនឈឺ តែរយៈពេលនៃអវត្តមានដែលបានរកឃើញនៅក្នុងការសិក្សានេះគឺមានរយៈពេលវែងពេក ហើយយើងគួរកត់សម្គាល់ផងដែរថានៅពេលដែលគ្រូអវត្តមាននោះ គឺវាកម្រនឹងមាននាយកសាលា ឬបុគ្គលិកណាផ្សេងទៀតមកបង្រៀនជំនួសណាស់។ នេះមានន័យថានៅពេលដែលគ្រូអវត្តមានគឺសិស្សមិនបានរៀនដូចធម្មតានោះទេ។ នៅពេលដែលមានគ្រូបង្រៀនចំនួនមួយភាគប្រាំបានរៀបរាប់ថាចំនួនមេរៀនក្នុងកម្មវិធីសិក្សា គឺមិនសមទៅនឹងរយៈពេលដែលមាននៅក្នុងឆ្នាំសិក្សាទេ ហើយមានគ្រូបង្រៀនច្រើនជាងមួយភាគប្រាំបានរៀបរាប់ថាពួកគាត់មិនអាចបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ និងមុខវិជ្ជាសិក្សាសង្គម ឱ្យចប់តាមកម្មវិធីបានទេ នេះគឺច្បាស់ណាស់ថាវាមានផលប៉ះពាល់ទៅលើអ្វីដែលគេបានកំណត់ថាសិស្សត្រូវរៀន។

ការបាត់ម៉ោងបង្រៀនដោយសារការបង្រៀនសិស្សនៅក្នុងថ្នាក់ខ្លីរយៈពេលដែលបានកំនត់ ជាបញ្ហាដែលគេមើលមិនសូវឃើញនោះ ក៏មានផលប៉ះពាល់យ៉ាងខ្លាំងទៅលើការបាត់ម៉ោងបង្រៀនប្រចាំឆ្នាំនៅក្នុងចំណោមសាលារៀនដែល យើងបានជ្រើសរើសធ្វើជាសំណាក ដោយបានរំលេចឱ្យឃើញអំពីការបាត់ម៉ោងបង្រៀនដោយសារគ្រូមកបង្រៀនមកមិនទាន់ម៉ោង និងចេញមុនម៉ោង ព្រមទាំងការអនុវត្ត (ទម្លាប់)ជាទូទៅដែលគ្រូបង្រៀននៅតំបន់ជនបទបង្រៀនមេរៀនសិស្សបានចំនួនតិចម៉ោងជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជន។ វាប្រាកដណាស់ដែលគេអាចបដិសេធថា រយៈពេលនៃមេរៀនគឺមិនបានប្រាប់ឱ្យដឹងពីគុណភាពនៃការបង្រៀននោះទេ ប៉ុន្តែបញ្ហាសំខាន់នោះ គឺថាគ្រូបង្រៀន មួយក្រុមតូចមានទម្លាប់បង្រៀនមេរៀនមិនពេញម៉ោងដែលធ្វើឱ្យសិស្សមិនទទួលបាននូវឱកាសដូចគ្នាជាមួយនឹងសិស្សដែលត្រូវបានគ្រូបង្រៀនពេញម៉ោង។ ចំពោះ

យើង នេះហាក់ដូចជាបញ្ហានៃ "វប្បធម៌ និងទម្លាប់" ដែល ជាប់ទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងសមត្ថភាពរបស់នាយកសាលាដែលដើរតួជាអ្នកគ្រប់គ្រងបុគ្គលិកបង្រៀនរបស់ខ្លួន និងកម្រិតនៃអាទិភាពដែលផ្តោតទៅលើវត្តមាន និងការគោរពម៉ោងពេលរបស់គ្រូបង្រៀន។ នេះគឺបណ្តាលមកពីការទទួលរងការជះឥទ្ធិពលពីបញ្ហានៃការជ្រើសរើស និងពង្រាយគ្រូបង្រៀន។

តាមរយៈការរកឃើញក្នុងការស្រាវជ្រាវនេះ យើងអាចសន្និដ្ឋានបានថាការផ្តល់ម៉ោងបង្រៀនឱ្យសិស្សនៅតែមានកម្រិតទាបនៅឡើយបើធៀបទៅនឹងអ្វី ដែលបានចែងក្នុងគោលនយោបាយអភិវឌ្ឍន៍កម្មវិធីសិក្សា ២០០៥-២០០៩។ ថ្វីត្បិតតែមានការសិក្សាពីមុនៗនៅក្នុងផ្នែកនេះ និងសកម្មភាពជាច្រើនត្រូវបានអនុវត្តនៅកម្រិតថ្នាក់គោលនយោបាយ ដើម្បីដោះស្រាយបញ្ហាទាំងនេះក៏ដោយ ក៏បញ្ហាទាំងនេះហាក់ដូចជានៅដដែលបើធៀបទៅនឹងភស្តុតាងដែលមានពីមុនៗ។ ដោយសារតែវិធីសាស្ត្រនៃការគណនាមានលក្ខណៈខុសគ្នា ហើយថាតើការសិក្សាដែលមានពីមុនទាំងអស់នោះបានដាក់បញ្ចូលការបង្រៀនថ្ងៃព្រហស្បតិ៍ដែរឬអត់ គឺវាធ្វើឱ្យមានការលំបាកក្នុងការប្រៀបធៀបគ្នាដោយផ្ទាល់ ប៉ុន្តែវាច្បាស់ណាស់ថាបញ្ហាប្រឈមសំខាន់ៗក្នុងការធានាឱ្យកុមារមានឱកាសបានរៀនចប់កម្មវិធីសិក្សានោះ គឺនៅតែមាននៅឡើយនៅបណ្តាសាលារៀនជាច្រើននៅក្នុងប្រទេសកម្ពុជា។ នេះជាការសបញ្ជាក់ឱ្យឃើញថា វាមានតម្រូវការចាំបាច់ក្នុងការចាត់វិធានការថ្មីៗដើម្បីដោះស្រាយបញ្ហាទាំងនេះ និងជជែកពិភាក្សាជាមួយគ្នាអំពីអាទិភាពក្នុងចំណោមសហគមន៍ ដែលធ្វើការផ្នែកអប់រំ និងក្នុងសង្គមកម្ពុជាទាំងមូល។

### សេចក្តីសន្និដ្ឋានទី២: ម៉ោងសិក្សាដែលបានផ្តល់ឱ្យសិស្សនៅមានក្រមិតទាបមែនទែននៅតំបន់ជនបទ ដែលនេះបានបង្ហាញឱ្យឃើញពីវិសមភាពនៅតាមតំបន់

ការរកឃើញរបស់យើង បានបង្ហាញថាការបាត់ម៉ោងសិក្សានៅតាមសាលារៀននៅតំបន់ជនបទដាច់ស្រយាល គឺមានលក្ខណៈធ្ងន់ធ្ងរជាងគេ។ អវត្តមានគ្រូបង្រៀន ការបិទសាលារៀន និងការកាត់បន្ថយម៉ោងសិក្សាដោយការបង្រៀនមិនពេញម៉ោង គឺបានកើតមានឡើងជាច្រើននៅតាមសាលារៀននៅតំបន់ជនបទ ហើយនៅក្នុងការសិក្សា របស់យើងបានរកឃើញថាគ្រូបង្រៀននៅតាមសាលារៀននៅជនបទ គឺមានអវត្តមានច្រើនជាងគេបំផុត។

វាមានកត្តាជាច្រើន ហើយនេះគឺជាបទពិសោធន៍ ដែលបានរកឃើញនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀតនៅក្នុងការស្រាវជ្រាវស្រដៀងគ្នានេះ។ មានសម្មតិកម្មមួយដែលលើកឡើងថាហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅតំបន់ជនបទមានកម្រិតគុណភាពទាប ដែលបង្កជាឧបសគ្គដល់វត្តមានគ្រូបង្រៀន ហើយនេះអាចជាករណីមួយ។ ប៉ុន្តែនៅពេលដែលយើងមើលអំពីការរកឃើញក្នុងការស្រាវជ្រាវនេះ យើងមិនបានរកឃើញថាគ្រូបង្រៀនដែលនៅឆ្ងាយពីសាលារៀន លើកលែងតែគ្រូបង្រៀនដែលនៅឆ្ងាយលើសពី ២៥ គ.ម ពីសាលារៀន គឺបានអវត្តមាន ឬមកបង្រៀនយឺតជាញឹកញាប់ទេ។

ស្រដៀងគ្នានេះដែរ គេបានលើកឡើងថាគ្រូបង្រៀននៅតំបន់ជនបទជារឿយៗត្រូវបានគេពង្រាយឱ្យទៅបង្រៀននៅស្រុកដែលនៅឆ្ងាយពីស្រុក ឬខេត្តកំណើតរបស់ខ្លួន ហើយការធ្វើដំណើរមកលេងក្រុមគ្រួសារ ឬការលះបង់/ប្តេជ្ញាចិត្តមានកម្រិតទាបចំពោះសហគមន៍មូលដ្ឋាន អាចធ្វើឱ្យវត្តមានរបស់គ្រូបង្រៀនមានការថយចុះ។ ជាថ្មីម្តងទៀត ក្នុងការសិក្សានេះ យើងបានរកឃើញថាវាពុំមានការជាប់ទាក់ទងគ្នាអ្វីគួរឱ្យកត់សម្គាល់ទេរវាងការរស់នៅរបស់គ្រូបង្រៀននៅនឹងមូលដ្ឋានផ្ទាល់ និងអត្រាវត្តមានរបស់គ្រូបង្រៀននោះ។

ប្រហែលជារឿងគួរឱ្យចាប់អារម្មណ៍ គឺសម្មតិកម្មមួយដែលផ្អែកលើការរកប្រាក់ចំណូល និងជីវភាពរស់នៅ។ ការសិក្សាមុនៗរបស់ NEP និងការសិក្សាដទៃទៀតបានបង្ហាញអំពីការអនុវត្តទូទៅរបស់គ្រូបង្រៀនក្នុងការរកចំណូលបន្ថែមក្រៅដើម្បីបំពេញលើប្រាក់ខែរបស់គាត់ (NEP, 2012; VSO, 2008) ។ ថ្វីត្បិតតែគ្រូបង្រៀនក្នុងការសិក្សារបស់យើងមិនបានលើកឡើងជាញឹកញាប់ថាការរកប្រាក់ចំណូលជាមូលហេតុនៃអវត្តមានរបស់ខ្លួន ហើយមានតែ ២% នៃចំនួនអវត្តមានប៉ុណ្ណោះដែលជាមូលហេតុជាប់ពាក់ព័ន្ធក្នុងការរកប្រាក់ចំណូលបន្ថែមក៏ដោយ ក៏មូលហេតុមួយក្នុងចំណោមមូលហេតុសំខាន់ៗ ដែលធ្វើឱ្យនាយកសាលាមានភាពអនុគ្រោះច្រើននៅក្នុងការគ្រប់គ្រងអវត្តមានគ្រូបង្រៀននោះ គឺដោយសារតែគាត់ទទួលស្គាល់ថាគ្រូបង្រៀនត្រូវរកប្រាក់ចំណូលបន្ថែមដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។ នៅក្នុងការវិភាគនេះ កត្តានៃតំបន់ជនបទ ឬទីប្រជុំជន គឺមានការជាប់ទាក់ទងជាមួយនឹងវិធីផ្សេងៗក្នុងការរកប្រាក់ចំណូលបន្ថែមរបស់គ្រូបង្រៀន។ ការសិក្សាពីមុនរបស់ NEP បានរកឃើញថាគ្រូបង្រៀននៅទីប្រជុំជន ទំនងជាអាចរកប្រាក់ចំណូលបន្ថែមតាមរយៈការបង្រៀនគួរបន្ថែមនៅសាលារៀនដែលពួកគាត់បង្រៀន និងការបង់ប្រាក់ក្រៅផ្លូវការឱ្យគ្រូបង្រៀន ហើយមានគ្រូបង្រៀនមួយចំនួននៅទីប្រជុំជន ទទួលបានផលប្រយោជន៍បែបនេះច្រើនជាងគ្រូបង្រៀននៅតំបន់ជនបទ (NEP, 2012)។ ក្នុងអំឡុងពេលសម្ភាសជាមួយគ្រូបង្រៀននៅក្នុងការសិក្សានេះ គ្រូបង្រៀននៅទីប្រជុំជនលើកឡើងថាវាជាការបាត់ប្រាក់ចំណូល ប្រសិនបើពួកគាត់មិនបានមកបង្រៀន ហេតុដូច្នេះហើយពួកគាត់កម្រនឹងខានបង្រៀនសិស្សណាស់។ គ្រូបង្រៀននៅតំបន់ជនបទទំនងជាអាចរកប្រាក់ចំណូលបន្ថែមតាមរយៈការធ្វើការងារកសិកម្មទៅតាមរដូវកាល ឬមុខជំនួញនៅឆ្ងាយពីសាលារៀន។ វាជាការសមហេតុផលមួយ ដែលយើងអាចសន្និដ្ឋានថានេះគឺភាពខុសគ្នារវាងជនបទ និងទីប្រជុំជនដែលយើងបានសង្កេតក្នុងការសិក្សានេះ។

មានគ្រូបង្រៀនចេញថ្មីមួយចំនួនតូចតែគួរឱ្យកត់សំគាល់នៅតំបន់ជនបទ បានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រពីសាកលវិទ្យាល័យ។ ការបន្តការសិក្សានេះធ្វើឱ្យគ្រូទាំងនោះអវត្តមានមិនបានទៅបង្រៀនជាញឹកញាប់នៅរាល់ថ្ងៃសៅរ៍ ដោយសារពួកគាត់រវល់រៀននៅសាកលវិទ្យាល័យ។ ក្រោយពីរៀនចាប់បរិញ្ញាបត្រពួកគាត់នឹងបានប្រាក់បៀវត្សរ៍ខ្ពស់ក្នុងតួនាទីជាគ្រូបង្រៀន។ យើងនឹងមិនធ្វើការពន្យល់អំពីទំហំនៃភាពខុសគ្នាដែលយើងបានរកឃើញនោះទេ ប៉ុន្តែយើងពន្យល់ពីអត្រាអវត្តមានដ៏ខ្ពស់របស់គ្រូបង្រៀនមួយចំនួននៅតំបន់ជនបទ។ ដោយសារប្រទេសកម្ពុជាធ្វើដំណើរឆ្ពោះទៅសញ្ញាប័ត្រសមមូលថ្នាក់បរិញ្ញាបត្រនៅក្នុងការបណ្តុះបណ្តាលគ្រូបង្រៀន ការបន្តការសិក្សរបស់គ្រូនឹងមិនសូវជាបញ្ហាចោទទៀតទេនៅពេលខាងមុខ។ ទោះបីយ៉ាងណាក៏ដោយ វាជាការរំលឹកដ៏សំខាន់ថានៅពេលដែលគ្រូបង្រៀនទៅរៀនបន្តជាលក្ខណៈឯកជនក្តី ឬការបណ្តុះបណ្តាលផ្លូវការក្តី ការសិក្សានេះបានរកឃើញថាថ្នាក់រៀនរបស់សិស្សទំនងជាត្រូវបានឈប់សម្រាក ហើយសិស្សត្រូវខកអស់មួយថ្ងៃនៅក្នុងកម្មវិធីសិក្សា។

ទាក់ទិនទៅនឹងការទទួលយកថាគ្រូបង្រៀនវ័យក្មេងមួយចំនួន អាចមិនបានបង្រៀនសិស្សដោយសារពួកគាត់មករៀនបន្តនៅសាកលវិទ្យាល័យ នាយកសាលាបានរៀបរាប់ជាញឹកញាប់អំពីភាពតានតឹងរវាងស្ថានភាពមានគ្រូតែអវត្តមានញឹកញាប់ និងមកធ្វើការយឺត ជាមួយនឹងស្ថានភាពដែលគ្មានគ្រូមកបង្រៀនជំនួសនៅពេលដែលមានគ្រូបង្រៀនណាមួយអវត្តមាននោះ។ នេះធ្វើឱ្យស្ថានភាពនៃកង្វះគ្រូបង្រៀនដែលបានរកឃើញ ជាពិសេសនៅតំបន់ជនបទ គឺកាន់តែមានសភាពធ្ងន់ធ្ងរ នាយកសាលាប្រហែលជាត្រូវសម្រេចចិត្តថាមានគ្រូបង្រៀនហើយមិនបានមកបង្រៀនទៀងទាត់ នោះគឺវាប្រសើរជាងគ្មានគ្រូបង្រៀនសោះ។ នេះ

គឺបានបន្ថែមជាសម្មតិកម្មថ្មីមួយទៀតអំពីភាពខុសគ្នារវាងតំបន់ជនបទ និងទីប្រជុំជន។ ការគ្រប់គ្រងបុគ្គលិកតឹងរ៉ឹង គឺអាចមាននៅតែតំបន់ទីប្រជុំជនដែលពុំមានការខ្វះខាតគ្រូបង្រៀនឡើយ។

កត្តាសំខាន់ចុងក្រោយនៅក្នុងបែងចែកភាពខុសគ្នារវាងទីជនបទ និងទីប្រជុំជន នៅក្នុងការសិក្សានេះ គឺវិសាលភាពនៃការអនុវត្ត (ទម្លាប់) ទូទៅចំពោះថ្ងៃឈប់សម្រាក ហើយការអនុវត្តនេះកើតមានឡើងនៅតំបន់ជនបទច្រើនជាងនៅតំបន់ទីប្រជុំជន។ ការអនុវត្តទាំងនេះ គឺត្រូវបានគេពិភាក្សាលម្អិតក្នុងផ្នែកបន្ទាប់ ប៉ុន្តែជាការគួរឱ្យចាប់អារម្មណ៍នៅក្នុងការពិភាក្សាផ្នែកនេះបន្ថែម និងការស្រាវជ្រាវនៅថ្នាក់មូលដ្ឋាន ហើយនឹងដឹងថាតើការរំពឹងរបស់សហគមន៍ទៅលើសាលារៀនមានភាពខុសគ្នាយ៉ាងណារវាងនៅតំបន់ជនបទ និងទីប្រជុំជន និងថាតើអំណាចប្រជាពលរដ្ឋមានតួនាទីយ៉ាងណានៅក្នុងកំណត់អាទិភាពឱ្យសាលារៀន បានផ្តល់ម៉ោងបង្រៀនទៅតាមចំនួនម៉ោងកំណត់រវាងសាលារៀននៅតំបន់ជនបទ និងទីប្រជុំជន។

## សេចក្តីសន្និដ្ឋានទី៣: ការបិទសាលារៀនដែលជា "ទម្លាប់ទូទៅ"

**ការបិទសាលារៀនដែលជា "ទម្លាប់ទូទៅ" មានន័យថាគ្រូបង្រៀន និងអ្នកគ្រប់គ្រងផ្នែកអប់រំ កំពុងតែធ្វើឱ្យមានការថយចុះនូវចំនួនថ្ងៃសិក្សាប្រចាំឆ្នាំសិក្សា និងធ្វើឱ្យកុមារមិនបានរៀនចប់តាមកម្មវិធីសិក្សា**

គ្រូបង្រៀនបានឱ្យដឹងថាស្ទើរតែពាក់កណ្តាលនៃថ្ងៃអវត្តមានរបស់ខ្លួន គឺពាក់ព័ន្ធទៅនឹង "ទម្លាប់ទូទៅ" ក្នុងការបិទទ្វារសាលារៀននៅក្នុងអំឡុងពេលជុំវិញថ្ងៃឈប់សម្រាកជាផ្លូវការ ឬថ្ងៃឈប់សម្រាកក្រៅផ្លូវការ ដូចជាបុណ្យចូលឆ្នាំចិន។ ១៦% នៃការចុះសាលារៀនដោយមិនផ្តល់ដំណឹងជាមុន នៅពេលកៀកថ្ងៃឈប់សំរាក គឺពុំមានឃើញគ្រូមកបង្រៀនទេ ហើយជាញឹកញាប់សាលារៀនទាំងមូលត្រូវបានបិទទ្វារ។ ៦១% នៃអវត្តមានរបស់គ្រូបង្រៀនក្នុងអំឡុងពេលចុះសាលារៀនដោយមិនផ្តល់ដំណឹងជាមុន គឺជួនគ្នាជាមួយនឹងការបិទសាលារៀនទាំងមូល។ នេះធ្វើឱ្យកាត់បន្ថយនូវថ្ងៃសិក្សាដែលកំពុងតែមានចំនួនតិចជាងប្រទេសដទៃរួចទៅហើយនោះ។

នៅក្នុងការសិក្សានេះ និងការសិក្សាដទៃទៀតរបស់យើងបានរកឃើញថាគ្រូបង្រៀន និងនាយកសាលាអះអាងថាឪពុកម្តាយមិនបានបញ្ជូនកូនមករៀននៅក្នុងពេលទាំងនោះទេ ដូច្នេះហើយវាពុំមានប្រយោជន៍អ្វីដល់ការបើកឱ្យសាលារៀនដំណើរការនោះទេ។ ផ្ទុយទៅវិញ យើងបានរកឃើញថាឪពុកម្តាយមិនបានឱ្យកូនទៅសាលារៀន ដោយសារតែសាលារៀនមិនបើកទ្វារដំណើរការ។ វាហាក់បីដូចជាមានការឯកភាពគ្នាជាឯកច្ឆ័ន្ទដោយមិនចាំបាច់និយាយ យ៉ាងហោចណាស់នៅក្នុងសហគមន៍មួយចំនួន ដែលផ្តល់តម្លៃឱ្យសកម្មភាព ឬកត្តាដទៃទៀត ជាងការឱ្យកូនមករៀននៅក្នុងពេលទាំងនោះ។ តំបន់មួយក្នុងចំណោមតំបន់ដែលយើងបានធ្វើការសិក្សា ជាឧទាហរណ៍ បានលើកឡើងថាចរាចរណ៍មានការមមាញឹកខ្លាំង នៅថ្ងៃចាប់ផ្តើម និងចុងបញ្ចប់នៃពេលបុណ្យឈប់សម្រាក ហើយនេះអាចបណ្តាលឱ្យកូនរបស់គាត់ដែលធ្វើដំណើរទៅសាលារៀននោះមិនមានសុវត្ថិភាពនៅក្នុងពេលទាំងនោះ។

ទោះបីយ៉ាងណាក៏ដោយ វាជាការទទួលខុសត្រូវរបស់សាលារៀន ដើម្បីផ្តល់ឱកាសឱ្យសិស្សបានរៀនចប់តាមកម្មវិធីសិក្សា ហើយដោយសារការបិទសាលារៀននៅពេលទាំងនោះ វាធ្វើឱ្យកុមារដែលមករៀនបានបាត់បង់នូវឱកាសទាំងនោះ។

មានការវិភាគដាច់ដោយឡែកចំពោះបញ្ហាឈប់សម្រាកនៅថ្ងៃបុណ្យចូលឆ្នាំចិន។ ដូចបានកត់សម្គាល់រួចមកហើយ ៤៧% នៃគ្រូបង្រៀននៅក្នុងការសិក្សានេះបានអវត្តមានពីការងារក្នុងអំឡុងពេលគេចុះ

សាលារៀនដោយមិនផ្តល់ដំណឹងជាមុន ដែលបានធ្វើឡើងក្នុងពេលថ្ងៃចូលឆ្នាំចិន ហើយមួយភាគបីនៃសាលារៀនដែលត្រូវបានចុះនោះ គឺបិទទ្វារមិនដំណើរការទេ។ អ្នកធ្វើការវិស័យអប់រំនៅក្នុងប្រទេសកម្ពុជាគួរតែគិតគូរពិចារណាថា តើអាចទទួលយកបានទេចំពោះចំនួនម៉ោងសិក្សាដែលកុមារទទួលបានត្រូវបានកាត់បន្ថយតាមរបៀបដែលអាចព្យាករណ៍ទុកបាននោះ។

គោលការណ៍ណែនាំមានជាច្រើនឆ្នាំណាស់មកហើយ ដែលតម្រូវឱ្យអ្នកពាក់ព័ន្ធថ្នាក់មូលដ្ឋានផ្តោតការយកចិត្តទុកដាក់យ៉ាងសំខាន់ ទៅលើការធ្វើអធិការកិច្ចសាលារៀននៅមុនអំឡុងពេលឈប់សម្រាក។ លទ្ធផលនៃការសិក្សានេះបានបង្ហាញថា ប្រសិនបើគោលការណ៍ណែនាំទាំងនេះត្រូវបានគេអនុវត្តតាមមែននោះ អ្នកពាក់ព័ន្ធថ្នាក់មូលដ្ឋានពិតជាបានដឹងច្បាស់ពីការបាត់ម៉ោងសិក្សា ដែលកុមារកំពុងទទួលរង។ ប៉ុន្តែនៅក្នុងកិច្ចសម្ភាសជាមួយនាយកសាលាបានបង្ហាញថាមានការត្រួតពិនិត្យតិចតួចប៉ុណ្ណោះរបស់ក្រុម DTMT ក្នុងកំឡុងពេលទាំងនោះ ហើយយើង គួរចងចាំថាប្រព័ន្ធអធិការកិច្ចក្នុងកំឡុងពេលនៃការសិក្សានេះភាគច្រើនគឺមានការផ្តល់ដំណឹង ឬការរៀបចំផែនការទុកជាមុន។

ការសន្និដ្ឋាននេះ បានរកឃើញថាមានបញ្ហាប្រឈមដ៏ចម្បងក្នុងអ្វីដែលគេចាត់ទុកថាអាចទទួលយកបាន ពីសំណាក់អ្នកពាក់ព័ន្ធផ្នែកអប់រំ និងជាសាធារណៈនៅពេលដែលគិតទៅដល់អំឡុងពេលនៃថ្ងៃឈប់សម្រាក។ ការដោះស្រាយបញ្ហាដែលចាក់ឫសយ៉ាងជ្រៅទៅក្នុងអាកប្បកិរិយាសង្គម គឺវាមានភាពស្មុគ្រស្មាញ និងត្រូវការពេលវេលា ប៉ុន្តែនេះអាចចាប់ផ្តើមជាមួយអ្វីដែលអ្នកគ្រប់គ្រងអប់រំខ្លួនឯងជឿជាក់ថាជាមធ្យោបាយដ៏ល្អបំផុត ដើម្បីធានាបានថាកុមារកម្ពុជាបានរៀនចប់ទៅតាមកម្មវិធីសិក្សា។

## សេចក្តីសន្និដ្ឋានទី ៤: ការគ្រប់គ្រងគ្រូបង្រៀន ការជ្រើសរើសគ្រូបង្រៀន និងការអនុវត្តការពង្រាយគ្រូបង្រៀន រួមចំណែកក្នុងការបាត់ម៉ោងបង្រៀន

បន្ថែមលើការបូកបញ្ចូលគ្នារវាងការត្រួតពិនិត្យតាមដានអវត្តមានគ្រូបង្រៀន និងម៉ោងបង្រៀនដែលបានផ្តល់ឱ្យសិស្ស ការសិក្សារបស់យើងក៏បានពិនិត្យមើលផងដែរនូវវិធីសាស្ត្រនៃការគ្រប់គ្រងបុគ្គលិកបច្ចុប្បន្ន តើវាអាច ឬមិនអាចដោះស្រាយបញ្ហាម៉ោងបង្រៀននេះបាន។ នៅពេលនាយកសាលាមិននៅសាលារៀន គ្រូបង្រៀនទំនងជាមានអវត្តមានច្រើន។ ស្របពេលដែលនាយកសាលាអាចកំណត់បាននូវវិធីសាស្ត្រជាច្រើនដែលពួកគាត់ព្យាយាមប្រើ ដើម្បីលើកទឹកចិត្តគ្រូបង្រៀនឱ្យមកបង្រៀនបានទៀងទាត់ និងការដាក់ទណ្ឌកម្មទៅតាមអ្វីដែលត្រូវធ្វើ តែគ្រូបង្រៀនដែលបានទទួលទណ្ឌកម្មមានតិចតួចប៉ុណ្ណោះ។ គោលនយោបាយបុគ្គលិកបញ្ជាក់ថា នាយកសាលាមានសិទ្ធិអំណាចក្នុងការគ្រប់គ្រងគ្រូបង្រៀន ប៉ុន្តែបែរជានៅក្នុងកិច្ចសម្ភាសបានបង្ហាញយ៉ាងច្បាស់ថា ពួកគាត់មានតួនាទីក្នុងការផ្តល់អនុសាសន៍ទៅឱ្យការិយាល័យអប់រំស្រុក។

៤០% នៃនាយកសាលា បានរៀបរាប់ថាគ្រូបង្រៀនពេលខ្លះអវត្តមានពីសាលារៀន ដោយគ្មានការអនុញ្ញាត ប៉ុន្តែនៅចុងបញ្ចប់ការសិក្សាបានរកឃើញថានាយកសាលាមានភាពរួញរា ឬអសមត្ថភាព ឬគ្មានសិទ្ធិអំណាចដើម្បីដោះស្រាយបញ្ហានេះឱ្យបានពេញលេញ។ ឧបសគ្គដែលមិនមែនជាផ្នែកបច្ចេកទេស ក្នុងការពង្រឹងការងាររបស់គ្រូបង្រៀន ត្រូវបានគេរកឃើញ គឺទំនាក់ទំនងជិតស្និទ្ធនិងការយោគយល់រវាងនាយកសាលា និងគ្រូបង្រៀនរបស់ខ្លួន ហើយនាយកសាលាទទួលស្គាល់ថាគ្រូបង្រៀនចាំបាច់ត្រូវរក្សាប្រកព ចំណូលផ្សេងៗរបស់ខ្លួន។ ឧបសគ្គផ្នែកបច្ចេកទេសដូចដែលបានកត់សម្គាល់ខាងលើ គឺមានផលលំបាកក្នុងការរក្សាគ្រូបង្រៀនឱ្យនៅគង់វង្ស និងគ្រប់គ្រាន់ ជាពិសេសនៅសាលារៀននៅតំបន់ជនបទ។ ការប្រើប្រាស់

ទណ្ឌកម្មអាចបណ្តាលឱ្យគ្រូបង្រៀនសុំលាឈប់ពីការងារ ហើយនេះជាការលំបាកមួយដែលគេអាចយល់បាន និងអាចធ្វើឱ្យសាលារៀនជួបបញ្ហាការខ្វះខាតគ្រូបង្រៀន។

ជាមួយគ្នានេះផងដែរ វាជាការសំខាន់ដែលទទួលស្គាល់ថានាយកសាលា គឺអវត្តមានពីសាលារៀនជាញឹកញាប់ក្នុងកំឡុងពេលចុះពិនិត្យសាលារៀនភ្លាមៗ ដោយមិនផ្តល់ដំណឹងជាមុន – អវត្តមានក្នុងកំឡុងពេល ១៦% នៃការចុះពិនិត្យសាលារៀនភ្លាមៗ។ ការសិក្សាមិនបានស្វែងរកអំពីមូលហេតុចំពោះអវត្តមានរបស់នាយកសាលានោះទេ ហេតុដូច្នេះហើយវាអាចទំនងជាអវត្តមានជាច្រើនរបស់នាយកសាលា គឺដើម្បីចូលរួមក្នុងកិច្ចការជាផ្លូវការផ្សេងៗ។ ប៉ុន្តែវាក៏ជាការសមហេតុផលមួយដែរដែលសន្មតថានាយកសាលាក៏មានចំណែកក្នុងការឯកភាពថា តើសាលារៀនទាំងមូលនឹងត្រូវបិទទ្វារនៅថ្ងៃទាំងនោះដែលជាផ្នែកនៃថ្ងៃសិក្សាជាផ្លូវការក្នុងឆ្នាំសិក្សា "ការបិទសាលារៀនដែលជាការអនុវត្ត (ទម្លាប់) ទូទៅ" – ហើយ ៣៨% នៃនាយកសាលាបានអវត្តមានក្នុងកំឡុងពេលត្រួតពិនិត្យសាលារៀន ភ្លាមៗក្នុងកំឡុងពេលបុណ្យចូលឆ្នាំចិន។

ភាគច្រើន នៅពេលដែលនាយកសាលាពិភាក្សាអំពីការពិនិត្យតាមដានគ្រូបង្រៀន ពួកគាត់គិតតែអំពីការជាប់ទាក់ទងជាមួយគុណភាពនៃការបង្រៀន និងការអនុវត្តជាក់ស្តែងក្នុងថ្នាក់រៀនជាជាងបញ្ហាវត្តមានរបស់គ្រូបង្រៀន និងរយៈពេលនៃការបង្រៀនមេរៀននៅក្នុងថ្នាក់។ នេះក៏ត្រូវបានគេឆ្លុះបញ្ចាំងផងដែរថាជាការផ្តោតសំខាន់នៅក្នុងការធ្វើអធិការកិច្ច និងការចុះពិនិត្យតាមដានរបស់ក្រុម DTMT ។ ស្របពេលដែលមានចំណុចជាវិជ្ជមានថាការពិនិត្យតាមដាន ត្រូវបានធ្វើដើម្បីមើលលើការអនុវត្តជាក់ស្តែងក្នុងថ្នាក់រៀន ហើយគ្រូបង្រៀនយល់ថានេះគឺបានជួយដល់ពួកគាត់។ វាជាការរំលងមួយដ៏សំខាន់ដែលមិនបានដាក់បញ្ចូលការគ្រប់គ្រងបុគ្គលិកជាផ្នែកមួយនៅក្នុងសកម្មភាពនៃការត្រួតពិនិត្យតាមដាន។ នេះគឺជាករណីមួយ ហើយបើមើលលើគោលការណ៍ណែនាំសម្រាប់ក្រុម DTMT ដូចដែលបានសំអាងនៅខាងលើ បានកំណត់យ៉ាងជាក់លាក់អំពីតម្រូវការដើម្បីត្រួតពិនិត្យសាលារៀនថា តើសាលារៀនបើកទ្វារដំណើរការនៅជុំវិញកំឡុងពេលឈប់សម្រាកជាផ្លូវការដែរឬអត់។ ភ័ស្តុភារក្នុងផ្នែកនេះសម្រាប់ក្រុមតូចៗរបស់ DTMT គឺមានការលំបាកខ្លាំង ហើយវាជាការមួយដែលអាចយល់បានថាប្រសិនបើអធិការកិច្ចផ្តោតលើការអនុវត្តជាក់ស្តែងក្នុងថ្នាក់រៀន នោះមន្ត្រីអប់រំចង់ឱ្យប្រាកដថាសាលារៀនបើកទ្វារដំណើរការ និងគ្រូបង្រៀនមាន វត្តមាននៅមុនពេលចុះទៅអធិការកិច្ច។ ប៉ុន្តែនេះមានន័យថាប្រព័ន្ធត្រួតពិនិត្យតាមដានពីខាងក្រៅនាពេលបច្ចុប្បន្ន មិនទាន់បានរៀបចំឱ្យបានល្អនៅឡើយទេដើម្បីកំណត់បញ្ហាសំខាន់ៗទាំងអស់នេះ ហើយប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងទៀតសោត គឺអាស្រ័យទៅលើការលើកទឹកចិត្ត និងការធ្វើអាទិភាពរបស់នាយកសាលា។

វាជាការសំខាន់ដែលអ្នកគ្រប់គ្រងអប់រំនៅមូលដ្ឋានមានសិទ្ធិអំណាច និងសមត្ថភាពដើម្បីពង្រឹងគោលនយោបាយ បុគ្គលិកដែលបានបង្កើតឡើងដើម្បីធានាបានថាគ្រូបង្រៀនបំពេញការងារបានល្អ។ វត្តមានគឺជាផ្នែកមួយសំខាន់នៃកិច្ចការនេះ ប៉ុន្តែវាហាក់ដូចជាមិនត្រូវបានគេផ្តល់ជាអាទិភាពឱ្យឡើយ។ ការអភិវឌ្ឍន៍គោលនយោបាយនៅក្នុងផ្នែក នៃការគ្រប់គ្រងនៅតាមសាលារៀនត្រូវគិតដល់ចំណុចនេះផងដែរ ប៉ុន្តែក៏ត្រូវទទួលស្គាល់ផងដែរអំពីឧបសគ្គផ្នែកបច្ចេកទេស និងឧបសគ្គផ្ទាល់ខ្លួន ដែលបានរកឃើញនៅក្នុងចំណោមអ្នកគ្រប់គ្រងនៅមូលដ្ឋានដោយប្រើប្រាស់សិទ្ធិអំណាចបច្ចុប្បន្ន ដើម្បីដោះស្រាយអវត្តមានគ្រូបង្រៀន ឬការបាត់ម៉ោងបង្រៀនតាមរយៈការបិទសាលារៀន។

## VI. **អនុសាសន៍**

ដោយលទ្ធផលរកឃើញសំខាន់ៗបានបង្ហាញពីភាពខុសគ្នានូវលក្ខណៈនៃការបាត់ម៉ោងបង្រៀននៅក្នុងប្រទេសកម្ពុជា អង្គការNEP សូមផ្តល់នូវអនុសាសន៍ដូចខាងក្រោម ដើម្បីឱ្យសិស្សមានពេលវេលារៀនសូត្រជាអតិបរមា ព្រមទាំងផ្តល់នូវលទ្ធភាពរៀនសូត្រកាន់តែប្រសើរឡើង និងស្មើភាពគ្នាសម្រាប់កុមារនៅបឋមសិក្សានៅក្នុងប្រទេសកម្ពុជា។ ហេតុដូច្នេះហើយ ត្រូវតែមានការផ្តោតយកចិត្តទុកដាក់ក្នុងការធានាបាននូវការអនុវត្តន៍ឱ្យបានស្មើភាពគ្នានូវអនុសាសន៍ទាំងនេះ ទាំងនៅតំបន់ជនបទ និងទីប្រជុំជន។

**១. ក្រសួងអប់រំ យុវជន និងកីឡា គួរផ្តួចផ្តើមឱ្យមានការពិនិត្យមើលឡើងវិញជាមូលដ្ឋានមួយពីឆ្នាំសិក្សា និងថ្ងៃឈប់សំរាកដែលត្រូវរាប់បញ្ចូល ៖**

**ក. ការដាក់បញ្ចូល"ថ្ងៃឈប់សម្រាកផ្លូវការបន្ថែម" ដែលមានជារៀងរាល់ឆ្នាំទៅក្នុងថ្ងៃឈប់សម្រាកផ្លូវការ ហើយបន្ថែមថ្ងៃសិក្សានៅ សាលារៀន ឬម៉ោងសិក្សាដើម្បីបង្រៀនសង "ថ្ងៃឈប់សម្រាកជាផ្លូវការបន្ថែម"**

ឆ្នាំសិក្សាដែលក្រសួងអប់រំ យុវជន និងកីឡា បានកំណត់ចំនួន១៩០ថ្ងៃក្នុង១ឆ្នាំ ពុំបានដាក់បញ្ចូលនូវថ្ងៃសម្រាប់បង្រៀនសង ដើម្បីទូទាត់ចំពោះថ្ងៃដែលមិនបានរៀនដោយការបិទសាលារៀនទូទាំងប្រទេសសម្រាប់ការប្រឡងមួយចំនួន និងព្រឹត្តិការណ៍ផ្សេងៗទៀត។ ចំណុចនេះមានន័យថាឆ្នាំសិក្សាចាប់ផ្តើមដោយមានការកាត់បន្ថយម៉ោងរបស់កម្មវិធីសិក្សា ហើយថាសាលារៀនពុំអាចប្រកាន់ខ្ជាប់នូវគោលនយោបាយស្តីពីការអភិវឌ្ឍន៍កម្មវិធីសិក្សានោះទេ ទោះបីជាមានការគិតគូរពិចារណាទៅលើការបិទសាលារៀនក្រៅផ្លូវការ ឬអវត្តមានរបស់គ្រូបង្រៀនក៏ដោយ។ ឧទាហរណ៍ ប្រសិនបើគេគិតគូរពិចារណាពីការបិទសាលារៀនច្រើនថ្ងៃមុនថ្ងៃបោះឆ្នោត រយៈពេលសិក្សាគួរត្រូវបានគេកំណត់ឱ្យមានរយៈពេលវែងជាងធម្មតាសម្រាប់ឆ្នាំដែលមានការបោះឆ្នោត ដើម្បីឱ្យគ្រូបង្រៀនមានឱកាសបង្រៀនតាមកម្មវិធីសិក្សាទាំងមូល។

**ខ. តើថ្ងៃបុណ្យចូលឆ្នាំចិនគួរប្រកាន់យកជាថ្ងៃរៀនជាធម្មតា ឬគួរដាក់បញ្ចូលជាថ្ងៃឈប់សម្រាកជាផ្លូវការនៅក្នុងសាលារៀន**

ថ្ងៃបុណ្យចូលឆ្នាំចិនមិនមែនជាថ្ងៃឈប់សម្រាកជាផ្លូវការនៅក្នុងប្រទេសកម្ពុជានោះទេ ប៉ុន្តែគេសង្កេតឃើញជាទូទៅថាមានគេឈប់សម្រាកច្រើន ហើយបានក្លាយជាផ្នែកមួយដ៏សំខាន់នៃវប្បធម៌ក្នុងស្រុកសម្រាប់គ្រួសារជាច្រើន។ លទ្ធផលរកឃើញរបស់យើងបានបង្ហាញថា គ្រូបង្រៀនស្ទើរតែ៥០%ដែលយើងបានចុះដោយពុំមានផ្តល់ដំណឹងជាមុន បានអវត្តមាននៅថ្ងៃបុណ្យចូលឆ្នាំចិន ហើយសាលារៀនចំនួន១ភាគ៣ត្រូវបានបិទទ្វារ។ ជម្រើសមួយគឺត្រូវបង្កើនការអនុវត្តន៍ការដំណើរការសាលារៀននៅក្នុងរយៈពេលនេះ។ ជម្រើសមួយទៀតគឺត្រូវបញ្ចូលថ្ងៃបុណ្យចូលឆ្នាំចិនទៅក្នុងថ្ងៃឈប់ សម្រាករបស់សាលារៀន ដើម្បីទទួលស្គាល់ចំពោះបទដ្ឋានវប្បធម៌ដែលកំពុងវិវឌ្ឍនេះ ដោយបន្ថែមចំនួនថ្ងៃរៀននៅមុនបញ្ចប់ឆ្នាំសិក្សា។

**គ. ពិគ្រោះយោបល់ពីគោលការណ៍ណែនាំស្តីពីនាពបត់បែននៃឆ្នាំសិក្សា និងធ្វើវិមជ្ឈការប្រតិទិនសាលារៀននៅតំបន់ណាមួយត្រូវធានាថាមានយន្តការត្រួតពិនិត្យតាមដានគ្រប់គ្រាន់នៅក្នុងគោលការណ៍ណែនាំនោះ**

ការសាកល្បងស្តីពីភាពបត់បែននៃកាលវិភាគឆ្នាំសិក្សា ត្រូវបានគេធ្វើឡើងដើម្បីឱ្យសាលារៀននៅតាមតំបន់ជនបទដើម្បីឆ្លើយតបនឹងអវត្តមានរបស់គ្រូបង្រៀន និងសិស្សនៅរដូវដាំដុះ និងប្រមូលផលនៅតំបន់ជនបទ។ ប្រសិនបើក្រសួងអប់រំ យុវជននិងកីឡា មានផែនការពង្រីកការសាកល្បងនេះ និងធ្វើវិមជ្ឈការប្រតិទិនសាលារៀន គួរតែមានការពិគ្រោះយោបល់ជាមួយគណៈគ្រប់គ្រងសាលា សមាគមគ្រូបង្រៀន និងអង្គការមិនមែនរដ្ឋាភិបាលពីសេចក្តីណែនាំឱ្យមានលក្ខណៈច្បាស់លាស់ ហើយមន្ត្រីមន្ទីរអប់រំខេត្ត និងមន្ត្រីការិយាល័យក្រុង ខេត្ត ជាពិសេសនៅតំបន់ជនបទគឺជាធនធានចាំបាច់សម្រាប់ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់សាលារៀនក្នុងការអនុវត្តន៍គោលការណ៍ណែនាំនេះ។ ការគាំទ្រផ្នែកបច្ចេកទេសនេះគួរពិគ្រោះយោបល់ជាមួយសហគមន៍ស្តីពីតម្រូវការតាមមូលដ្ឋាន ដើម្បីធានាបានថាស្តង់ដារអប្បរមានៃម៉ោងបង្រៀនឆ្លើយតបទៅនឹងប្រតិទិនសាលារៀនដែលកែប្រែ ព្រមទាំងការវាយតម្លៃពីផលប៉ះពាល់ទៅលើការរៀនសូត្រ និងវត្តមានរបស់សិស្ស។

យោងតាមលទ្ធផលរកឃើញរបស់យើងទៅលើអទិភាពដែលនាយកសាលា មន្ត្រីអប់រំរាជធានី ខេត្ត និងមន្ត្រីអប់រំស្រុក កំណត់ទៅលើវត្តមានរបស់គ្រូបង្រៀន និងការបើកសាលារៀន ការធ្វើវិមជ្ឈការឆ្នាំសិក្សាណាមួយចាំបាច់ត្រូវឱ្យស្របគ្នាជាមួយនឹងការបង្កើនការត្រួតពិនិត្យតាមដាន ក្នុងគោលបំណងធានាបានថាអ្នកដែលរស់នៅក្នុងតំបន់ជនបទ នឹងមិនទទួលរងផលប៉ះពាល់ដោយសារការកាត់បន្ថយម៉ោងបង្រៀនទេ។

**២. ក្រសួងអប់រំ ចាំបាច់ត្រូវបន្តផ្តល់អាទិភាពដល់វិធានការនានាស្តីពីការជ្រើសរើស ការរក្សាទុក និងការពង្រាយគ្រូបង្រៀនក្នុងគោលបំណងធ្វើឱ្យការគ្រប់គ្រងបុគ្គលិកកាន់តែមានភាពរឹងមាំថែមទៀត ដោយពុំនាំទៅរកការខ្វះគ្រូបង្រៀនកាន់តែច្រើនឡើង ដោយរាប់បញ្ចូលទាំង៖**

**ក. បន្តលើកកម្ពស់ស្ថានភាពផ្នែកវិជ្ជាជីវៈ ប្រាក់បៀវត្សរ៍ និងគ្រឿងលើកទឹកចិត្តគ្រូបង្រៀន**

អង្គការ NEP សូមគាំទ្រយ៉ាងមុតមាំចំពោះការកែលម្អក្នុងពេលថ្មីៗនេះទៅលើប្រាក់បៀវត្សរ៍របស់គ្រូបង្រៀន និងទទួលស្គាល់នូវអាទិភាពដែល MoEYS បានកំណត់ដើម្បីកែលម្អស្ថានភាពរស់នៅរបស់គ្រូបង្រៀន។ ការបង្កើនប្រាក់បៀវត្សរ៍ និងគ្រឿងលើកទឹកចិត្តរបស់គ្រូបង្រៀនដើរតួនាទីដ៏សំខាន់មួយក្នុងការពង្រឹងការអនុវត្តន៍ច្បាប់ និងបទបញ្ជាផ្សេងៗទាក់ទងនឹងវត្តមាន និងវិជ្ជាជីវៈរបស់នាយកសាលា និងគ្រូបង្រៀន។ ទោះបីជាមានការកែលម្អគួរឱ្យកត់សម្គាល់ក៏ដោយ ក៏កញ្ចប់ប្រាក់បៀវត្ស និងគ្រឿងលើកទឹកចិត្តដែលមានស្រាប់របស់គ្រូបង្រៀននៅតែស្ថិតនៅក្នុងកម្រិតមួយដែលគ្រូបង្រៀនជាច្រើនគិតថាគាត់ត្រូវតែមានមុខរបរបន្ថែម ដើម្បីធានាបាននូវប្រាក់ចំណូលបន្ថែមរបស់គាត់។ នាយកសាលា ជាពិសេសនៅតាមតំបន់ដាច់ស្រយាលមានភាពស្ទាក់ស្ទើរក្នុង ការចាត់វិធានម៉ឺងម៉ាត់ណាមួយ ដើម្បីដាក់ទណ្ឌកម្មទៅលើគ្រូបង្រៀនដែលអវត្តមានជាញឹកញាប់ដើម្បីជាប្រយោជន៍រក្សាទុកគ្រូបង្រៀន និងជៀសវាងការខ្វះគ្រូ ហើយវាក៏ជាផ្នែកមួយចំពោះវិធីសាស្ត្រប្រកបដោយភាពប្រាកដប្រជាដែរចំពោះតម្រូវការប្រាក់ចំណូលបន្ថែមរបស់គ្រូបង្រៀន។ ការបង្កើនប្រាក់លើកទឹកចិត្តបន្ថែម ដើម្បីឱ្យគ្រូបង្រៀនទៅបង្រៀននៅតំបន់ជនបទ និងតំបន់ដាច់ស្រយាលក៏មានសារៈសំខាន់ផងដែរចំពោះការពង្រាយគ្រូបង្រៀនកាន់តែច្រើនថែមទៀតទៅកាន់សាលារៀនដែលត្រូវការគ្រូបង្រៀន។

ខ. ការជ្រើសរើសគ្រូបង្រៀនច្រើនថែមទៀតនៅកម្រិតបឋមសិក្សា

នាយកសាលា ត្រូវបានគេដាក់ឱ្យនៅក្នុងតំណែងដ៏លំបាកមួយនៅពេលប្រឈមមុខជាមួយនឹងគ្រូបង្រៀនដែលអនុវត្តការងារមិនបានល្អ។ ការព្រួយបារម្ភរបស់ពួកគាត់ដែលថាការដោះស្រាយវត្តមានមិនល្អនឹងនាំទៅរកការបាត់បង់បុគ្គលិកបង្រៀនគឺគេអាចយល់បាន។ ចំនួនគ្រូបង្រៀននៅថ្នាក់បឋមសិក្សានៅក្នុងប្រទេសកម្ពុជាបាននឹងកំពុងធ្លាក់ចុះក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ហើយក៏មានការបោះបង់ច្រើនដែរនៅអំឡុងពេលបណ្តុះបណ្តាលគ្រូបង្រៀន។ ចំនួនគ្រូបង្រៀនដែលត្រូវជ្រើសរើសចាំបាច់ត្រូវតែបង្កើនក្នុងគោលបំណងធ្វើឱ្យការគ្រប់គ្រងបុគ្គលិកកាន់តែមានភាពរឹងមាំថែមទៀត។ ការអនុញ្ញាតឱ្យចូលទៅក្នុងវិជ្ជាជីវៈនៃការបង្រៀនឡើងវិញពីសំណាក់អតីតគ្រូបង្រៀនដែលមានលក្ខណៈសម្បត្តិ និងការចូលទៅទទួលវគ្គបណ្តុះបណ្តាលគ្រូបង្រៀនរបស់អ្នកដែលមានវ័យចំណាស់អាចជួយដោះស្រាយបញ្ហានេះបាន។

គ. កែលម្អប្រព័ន្ធពង្រាយគ្រូបង្រៀនដើម្បីឱ្យគេអាចបំពេញការជ្រើសរើសបុគ្គលិកនៅក្នុងឆ្នាំនោះបាន

បច្ចុប្បន្ននេះសកម្មភាពនៃការពង្រាយគ្រូភាគច្រើនកើតមានឡើងនៅដើមឆ្នាំសិក្សាសម្រាប់គ្រូបង្រៀនថ្មីដែលទើបនឹងបញ្ចប់វគ្គបណ្តុះបណ្តាល។ ចំណុចនេះបណ្តាលឱ្យនាយកសាលាមានអារម្មណ៍ថា ប្រសិនបើគ្រូបង្រៀនបោះបង់ការងាររបស់គាត់ចោលនៅពាក់កណ្តាលឆ្នាំ នោះនឹងពុំមានការដាក់គ្រូជំនួសតាមរយៈការពង្រាយគ្រូបង្រៀនឡើងវិញនៅពេលនោះទេ។ នៅពេលបញ្ហាខ្វះគ្រូនៅតែចោទ វាជាការប្រឈមមុខក្នុងការរកគ្រូមកបង្រៀនជំនួសនៅពេលគ្រូបង្រៀនអវត្តមានជាបន្ទាន់។ ទោះជាយ៉ាងណាក៏ដោយ គេគួរគិតគូរពិចារណាប្រើប្រាស់ក្រុមគ្រូបង្រៀនដែលអាចបង្រៀនជំនួសគ្រូដែលអវត្តមានរយៈពេលវែង ឬឈប់នៅពាក់កណ្តាលឆ្នាំដោយមានកញ្ចប់គ្រឿងលើកទឹកចិត្តជាក់លាក់សម្រាប់ក្រុមគ្រូបង្រៀនប្រភេទនេះ។

៣. MoEYS និងមន្ត្រីអប់រំថ្នាក់ក្រោមជាតិត្រូវពង្រឹងការគ្រប់គ្រងបុគ្គលិក និងអធិការកិច្ចសាលារៀនដើម្បីកែលម្អវត្តមានរបស់គ្រូបង្រៀន និងកាត់បន្ថយការបិទសាលារៀន តាមរយៈ៖

ក. ការធានាថាបញ្ហាវត្តមាន និងម៉ោងពេលត្រូវបានកត់ត្រាទុកយ៉ាងច្បាស់លាស់ ហើយថាចំណុចទាំងនេះពាក់ព័ន្ធនឹងឱកាសសម្រាប់ការតម្លើងឋានៈរបស់គ្រូបង្រៀន និងនាយកសាលា

ដូចដែលបានឃើញតាំងពីដើមរហូតដល់ចប់របាយការណ៍នេះ ម៉ោងបង្រៀនយ៉ាងច្រើនត្រូវបានបាត់ដោយសារអវត្តមានរបស់គ្រូបង្រៀន ប៉ុន្តែប្រព័ន្ធសម្រាប់ឆ្លើយតបទៅនឹងបញ្ហានេះពុំដំណើរការឱ្យបានគ្រប់គ្រាន់ទេ។ ហេតុដូច្នេះហើយ ការពង្រឹងប្រព័ន្ធត្រួតពិនិត្យគឺជាអាទិភាពមួយ។ ការមានប្រព័ន្ធព្រមានជាមុនដើម្បីរកមើលគ្រូបង្រៀនដែលបំពេញការងារមិនបានល្អ មានសារៈសំខាន់ដូចគ្នាទៅនឹងការមានប្រព័ន្ធផ្តល់រង្វាន់ដល់គ្រូបង្រៀនដែលបំពេញការងារបានល្អបំផុតដែរ។ គ្រូបង្រៀនជាច្រើននៅក្នុងការសិក្សារបស់យើងបង្ហាញនូវការប្តេជ្ញាចិត្តខ្ពស់ ប៉ុន្តែក៏មានគ្រូបង្រៀនមួយចំនួនតូចដែលបំពេញការងារមិនទាន់បានល្អ។

